**IDEA BOOK**

សៀវភៅបណ្ណាគំនិត

# និព្វានទស្សនៈ





ភិក្ខុធម្មបាល ខៀវ-ជុំ

១៩៧០

www.elibraryofcambodia.org

អំណោយពីលោក ឡៅ ឃុនសំរ៉ែ ស្វែងរកគុណធម៌ខ្មែរ ដើម្បី
និងដាក់ក្នុង eLibrary of Cambodia

កក្កដា 2015

# អារម្ភកថា

ដោយខ្ញុំយល់ឃើញថា **និព្វាន** ជាចំណុចគោលដៅនៃពុទ្ធសាសនា ជាធម៌ដែលព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់ស្រាវជ្រាវរកឃើញផ្ទាល់ព្រះអង្គ, មិនមែនជាធម៌ចម្លងបែបគ្រាប់ទំនៀមរបស់លទ្ធិណា, របស់ជំនឿនៃជនពួកណា។ និព្វានជាបរមត្ថធម៌ ដែលពុទ្ធសាសនិកគ្រប់ភេទ គ្រប់វ័យ គួរយកចិត្តទុកដាក់សិក្សាដើម្បីបូជាចំពោះព្រះពុទ្ធបរមគ្រូផង ដើម្បីប្រយោជន៍យ៉ាងខ្ពស់របស់ខ្លួនផង។ ខ្ញុំក៏ចាប់សរសេរសៀវភៅនេះ ក្នុងបំណងដឹកនាំពុទ្ធសាសនិកឲ្យប្រមូលគំនិត, ប្រមូលសេចក្តីព្រាថ្នារបស់ខ្លួនឲ្យនៅជុំវិញនិព្វាន, ជុំវិញគោលបំណង, ជុំវិញឧត្តមគតិនៃពុទ្ធសាសនារបស់ខ្លួន។ បើនិយាយឲ្យច្បាស់ជាងនេះ គឺចង់ដឹកនាំពុទ្ធសាសនិកក្នុងសាធារណរដ្ឋខ្មែរយើង ឲ្យចាប់អារម្មណ៍លើនិព្វាន ព្រោះនិព្វានជាបរមត្ថធម៌ ដែលមានចែងទុកក្នុងគម្ពីរអភិធម្មថា ចិត្ត, ចេតសិក, រូប, និព្វាន។ ក្រៅអំពីធម៌ទាំង៤នេះ លោកពុំបានសង្គ្រោះចូលក្នុងបរមត្ថធម៌ទេ តែលោកសង្គ្រោះចូលក្នុងជំនឿធម្មតា, សេចក្តីស្រឡាញ់រាប់អានធម្មតា ដូចជាជំនឿក្នុងទេវតា, ឥន្ទ្រ, ព្រហ្ម, សេចក្តីស្រឡាញ់រាប់អានទេវតា, ឥន្ទ្រ, ព្រហ្ម ជាដើម។ ជំនឿទាំងអស់នេះ សេចក្តីស្រឡាញ់រាប់អានទាំងអស់នេះ ពុទ្ធសាសនាពុំបានបដិសេធ, ពុំបានហាមឃាត់ទេ, តែពុទ្ធសាសនាបានប្រាប់ថា របស់ទាំងអស់នេះមានគុណប្រយោជន៍បានត្រឹមតែជាស្ពានឬជាជណ្តើរ ប៉ុណ្ណោះ; អ្នកដំណើរទាំងអស់គ្នាត្រូវតែខំប្រឹងឆ្លង ខំប្រឹងឡើងឲ្យផុត កុំឈប់នៅលើស្ពានលើជណ្តើរនោះឡើយ។

ដូច្នេះ អ្នកអានម្នាក់ៗ គប្បីធ្វើទានដើម្បីនិព្វាន, ធ្វើសីលដើម្បីនិព្វាន, ភាវនាធម៌ដើម្បីនិព្វាន។ ក្នុងកាលណាយើងធ្វើអ្វីៗដើម្បីនិព្វាន ចិត្តរបស់យើងក៏មាននិព្វានជាឧត្តមគតិ, ជាវត្ថុបំណងជាទីដៅ, ក្នុងពេលនោះវាសនារបស់យើង

www.elibraryofcambodia.org

ក៏បានទាក់ភ្ជាប់ទៅជាមួយនឹងនិញ្វាន។ កាលណាវាសនារបស់យើងបានចង ភ្ជាប់ខ្លួនយើងជាមួយនឹងនិញ្វានហើយ, ទោះជាយើងអន្ទោលជាតិទៅកើតក្នុង ពិភពលោកណា, មានជាតិជាអ្វី, ជាមនុស្សក្តី, ជាទេវតាក្តី។ល។ យើងក៏មាន ចិត្តជាអ្នកនិញ្វាន; បើជាមនុស្ស, មនុស្សនោះចេះអាណិតអ្នកដទៃដូចអាណិត ខ្លួនឯង, បើជាទេវតា ទេវតានោះមានចិត្តស្ងប់ស្ងាត់ មិនចេះតែសប្បាយម្នាក់ ឯង ទេវតាដទៃមានសេចក្តីទុក្ខព្រួយក៏មិនឈឺក្បាល ព្រោះអ្វី ? ព្រោះអ្នកនិញ្វាន ជាបុគ្គលមានចិត្តស្ងប់ មានសេចក្តីមេត្តា មានសេចក្តីសន្តោស។ល។ ទៅកើត ក្នុងជាតិណា រមែងធ្វើឲ្យជាតិរបស់ខ្លួនមានសេចក្តីសុខស្ងប់ មានសេចក្តី រាប់អានគ្នា មានវត្ថុបំណងរស់នៅរួមគ្នាក្នុងសេចក្តីចំរើន។ល។ ផ្ទុយទៅវិញអ្នក ចង់តែសប្បាយ អ្នកចង់តែធ្វើទេវតា គេធ្វើអ្វីៗដើម្បីសប្បាយ ដើម្បីទេវតា។ ក្នុង កាលណាគេធ្វើអ្វីៗដើម្បីសប្បាយ ដើម្បីទេវតា ចិត្តរបស់គេក៏មានទេវតាជា ឧត្តមគតិ ជាវត្ថុបំណង ជាទិដៅ ក្នុងកាលនោះវាសនារបស់គេ ក៏បានទាក់ភ្ជាប់ ទៅជាមួយនឹងទេវតា ជាមួយនឹងសេចក្តីសប្បាយ។ កាលណាវាសនារបស់គេ បានចងភ្ជាប់ខ្លួនរបស់គេទៅជាមួយទេវតា ជាមួយសេចក្តីសប្បាយហើយ ទោះ ជាខ្លួនគេអន្ទោលជាតិទៅកើតក្នុងភពណា មានជាតិជាអ្វីក៏ដោយ, ជាមនុស្សក្តី ទេវតាក្តី។ល។ គេរមែងមានចិត្តជាអ្នកសប្បាយ ជាអ្នកមិនមានចិត្តមេត្តា ជា អ្នកជិះជាន់អ្នកដទៃ ដើម្បីសេចក្តីសុខសប្បាយរបស់ខ្លួន។ល។ ដរាបណា ពិភពលោកមានតែមនុស្សបូជានូវសេចក្តីសប្បាយរបស់ខ្លួនដរាបនោះពិភពលោក ត្រូវតែមានសង្គ្រាមកើតឡើង បើមិនសង្គ្រាមខាងផ្លូវអាវុធ ក៏សង្គ្រាមខាងផ្លូវចិត្ត ណាមួយមិនខាន។ ដូច្នេះមនុស្សម្នាក់ៗ ប្រសិនបើចង់បានសេចក្តីសុខស្ងប់ គួរ ធ្វើបុណ្យដើម្បីបុណ្យ ដើម្បីសេចក្តីល្អរបស់មនុស្សនិងដើម្បីសេចក្តីសុខចម្រើន នៃប្រជាសត្វលោក គឺដើម្បីនិញ្វាននោះឯង។

សៀវភៅនេះខ្ញុំឲ្យឈ្មោះថា «**និញ្វានទស្សនៈ**» ប្រែថា «ការឃើញនូវ និញ្វាន» ឈ្មោះនេះ មិនមែនតាំងឡើងក្នុងមានបំណងថា ខ្លួនខ្ញុំជាអ្នកបានដល់



www.elibraryofcambodia.org

និព្វានឬបានឃើញនូវនិព្វាន តាមលំដាប់នៃអរិយមគ្គ ឬបានស្រាវជ្រាវឃើញនិព្វានដោយខ្លួនឯងទេ គឺខ្ញុំមានបំណងថា ខ្លួនខ្ញុំបានឃើញគម្ពីរសៀវភៅ ដែលបណ្ឌិតទាំងឡាយក្នុងពុទ្ធសាសនា លោកបានសរសេរ បានតែងទុកមក សម្រាប់ខ្លួនខ្ញុំបានត្រឹមតែជាអ្នកស្រង់ប្រមូល និងឲ្យយោបល់ផ្ទាល់ខ្លួនខ្លះប៉ុណ្ណោះ។ ឆ្លៀតឱកាសនេះ ខ្ញុំសូមអរគុណបណ្ឌិតទាំងឡាយនេះ ដែលខ្ញុំមិនបានចេញឈ្មោះរបស់លោកក្នុងសៀវភៅនេះ ព្រោះមានចំនួនច្រើនពេក។ អ្នកអានទាំងឡាយ ប្រសិនបើមានបំណងចង់យល់អំពីរឿងនិព្វាន គប្បីទន្ទេញឲ្យចាំ ឬអានឲ្យបានច្រើនចប់ ក្រោយពីបានអាន បានទន្ទេញចាំហើយ បើឲ្យល្អបំផុតត្រូវព្យាយាមធ្វើតាមរបៀបនេះគឺ :

១ ) បិទសៀវភៅទុកមួយអន្លើសិន ;

២ ) លើកយកសេចក្ដីទាំងអស់មកគិតពិចារណា ;

៣ ) បើនៅមិនទាន់យល់សេចក្ដីនៅត្រង់ណា ត្រូវសួរបណ្ឌិតទាំងឡាយក្នុងពុទ្ធសាសនា ជាពិសេស គឺអ្នកសរសេរសៀវភៅនេះ ;

៤ ) ប្រសិនបើអាចធ្វើបាន ក្នុងពេលសួរម្ដងៗ ត្រូវមានក្រដាស ដីខ្មៅសម្រាប់កត់ចម្លើយរបស់លោក ;

៥ ) គប្បីជជែករឿយៗជាមួយបុគ្គលដែលមានចិត្តស្រឡាញ់ធម៌នេះដូចគ្នា។

ដោយនិព្វានជាបរមត្ថធម៌ ជាកុសលឈ្នះកុសលទាំងអស់ ខ្ញុំសូមលើកកុសលនេះជូនប្រជាជាតិក្នុងសកលលោកគ្រប់វណ្ណៈពណ៌សម្បុរ សូមបានទទួលនូវមនុស្សធម៌អំពីមនុស្សគ្នាឯង, បានទទួលនូវភពវាសនាសុខចម្រើនអស់កាលជាអង្វែងទៅហោង។



www.elibraryofcambodia.org

**ចិរំ តិដ្ឋតុ ពុទ្ធសាសនំ**

សេចក្តីបញ្ជាក់ក្នុងគ្រាបោះពុម្ពលើកទី២នេះ បានលើកយកភាគទី២ មករួមជាមួយនឹងភាគទី១នេះ, រួមគ្នាជាមួយភាគស្រេចតែម្តង។

ភ្នំពេញ វត្តលង្កា
នៅថ្ងៃទី៩ វិច្ឆិកា ១៩៧០
ភិក្ខុជម្មបាល ខៀវ-ជុំ



www.elibraryofcambodia.org

# និព្វានទស្សនៈ

អ្នកមិនស្គាល់នូវនិព្វាន ក៏ឈ្មោះថាមិនស្គាល់ច្បាស់នូវជីវិត; ការសិក្សាពុទ្ធទស្សនវិជ្ជា, បើមិនបានសិក្សាឲ្យចូលចិត្តអំពីរឿងនិព្វាន លោកថាមិនស្គាល់រឿងរបស់ជីវិតគ្រប់គ្រាន់ឡើយ។ ដូចនេះព្រោះអ្វី ? ព្រោះពុទ្ធទស្សនវិជ្ជា ជាវិជ្ជាដែលមានសេចក្ដីអធិប្បាយឲ្យយល់រឿងជីវិតយ៉ាងត្រឹមត្រូវតាមសេចក្ដីពិត និព្វានជាទីបំផុតរបស់ជីវិត, ជាទីបំផុតរបស់ពុទ្ធទស្សនវិជ្ជា។ ការសិក្សាអ្វីក៏ដោយ ប្រសិនណាបើមិនសិក្សាឲ្យដល់ទីបំផុត, សេចក្ដីចូលចិត្តក៏មិនទាន់ដល់ទីបំផុតដែរ។ ក្នុងព្រហ្មជាលសូត្រ លោកបានសម្ដែងឲ្យឃើញយ៉ាងច្បាស់ថា សាស្ត្រាចារ្យក្នុងសម័យពុទ្ធកាល ដែលមានសេចក្ដីយល់ឃើញខុស ឬមានសេចក្ដីយល់ឃើញមិនសព្វគ្រប់ ក៏ព្រោះតែការស្រាវជ្រាវរបស់ខ្លួន មិនទាន់ឃើញនូវនិព្វាននោះឯង។ ព្រះពុទ្ធបរមគ្រូជាសាស្ត្រាចារ្យដំបូង ដែលបានស្រាវជ្រាវរកឃើញនិព្វាន។ ព្រះអង្គបានចូលដល់និព្វានដោយចិត្ត, ព្រះអង្គទើបសព្វញ្ញូស្គាល់ច្បាស់នូវរបស់ដែលទាក់ទងជាមួយនឹងជីវិតរបស់សត្វលោកមិនមានសល់ខាន។ ក្រៅអំពីព្រះពុទ្ធបរមគ្រូ សាវ័ករបស់ព្រះអង្គ ដែលបានធ្វើឲ្យច្បាស់លាស់នូវនិព្វានហើយ លោកក៏បានស្គាល់រឿងរបស់ជីវិតយ៉ាងត្រឹមត្រូវតាមសេចក្ដីពិត។ សូមសង្កេតមើល៍ ពុទ្ធភាសិតដែលយើងធ្លាប់ពោលអាងមកហើយថា សេខបុគ្គលលោកស្គាល់ច្បាស់រឿងជីវិតនេះ និងនាទីដែលជីវិតត្រូវមានតទៅ។ សេខបុគ្គល គឺបុគ្គលដែលទើបនឹងចូលទៅដល់និព្វានដោយចិត្តរបស់ខ្លួន បានដល់ព្រះអរិយបុគ្គលតាំងតែអំពីថ្នាក់សោតាបន្នឡើងទៅ។ មេត្តាសង្កេតថា ព្រះអរិយបុគ្គលក្នុងសម័យពុទ្ធកាលនោះ ប្រាកដថា លោកមិនធ្លាប់បានរៀនវិទ្យាសាស្ត្រ, ចិត្តសាស្ត្រ ដូចអ្នកសិក្សាក្នុងសម័យនេះឡើយ។ តែទោះជាដូច្នោះ ព្រះពុទ្ធបរមគ្រូក៏ទ្រង់បញ្ជាក់ថា មានតែសេខបុគ្គលប៉ុណ្ណោះទេ ដែលស្គាល់ច្បាស់នូវរឿងរបស់ជីវិត។ សេចក្ដីនេះមានន័យថាបុគ្គលដទៃក្រៅអំពី



www.elibraryofcambodia.org

សេខបុគ្គល សូម្បីជាអ្នកស្ទាត់ជំនាញខាងវិទ្យាសាស្ត្រ ឬជីវសាស្ត្រដល់ថ្នាក់ណាក៏ដោយ គង់មានសេចក្តីចូលចិត្តខុសខ្លះជាមិនខាន។ សូមមើលបុគ្គលតួយ៉ាងក្នុងព្រហ្មជាលសូត្រ ខ្លះជាសាស្ត្រាចារ្យដែលមានកូនសិស្សៈនៅក្នុងសំណាក់យ៉ាងច្រើន។ ក៏គង់មានសេចក្តីចូលចិត្តខុសក្នុងរឿងរបស់ជីវិត ព្រោះគេមិនស្គាល់ច្បាស់នូវរឿងរបស់និព្វាន។

## សេចក្តីចូលចិត្តខុសក្នុងរឿង ទាក់ទងជាមួយនឹងនិព្វាន

រឿងនៃនិព្វាន. ជនភាគច្រើនចូលចិត្តខុសថា និព្វានជារឿងទាក់ទងតែជាមួយនឹងបុគ្គល ដែលមានចិត្តនឿយណាយនឹងលោកហើយប៉ុណ្ណោះ ចំណែកមនុស្សដែលនៅត្រូវការសប្បាយក្នុងលោក, រឿងនិព្វានមិនមែនជាការចាំបាច់ទេ។

ដទៃអំពីនេះ, មានជនពួកមួយទៀត ចូលចិត្តខុសថា មនុស្សយើងនឹងបានសម្រេចនិព្វានក្រោយដែលខ្លួនស្លាប់ទៅហើយ។ មនុស្សខ្លះកាលណានិយាយរឿងនិព្វាន គេនឹកឃើញថា ការបានដល់និព្វាន ក៏គឺការមិនកើត ឬការរលត់សូន្យមិនមានអ្វីសេសសល់សោះ គេគិតថានិព្វាន មិនមានគុណលក្ខណៈអ្វី គួរឲ្យយកចិត្តទុកដាក់ទេ។ ការមានជីវិតនៅក្នុងលោកនេះ សូម្បីជួបប្រទះសេចក្តីទុក្ខលំបាកផ្សេងៗ ក៏នៅល្អជាងការបានសម្រេចនិព្វាន។ សេចក្តីចូលចិត្តខុសនេះ ជាហេតុនាំឲ្យមនុស្សភាគច្រើនមិនធ្ងន់ចិត្តអំពីរឿងនិព្វាន សឹងជារឿងចាំបាច់ដល់ជីវិតមនុស្ស មិនថាក្មេងឬចាស់ មិនថាអ្នកស្ម័គ្រចិត្តនៅក្នុងលោក ឬអ្នកមានចិត្តណាយលោកហើយ។



www.elibraryofcambodia.org

# និព្វានជារឿងរបស់មនុស្សគ្រប់រូប

សេចក្តីពិត, **និព្វាន** ជារឿងទាក់ទងជាមួយនឹងមនុស្ស ព្រោះនិព្វានមានអត្ថថា "សេចក្តីស្ងប់, សេចក្តីត្រជាក់, សេចក្តីស្ងាត់" តាមប្រក្រតីចិត្តរបស់មនុស្សធម្មតា ជាចិត្តមានសេចក្តីក្តៅក្រហាយដោយកិលេសនានាដុតបំពក់ជានិច្ចកាល ជាពិសេសគឺតណ្ហា កិលេសនេះធ្វើឲ្យមនុស្សយើងមានចលនារឿយៗ ក្នុងរូបធាតុនិងអរូបធាតុ។ តែមានពេលខ្លះ ចិត្តរបស់មនុស្សយើងមានសេចក្តីស្ងប់ដែរ ដូចជាក្នុងពេលដែលយើងធ្វើការស្រេចបាច់រៀបរយហើយ យើងក៏បានចប់ភារៈកង្វល់ ចិត្តរបស់យើងក៏បានសប្បាយរីករាយ ក្នុងខណៈចិត្តស្ងប់ ចិត្តរមែងត្រជាក់។ ចូរសង្កេតថា ក្នុងខណៈដែលមានសេចក្តីប្រាថ្នា សេចក្តីស្រេកឃ្លាន ក្នុងខណៈនេះជាសេចក្តីទុក្ខ តែមនុស្សច្រើនតែមិនដឹងថាជាសេចក្តីទុក្ខ ព្រោះក្នុងខណៈនោះចិត្តរបស់យើងទៅចុចលើកសេចក្តីបំណងដែលយើងគិតថា បើបានសមតាមបំណងហើយ នឹងបានទទួលនូវសេចក្តីសុខយ៉ាងនេះយ៉ាងនោះ។ ដូច្នេះទើបមិនដឹងថាខ្លួនមានសេចក្តីទុក្ខ។ យើងដឹងថាយើងមានសេចក្តីទុក្ខចំពោះតែក្នុងពេលដែលមិនបានសមដូចបំណងប៉ុណ្ណោះ។ តែទោះជាយ៉ាងណាក្តីចូរសង្កេតថា រាល់ពេលដែលយើងមានសេចក្តីសុខនោះត្រូវតែជាពេលដែលយើងមានចិត្តស្ងប់ជានិច្ច តួយ៉ាងដូចគេចង់ទទួលទានអាហារអ្វី កាលណាគេបានសមតាមប្រាថ្នា គេក៏សប្បាយចិត្ត ព្រោះក្នុងខណៈនោះ ចិត្តរបស់គេស្ងប់ចាកសេចក្តីប្រាថ្នា ដូច្នេះទើបគេបានសេចក្តីសុខ។

ក្នុងចំណុចថា សេចក្តីសុខគ្រប់យ៉ាង ត្រូវបានមកចាកសេចក្តីស្ងប់នោះ នេះគឺជាសេចក្តីពិត មិនមាននរណាអាចបដិសេធបានទេ ទើបមានពុទ្ធភាសិតថា ៖

**"នត្ថិ សន្តិ បរំ សុខំ"**

"សេចក្តីសុខក្រៅចាកសេចក្តីស្ងប់មិនមាន"



www.elibraryofcambodia.org

សេចក្តីស្ងប់មានច្រើនថ្នាក់ កូនក្មេងតូចៗបានរបស់លេងសមតាមបំណង ក្នុងខណៈនោះចិត្តរបស់វាក៏ស្ងប់ ជនចម្រើនវ័យចង់ធ្វើអ្វី កាលណាធ្វើបានសមតាមប្រាថ្នា ចិត្តរបស់គេក៏រមែងបានស្ងប់ តែសេចក្តីស្ងប់បែបនេះ ជាសេចក្តីស្ងប់មិនប្រាកដទៀងទាត់ ព្រោះមានសេចក្តីប្រាថ្នា ចង់បានឲ្យសមតាមបំណងក្នុងរបស់ដទៃតទៅទៀត ដូចជាភ្លើងក្នុងខណៈដែលកំពុងឆេះ កាលណា គេយកឧសទៅដាក់ថែម ភ្លើងក៏ស្ងប់មួយស្របក់ តែអស់កាលមិនយូរប៉ុន្មាន កាលណាឧសនោះត្រូវកំដៅសព្វហើយ ភ្លើងក៏ឆេះឡើងទៀត ប្រសិនណាយើងដាក់ឧសច្រើនអណ្តាតភ្លើងអាចរលត់បាត់ភ្លាម តែពេលក្រោយមក ភ្លើងក៏ឆេះខ្លាំងលើសដើម។ តួយ៉ាងនេះ ប្រៀបបាននឹងបុគ្គលដែលមានចិត្តប្រកបដោយតណ្ហាប្រាថ្នាចង់បំពេរសេចក្តីសប្បាយរបស់ខ្លួន បុគ្គលប្រភេទនេះ មានចំណង់លើរបស់មិនរើសមុខ ចង់បានរបស់នេះហើយ ចង់បានរបស់នោះទៀត ជាបុគ្គលហាមប្រាមចិត្តរបស់ខ្លួនបានដោយតឹងជាទីបំផុត ព្រោះភ្លើងនៃតណ្ហារបស់គេមានកម្លាំងខ្លាំងក្លា ដូចជាគំនរភ្លើងដែលកំពុងឆេះយ៉ាងសន្ធោសន្ធៅដែលគេមិនងាយលត់បានយ៉ាងដូច្នោះឯង។ ប្រសិនបើយើងពិចារណាតាមល័ខគោលនៃបដិច្ចសមុប្បាទ យើងតង់ចូលចិត្តបានច្បាស់លាស់ ព្រោះបដិច្ចសមុប្បាទមានសម្តែងបញ្ជាក់ថា «បើវេទនាមានកម្លាំងខ្លាំងក្លា តណ្ហាក៏មានកម្លាំងខ្លាំងក្លា បើតណ្ហាមានកម្លាំងខ្លាំងក្លា ឧបាទានក៏មានកម្លាំងខ្លាំងក្លា ក្នុងកាលណាឧបាទាន វេទនាខ្លាំងក្នុងខណៈដែលសមតាមប្រាថ្នា ក៏បានសេចក្តីសុខច្រើន ក្នុងខណៈដែលមិនសមតាមប្រាថ្នាក៏កើតទុក្ខច្រើន កាលណាកើតសេចក្តីសុខឬសេចក្តីទុក្ខច្រើន តណ្ហាក៏មានច្រើន» បុគ្គលដែលប្រព្រឹត្តតាមចិត្តរបស់ខ្លួន ដោយអំណាចរបស់តណ្ហា រមែងជាហេតុឲ្យកើតតណ្ហាជាប់តគ្នា មិនមានទីបំផុត។

សេចក្តីសុខកើតឡើងក្នុងពេលមានសេចក្តីស្ងប់ ព្រោះថាមនុស្សលោកប្រសិនបើមិនមានសេចក្តីស្ងប់ មានចិត្តក្តៅក្រហាយអស់កាលជានិច្ចនោះ នឹងកើតជម្ងឺទាក់ទងដោយខួរក្បាលជាមិនខានឡើយ។ ដូច្នេះសេចក្តីស្ងប់ ទើបជា



www.elibraryofcambodia.org

របស់ចាំបាច់សម្រាប់ជីវិតមនុស្សទូទៅ មិនមានកំណត់ដោយពេលដោយវ័យទេ។ ដែលថានិព្វានជារបស់ចាំបាច់សម្រាប់មនុស្ស ព្រោះនិព្វានដៅដល់សេចក្ដីស្ងប់ដ៏ខ្ពង់ខ្ពស់ ជាសេចក្ដីស្ងប់កើតមានឡើងខាងក្រោយអំពីការចូលចិត្តបញ្ហាជីវិតយ៉ាងជ្រាលជ្រៅហើយ។

សេចក្ដីស្ងប់ដែលហៅថានិព្វាននោះ ផ្សេងអំពីសេចក្ដីស្ងប់ធម្មតាក្នុងលោក ព្រោះសេចក្ដីស្ងប់ធម្មតា ជាសេចក្ដីស្ងប់កើតតាមពេល ជាសេចក្ដីស្ងប់មិនមានស្ថិរភាព ជាសេចក្ដីស្ងប់មានគូជាមួយនឹងសេចក្ដីមិនស្ងប់។ និព្វានជាសេចក្ដីស្ងប់ មិនមានគូជំនួស ព្រោះនិព្វានស្ងប់កិលេស ជាគ្រឿងពង្វិលមានលោភៈ ទោសៈ មោហៈជាដើម កិលេសទាំងឡាយដែលរលាយអស់ហើយ មិនមានពេលត្រឡប់កើតទៀតបាន។

ដែលថា កិលេសរលត់អស់ហើយ កើតវិញមិនបាននោះ ព្រោះនិព្វានមានសេចក្ដីភ្លឺស្វាងជាគ្រឿងធ្វើឲ្យមានសតិសម្បជញ្ញៈជានិច្ចកាល ដូចជាផ្ទះដែលមានម្ចាស់ចាំយាមនៅគ្រប់ពេល ចោរចូលលួចទ្រព្យសម្បត្តិមិនបានដូច្នោះឯង។

ការសិក្សាអំពីរឿងនិព្វាន ប្រសិនបើសិក្សាចាកចំណុច នៃសេចក្ដីស្ងប់នេះនឹងចូលចិត្តងាយ មានសេចក្ដីធូន់ចិត្តចង់រៀនតទៅមុខទៀត។ តែសេចក្ដីស្ងប់ដែលហៅថា**និព្វាន**នោះ មិនមែនជាសេចក្ដីស្ងប់រាក់ៗ ស្រាលៗទេ គឺជាសេចក្ដីស្ងប់ជ្រៅធូន់ ដែលនៅក្នុងនោះមានពន្លឺស្វាង មានសេចក្ដីត្រជាក់នាំមកនូវសេចក្ដីរីករាយចិត្តរបស់អ្នកបាននិព្វានជាចិត្តស្អាត ស្គាល់បញ្ហាជីវិតយ៉ាងជ្រាលជ្រៅដល់ទីបំផុត។ នេះជាលក្ខណៈដោយសង្ខេបរបស់ចិត្តនៃបុគ្គលអ្នកបាននិព្វាន, អ្នកបាននិព្វានហើយ មិនដែលត្រឡប់ថយក្រោយ ឬទ្រាន់ណាយចំពោះនិព្វានដោយអាស្រ័យគុណសម្បត្តិដូចពោលមក។

មានសេចក្ដីអស្ចារ្យមួយបែបទៀត តែងកើតមកដល់អ្នកបាននិព្វាន គឺធ្វើឲ្យគេចូលចិត្តជ្រៅក្នុងបញ្ហាធម្មជាតិ ព្រោះអ្វី ? ព្រោះនិព្វានជាគុណធម៌នៅ



www.elibraryofcambodia.org

ខាងក្រោយធម្មជាតិ, ធម្មជាតិក្តី ច្បាប់ធម្មជាតិក្តី កើតឡើងយ៉ាងណាៗ គេរមែងចូលចិត្តបានទាំងអស់។ ដោយអាស្រ័យសេចក្តីចូលចិត្តរឿងធម្មជាតិយ៉ាងជ្រៅនេះ ទើបគេមានជីវិតរស់នៅដោយសេរីយ៉ាងសម្បូណ៌បំផុត សឹងរាប់ថាជាសេចក្តីអស្ចារ្យយ៉ាងចម្លែកមួយរបស់អ្នកបាននិព្វាន។

និព្វានមានគុណតម្លៃដូចពោលមកនេះ ទើបលោកស្តីថានិព្វានជារឿងរបស់មនុស្សរាល់រូប, ជារឿងដែលមនុស្សត្រូវយកចិត្តទុកដាក់សិក្សា។ កាលណាបើយើងចាប់ផ្តើមសិក្សាដំបូង យើងត្រូវលះបង់គំនិតថា ការបានសម្រេចដល់និព្វាន គឺការមិនកើតថ្មីទៀត, អ្នកបាននិព្វានជាព្រះអរហន្តហើយ នឹងកើតឬមិនកើតជារឿងដែលយើងដឹងមិនបានក្នុងពេលនេះឡើយ តែយើងគង់ដឹងបានក្នុងពេលដែលយើងបានជាព្រះអរហន្ត។ ការសិក្សារឿងនិព្វាន ត្រូវសិក្សាចាកសេចក្តីពិត ដែលអាចពិសោធបាន មានមនុស្សជាច្រើនបានធ្វើសេចក្តីសន្និដ្ឋានដោយដៅស្មាន ព្រោះគេចូលចិត្តខុសថាការបានសម្រេចដល់និព្វានមានតែក្នុងពេលដែលមនុស្សយើង បានដល់នូវសេចក្តីស្លាប់ហើយៗ។ សេចក្តីពិតការបានសម្រេចនូវនិព្វាន ក៏គឺការបានដល់សេចក្តីស្ងប់, សេចក្តីភ្លឺស្វាង និងសេចក្តីបរិសុទ្ធ ដែលមនុស្សយើងឃើញបានដោយច្បាស់ថា ការសម្រេចដល់ភាវៈស្ងប់សុខសាន្តនេះ ត្រូវបានក្នុងពេលដែលខ្លួនកំពុងមានជីវិតនៅឡើយ។ តាមប្រក្រតី ភាពស្ងប់នេះយើងធ្លាប់មានស្រាប់ តែសេចក្តីស្ងប់ស្ងាត់, សេចក្តីភ្លឺស្វាង និងសេចក្តីបរិសុទ្ធដែលយើងធ្លាប់មាននោះ រមែងប្រែប្រួលមិនបាត់ស្ថិតស្ថេរជាស្ថាពរ។ ស្ងប់ , ស្វាងបរិសុទ្ធកើតឡើងហើយ ត្រឡប់រលត់បាត់ទៅវិញ ព្រោះយើងស្គាល់ធម៌ត្រៃលក្ខណ៍, អរិយសច្ច និងបដិច្ចសមុប្បាទមិនទាន់ច្បាស់លាស់។

**ការសម្រេចដល់និព្វានមានច្រើនថ្នាក់,** ព្រះអរិយបុគ្គលតាំងអំពីថ្នាក់សោតាបន្នឡើងទៅ ឈ្មោះថាបានសម្រេចនិព្វានហើយ តែនិព្វានរបស់បុគ្គល-ទាំងអស់នោះមិនដូចគ្នាទេ។ ព្រះសោតាបន្ន បានសម្រេចនិព្វានមិនទាន់ដល់



www.elibraryofcambodia.org

ទីបំផុត ព្រះអរិយបុគ្គលដែលសម្រេចនិព្វានដល់ទីបំផុត ក៏គឺព្រះអរហន្តមួយពួកប៉ុណ្ណោះ។ ព្រះសោតាបន្ន លោកលះបង់សំយោជនបាន៣យ៉ាងគឺ : សក្កាយទិដ្ឋិ, វិចិកិច្ឆា និងសីលព្វតបរាមាស។ កិលេសធម៌នេះ ព្រះសោតាបន្នលះបានដោយដាច់ខាត មិនបានត្រឡប់កើតទៀតឡើយ។ ព្រះសកិទាគាមិលះសំយោជនៈបាន៣ដូចព្រះសោតាបន្ន តែលោកបានធ្វើឲ្យកាមរាគនិងបដិឃៈស្រាលជាងព្រះសោតាបន្ន។ ព្រះអានាគាមិលះសំយោជនៈបាន៣ដូចព្រះអរិយបុគ្គលពីរប្រភេទខាងដើម ហើយលោកបានលះបង់កាមរាគនិងបដិឃៈដោយដាច់ខាងថែមទៀត។ ព្រះអរិយបុគ្គលទាំងឡាយ លោកដឹងច្បាស់ថាកិលេសមិនមែនជារបស់ធម្មជាតិ ព្រោះកិលេសទាំងឡាយមានកាមរាគជាដើមជារបស់ត្រូវរលាយអស់ដោយមិនមានសេសសល់។ ហើយលោកចូលចិត្តដោយច្បាស់លាស់ថា អវយវៈដែលជាគ្រឿងកំណត់សំគាល់នៃភេទ[១] កើតឡើងព្រោះអាស្រ័យកាមរាគជាឫសគល់ កាលណាកាមរាគផុតរលត់ចាកសន្តានហើយ គ្រឿងផ្សំឬគ្រឿងអង្រន់ឲ្យកើតកាមរាគ ទោះជានៅមាន ក៏មិនមានឥទ្ធិពលដូចក្នុងកាលមុន ដូចជាគំនរភ្លើងដែលអស់គ្រឿងផ្សំសម្រាប់ឆេះហើយ ការដាក់ឧសចូលទៅក្នុងគំនរភ្លើងនោះ ក៏អស់មានន័យ ព្រោះមិនមានបច្ច័យសម្រាប់ធ្វើឲ្យមានភ្លើង។ ព្រះអរិយបុគ្គលថ្នាក់ព្រះអនាគាមី លោកដឹងច្បាស់ថា កាលណាស្លាប់ចាកលោកនេះហើយ លោកមិនត្រឡប់មកកើតក្នុងលោកនេះតទៅទៀត ព្រោះលោកនេះជាលោកនៃកាមារម្មណ៍ តែលោកទៅកើតក្នុងលោកដទៃ ដែលមានភាពលក្ខណៈត្រូវគ្នានឹងនិស្ស័យសន្តានរបស់លោក។

ចំណែកព្រះអរហន្ត លោកលះបង់សំយោជនក្កិលេសដូចព្រះអនាគាមីផង លះបង់សំយោជនៈខាងចុង(រូបរាគ អរូបរាគ មានៈ ឧទ្ធច្ច អវិជ្ជា) ផង។ ដូច្នោះព្រះអរហន្ត ទើបជាបុគ្គលបានសម្រេចដល់សេចក្ដីស្ងប់ត្រជាក់ សេចក្ដីភ្លឺស្វាងនិងសេចក្ដីបរិសុទ្ធយ៉ាងខ្ពស់បំផុត។

---

១- ភេទ-អវយវៈជាគ្រឿងសម្គាល់ឲ្យដឹងជាបុរស ជាស្ត្រី ដែលបាលីហៅថា បុំលិង្គ ឥត្ថិលិង្គ។



www.elibraryofcambodia.org

យើងគួរចូលចិត្តថា ការសម្រេចនិព្វាននោះជារបស់ធម្មតានៃមនុស្សគ្រប់រូប ដូចជាមនុស្សកើតមកហើយត្រូវសម្រេចសេចក្ដីចាស់ ឈឺ ស្លាប់ជាធម្មតាហ្នឹងដែរ។ បុគ្គលដែលគេយល់ច្បាស់នូវរឿងជីវិត ចិត្តរបស់គេក៏ឱនទៅរកនិព្វានជាធម្មតា។ និព្វានជាភាវៈមាននៅដោយធម្មតា មិនមាននរណាអាចសាងបាន។ ការសម្រេចនិព្វាន បើប្រៀបឲ្យងាយយល់ក៏ដូចជាកន្លែងណាមួយមានងងឹត កាលណាកំចាត់ងងឹតចេញអស់ហើយ របស់ដែលសល់នៅ គឺសេចក្ដីភ្លឺស្វាង ឬក្នុងទីណាមានកំដៅ កាលណាកំដៅត្រូវដេញកំចាត់អស់ហើយ របស់ដែលសល់នៅក៏គឺសេចក្ដីត្រជាក់។ នៅខាងក្នុងចិត្តរបស់មនុស្សយើងនេះ កាលណាបានកំចាត់សេចក្ដីងងឹតនៃអវិជ្ជា និងសេចក្ដីក្ដៅក្រហាយនៃតណ្ហាអស់ហើយ របស់ដែលសល់នៅក៏គឺភាពភ្លឺស្វាងនិងភាពត្រជាក់។ គប្បីចូលចិត្តថាភាពភ្លឺស្វាងនិងភាពត្រជាក់នេះ ជារបស់មានព្រមនៅជានិច្ច គឺជាធាតុមួយសម្រាប់សម្ពស្សជាមួយនឹងចិត្ត ប្រៀបបាននឹងសត្វហ៊ីងនៅក្នុងឆ្នាំងផ្កាប់ កាលណាគេផ្ងារឆ្នាំង សត្វហ៊ីងក៏ត្រូវបានទទួលសម្ពស្សជាមួយនឹងពន្លឺក្នុងខាងក្រៅ។

ការសិក្សាអំពីរឿងនិព្វាន, ប្រសិនបើអ្នកអានធ្វើសេចក្ដីចូលចិត្ត ដូចសេចក្ដីដែលបាននិយាយមកហើយទាំងប៉ុន្មាន យើងក៏មុខជាមិនខានដឹងថានិព្វានជារបស់ល្អ, ជារបស់គួរឲ្យយកចិត្តទុកដាក់, ជារបស់មានប្រយោជន៍ដល់ជីវិតយ៉ាងឆាប់រហ័ស។

## និព្វានគឺជាសេចក្ដីស្ងប់

**និព្វាន** ដៅដល់ «សេចក្ដីស្ងប់» ចំណុចនេះយើងនឹងបានឃើញច្បាស់ចាកពុទ្ធភាសិតទាំងឡាយ ដូចមានតទៅនេះ ៖

ម្នាលភិក្ខុទាំងឡាយ! ភិក្ខុប្រកបដោយធម៌៦យ៉ាងនេះ រមែងជាបុគ្គល



www.elibraryofcambodia.org

អាចធ្វើឲ្យជាក់ច្បាស់នូវនិព្វានគឺ :

១ ) ក្នុងពេលណាគួរសង្កត់ចិត្ត ក៏ព្យាយាមសង្កត់ចិត្ត។

២ ) ក្នុងពេលណាគួរប្រោងចិត្ត ក៏ព្យាយាមប្រោងចិត្ត។

៣ ) ក្នុងពេលណាគួរធ្វើចិត្តឲ្យរីករាយ ក៏ព្យាយាមធ្វើចិត្តឲ្យរីករាយ។

៤ ) ក្នុងពេលណាគួរធ្វើចិត្តឲ្យនៅព្រងើយ ក៏ព្យាយាមធ្វើចិត្តឲ្យនៅព្រងើយ។

៥ ) ជាបុគ្គលមានអធ្យាស្រ័យប្រណីត។

៦ ) ជាបុគ្គលមានចិត្តត្រេកអរខ្លាំងក្លាក្នុងនិព្វាន។

## មនោសញ្ចេតនារបស់បុគ្គល ដែលចូលទៅដល់និព្វាន

និព្វានគឺអ្វី? មានគុណតម្លៃដូចម្ដេច? សាសនភាសិតសម្រាប់ដោះស្រាយអំពីរឿងនេះ ច្រើនតែជារបស់ព្រះអរិយបុគ្គលដែលបានដល់និព្វានហើយ . មានចិត្តសម្ផស្សជាមួយនឹងនិព្វានហើយ ក្នុងខណៈព្រមគ្នានេះ លោកតែងមានមនោសញ្ចេតនាខាងគំនិតថា ៖

**“ឯតំ សន្តំ ឯតំ បណីតំ យទិទំ មទនិម្មទនោ**

**បិបាសវិនយោ អាលយសមុគ្ឃាតោ វដ្ដុបច្ឆេទោ**

**តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ”។**

“នេះជាទីស្ងប់ពិត នេះជាទីប្រណីតពិត ទីនេះឯងជាទីញាំញីសេចក្ដីស្រវឹង ជាទីកំចាត់បង់នូវសេចក្ដីស្រេកឃ្លាន ជាទីដកចេញនូវសេចក្ដីអាល័យ ជាទីកាត់បង់នូវវដ្ដៈ ជាទីអស់ទៅនៃតណ្ហា ជាទីរំលាយចោលនូវកាមរាគ ជាទីរំលត់បង់នូវកិលេសនេះឯងគឺ “និព្វាន”។

ពុទ្ធភាសិតនេះ សម្ដែងឲ្យយើងឃើញយ៉ាងច្បាស់ថា និព្វានគឺជាសេចក្ដីស្ងប់យ៉ាងប្រណីត។ ពាក្យថា “ប្រណីត” នោះក្នុងអត្ថកថាប្រាប់ថា បានដល់



www.elibraryofcambodia.org

គុណធម៌ដែលមានតម្លៃខ្ពង់ខ្ពស់បំផុត ដែលធ្វើឲ្យបុគ្គលអ្នកបរិភោគមិនចេះធុញទ្រាន់, មិនចេះឆ្អែត។ ស្ងប់ក្នុងទីនេះសំដៅយកសេចក្ដីស្ងប់ដែលហៅថា «និព្វាន» បុគ្គលដែលបានដល់សេចក្ដីស្ងប់នេះហើយ រមែងមិនចេះណាយ, មិនចេះឆ្អែត. ត្រូវនឹងពុទ្ធភាសិតមួយកន្លែងទៀតថា ៖

**«បវិវេករសំ បិត្វា រសំ ឧបសមស្ស ច**

**និទ្ទរោ ហោតិ និប្បាបោ ធម្មបីតិរសំ បិវំ។**

«បុគ្គលបានផឹករសនៃសេចក្ដីស្ងាត់ចាកកិលេស, បានផឹករសនៃសេចក្ដីស្ងប់ហើយ រមែងជាអ្នកមិនមានសេចក្ដីក្រវល់ក្រវាយ ជាបុគ្គលចេញចាកបាបបាន បុគ្គលដែលបានផឹកនូវរសនៃធម្មបីតិរមែងមានផលដូចនេះឯង»។

**«ធម្មបីតិ សុខំ សេតិ វិប្បសន្នេន ចេតសា**

**អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ»។**

«បុគ្គលមានបីតិក្នុងធម៌ មានចិត្តជ្រះថ្លារមែងនៅជាសុខ បណ្ឌិតរមែងត្រេកអរក្នុងធម៌ដែលព្រះអរិយៈ សម្ដែងហើយគ្រប់កាល»។

**«ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារ**

**សមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហក្ខយោ**

**វិរាគោ និរោធោ និព្វានំ»។**

«ធម្មជាតុនេះស្ងប់ពិត ធម្មជាតុនេះប្រណីតពិត ទីនេះឯងជាទីស្ងប់សង្ខារទាំងពួង ជាទីលះបង់ដោយមិនមានសល់ នូវឧបនិធិទាំងពួង ជាទីអស់ទៅនៃតណ្ហា ជាទីប្រាសចាកសេចក្ដីសៅហ្មង ជាទីរំលត់បង់នូវកិលេសធម៌នេះឯងគឺ «និព្វាន»។

**«និព្វាន»** ដៅដល់សេចក្ដីស្ងប់ តែមិនមែនសេចក្ដីស្ងប់ធម្មតា ដែលយើងធ្លាប់ស្គាល់ធ្លាប់ជួបប្រទះក្នុងពេលខ្លះ បាត់បង់ទៅវិញក្នុងពេលខ្លះនោះទេ គឺលោកដៅយកសេចក្ដីស្ងប់ទៀតទាត់ មិនមានអ្វីរចនាតាក់តែង មិនមែនកើតមកចាកអ្វី ឬផ្លាស់ប្ដូរមកចាករបស់អ្វី ជារបស់ដែលមាននៅឯង១ ជាសេចក្ដី



www.elibraryofcambodia.org

ពិតដែលមានមកនៅក្នុងខាងក្រោយនៃធម្មជាតិទាំងឡាយ ទាំងខាងរូបធាតុ ទាំងខាងនាមធាតុ។ របស់ទាំងឡាយណា ដែលមានបច្ច័យរចនាតាក់តែង កាលណាអស់ធាតុអស់បច្ច័យ ហើយរបស់ទាំងឡាយនោះរមែងជ្រួតជ្រាបចូលទៅនៅក្នុងសេចក្តីស្ងប់ស្ងាត់របស់សាកលចក្រវាលនេះ។ សេចក្តីស្ងប់ស្ងាត់សឹងមាននៅគ្រប់ទិស គ្រប់កន្លែង គ្រប់កាលទាំងអស់។

## និព្វានគេត្រូវស្គាល់បានយ៉ាងណា?

សេចក្តីស្ងប់ ដែលហៅថា «**និព្វាន**» នោះ អ្នកគិតពិចារណាអំពីរឿងនេះ តាមតម្រាយនៃតក្កវិជ្ជាថា របស់មួយមុខឬរបស់ច្រើនមុខរួមគ្នា បើអស់ហេតុអស់បច្ច័យ ឬរំលាយហេតុបច្ច័យអស់ព្រមគ្នាហើយ របស់ដែលសល់នៅក៏គឺជាតុវាលទំនេរប្រាសចាកខ្លួនប្រាណនៃរបស់នោះៗ ហើយនៅក្នុងធាតុវាលនោះ មិនមានអ្វីដទៃក្រៅអំពីសេចក្តីស្ងប់ស្ងៀម ដែលធ្លាប់មានអស់កាលជានិច្ច មិនចាំបាច់ត្រូវមានអ្វីរចនាតាក់តែង ព្រោះរបស់នេះ វាមិនមានអ្វីជាតួប្រាកដការណ៍ តែវាធ្វើឲ្យយើងដឹងថា របស់រាល់យ៉ាងដែលមានប្រាកដការណ៍នោះ វាកើតឡើងអំពីហេតុបច្ច័យច្រើនយ៉ាង រួបរួមគ្នាកសាងជារបស់នោះឡើង មិនមានរបស់ណាដែលមានខ្លួនប្រាណរបស់វាយ៉ាងពិតប្រាកដទេ។ សេចក្តីដៅនេះ ហាក់ដូចធ្វើឲ្យយើងចូលចិត្តបានងាយដែរ តែយើងត្រូវកុំភ្លេចថា **និព្វាន** គឺជារបស់មួយដែលគេអាចដឹងបាន គឺដឹងដល់សេចក្តីស្ងប់ស្ងាត់នោះពិតៗ ទើបឈ្មោះថាដឹងច្បាស់ក្នុងរឿងនិព្វាន។ បើត្រឹមតែចូលចិត្តតែមិនដឹងក៏មិនឈ្មោះថាបានដឹងច្បាស់នូវនិព្វានទេ។

ពាក្យថា «**ធ្វើឲ្យជាក់ច្បាស់នូវនិព្វាន**»[១] លោកអធិប្បាយថា បានដល់ការដឹងទូទៅដល់និព្វាន លោកមានបញ្ជាក់ដោយបាលីថា **សច្ឆិកិរិយបញ្ញា**

[១] លោក គឺព្រះអដ្ឋកថាចារ្យ ក្នុងទីនេះជាពាក្យព្រះសារិបុត្តត្ថេរ។



www.elibraryofcambodia.org

**ផុស្សផ្ដេនញាណំ** ប្រែថាបញ្ញាដែលធ្វើឲ្យជាក់ច្បាស់នូវនិព្វានក៏គឺញាណដែលបានសម្ផស្សនូវនិព្វាន។ សេចក្ដីពន្យល់របស់លោក ត្រូវនឹងពុទ្ធភាសិតថា **ផុសន្តិ ធីរា និព្វានំ យោគក្ខេមំ អនុត្តរំ** ប្រែថា អ្នកប្រាជ្ញទាំងឡាយរមែងសម្ផស្សនិព្វាន ជាភាពក្សេមចាកគ្រឿងប្រកបគឺកិលេសយ៉ាងខ្ពស់ខ្ពស់។

**និព្វានជាទីស្ងប់នៃសង្ខារទាំងពួង** ពាក្យថា **និព្វាន** ជាទីស្ងប់នៃសង្ខារទាំងពួង មានន័យថា របស់ដែលមានបច្ច័យរចនាតាក់តែង។ ក្នុងន័យនេះ ពាក្យថាសង្ខារលោកសំដៅយក **នាមរូប**។

វិញ្ញាណ ក្នុងកាលណាបានជួបប្រទះសេចក្ដីស្ងប់ដ៏ប្រណីតនេះហើយ អវិជ្ជា តណ្ហា និងឧបាទាន សន្សឹមរលាយអស់ទៅបន្តិចម្ដងៗ លុះដល់ទីបំផុតក៏រលាយអស់មិនមានសេសសល់។ ក្នុងកាលណាកិលេសធម៌ មិនមានសល់នូវក្នុងសន្តានរបស់សត្វទាំងឡាយហើយ ក្នុងកាលនោះសត្វធ្វើកម្មអ្វី ក៏មិនមែនជាកម្មទេ។ កាលណាអស់កម្មអស់កិលេស បដិសន្ធិវិញ្ញាណក្នុងជាតិតទៅក៏មិនមាន កាលណាបដិសន្ធិវិញ្ញាណមិនមាន នាមរូបក៏មិនមាន។ ដោយហេតុនេះ, និព្វានទើបបានឈ្មោះថា ជាទីស្ងប់នៃសង្ខារទាំងពួង។ សេចក្ដីដៅនេះយើងនឹងឃើញបានយ៉ាងច្បាស់ចាកសំនួរចម្លើយរបស់អជិតយុវជន ជាមួយនឹងព្រះបរមគ្រូដូចមានតទៅនេះ ៖

«បពិត្រព្រះអង្គទ្រង់និរទុក្ខ បញ្ញា, សតិ, និងនាមរូប របស់ទាំងនេះរលត់ក្នុងទីណា ?»

**អជិតៈ** «អ្នកសួរយើងនូវបញ្ហាណា យើងនឹងប្រាប់អ្នកនូវបញ្ហានោះ នាមនិងរូបរលត់បាត់ទៅមិនមានសល់នៅក្នុងទីណា បញ្ញានិងសតិក៏រលត់បាត់ទៅក្នុងទីនោះ ព្រោះអ្វី ? ព្រោះវិញ្ញាណរលត់អស់មិនមានសេសសល់»។

បញ្ញានិងសតិជាចំណែកមួយនៃនាមធម៌ក្នុងពួកសង្ខារ សេចក្ដីឆ្លើយដែលព្រះអង្គទ្រង់ធ្វើចំពោះអជិតយុវជន ជាចម្លើយគួរឲ្យយើងយកមកគិតពិចារណាយ៉ាងច្រើនបំផុត។ តាមធម្មតាអ្នកសិក្សាធម៌ជាន់ខ្ពស់ច្រើនចូលចិត្ត



www.elibraryofcambodia.org

ថា សតិនិងបញ្ញាជារបស់នូវដដែល, ជារបស់ទៀងទាត់មិនរលត់រលាយ ជាអសង្ខតធម៌។ តែតាមសេចក្តីពិត, សតិបញ្ញាជាសង្ខតធម៌ ជារបស់ត្រូវបានរលត់រលាយបាត់ទៅក្នុងទីបំផុត។ បុគ្គលដែលមានកំណាន់ក្នុងសតិបញ្ញាច្រើនហួសពេក នឹងរួចចាកសេចក្តីទុក្ខដល់ទីបំផុតពុំបានឡើយ។ ការពិចារណាឲ្យឃើញថា សតិបញ្ញាជារបស់មិនទៀង ជាទុក្ខ និងជាអនត្តា ជាចំណុចសំខាន់បំផុតក្នុងការធ្វើឲ្យចិត្តរួចចាកផុតអាសវក្កិលេសទាំងពួង។ ដោយសេចក្តីពិតយើងក៏រមែងពិចារណាឃើញគ្រប់ពេលថា សតិបញ្ញាជារបស់កើតបានរលត់បានតាមអារម្មណ៍។

## និព្វានជាទីលះបង់ស្រឡះ
## នូវឧបនិធិទាំងពួង

ពាក្យថា **និព្វាន** ជាទីលះបង់ស្រឡះនូវឧបនិធិទាំងពួង ឧបធិក្នុងទីនេះលោកសំដៅយកកិលេសក៏មាន ដូចមានក្នុងពាក្យថា «**ឧបធិវិវេកោ**» សេចក្តីស្ងាត់ចាកឧបធិ ឧបធិក្នុងទីនេះ ដៅយកកិលេស។ លោកសំដៅយកបញ្ចក្ខន្ធក៏មាន ដូចមានក្នុងពាក្យថា ៖

**«រូបេ ច សទ្ទេ ច អថោ រសេ ច**
**កាមិត្ថិយោ បាតិវទន្តិ យញ្ញា**
**ឯតំ មលន្តិ ឧបធិសុ ញត្វា**
**តស្មា ន យិដ្ឋេ ន ហុតេ អនញ្ជី»។**

«យញ្ញទាំងឡាយ រមែងពោលសរសើរ រូប, សម្លេង, រស, កាម និងស្រីទាំងឡាយ ខ្ញុំដឹងថា នោះជាមន្ទិលក្នុងឧបធិទាំងឡាយ ហេតុនោះទើបមិនត្រេកអរហើយក្នុងការសែនព្រេន មិនត្រេកអរហើយក្នុងការបួងសួងបន់ស្រន់»



www.elibraryofcambodia.org

ឧបធិក្នុងទីនេះ បានដល់បញ្ចក្ខន្ធ សឹងជាវេវចនៈរបស់ពាក្យថា សង្ខារ ដូចបានពោលមកហើយក្នុងខាងដើម។

## និព្វានគឺជាវិរាគធម៌

ក្នុងកន្លែងខ្លះ, ព្រះសម្មុទ្ធទ្រង់ហៅនិព្វានថា **វិរាគធម៌** ប្រែថាធម៌ជាទីប្រាសចាកនូវកិលេស សំដៅសេចក្ដីថា ចិត្តរបស់បុគ្គលណាក៏ដោយ ក្នុងកាលណាបានជួបប្រទះវិរាគធម៌ហើយ កិលេសទាំងឡាយរមែងរលាយអស់ចាកចិត្ត។ ពាក្យថាវិរាគធម៌ក្នុងទីនេះ សំដៅយកសេចក្ដីស្ងប់ដ៏ប្រណីតនោះឯង។ ចំពោះវិរាគធម៌នេះ យើងនឹងឃើញបានច្បាស់ចាកពុទ្ធភាសិតដូចមានតទៅនេះ ៖

**«យាវតា ភិក្ខវេ ធម្មា សង្ខតា វា អសង្ខតា វា**
**វិរាគោ តេសំ អគ្គមខាយតិ យទិទំ មទនិម្មទនោ**
**បិបាសវិនយោ អាលយសមុគ្ឃាតោ វដ្ដុបច្ឆេទោ**
**តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ»**

«ម្នាលភិក្ខុទាំងឡាយ! សង្ខតធម៌ឬអសង្ខតធម៌មានប្រមាណប៉ុណ្ណោះ វិរាគធម៌ យើងពោលថា ជាកំពូលនៃសង្ខតធម៌ឬអសង្ខតធម៌ទាំងអស់នោះ វិរាគធម៌នេះ ជាធម៌ញាំញីនៃសេចក្ដីស្រវឹង ជាធម៌កំចាត់បង់នូវសេចក្ដីស្រេកឃ្លាន ជាធម៌ដកចោលនូវសេចក្ដីអាល័យ ជាធម៌កាត់ផ្ដាច់នូវឫសគល់នៃវដ្ដៈ ជាធម៌អស់ទៅនៃតណ្ហា។ ជាធម៌រំលត់ដោយមិនមានសេសសល់នូវកិលេស នេះគឺជា «និព្វាន»។

សូមសង្កេតថា ពាក្យបាលីក្នុងទីនេះ និងពាក្យថា **ឯតំ សន្តំ ឯតំ បណីតំ** ជាពាក្យមានន័យដូចគ្នា។ ដូច្នេះ ពាក្យថា វិរាគធម៌ ទើបសំដៅយកសេចក្ដីស្ងប់ ឬភាវៈដ៏ស្ងប់ដ៏ប្រណីតនោះឯង។ ម្យ៉ាងទៀត គប្បីសង្កេតថា ភាវៈដ៏ស្ងប់ដ៏



www.elibraryofcambodia.org

ប្រណីតនេះ ជាអសង្ខតធម៌ គឺជារបស់ដែលមិនមានរចនាតាក់តែង ជារបស់ដែលមានឯង, កើតឯង, ធ្លាប់មាននៅយ៉ាងណា ក៏គង់នៅយ៉ាងនោះគ្រប់កាល។

## និព្វានជាអសង្ខតធម៌

ក្នុងចំណុចថា និព្វានជាអសង្ខតធម៌នេះ យើងនឹងបានឃើញច្បាស់ចាកពុទ្ធភាសិតដូចតទៅនេះទៀត ៖

**«អត្ថិ ភិក្ខវេ អជាតំ អភូតំ អកតំ អសង្ខតំ»។**
**នោចេ តំ ភិក្ខវេ អភវិស្ស អជាតំ អភូតំ អកតំ**
**អសង្ខតំ។ នយិធ ជាតស្ស ភូតស្ស កតស្ស សង្ខតស្ស**
**និស្សរណំ បញ្ញាយេថ យស្មា ច ខោ ភិក្ខវេ**
**អត្ថិ អជាតំ អភូតំ អកតំ អសង្ខតំ។ តស្មា ជាតស្ស**
**ភូតស្ស កតស្ស សង្ខតស្ស និស្សរណំ បញ្ញាយតិ»**

«ម្នាលភិក្ខុទាំងឡាយ! អាយតនៈមិនកើតហើយ មិនមានហើយ មិនមានបច្ច័យអ្វីតាក់តែងហើយ មិនសាងហើយ មិនមានហើយ។ ការចេញទៅនៃរបស់ ដែលកើតដែលមាន ដែលមានបច្ច័យរចនាតាក់តែង សាងសង់ក្នុងលោកនេះ ក៏មិនប្រាកដ។ តែព្រោះហេតុដែលអាយតនៈមិនកើតហើយ មិនមានហើយ មិនមានបច្ច័យរចនាតាក់តែងហើយ មិនមានសំណង់សាងសង់ហើយនៅមាន។ ដូច្នេះ, ការចេញនៃរបស់ដែលកើតដែលមាន ដែលមានបច្ច័យតាក់តែង ដែលមានសំណង់ទើបប្រាកដ»។



www.elibraryofcambodia.org

## និព្វានជាអាយតនៈ

«អត្ថិ ភិក្ខវេ តទាយតនំ។ យត្ថ នេវ បថវី
ន អាបោ ន តេជោ ន វាយោ ន អាកាសា
នញ្ចាយតនំ ន វិញ្ញាណញ្ចាយតនំ ន អាកិញ្ច-
ញ្ញាយតនំ ន នេវ សញ្ញានាសញ្ញាយតនំ។
នាយំ លោកោ ន បរលោកោ ន ឧភោ ចន្ទិមសុរិយា។
តមហំ ភិក្ខវេ នេវ អាគតិំ
វទាមិ ន គតិំ ន ឋិតិំ ន ចុតិំ ន ឧប្បត្តិំ។ អប្បតិដ្ឋំ
អប្បវត្តំ អនារម្មណមេវតំ។ ឯសេវន្តោ ទុក្ខស្ស»។

«ភិក្ខុទាំងឡាយ អាយតនៈនោះមាន។ ក្នុងអាយតនៈនោះ មិនមានដី មិនមានទឹក មិនមានភ្លើង មិនមានខ្យល់ មិនមែនជាអាកាសានញ្ចាយតន មិនមែនជាវិញ្ញាណញ្ចាតន មិនមែនជាអាកិញ្ចញ្ញាយតន មិនមែននេវសញ្ញានាសញ្ញា-យតន។ លោកនេះក៏មិនមែន លោកដទៃក៏មិនមែន ដួងច័ន្ទដួងអាទិត្យ ទាំងពីរនេះក៏មិនមែន។ ភិក្ខុទាំងឡាយយើងមិននិយាយឡើយនូវអាយតននោះថាជាការមក ជាការទៅ ជាការស្ថិតនៅ ជាការចុតិ ជាការកើត។ អាយតននោះមិនមានទីតាំងអាស្រ័យនៅ មិនមានការប្រព្រឹត្តទៅ មិនមានអារម្មណ៍ នេះឯងគឺជាទីបំផុតនៃទុក្ខ»។

ក្នុងពុទ្ធភាសិតនេះ ព្រះពុទ្ធបរមគ្រូទ្រង់ហៅនិព្វានថា «អាយតន» ពាក្យថា «អាយតន» ប្រែថា ជាដែនកើត តែក្នុងទីនេះ មិនមែនសំដៅសេចក្ដីថា និព្វានជាដែនកើតនូវរបស់អ្វីមួយប្រភេទដូចគេធ្លាប់ចូលចិត្តថា និព្វាន គឺជាពន្លឺរបស់ចិត្តឬនិព្វានចាំងពន្លឺចេញមកជាចិត្ត ឬនិព្វានបណ្ដាលឲ្យកើតនូវរបស់ទាំងពួងដូចព្រះអាទិទេពទេ។ និព្វានដែលហៅថា «អាយតន» នោះ សំដៅសេចក្ដីថាជាធម្មាយតន គឺជាធម្មារម្មណ៍ដែលចិត្តត្រូវពឹងអាស្រ័យ ជាបង្អែក



www.elibraryofcambodia.org

ក្នុងការឈានឡើងកាន់លោកុត្តរធម៌។ ក្នុងគម្ពីរវិសុទ្ធិមគ្គលោកអធិប្បាយថា ក្នុងខណៈដែលចិត្តឈានឡើងកាន់អរិយមគ្គនោះ និព្វានមកប្រាកដក្នុងចិត្ត ដូចដួងចន្ទក្នុងថ្ងៃ១៥កើត ប្រសិនបើកិលេសនៅមិនទាន់អស់ ឬមិនទាន់ស្ងប់ល្មមទេ «និព្វាន» ក៏មិនប្រាកដច្បាស់លាស់ដល់អ្នកចំរើនមគ្គ ដូចជាដួងចន្ទ មិនប្រាកដច្បាស់លាស់ដល់ភ្នែកមនុស្ស ព្រោះត្រូវពពកបាំង។ អ្នកចំរើនមគ្គ ត្រូវពិចារណាត្រៃលក្ខណ៍តទៅទៀត រហូតដល់កិលេសដែលគ្រប់សង្កត់ចិត្តរលាយអស់ និព្វានក៏មកប្រាកដក្នុងមនោសញ្ចេតនាខាងគំនិតរបស់ខ្លួន។ ដូច្នេះ និព្វាន ទើបបានឈ្មោះថា "អាយតន" គឺជាធម្មាយាតនឬជាធម្មារម្មណ៍ ចាត់ទុកជាអាយតនខាងក្រៅ ជាគូជាមួយនឹងចិត្ត។

ដើម្បីចូលចិត្តអំពីរឿងនិព្វានឲ្យបានជ្រៅល្អិត តាមសេចក្ដីពិត យើងគួរសិក្សាពុទ្ធភាសិតមួយទៀតដូចមានតទៅនេះ។

**"និស្សិតស្ស ចលិតំ។ អនិស្សិតស្ស ចលិតំ**
**នត្ថិ។ ចលិតេ អសតិ បស្សទ្ធិ។ បស្សទ្ធិយា**
**សតិ រតិ ន ហោតិ។ រតិយា អសតិ អាគតិ**
**គតិ ន ហោតិ។ អាគតិ គតិយា អសតិ ចុតូបបាតោ**
**ន ហោតិ។ ចុតូបបាតេ អសតិ នេវិធ ន ហុរំ**
**ន ឧភយមន្តរេ។ ឯសេវន្តោ ទុក្ខស្ស"។**

សេចក្ដីញាប់ញ័រ រមែងកើតមានដល់បុគ្គលអ្នកអាស្រ័យតណ្ហា សេចក្ដីញាប់ញ័ររមែងមិនមានដល់បុគ្គលមិនអាស្រ័យតណ្ហា។ កាលណាសេចក្ដីញាប់ញ័រមិនមាន បស្សទ្ធិ គឺសេចក្ដីស្ងប់រមែងមាន។ កាលណាបស្សទ្ធិមាន រតិ គឺសេចក្ដីត្រេកអររមែងមិនមាន។ កាលណាការមកការទៅមិនមាន ការចុតិនិងការបដិសន្ធិរមែងមិនមាន។ កាលណាការចុតិនិងការបដិសន្ធិមិនមាន លោកនេះលោកដទៃក៏មិនមាន លោកក្នុងចន្លោះលោកទាំងពីក៏មិនមាន នេះឯងគឺជាទីបំផុតនៃទុក្ខ"។



www.elibraryofcambodia.org

ពុទ្ធភាសិតនេះ, មិនមែនត្រឹមតែសម្តែងឲ្យឃើញដល់បដិបទា គឺសេចក្តីប្រតិបត្តិដើម្បីនិព្វានប៉ុណ្ណោះទេ គឺសម្តែងឲ្យឃើញដល់ហេតុនៃការចុតិនិងការបដិសន្ធិថា នឹងប្រព្រឹត្តទៅឬមិនប្រព្រឹត្តទៅ ព្រោះហេតុអ្វីផង។ ជាពុទ្ធភាសិតដែលសម្តែងឲ្យឃើញដល់លំដាប់របស់ចិត្ត ដែលឈានឡើងទៅកាន់និព្វានយ៉ាងច្បាស់លាស់។ ប្រសិនបើធ្លាប់បានសិក្សាអំពីបដិច្ចសមុប្បាទធម៌មកហើយ អ្នកនឹងចូលចិត្តសេចក្តីក្នុងឃ្លាដែលពោលថា ភពជាបច្ច័យឲ្យកើតជាតិជាមិនខាន។

## និព្វានមិនមែនរបស់សូន្យទេ

តាមពុទ្ធភាសិតទាំងឡាយនេះ សម្តែងឲ្យឃើញថា និព្វាននោះជាភាពមាននៅពិតប្រាកដ មិនមែនជាភាពសូន្យទទេ ដោយមិនមានអ្វីនោះសោះឡើយ។ ចំពោះរឿងនេះព្រះអដ្ឋកថាចារ្យលោកនិយាយថា «និព្វានជារបស់មាននៅពិតប្រាកដ មិនមែនរបស់កើតឡើងដោយចិត្តនិម្មិតឡើងជាមនោគតិ គឺមិនមែនជាមនោភាពដែលកើតឡើងដោយកម្លាំងចិត្តនឹងគិតទេ។ ពុកមាត់អណ្តើក, ស្នែងទន្សាយជារបស់មិនធ្លាប់មាននៅក្នុងលោកនេះ តាំងអំពីកាលណាៗមក។ ដូច្នេះ ហៅថាពុកមាត់អណ្តើក, ស្នែងទន្សាយ ជារបស់ដែលមិនមានយ៉ាងពិតប្រាកដ។ ចំណែកនិព្វាននោះ, មិនមែនជាមិនមានដូចពុកមាត់អណ្តើក, ស្នែងទន្សាយទេ ព្រោះនិព្វានជារបស់ដែលមានពិតៗ តែជារបស់ដែលមានដោយមិនមានប្រាកដការណ៍។ ការកើតឡើង, ការតាំងនៅ, ការបែកធ្លាយជាលក្ខណៈរបស់សង្ខារទូទៅ។ តែនិព្វាន, ការកើតឡើងក៏មិនប្រាកដ ការបែកធ្លាយទៅវិញក៏មិនប្រាកដ, ប្រាកដតែភាពមាននៅយ៉ាងនោះរហូតអនន្តកាល»។



www.elibraryofcambodia.org

# និព្វានមិនមែនជាចិត្តទេ

ក្នុងចំណុចនេះ, យើងត្រូវធ្វើសេចក្តីចូលចិត្តថា ចិត្តដែលរួចចាកអាសវក្កិលេសដោយមិនមានសេសសល់ ហៅថាចិត្តបានសម្រេចដល់និព្វាន តែមិនមែនសំដៅសេចក្តីថាចិត្តដែលបរិសុទ្ធនោះជានិព្វានទេ ព្រោះចិត្តដែលស្តីមកនេះ សំដៅយកមនោសញ្ចេតនាខាងគំនិត សឹងក្នុងទីបំផុតជាតុនេះត្រូវរលត់បាត់ទៅដែរ។ ដូចនេះក្នុងគម្ពីរអភិធម្មទើបមានតាំងសំនួរថា :

**"កតមេ ធម្មា ចិត្តា ? ចក្ខុវិញ្ញាណំ សោតវិញ្ញាណំ**
**ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ**
**មនោធាតុ មនោវិញ្ញាធាតុ។ ឥមេ ធម្មា ចិត្តា"។**

"ធម៌ពួកណាខ្លះ ហៅថាចិត្ត? ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោធាតុ និងមនោវិញ្ញាណធាតុ ពួកធម៌នេះហៅថា ចិត្ត"។

**"កតមេធម្មា នោ ចិត្តា ? វេទនាខន្ធោ**
**សញ្ញាខន្ធោ សង្ខារខន្ធោ សព្វញ្ច រូបំ**
**អសង្ខតា ច ធាតុ ឥមេ ធម្មា នោ ចិត្តា"។**

"ធម៌ពួកណាខ្លះហៅថាមិនមែនចិត្ត ? វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ ធម៌ពួកនេះហៅថា មិនមែនចិត្ត"

ពាក្យថា អសង្ខតធាតុក្នុងទីនេះ ក៏គឺនិព្វាននោះឯង ក្នុងគម្ពីរធម្មសង្គណីអភិធម្មប្រាប់យ៉ាងច្បាស់ថា និព្វានមិនមែនជាចិត្តទេ។



www.elibraryofcambodia.org

## និព្វានដែលថាជារបស់សូន្យនោះ តើសូន្យនូវអ្វី ?

និព្វានជារបស់មានភាពពិតប្រាកដ. និព្វានមិនមែនជារបស់សូន្យទទេ ដូចអាកាសធាតុទេ ព្រោះថា «និព្វាន» ក៏គឺធាតុអាកាសទៅហើយ ប្រសិនបើ និព្វានសូន្យដូចអាកាសធាតុ ព្រះពុទ្ធបរមគ្រូយើង ព្រះអង្គមិនទ្រង់ត្រាស់ថា **«និព្វានំ បរមំ វទន្តិ ពុទ្ធា»** ព្រះពុទ្ធទាំងឡាយទ្រង់ពោលថា «និព្វានជាគុណធម៌ខ្ពង់ខ្ពស់បំផុតទេ»។ ការដែលព្រះអង្គទ្រង់ពោលថា **«និព្វានំ បរមំ សុញ្ញំ»** «និព្វានជារបស់សូន្យក្រៃលែងសូន្យនោះ»។ ចំណុចនេះ, មានសេចក្ដីដៅត្រឹមតែថា «និព្វាន» ជារបស់វាលទទ មិនមានរូប មិនមាននាមប៉ុណ្ណោះ មិនមែនមានន័យថា និព្វានមិនមែនជារបស់ដែលមាន ឬជារបស់ដែលគ្មានឡើយ។

## និព្វានមិនមែនជាខន្ធមួយផ្សេងទៀតទេ

ការណ៍ដែលនិយាយថា «និព្វាន» មានន័យថា ស្ងប់ប្រណីតនោះ។ សូមចូលចិត្តថា នេះត្រឹមតែជាសញ្ញាលក្ខ័ណ៍មួយរបស់ភាវៈ ដែលហៅថា «និព្វាន» ជាសញ្ញាលក្ខ័ណ៍ដែលមើលឃើញងាយ, ជាសញ្ញាលក្ខ័ណ៍ដែលជួបប្រទះភ្លាមៗ ក្នុងកាលដែលចិត្តបានចូលដល់និព្វាន ជាមួយនឹងគុណលក្ខណៈផ្សេងៗ ដែលត្រូវកើតមានព្រមគ្នាមានការញាំញីនូវសេចក្ដីស្រវឹង (មទនិម្មទនោ) ជាដើម។

ព្រោះហេតុដែលនិព្វានជាភាវៈដែលមាននៅពិតប្រាកដក្រៅអំពីចិត្តឬវិញ្ញាណ (គឺចិត្តឬវិញ្ញាណដែលយើងធ្លាប់ស្គាល់) នេះហើយដែលធ្វើឲ្យមនុស្សខ្លះចូលចិត្តខុសថា និព្វាននេះជាខន្ធមួយទៀត ក្រៅអំពីបញ្ចក្ខន្ធ។ សេចក្ដីចូលចិត្តដូចនេះខុសព្រោះផ្ទុយអំពីអភិធម្មត្ថសង្គហៈ ដែលនិពន្ធឡើងដោយព្រះ



www.elibraryofcambodia.org

អនុរុទ្ធាចារ្យក្នុងឃ្លាថា ៖

**«ភេទាភាវេន និព្វានំ ខន្ធសង្គហនិស្សដំ»** «និព្វានផុតចាកការសង្គ្រោះចូលជាខន្ធ ព្រោះមិនមានប្រភេទឬព្រោះមិនមានសេចក្ដីប្លែកផ្សេងគ្នា»។

## និព្វានជាធម្មធាតុមិនស្លាប់

«និព្វាន» បានឈ្មោះថាជាភាវៈទៀតទាត់, មិនចេះប្រែប្រួល, មិនចេះចាស់ស្លាប់, ដូចមានពុទ្ធភាសិតសំដែងបញ្ជាក់តទៅនេះ ៖

**«អសង្ខតញ្ច វោ ភិក្ខវេ ទេសេស្សាមិ សច្ចញ្ច**
**បារញ្ច សុទុទ្ទសញ្ច អជ្ជរញ្ច ធុវញ្ច និប្បបញ្ច**
**អមតញ្ច សិវញ្ច ខេមញ្ច អភូតញ្ច អនីតិកញ្ច**
**អព្យាបជ្ឈញ្ច វិសុទ្ធិញ្ច ទីបញ្ច តាណញ្ច**
**លេណញ្ច វោ ភិក្ខវេ ទេសេស្សាមិ»។**

«ម្នាលភិក្ខុទាំងឡាយ យើងនឹងសំដែងនូវអសង្ខតធម៌ដ៏ជាសច្ចធម៌ជាត្រើយខាងណោះ ជារបស់ដែលបុគ្គលមើលឃើញដោយក្រ ជារបស់ដែលមិនចេះចាស់ ជាធម៌ទៀងទាត់ ជាធម៌មិនមានកិលេសជាគ្រឿងធ្វើឲ្យយឺតយូរ ជាធម៌ដែលមិនចេះស្លាប់ ជាសិវៈ ជាធម៌ក្សេម ជាធម៌អស្ចារ្យ ជាធម៌មិនមានចង្រៃ ជាធម៌មិនមានទុក្ខ ជាធម៌បរិសុទ្ធ ជាកោះ ជាកំពែងការពារ ជាលេណដ្ឋាន»

ពុទ្ធភាសិតនេះមានពាក្យពីរម៉ាត់ ដែលត្រូវអធិប្បាយគឺ : «និប្បបញ្ច» ប្រែថា មិនមានកិលេសជាគ្រឿងធ្វើឲ្យយឺតយូរ ក្នុងទីនេះសំដៅសេចក្ដីថា មិនមានតណ្ហា, មានះ និងទិដ្ឋិ។ កិលេសទាំង៣នេះប្រសិនបើមាននៅក្នុងសន្ដាននៃបុគ្គលណា នឹងធ្វើឲ្យបុគ្គលនោះយឺតយូរក្របានសម្រេចនិព្វាន។

«សិវ.» ពាក្យនេះប្រែបានច្រើនយ៉ាង។ ប្រែថា «ព្រះសិវៈ» សំដៅយក



www.elibraryofcambodia.org

ព្រះឥសូរក្នុងសាសនាព្រាហ្មណ៍ ប្រែថា សុភនិមិត្ត , សុភមង្គល សេរីសួស្តី ក៏បាន។ តែក្នុងទីនេះ ព្រះអដ្ឋកថាចារ្យទាំងឡាយ ដែលលោកអធិប្បាយអំពីរឿងនិព្វាន មានឈ្មោះថា សិវៈនោះ លោកសំដៅសេចក្តីថា ជារបស់មានសេរីមង្គល។

## និព្វានគឺជាព្រះសិវៈមែនឬទេ ?

ពុទ្ធសាសនាបានលើកយកពាក្យថា "សិវៈ" ដែលជាឈ្មោះរបស់ព្រះអាទិទេពក្នុងសាសនាព្រាហ្មណ៍ មកធ្វើជាឈ្មោះរបស់និព្វាន។ ដូច្នេះ, គួរសិក្សាន័យរបស់ពាក្យថា ព្រះសិវៈ តាមទស្សនវិជ្ជារបស់ព្រាហ្មណ៍ ដើម្បីចូលចិត្តរឿងនិព្វានឲ្យកាន់តែជ្រៅជ្រះឡើងទៀត។

ក្នុងសៀវភៅទស្សនវិជ្ជាយោគៈខ្លះ គេបានអធិប្បាយលក្ខណៈព្រះសិវៈថា :

ព្រះសិវៈ គឺជាបុរសវិសេស ព្រោះអង្គមិនមានជាប់ជំពាក់ដោយកិលេស , កម្ម , វិបាក និងតណ្ហា។ នៅក្នុងអង្គនៃព្រះសិវៈនោះ មានពូជនៃសព្វញ្ញុស្ថិតនៅអស់កាលជានិច្ច។

ក្នុងសៀវភៅខ្លះ ដែលសរសេរដោយអ្នកប្រាជ្ញខាងបស្ចិមប្រទេសគេបាននិយាយថា :

យោគៈ ក្នុងលទ្ធិព្រាហ្មណ៍កើតមានមុនពុទ្ធសម័យ គ្រូដំបូងរបស់ព្រះពុទ្ធបរមគ្រូ គឺអាឡារតាបសនិងឧទកតាបស ជាយោគីមានការប្រព្រឹត្តខាងយោគៈ តែព្រះអង្គឃើញថាវិធីនេះមិនមែនជាផ្លូវនាំទៅកាន់សេចក្តីផុតទុក្ខពិតប្រាកដ ទើបលះបង់ចោលទៅ។ យោគៈអំពីដើមមក គេមិនបានរៀបចំជារបៀបទេ គេទើបតែនឹងរៀបចំក្នុងសម័យខាងក្រោយមក។

ក្នុងសៀវភៅដដែលនេះបានបញ្ជាក់ថា "យោគៈ ក្នុងសម័យក្រោយបានត្រូវធ្លាក់ចុះនៅក្រោមឥទ្ធិពលរបស់ពុទ្ធសាសនា"។ អ្នកនិពន្ធបានអធិប្បាយ



www.elibraryofcambodia.org

ពាក្យថា **យោគៈ** និង "**អត្តា**" ថាៈ "យោគ" បើប្រើជាព្រាហ្មណ៍ មានសេចក្តីដៅដល់ការរួមចូល ( UNION ) ជាមួយព្រះព្រហ្ម តែបើប្រើជាពុទ្ធសាសនា សំដៅសេចក្តីថា ការចូលទៅដល់និព្វាន។

ពាក្យថា "**អត្តា**" ខាងព្រាហ្មណ៍ សំដៅយកវិញ្ញាណដែលមិនចេះស្លាប់ ( IMPORTAL SOUL ) ខាងពុទ្ធសាសនាសំដៅយកបុគ្គលិកភាពឬបុគ្គលិកជីព ( PERSONALITY OR IMDISEDUALITY ) តែព្រោះហេតុថារបស់នេះមិនមានភាពជាស្ថាពរ ( IMPERMANANT ) ទើបមិនប្រកាន់យកថាជារបស់មិនស្លាប់ ( IMPORTAL )។

សៀវភៅដែលកើតមានឡើងក្នុងសម័យពុទ្ធទស្សនវិជ្ជានិងព្រាហ្មណទស្សនវិជ្ជា កំពុងមានអានុភាពស្មើគ្នាក្តី ដែលកើតក្នុងសម័យដែលសាសនាព្រាហ្មណ៍ធ្លាក់នៅក្រោមឥទ្ធិពលរបស់ពុទ្ធសាសនាក្តី សុទ្ធតែបាននិយាយអំពីនិព្វាននិង **យោគៈ** ដោយសេចក្តីយ៉ាងពិស្តារ។ តែយ៉ាងណាក៏ដោយ លក្ខណៈរបស់ព្រះសិវៈស្រដៀងនឹងនិព្វាន របស់ព្រះពុទ្ធសាសនាជាទីបំផុត ផ្សេងគ្នាតែទស្សនវិជ្ជារបស់ព្រាហ្មណ៍ អធិប្បាយអំពីរឿងនិព្វានជ្រុលទៅខាងបុគ្គលាធិដ្ឋានៈ ប្រកាន់មាំថា ការចូលទៅដល់ទីបំផុតសាសនារបស់គេក៏គឺការធ្វើឲ្យជាក់ច្បាស់នូវព្រះសិវៈ ប្រសិនបើបានធ្វើឲ្យជាក់ច្បាស់នូវព្រះសិវៈ ឬបានចូលទៅដល់ព្រះសិវៈនោះហើយ គេក៏ក្លាយទៅជាបុគ្គលពិសេសដូចព្រះសិវៈ។ ចំណែកពុទ្ធសាសនា អធិប្បាយអំពីរឿងនិព្វានជ្រុលទៅខាងធម្មាធិដ្ឋានៈ។ ដូច្នេះសាសនាទាំងពីរទើបមានជំនឿក្នុងរឿងនិព្វានមិនត្រូវគ្នាក្នុងចំណុចខ្លះ។

ទស្សនវិជ្ជាខាងព្រាហ្មណ៍ អធិប្បាយថា "ព្រះសិវៈឬអាត្ម័ននោះជារបស់ដែលទ្រទ្រង់ទុកនូវសាកលចក្រវាល ជារបស់ដែលជ្រួតជ្រាបចូលទៅក្នុងរបស់គ្រប់យ៉ាង បុគ្គលណាឃើញច្បាស់នូវភាវៈទាំងអស់នេះ បុគ្គលនោះនឹងអស់កិលេស, អស់កម្ម, អស់សេចក្តីស្លាប់កើតតទៅទៀត" យោបល់នេះ ស្រដៀងនឹងយោបល់ពុទ្ធសាសនាជាទីបំផុត។

តែខាងពុទ្ធសាសនា, មានជំនឿថា "ចិត្តដែលបានសម្រេចដល់និព្វាន



www.elibraryofcambodia.org

ចិត្តនោះរមែងរលត់ក្នុងកាលដែលមនុស្សយើងអស់ជីវិត ចិត្តដែលរលត់ទៅនោះ ក៏រលត់ទៅរហូត តែភាវៈដែលហៅថានិព្វាននៅមានជាដរាប» ពុទ្ធសាសនា មានបញ្ជាក់ថា «និព្វានមិនមែនជាចិត្តទេ»។

បើពិចារណារឿងនិព្វាន, ដូចបាននិយាយមកនេះ និព្វានខាងពុទ្ធសាសនា ហាក់ដូចជាមិនមានប្រយោជន៍អ្វីដល់យើងសោះព្រោះរបស់ទាំងឡាយរលត់ អស់រលីង សូម្បីតែចិត្តស្អាតល្អក៏រលត់ទៅដែរ។ ការបានសម្រេចនិព្វានតាម សាសនាព្រាហ្មណ៍គួរឲ្យយើងចង់បាន ព្រោះមានរលត់ខ្លះ មានសល់នៅខ្លះ ដូចបាននិយាយមកហើយ។ តែទោះជាយ៉ាងណាក្តី សូមកុំភ្លេចថា: បំណងពុទ្ធ សាសនាចង់ឲ្យមនុស្សរួចចាកសេចក្តីទុក្ខដោយដាច់ខាត។ ពុទ្ធសាសនាបាន រៀបចំអង្គការរំដោះទុក្ខយ៉ាងសម្បូណ៌ មិនមានលទ្ធិសាសនា ណាអាចធ្វើឲ្យ ស្មើបាន។ពុទ្ធសាសនាបង្រៀនឲ្យយើងគិតចំពោះតែរបស់ពិតដែលមើលឃើញ យ៉ាងជាក់ច្បាស់តាមផ្លូវចិត្តប៉ុណ្ណោះ។ ពុទ្ធសាសនាហាមដាច់ខាតមិនឲ្យប្រើ ជំនឿដោយមិនមានហេតុផល របស់ណាដែលមើលមិនឃើញច្បាស់ ដែល ពិសោធមិនបាន ឲ្យលើកទុកមួយអន្លើសិន។ ពុទ្ធសាសនានិយាយតែអំពីរបស់ ដែលគួរជឿបាន ដែលអាចធ្វើការពិសោធន៍ទៅកើត។ ចំណែកទស្សនវិជ្ជាខាង ព្រាហ្មណ៍ មានលក្ខណៈច្របូកច្របល់ច្រើនព្រោះគេនិយាយ ដោយបានឃើញ ជាក់ច្បាស់ផងដោយដៅស្មានផង។

ព្រះពុទ្ធបរមគ្រូទ្រង់បញ្ជាក់ថា ចិត្តដែលបានសម្រេចនិព្វានដោយបរិបូណ៌ ហើយ នឹងបានសម្រេចនូវញាណជាសព្វញ្ញូ តែញាណជាសព្វញ្ញូនោះមានកំណត់ ព្រំដែនដែរ គឺចំពោះតែសេចក្តីដឹងគ្រប់យ៉ាង ដែលមានទាក់ទងជាមួយនឹងការ កើត, ការរលត់របស់ជីវិត និងការរួចផុតចាកសេចក្តីទុក្ខ។ របស់ទាំងអស់នេះ ព្រះអរហន្តទាំងឡាយមានដូចគ្នា ចំណែកញាណពិសេស (សេចក្តីដឹងពិសេស) ដទៃក្រៅអំពីនេះ ព្រះអរហន្តលោកមានមិនដូចគ្នាទេ។



www.elibraryofcambodia.org

## ព្រះអរហន្តអនិច្ចកម្មហើយសូន្យឬ ?

កាលបើមានសំនួរដូចនេះកើតឡើង ព្រះសម្មាសម្ពុទ្ធទ្រង់ឆ្លើយថា ៖

**“អច្ចិ យថា វាតវេគេន ខិត្តំ អត្ថំ បលេតិ**

**ន ឧបេតិ សង្ខំ ។ ឯវំ មុនី នាមកាយា**

**វិមុត្តោ អត្ថំ! បលេតិ ន ឧបេតិ សង្ខំ”។**

“អណ្តាតភ្លើងដែលត្រូវខ្យល់បក់រលត់ទៅហើយ រមែងមិនប្រាកដថាភ្លើងនោះទៅនៅនាទីណា យ៉ាងណាមិញ។ មុនីដែលផុតចាកនាមកាយ (រលត់ទៅហើយ) ក៏រមែងមិនប្រាកដថា ទៅកើតនាទីណា យ៉ាងនោះដែរ”។

ការរួចចាកទុក្ខ តាមបែបនៃពុទ្ធសាសនា គឺការពិចារណាសង្ខារទាំងឡាយឲ្យឃើញថាមិនទៀង, ជាទុក្ខ, ពិចារណាធម៌ទាំងឡាយ ឲ្យឃើញថាជាអនត្តា ឬពិចារណាតាមល័ខគោលនៃបដិច្ចសមុប្បាទ។ ការពិចារណាដូចនេះ, ជាការណ៍ពិចារណាតាមសេចក្តីពិតដែលគេអាចពិសោធបាន, បុគ្គលអ្នកពិចារណានឹងអស់សេចក្តីសង្ស័យក្នុងបញ្ហាជីវិត។ ក្នុងទីបំផុត, ចិត្តក៏បានទទួលសេចក្តីស្ងប់ វិធីនេះហើយដែលធ្វើឲ្យរួចចាកទុក្ខយ៉ាងពិតប្រាកដ។

ចំណែកវិធីរបស់ព្រាហ្មណ៍ គេបង្រៀនឲ្យពិចារណាព្រះសិវៈ ឬឲ្យយកព្រះសិវៈធ្វើជាអារម្មណ៍នៃការពិចារណា, ឲ្យនឹកសង្ឃឹមក្នុងចិត្តថា កាលណាខ្លួនបានចូលទៅដល់ព្រះសិវៈឬធ្វើឲ្យជាក់ច្បាស់នូវព្រះសិវៈ ហើយខ្លួនក៏នឹងបានជាបុគ្គលវិសេស ដូចព្រះសិវៈ។ វិធីនេះនាំឲ្យកើតសេចក្តីពេញចិត្តក្នុងខ្លួនឯង, នាំឲ្យកើតតណ្ហា, ឧបាទាន និងអវិជ្ជាយ៉ាងប្រណីតឡើងទៀត, ក្នុងទីបំផុតក៏ពុំបានរួចចេញចាកទុក្ខដោយដាច់ខាតឡើយ។

សូមឲ្យអ្នកសិក្សា, ចងចាំនូវសញ្ញាលក្ខណ៍របស់ព្រះពុទ្ធសាសនា ដែលស្តីអំពីសេចក្តីប្រព្រឹត្តធម៌ឲ្យច្រើនហើយ ត្រូវយកចិត្តទុកដាក់ចំពោះការប្រតិបត្តិឲ្យច្រើនជាងទ្រឹស្តី។ កុំគប្បីដៅស្មានទៅលើរបស់ដែលខ្លួនចូលចិត្តមិនដល់



www.elibraryofcambodia.org

យល់មិនបាន ដូចគិតថា ព្រះអរហន្តអស់ជីវិតហើយ សូន្យឬកើតទៀត។ បញ្ហានេះមិនគួរនាំមកគិតឲ្យធ្ងន់ខួរក្បាល, នាំឲ្យខាតពេលទេ, គុណធម៌ដែលខ្លួនបានប្រតិបត្តិ នឹងប្រាប់ឲ្យដឹងក្នុងអនាគតជាមិនខាន។ ដើម្បីបំពេញបំណងអ្នកសិក្សាខ្លះ ដែលចង់ដឹងគតិរបស់ព្រះអរហន្តខាងក្រោយ ដែលលោកអស់ជីវិត ខ្ញុំសូមនាំយកសំនួរនិងចម្លើយរបស់ព្រះសារីបុត្រនិងព្រះយមកៈ មកសរសេរក្នុងទីនេះដូចមានតទៅ ៖

រឿងមានមកថា : ព្រះយមកៈមានសេចក្តីឃើញខុសថា ព្រះអរហន្តទាំងឡាយអស់ជីវិតហើយសូន្យបាត់ទៅ ភិក្ខុទាំងឡាយព្យាយាមធ្វើអន្តរាគមន៍ឲ្យលោកផ្លាស់សេចក្តីឃើញខុសនេះ តែមិនបានសម្រេច ទើបនាំខ្លួនលោកទៅរកព្រះសារីបុត្រ ដើម្បីឲ្យព្រះសារីបុត្រជួយកែកំហុសនោះ។ ព្រះសារីបុត្រលោកទទួលកែដោយតាំងសំនួរដូចមានតទៅនេះ ៖

ស. យមកៈ! សេចក្តីនេះលោកចូលចិត្តយ៉ាងណា លោកឃើញថារូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ជារបស់ព្រះខីណាស្រពឬ?

យ. មិនមែនយ៉ាងនោះទេ អាវុសោ!។

ស. ឃើញថា ព្រះខីណាស្រពមាននៅក្នុងរូប ក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណឬ?

យ. មិនមែនយ៉ាងនោះទេ អាវុសោ !។

ស. លោកឃើញថា ព្រះខីណាស្រពជាយ៉ាងដទៃក្រៅអំពីរូប វេទនា សញ្ញា សង្ខារ វិញ្ញាណឬ?

យ. មិនមែនយ៉ាងនោះទេ អាវុសោ!។

ស. លោកចូលចិត្តថា ព្រះខីណាស្រពមិនមានរូប មិនមានវេទនា មិនមានសញ្ញា មិនមានសង្ខារ មិនមានវិញ្ញាណយ៉ាងនោះឬ?

យ. មិនមែនយ៉ាងនោះទេ អាវុសោ! ។

ម្នាលយមកៈ! លោករកព្រះខីណាស្រពក្នុងខន្ធ៥ មិនឃើញតាមសេចក្តី



www.elibraryofcambodia.org

ពិតប្រាកដ សូម្បីក្នុងបច្ចុប្បន្នមិនឃើញទៅហើយ គួរដែរឬដែលលោកនិយាយថាខ្លួនលោកដឹងទៅដល់ធម៌ ដែលព្រះមានព្រះភាគទ្រង់សំដែងថា ដោយសេចក្តីពិត ភិក្ខុជាព្រះខីណាស្រព កាលណាកាយបែកធ្លាយ (អស់ជីវិតទៅ) រមែងដល់នូវសេចក្តីរលត់សូន្យ។

បពិត្រសារីបុត្រ! កាលអំពីមុនខ្ញុំមិនដឹងច្បាស់ ទើបមានសេចក្តីយល់ឃើញដ៏លាមកកើតឡើង។ តែឥឡូវនេះខ្ញុំបានស្តាប់ធម្មទេសនារបស់លោកហើយ ខ្ញុំលះបង់នូវទិដ្ឋិដ៏លាមកនោះបានហើយ។

ម្នាលយមកៈ! ប្រសិនបើមានគេសួរលោកថា ជាភិក្ខុព្រះអរហន្តខីណាស្រព កាលណាអស់ជីវិតទៅហើយ នឹងទៅជាយ៉ាងណា?

កាលណាត្រូវគេសួរយ៉ាងនេះ ខ្ញុំត្រូវឆ្លើយថា រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ជារបស់មិនទៀង របស់ណាដែលមិនទៀង របស់នោះរមែងជាទុក្ខ របស់ណាជាទុក្ខ របស់នោះរមែងសាបសូន្យទៅ។

សាធុ សាធុ យមកៈ! ខ្ញុំនឹងឧបមាឲ្យលោកស្តាប់ ដើម្បីលោកបានចូលចិត្តរឿងនេះ កាន់តែជ្រាលជ្រៅក្រៃលែងឡើងទៀត។

ម្នាលយមកៈ! ប្រៀបដូចសេដ្ឋីមានទ្រព្យសម្បត្តិច្រើន មានការថែរក្សាការពារយ៉ាងមាំមួន។ បុរសដែលមានបំណងចង់សម្លាប់សេដ្ឋីនោះមិនអាចប្រព្រឹត្តនូវអំពើឃាតកម្មបានឡើយ។ តែបុរសនោះក៏ពុំព្រមលះបង់នូវបំណងអាក្រក់របស់ខ្លួន គេចេះតែព្យាយាមរកមធ្យោបាយដើម្បីសម្លាប់សេដ្ឋីនោះឲ្យបាន។ ថ្ងៃមួយបុរសនោះចូលទៅរកសេដ្ឋី ហើយនិយាយថា ខ្ញុំសូមនៅបំរើលោកអស់មួយជីវិត។ សេដ្ឋីក៏ព្រមទទួលឲ្យនៅបំរើតាមពាក្យដែលបុរសនោះសុំ។ ឃាតករ, ក្រោយអំពីបានទទួលនៅបំរើសេដ្ឋីដូចបំណងហើយ គេក៏ព្យាយាមធ្វើការបំរើផ្គាប់ផ្គុនយ៉ាងប៉ិនប្រសប់។ លុះបានទទួលនូវសេចក្តីទំនុកចិត្ត និងសេចក្តីស្និទ្ធស្នាលជិតដិតអំពីសេដ្ឋីហើយ បុរសក៏សម្លាប់សេដ្ឋីនៅក្នុងបន្ទប់ស្និទ្ធស្នាលនោះទៅ។



www.elibraryofcambodia.org

ម្នាលយមកៈ! អស់ពេលយ៉ាងយូរ ដែលបុរសនេះចូលនៅបំរើ សេដ្ឋីមិនបានដឹងថា បុរសនោះត្រូវការសម្លាប់ខ្លួនឡើយ សូម្បីមានដំណើរទៅក្នុងទីស្ងាត់កំបាំងតែពីរនាក់ ក៏មិនមានការប្រុងប្រយ័ត្នឡើយយ៉ាងនេះមែនទេ លោកយមកៈ!។

ត្រូវហើយ អាវុសោ ! យ៉ាងនេះមែន។

រឿងនេះយ៉ាងណា បុគ្គលបុថុជ្ជនមិនបានស្តាប់ មិនបានឃើញធម៌ព្រះអរិយ មិនមានសេចក្តីឆ្លៀវឆ្លាតក្នុងធម៌របស់ព្រះអរិយ មិនឃើញធម៌របស់សប្បុរស មិនមានសេចក្តីឆ្លៀវឆ្លាតក្នុងធម៌របស់សប្បុរស មិនបានហ្វឹកហាត់អប់រំចិត្តដោយធម៌របស់សប្បុរស រមែងពិចារណាឃើញថា រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ជារបស់ខ្លួនខ្លះ។ ឃើញថាខ្លួនមានរូប មានវេទនា មានសញ្ញា មានសង្ខារ មានវិញ្ញាណខ្លះ។

ឃើញថា រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណមាននៅក្នុងខ្លួនខ្លះ។ ឃើញថាខ្លួនមាននៅក្នុងរូប ក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណខ្លះ។ ក៏រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណនោះ ជារបស់មិនទៀត ជាទុក្ខ ជាអនត្តា ជារបស់មានបច្ច័យរចនាតាក់តែង។ សេដ្ឋីត្រូវឃាតករសម្លាប់ក៏ព្រោះមិនដឹងយ៉ាងនោះដែរ។

ចូរសង្កេតថាបញ្ចក្ខន្ធរបស់យើងប្រៀបដូចបុរសអ្នកទទួលបំរើ ដែលចេះតែស្វែងរកឱកាសសម្លាប់យើង ក្នុងទីបំផុតគឺសម្លាប់យើងបានមែន ព្រោះយើងមិនដឹងខ្លួន តែបញ្ចក្ខន្ធសម្លាប់យើងបាន ចំពោះតែកាលណាយើងប្រកាន់មាំក្នុងបញ្ចក្ខន្ធ។ កាលណាយើងលះបង់ការប្រកាន់ក្នុងបញ្ចក្ខន្ធបានហើយ បញ្ចក្ខន្ធក៏សម្លាប់យើងពុំបានឡើយ។



www.elibraryofcambodia.org

# សភាពនៃវិញ្ញាណ
# ក្រោយអំពីបរិនិព្វានហើយ
# ជាយ៉ាងណាទៅ ?

ចិត្តឬវិញ្ញាណ ដោយសភាពមិនមែនជារូបធម៌មិនមែនជារបស់ឬជាផល កើតមកអំពីបច្ច័យ ខាងវត្ថុដោយចំពោះ ព្រោះពុទ្ធសាសនាស្តែងថា វិញ្ញាណ មាន ដោយមិនត្រូវអាស្រ័យរូបធម៌ក៏បាន ដូចជាវិញ្ញាណរបស់អរូប ព្រហ្មក្នុង អរូបភព។ វិញ្ញាណនេះតាំងនៅយូរណាស់យូរក្រៃលែងយូរជាងអាយុពិភព លោកយើងនេះទៅទៀត។ ការតាំងនៅយូរនៃវិញ្ញាណក្នុងអរូបភព នាំឲ្យមនុស្ស យើងគិតថា វិញ្ញាណជារបស់ស្ថិតស្ថេរចិរកាល។

កាលណាគិតតាមន័យនេះ នាំឲ្យយើងចូលចិត្តថាចិត្តបានសម្រេចដល់ និព្វាននោះមានន័យថា មនោសញ្ចេតនាខាងគិតនឹកទាំងឡាយ ដែលប្រកប ទៅដោយអវិជ្ជាទិក្កិលេសនោះ រលត់សូន្យអស់មិនមានសេសសល់ឡើយ តែ វិញ្ញាណដ៏បរិសុទ្ធនោះនៅមានមិនបាត់ទៅណាឡើយ។

សេចក្តីអធិប្បាយនេះ ស្តាប់ចូលចិត្តងាយ តែកុំភ្លេចថា សេចក្តីអធិប្បាយ បែបនេះ មានសេចក្តីស្របជាមួយនឹងទស្សនវិជ្ជារបស់ព្រាហ្មណ៍ ដែលបាន និយាយមកហើយ។ អ្នកសិក្សាពុទ្ធទស្សនវិជ្ជា ច្រើនចូលចិត្តបែបនេះ ពុទ្ធ សាសនិកខាងនិកាយមហាយានខ្លះ ក៏ចូលចិត្តបែបគ្នានេះដែរ។ តែខាងថេរវាទ បាននិយាយថា ចិត្តរបស់ព្រះអរហន្ត ក្នុងទីបំផុតក៏រលត់អស់មិនមានសេស សល់ឡើយ។ មិនមានពុទ្ធភាសិតក្នុងទីណាបានបញ្ជាក់ថាចិត្តដ៏បរិសុទ្ធព្រះអរហន្ត ដែលបរិនិព្វានទៅហើយនោះសល់ឡើយ។

បើមានបញ្ហាចោទឡើងដល់ចិត្ត ដែលបរិនិព្វានទៅហើយថា មាន លក្ខណៈយ៉ាងណា កើតទៀតឬសូន្យ ព្រះពុទ្ធបរមគ្រូទ្រង់តបដូចបាននិយាយ មកហើយ ព្រោះអ្វី ? ព្រោះសភាពវិញ្ញាណដែលមានប្រាកដជាក់ច្បាស់ ឲ្យ



www.elibraryofcambodia.org

យើងរៀនដឹងបាននោះ សុទ្ធតែជារបស់កើតឡើងចាកបច្ច័យផ្សេងៗ ដូចជាត្រូវអាស្រ័យសឡាយតនៈជាដើម សឡាយតនជាបច្ច័យឲ្យកើតវិញ្ញាណបាន ចំពោះតែក្នុងកាលមានជីវិតនៅ។ បើវិញ្ញាណរលត់ទៅហើយក៏មិនមានរបស់អ្វីយកមកឲ្យឈ្មោះខាងក្រោយបរិនិព្វានបានឡើយ។

ក្នុងបណ្ដាពុទ្ធភាសិតទាំងឡាយ ដែលនិយាយអំពីរឿងនិព្វាន មានភាសិតមួយកន្លែងដែលព្រះសម្មទ្ធយកវិញ្ញាណមកជាឈ្មោះរបស់និព្វាន គឺពុទ្ធភាសិតក្នុងកេវដ្ដសូត្រមានដូចនេះ។

**«វិញ្ញាណំ អនិទស្សនំ អនន្តំ សព្វតោបភំ ឯត្ថ**<br>
**អាបោ ច បឋវី ច តេជោ វាយោ ន គាធតិ**<br>
**ឯត្ថ ទីឃញ្ច រស្សញ្ច អណុំ ថូលំ សុភាសុភំ**<br>
**ឯត្ថ នាមញ្ច រូបញ្ច អសេសំ ឧបរុជ្ឈតិ**<br>
**វិញ្ញាណស្ស និរោធេន ឯត្ថេតំ ឧបរុជ្ឈតិ»។**

វិញ្ញាណ សឹងមើលមិនឃើញដោយភ្នែក ប្រៀបធៀបទៅនឹងអ្វីមួយៗ មិនកើត មានរស្មីត្រចះត្រចង់មិនមានទីបំផុត មានផ្លូវសម្រាប់ចូលទៅដល់បានដោយកម្មដ្ឋានគ្រប់យ៉ាង។ នាវិញ្ញាណនេះមិនមានទឹក មិនមានដី មិនមានភ្លើង មិនមានខ្យល់។ នាវិញ្ញាណនេះមិនមានវែង មិនមានខ្លី មិនមានតូច មិនមានធំ មិនមានល្អ មិនល្អ។ នាវិញ្ញាណនេះ នាមរូបរលត់អស់មិនមានសេសសល់ ព្រោះក្នុងទីនេះ វិញ្ញាណរលត់អស់មិនមានសេសសល់ (វិញ្ញាណដែលធ្លាប់មានអវិជ្ជាមកអំពីមុន គឺវិញ្ញាណទាំង៦ មានចក្ខុវិញ្ញាណជាដើម) នាមរូបទាំងអស់ទើបត្រូវរលត់សូន្យអស់មិនមានសេសសល់»។ ពាក្យថា «វិញ្ញាណ» ប្រែថា«ដឹងច្បាស់» ពាក្យនេះជាឈ្មោះរបស់ «និព្វាន» និព្វានឈ្មោះថា «អនិទស្សនំ» ព្រោះភាពមិនមាននៃនិទស្សនៈ។



www.elibraryofcambodia.org

ពាក្យថា «**និទស្សនៈ**» ប្រែបានពីរយ៉ាង គឺប្រែថារបស់ដែលគេគប្បីឃើញ ដោយភ្នែក ដូចពាក្យក្នុងអភិធម្មថា **សនិទស្សនសប្បដិឃាធម្មា** ប្រែថារបស់ដែលគេឃើញបានដោយភ្នែក។ ន័យមួយទៀត និទស្សនំ ប្រែថាឧទាហរណ៍ ឬសំដែងចេញ។ ចំពោះក្នុងទីនេះ អនិទស្សន ប្រព្រឹត្តទៅបានទាំងពីរន័យ គឺនិព្វាន មើលមិនឃើញដោយភ្នែកផង រកឧទាហរណ៍មកប្រៀបធៀបពុំបានផង។

ពាក្យថា «**អនន្តំ**» ដែលអត្ថកថាចារ្យអធិប្បាយថា និព្វានមិនមានទីបំផុតនោះ សំដៅសេចក្តីថា ទីបំផុតនៃការកើតឡើងរបស់និព្វានមិនមាន ឬទីបំផុតនៃសេចក្តីអស់ទៅមិនមាន ឬទីបំផុតនៃការតាំងនៅហើយប្រែប្រួលទៅជាយ៉ាងណាដទៃក៏មិនមាន។ ក្នុងទីនេះលោកសំដៅសេចក្តីថា និព្វាន មិនមានការផ្តើមរើបមិនមានទីបំផុត មិនមានបច្ច័យរចនាតាក់តែង មិនមានការផ្លាស់ប្តូរទៅតាមកាលវេលា ព្រោះជារបស់កើតឯងមានឯង, ធ្លាប់កើតធ្លាប់មានយ៉ាងណាក៏គង់នៅយ៉ាងនោះ រហូតអនន្តកាល។

ពាក្យថា «**សព្វតោ បភំ**» ។ ពាក្យថា «បភំ» លោកថាមកអំពី «**បបំ**» តាមវិធីវេយ្យាករណ៍ផ្លាស់ «ប» ជា «ភ»។ ពាក្យថា «បបំ» ឬ «បភំ» ប្រែថា «កំពង់» ដូច្នេះ ពាក្យថា «សព្វតោ បភំ» ទើបត្រូវប្រែថា និព្វានមានកំពង់ចុះទៅបានដោយជុំវិញ។ ពាក្យថា «កំពង់» ក្នុងទីនេះសំដៅយកកម្មដ្ឋាននានានោះឯង។

ពាក្យ «**បភំ**» ព្រះធម្មបាល ព្រះថេរដែលបានផ្តើមបង្កើតសមាគមមហាពោធិក្នុងឥណ្ឌា លោកប្រែសព្ទ «បភំ» ថារស្មី។ សព្វតោបភំ ប្រែថាមានរស្មីត្រចះត្រចង់មិនមានទីបំផុត។ «បភំ» ក្នុងទីទូទៅ ច្រើនប្រែថា ពន្លឺឬរស្មី។ ដូច្នេះក្នុងទីនេះ យើងប្រែនិព្វានស័ព្ទថាមានរស្មីដោយជុំវិញ ឬមានរស្មីទូទៅក៏បាន ព្រោះសម្មាសម្ពុទ្ធរបស់យើងក៏បានទ្រង់ត្រាស់ថា ៖



www.elibraryofcambodia.org

“យត្ថ អាបោ ច បឋវី ច តេជោ វាយោ
ន គាធតិ ន តត្ថ សុក្កា ជោតន្តិ អាទិច្ចោ
នប្បកាសតិ ន តត្ថ ចន្ទិមា ភាតិ តមោ
តត្ថ ន វិជ្ជតិ យទា ច អត្តនាវេទិ មុនី
មោនេន ព្រាហ្មណោ អថ រូបា អរូបា
ច សុខទុក្ខា បមុច្ចតិ”។

“ក្នុងទីណាមិនមានទឹក ដី ភ្លើង ខ្យល់តាំងនៅ។ មិនមានតារាបញ្ចាំងពន្លឺ មិនមានដួងអាទិត្យផ្សាយរស្មី មិនមានដួងចន្ទឆ្លុះសែង (តែមោះជាដូច្នោះ) ក្នុងទីនោះ ក៏មិនមានភាពងងឹត។ ក្នុងកាលណាព្រាហ្មណ៍ជាមុនីព្រោះញាណបានស្គាល់ច្បាស់ទីនោះដោយខ្លួនឯង ក្នុងកាលណោះគេរមែងរួចផុតចាករូបនិងអរូប រួចផុតចាកសុខនិងទុក្ខ”។

ពាក្យថា “**វិញ្ញាណ**” ក្នុងគាថាថា វិញ្ញាណំ អនិទស្សនំ។ល។ នោះ បើប្រែឲ្យមានសម្លេងតាមរូបដើមថា វិញ្ញាណក៏បាន ព្រោះលោកបានកំណត់ថា ជាវិញ្ញាណដែលមិនអាចអ្វីប្រៀបបាន សមនឹងពាក្យដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ព្រះខីណាស្រពដែលបរិនិព្វានទៅហើយនោះជាសភាពជ្រាលជ្រៅណាស់ មិនងាយគិតឲ្យយល់បានទេ តែព្រះអង្គពុំបានបដិសេធថានិព្វានជារបស់ទទេ មិនមានអ្វីឡើយ។ សេចក្ដីពិតបើយើងនិយាយដល់លក្ខណៈនិព្វាន ឲ្យបានយ៉ាងជិតដិតជាមួយនឹងរបស់ផ្សេងៗ ដែលយើងបានស្គាល់មកហើយ ក៏ឃើញថា មិនមានអ្វីក្រៅអំពីវិញ្ញាណទេ តែព្រះពុទ្ធបរមគ្រូទ្រង់ខ្លាចក្រែងថា មនុស្សទាំងឡាយនឹងចូលចិត្តខុសអំពីរឿងនិព្វាន (សំដៅយកអនុបាទិសេសនិព្វានធាតុ) ថា “និព្វាន” គឺវិញ្ញាណដ៏បរិសុទ្ធរបស់ព្រះអរហន្ត ដែលកំពុងមានជីវិតនៅ។ ដូច្នេះទើបព្រះអង្គទ្រង់បានបញ្ជាក់យ៉ាងច្បាស់ថា វិញ្ញាណដែលហៅថា “និព្វាន” នោះ ជាវិញ្ញាណមិនមានអ្វីប្រៀបផ្ទៀបបានទេ។



www.elibraryofcambodia.org

## និព្វានតាមសព្ទប្រែថាម៉េច ?

ពាក្យថា «**និព្វាន**» តាមរូបសព្ទប្រែថា «រលត់» ដូចពុទ្ធភាសិតនេះ ៖

**«ឧបាទានេ ភយំ ទិស្វា ជាតិមរណសម្ភវេ**

**អនុបាទា វិមុច្ចន្តិ ជាតិមរណសង្ខយេ តេ**

**ខេមប្បត្តា សុខិនោ ទិដ្ឋធម្មាភិនិព្វុតា»។**

«បុគ្គលដែលឃើញភ័យក្នុងឧបាទាន ដែលជាហេតុឲ្យកើតជាតិនិងមរណៈ រមែងផុតចាកសេចក្ដីមិនប្រកាន់ ព្រោះអាស្រ័យនិព្វាន ជាធម៌អស់ទៅនៃជាតិនិងមរណៈ បុគ្គលដែលរួចផុតហើយនោះ រមែងដល់នូវសេចក្ដីសុខក្សេមហើយរលត់ក្នុងបច្ចុប្បន្ននេះ»។

ពាក្យ «**អភិនិព្វុតា**» ដែលប្រែថា «រលត់» នោះលោកថាបានដល់ការរលត់កិលេសទាំងអស់។ លោកបញ្ជាក់ដោយបាលីថា :

**ទិដ្ឋធម្មាភិនិព្វុតាតិ: ទិដ្ឋធម្មេ ឥមស្មឹយេវ**

**អត្តភាវេ សព្វកិលេសេ និព្វានេន និព្វុតា។**

ចូរសង្កេតថា **សព្វកិលេស និព្វានេន** បាលីនេះប្រែថា ដោយការរលត់នៃកិលេសទាំងអស់។ និព្វានដែលនិយាយមកហើយនេះជារូបនាមស័ព្ទ បើជារូបកិរិយាស័ព្ទវិញ នឹងមានពុទ្ធភាសិតដូចតទៅនេះ ៖

**«ឯវញ្ចិ សោ ភិក្ខវេ មហាអគ្គិខន្ធោ**

**បុរិមស្ស ឧបាទានស្ស បរិយាទានា អញ្ញស្ស**

**ច អនុបហារា អនាហារោ និព្វាយេយ្យ ឯវ-**

**មេវ ខោ ភិក្ខវេ ឧបាទានិយេសុ ធម្មេសុ**

**អាទីនវានុបស្សិនោ វិហរតោ តណ្ហា និរុជ្ឈតិ»។**

«ម្នាលភិក្ខុទាំងឡាយ! គំនរភ្លើងធំព្រោះគ្រឿងផ្សំក្នុងកាលមុនអស់ទៅ ព្រោះមិនដាក់ចូលនូវគ្រឿងផ្សំថ្មីទៀត ភ្លើងអស់អាហារ គឺគ្រឿងផ្សំសម្រាប់ឆេះ



www.elibraryofcambodia.org

គប្បីរលត់ទៅយ៉ាងណាមិញ។ ភិក្ខុទាំងឡាយ! បុគ្គលមើលឃើញទោសក្នុងធម៌ជាទីតាំងនៃឧបាទានជានិច្ច តណ្ហាក៏រមែងរលត់ទៅយ៉ាងនោះឯង»។

ពាក្យថា «**និព្វាយេយ្យ**» ប្រែថា «រលត់» សំដៅយករលត់ភ្លើង ពាក្យថា «និព្វាន» ដែលប្រែថា «រលត់» នោះ សំដៅយកការរលត់ភ្លើងនៃកិលេស ដូចពុទ្ធភាសិតថា ៖

«**តណ្ហាយ វិប្បហានេន និព្វានំ ឥតិ វុច្ចតិ**» ព្រោះលះបង់តណ្ហាបានដោយដាច់ខាតយើងពោលថាជានិព្វាន។

សម័យមួយ បរិពាជកម្នាក់ឈ្មោះ ជម្ពុខាទកៈ សួរព្រះសារីបុត្តថា អាវុសោ សារីបុត្ត ដែលលោកនិយាយថា «និព្វាន, និព្វាន» ពាក្យថា និព្វាននេះដៅដល់អ្វី ?

អាវុសោ! «ការអស់ទៅនៃរាគៈ ការអស់ទៅនៃទោសៈ ការអស់ទៅនៃមោហៈ ហៅថា «និព្វាន»។

ក្នុងធម្មចក្កប្បវត្តនសូត្រថា «និរោធ» ពាក្យនេះ ដៅយកនិព្វានបានដល់សេចក្តីរលត់នៃតណ្ហាដោយមិនមានសេសសល់។ ក្រៅអំពីនេះ ពាក្យថា «និព្វាន» ដៅយកសេចក្តីរលត់ភព ដោយមិនមានសេសសល់, ភពក្នុងទីនេះសំដៅយកនាមរូប ដូចភាសិតព្រះសារីបុត្តថា ៖

**«ភវនិរោធោ និព្វានំ»**

«សេចក្តីរលត់ដោយឥតមានសេសសល់នៅនៃភពគឺ «និព្វាន»។ «និព្វាន» លោកថា មកអំពីពាក្យថា «និ» និង «វាន» ប្រែថាចេញចាកព្រៃគឺកិលេស ឬចេញចាកគ្រឿងចាក់ស្រេះ គឺតណ្ហា ( និ= ចេញ + វាន= ព្រៃ កិលេស ឬគ្រឿងចាក់ស្រេះ ផ្លាស់ វ ជា ព ហើយតម្រួតព្វ )។



www.elibraryofcambodia.org

# សឧបាទិសេសនិព្វាន
# និងអនុបាទិសេសនិព្វាន

និព្វានចែកជាពីរគឺ សឧបាទិសេសនិព្វាននិងអនុបាទិសេសនិព្វាន។ សឧបាទិសេសនិព្វាន រលត់កិលេសទាំងអស់តែមានបញ្ចក្ខន្ធសល់នៅ។ អនុបាទិសេសនិព្វាន រលត់កិលេសទាំងអស់ ព្រមទាំងបញ្ចក្ខន្ធក៏រលត់ឥតមានសល់នៅ។ ត្រង់ចំណុចនេះមានពុទ្ធភាសិតក្នុងឥតិវុត្តកៈថា :

"ម្នាលភិក្ខុទាំងឡាយ! និព្វានធាតុមានពីរយ៉ាងគឺ សឧបាទិសេសនិព្វានធាតុមួយ អនុបាទិសេសនិព្វានធាតុមួយ"។

"ភិក្ខុទាំងឡាយ! ដូចម្តេចហៅថា សឧបាទិសេសនិព្វានធាតុ? ភិក្ខុទាំងឡាយ! ភិក្ខុក្នុងធម្មវិន័យនេះជាព្រះអរហន្តមានអាសវៈអស់ហើយ, មានធម៌ប្រព្រឹត្តចប់ហើយ, បានធ្វើកិច្ចដែលត្រូវធ្វើស្រេចអស់ហើយ, បានដាក់ធុរៈចុះហើយ, បានធ្វើប្រយោជន៍របស់ខ្លួនឲ្យសំរេចហើយ មានកិលេសជាគ្រឿងចងភ្ជាប់ជាមួយនឹងភពទាំងអស់ហើយ, មានការរួចផុតចាកចំណងហើយ, មានឥន្ទ្រីយ៍តម្កល់នៅព្រមព្រោះហេតុដែលឥន្ទ្រីយ៍ទាំងឡាយមិនមានសេចក្តីវិបត្តិ។ ភិក្ខុនោះទើបសោយអារម្មណ៍ជាទីគាប់ចិត្តខ្លះ មិនជាទីគាប់ចិត្តខ្លះ សោយសេចក្តីសុខខ្លះ សេចក្តីទុក្ខខ្លះ។ សេចក្តីអស់ទៅនៃរាគៈ សេចក្តីអស់ទៅនៃទោសៈ សេចក្តីអស់ទៅនៃមោហៈ នេះហើយ, ភិក្ខុទាំងឡាយហៅថា "សឧបាទិសេសនិព្វានធាតុ"។

"ភិក្ខុទាំងឡាយ! ដូចម្តេចហៅថា អនុបាទិសេសនិព្វានធាតុ? ភិក្ខុទាំងឡាយ! ភិក្ខុក្នុងធម្មវិន័យនេះជាព្រះអរហន្តមានអាសវៈអស់ហើយ... រួចផុតចាកសេចក្តីសៅហ្មង ព្រោះសេចក្តីចេះដឹង។ ភិក្ខុទាំងឡាយ! វេទនាទាំងឡាយទាំងពួងរបស់គេមិនបានធ្វើឲ្យរីករាយត្រេកត្រអាលហើយ បញ្ចក្ខន្ធរបស់គេ នឹងរលត់អស់ទៅក្នុងលោកនេះ, ភិក្ខុទាំងឡាយ! នេះហៅថា "អនុបាទិសេសនិព្វានធាតុ"។



www.elibraryofcambodia.org

# សោតបន្នបុគ្គលក៏បានឈ្មោះថា បានសម្រេចនិព្វានហើយដែរ

សឧបាទិសេសនិព្វានធាតុប្រែថា និព្វានធាតុដែលមានឧបាទិសល់នៅ ( ស= មាន + ឧបាទិ= បញ្ចក្ខន្ធ + សេស= សល់ x និព្វាន )។

អនុបាទិសេសនិព្វានធាតុ ប្រែថា និព្វានធាតុដែលមិនមានឧបាទិសល់នៅ ( អន= មិនមាន x ឧបាទិ x សេស x និព្វានធាតុ )។

ពាក្យ "ឧបាទិ" អត្ថកថាប្រាប់ថា បានដល់បញ្ចក្ខន្ធ។

តាមន័យនេះ, អ្នកដែលបានឈ្មោះថាសម្រេចនិព្វាន ក៏គឺព្រះអរហន្ត។ បុគ្គលក្រៅអំពីព្រះអរហន្តមិនបានឈ្មោះថា បានសម្រេចនិព្វានទេ ព្រោះពាក្យថា និព្វាន ប្រែថា "រលត់" នោះសំដៅយករលត់ដោយមិនមានសេសសល់នៃរាគៈ ទោសៈ មោហៈ។

តែពាក្យថា "ឧបាទិ" សំដៅយកឧបាទានក៏មាន។ [១]អរិយបុគ្គលដទៃសូម្បីរាគៈ ទោសៈ មោហៈរបស់លោកមិនទាន់អស់ តែចិត្តរបស់លោកបានធ្លាក់ចុះក្នុងក្រសែនិព្វានហើយ។ តាមន័យនេះសោតាបន្នបុគ្គលក៏បានរួចផុតចាកកំណើតសត្វតិរច្ឆានរួចផុតចាកវិស័យនៃប្រេត, បុគ្គល៩ពួកនោះ គឺពួកអ្នកណាខ្លះ ?

ម្នាលសារីបុត្ត! បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយសីល ជាអ្នកបរិបូណ៌ដោយសមាធិ ជាអ្នកបរិបូណ៌ដោយបញ្ញា មានសំយោជនៈខាងដើម៥អស់ហើយ នឹងបរិព្វានក្នុងរវាងអាយុមិនទាន់ដល់ពាក់កណ្ដាលខ្លះ បរិនិព្វានក្នុងអាយុដល់ពាក់កណ្ដាលខ្លះ បរិនិព្វានដោយមិនមានប្រើសេចក្ដីព្យាយាមយ៉ាងខ្លាំងក្លាខ្លះ បរិនិព្វានដោយមានសេចក្ដីព្យាយាមយ៉ាងខ្លាំងក្លា

---

( ១ ) អរិយបុគ្គល ប្រែថា អ្នកនៅឆ្ងាយចាកសត្រូវរបស់ជីវិត ដែលធ្លាប់និយាយមកហើយថា បុគ្គលប្រសើរថ្លៃថ្នូរ។



www.elibraryofcambodia.org

ខ្លះ។ មិនបរិនិព្វានក្នុងជាតិនេះខ្លះ តែជាបុគ្គលមានចិត្តខ្ពស់ វេលាធ្វើមរណកាលរមែងទៅកើតក្នុងអកនិដ្ឋភព។ ម្នាលសារីបុត្ត! បុគ្គលទាំង៥ប្រភេទនេះជា **សឧបាទិសេស** មាន **ឧបាទិ** សល់នៅវេលាធ្វើមរណកាល ក៏រួចផុតចាកនរក រួចផុតចាកកំណើតសត្វតិរច្ឆាន រួចផុតចាកវិស័យនៃប្រេត...។

ម្នាលសារីបុត្ត! នៅមានទៀត បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយសីល ជាអ្នកបរិបូណ៌ដោយសមាធិ ជាអ្នកបរិបូណ៌ដោយបញ្ញា។ បុគ្គលនោះព្រោះអស់សំយោជនៈ ៣ ព្រោះ រាគៈ ទោសៈ មោហៈស្រាលស្តើងជាសកទាគាមី មកកាន់លោកនេះទៀតត្រឹមតែម្តង ហើយក៏បានដល់នូវទីបំផុតទុក្ខ។ ម្នាលសារីបុត្ត! បុគ្គលទី៦នេះក៏នៅជា **សឧបាទិសេស** វេលាធ្វើមរណកាល ក៏រួចផុតចាកនរក។ល។

នៅមានទៀត, សារីបុត្ត! បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយសីល ជាអ្នកបរិបូណ៌ដោយសមាធិ ជាអ្នកបរិបូណ៌ដោយបញ្ញា។ បុគ្គលនោះព្រោះអស់សំយោជនៈ៣, ជាឯកពិជិ មកកើតជាមនុស្សទៀតត្រឹមម្តង ហើយធ្វើឲ្យបានដល់នូវទីបំផុតនៃទុក្ខ។ ជាកោលំ កោលៈ កើត ២, ៣... ជាតិទៀត ហើយក៏ធ្វើខ្លួនឲ្យដល់នូវទីបំផុតនៃទុក្ខ។ ជាសត្តខត្តុបរមៈ កើត៧ជាតិទៀតយ៉ាងច្រើន ហើយក៏ធ្វើខ្លួនឲ្យដល់នូវទីបំផុតនៃទុក្ខ។ ម្នាលសារីបុត្ត! បុគ្គលប្រភេទទី៧ ៨ ៩ នេះក៏ជា **សឧបាទិសេស** វេលាធ្វើមរណកាល ក៏រួចចាកនរក រួចផុតចាកកំណើតសត្វតិរច្ឆាន រួចផុតចាកវិស័យនៃប្រេត។

ម្នាលសារីបុត្ត! ពួកបរិពាជកដែលមានជំនឿក្នុងលទ្ធិដទៃពួកខ្លះជាមនុស្សល្ងង់ខ្លៅមិនឆ្លាត។ ពួកខ្លះក៏ស្គាល់នូវ **សឧបាទិសេស** ថាជា **សឧបាទិសេស** ស្គាល់នូវ **អនុបាទិសេស** ថាជា **អនុបាទិសេស**។ ម្នាលសារីបុត្ត! បុគ្គល៩ប្រភេទនេះជា **សឧបាទិសេស** វេលាធ្វើមរណកាល ក៏រួចផុតចាកនរក រួចផុតចាកកំណើតសត្វតិរច្ឆាន រួចផុតចាកវិស័យនៃប្រេត រួចចាកអបាយ, ទុគ្គតិ, វិនិបាត។

សេចក្តីនេះសម្តែងឲ្យឃើញថា ព្រះសោតាបន្នបុគ្គល៣ពួក ព្រះសកទាគាមិ



www.elibraryofcambodia.org

បុគ្គលមួយពួក ព្រះអនាគាមិបុគ្គល៥ពួករួមគ្នាជា៩ពួក។ ព្រះអរិយបុគ្គលទាំង ៩ ពួកនេះ ដែលបានឈ្មោះថា **សឧបាទិសេស** នោះ សំដៅសេចក្តីថា មានឧបាទិសល់នៅ។ ពាក្យថា“ឧបាទិ” ប្រែថា “គ្រឿងផ្សំ” ក្នុងទីនេះដៅយក **ឧបាទាន** ព្រោះឧទានជាបច្ច័យឲ្យកើតភព។ ដូច្នេះ ទើបមានឈ្មោះថាជាគ្រឿងផ្សំនៃការកើតបុគ្គលដែលមិនមានគ្រឿងផ្សំនៃការកើតមានតែមួយពួក ប៉ុណ្ណោះគឺព្រះអរហន្ត។ រឿងដែលគួរសង្កេតក្នុងទីនេះ ក៏គឺ **ឧបាទិ** ដៅយក **ឧបាទាន**។ តែពាក្យថា **ឧបាទិ** ក្នុងបទថា **សឧបាទិសេសនិព្វាន**, **អនុបាទិសេសនិព្វាន** នោះលោកសំដៅយកបញ្ចក្ខន្ធ ពាក្យទាំងពីរនេះ មានសេចក្តីដៅផ្សេងគ្នា តែជាពុទ្ធភាសិតដូចគ្នា។ ចំពោះរឿងនេះយើងត្រូវកាន់សេចក្តីថា ពាក្យថា **ឧបាទិ** ក្នុងកន្លែងខ្លះលោកសំដៅយក **បញ្ចក្ខន្ធ** ក្នុងកន្លែងខ្លះ លោកសំដៅយក **ឧបាទាន**។

ដូច្នោះ, បុគ្គលដែលបានឈ្មោះថា សម្រេចដល់និព្វាន ទើបមានសេចក្តីដៅពីរយ៉ាងគឺ ៖

យ៉ាងទី១ បុគ្គលដែលជាព្រះអរហន្ត ទើបបានឈ្មោះថា សម្រេចដល់និព្វានដោយបរិបូណ៌។

យ៉ាងទី២ បុគ្គលដែលជាព្រះសោតាបន្ន: ក៏បានឈ្មោះថា សម្រេចដល់និព្វានដែរ តែមិនទាន់បរិបូណ៌ដូចព្រះអរហន្ត ព្រោះ **ឧបាទាន** នៅមានមិនទាន់អស់ដោយដាច់ខាត។ តែយ៉ាងណាក៏ដោយ ព្រះសោតាបន្នបុគ្គល បានឈ្មោះថា ចូលដល់និព្វានក្នុងខាងដើមហើយ។ ព្រះអរិយបុគ្គលនេះ លោកមិនមានការត្រឡប់ថយក្រោយ គឺលោកចេះតែរុលទៅមុខបន្តិចម្តងៗ រហូតដល់ខាងចុងបំផុត គឺនិព្វានដូចព្រះអរហន្តក្នុងពេលណាមួយជាមិនខាន។

តាមការណ៍ពិត, កាលណាយើងនិយាយគ្នាដោយផ្លូវប្រតិបត្តិកុំនិយាយតាមរបៀប ហាត់ចិត្តក្នុងសមថកម្មដ្ឋាននិងវិបស្សនាកម្មដ្ឋាន យើងមុខជាមានជំនឿថា សូម្បីព្រះសោតាបន្នបុគ្គល ក៏បានឈ្មោះថា បានសម្រេចដល់និព្វានក្នុងខាងដើមនោះ ជាហេតុឲ្យមនុស្សយើងចូលចិត្តអំពីរឿងនិព្វានកាន់តែងាយ



www.elibraryofcambodia.org

ឡើង។ សេចក្តីចូលចិត្តនេះ បានជាបច្ច័យនាំឲ្យកើតសេចក្តីព្យាយាមក្នុងការប្រព្រឹត្តធម៌ ដើម្បីបានសម្រេចដល់និព្វានទៀតផង។ ដូច្នេះ, រឿងដែលនិយាយមកហើយនេះទើបជារឿងមានប្រយោជន៍ គួរឲ្យយកចិត្តទុកដាក់ តែអ្នកប្រព្រឹត្តធម៌ភាគច្រើនមិនសូវបានដឹងរឿងនេះទេ។

## ចំណុចសំខាន់ក្នុងការសម្រេចដល់និព្វាន

រឿងនិព្វាន. អ្នកប្រាជ្ញពុទ្ធសាសនាបានព្យាយាមធ្វើសេចក្តីអធិប្បាយដោយផ្អែកលើគម្ពីរខ្លះ ផ្អែកលើយោបល់ថ្មីៗខាងក្រោយខ្លះ ដូចខ្ញុំបានសរសេរមកហើយ អ្នកអានល្មមចូលចិត្តបានអំពីរឿងនិព្វាននេះ មិនច្រើនក៏តិចដែរ។ តែនៅមានរឿងសំខាន់មួយទៀតដែលយើងគួរដឹងព្រមគ្នានេះគឺ ចំណុចសំខាន់នៃការបានសម្រេចនិព្វាន ដោយខ្ញុំយល់ថា ចំណុចនេះមានប្រយោជន៍ច្រើនដល់អ្នកគិតគូររឿងនិព្វានយ៉ាងទូលំទូលាយ ជាចំណុចដែលអ្នកសិក្សាពុទ្ធសាសនាភាគច្រើនមិនសូវបានដឹង ខ្ញុំសូមលើកចំណុចនេះមកបកប្រែ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញា ដូចមានតទៅនេះ ៖

ក្នុងចំណុចមួយ យើងតែងតែនិយាយជាសេចក្តីអស់ទៅនៃអាសវៈព្រោះអាស្រ័យបឋមជ្ឈាន យើងនិយាយដូចនេះព្រោះអាស្រ័យអ្វី?

ម្នាលភិក្ខុទាំងឡាយ! ភិក្ខុក្នុងសាសនានេះ មានចិត្តស្ងាត់ចាកកាមទាំងឡាយ, មានចិត្តស្ងាត់ចាកអកុសលធម៌ទាំងឡាយ, ជាបុគ្គលចូលទៅដល់បឋមជ្ឈានសឹងមានវិតក្កៈ វិចារៈ បីតិ និងសុខៈ ក៏កើតចាកសេចក្តីស្ងាត់នោះធម៌ទាំងឡាយណាមាននៅក្នុងបឋមជ្ឈាននោះ គឺរូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ។ ភិក្ខុពិចារណាឃើញធម៌ទាំងឡាយនោះថា ជារបស់មិនទៀង, ជាទុក្ខ, ជាអនត្តា។ល។ ជារបស់វាលទទេ។ ភិក្ខុញ៉ាំងចិត្តរបស់ខ្លួនឲ្យតាំងនៅក្នុងធម៌គឺ **អនិច្ចំ ទុក្ខំ អនត្តា** ដោយប្រើបញ្ញាញាណពិចារណាឲ្យឃើញច្បាស់ថា



www.elibraryofcambodia.org

ធម៌ទាំងអស់នេះមាននៅក្នុងខន្ធ៥។ កាលណាភិក្ខុពិចារណាឃើញដូចនេះរឿយៗ រមែងមានចិត្តទៅក្នុងអមតធាតុ ( គឺនិព្វាន ) ថា ៖

នេះគឺជាសេចក្តីស្ងប់ពិតមែន នេះគឺជាសេចក្តីប្រណីតពិតមែន ទីនេះជាទីស្ងប់នៃសង្ខារទាំងពួង ជាទីលះបង់ ជាទីអស់ទៅនៃតណ្ហា ជាទីទំលាយបង់នៃកិលេស ជាទីរលត់ដោយឥតមានសេសសល់ នេះគឺ **និព្វាន**។

ភិក្ខុតាំងនៅក្នុងធម៌នេះ រមែងដល់ព្រមដោយសេចក្តីអស់ទៅនៃអាសវៈ ឬមិនទាន់អស់អាសវៈ ព្រោះចិត្តរបស់គេនៅជំពាក់ក្នុងធម៌នោះ គឺនៅមានចិត្តរីករាយត្រេកត្រអាលក្នុងធម៌នោះ តែព្រោះអស់សំយោជនៈ៥ ខាងដើមគេរមែងកើតក្នុងកំណើតជាឧបាតិកៈ ( ក្នុងព្រហ្មជាន់សុទ្ធាវាស ) ហើយបរិនិព្វានក្នុងភពនោះ មិនត្រឡប់មកកើតក្នុងលោកនេះទៀតឡើយ។

សេចក្តីបកប្រែនេះ ជាភាសិតរបស់ព្រះសារីបុត្ត។ សូមសង្កេតដោយល្អិតថា លោកសម្តែងអំពីបដិបទាសំរាប់នាំមនុស្សទៅកាន់និព្វានយ៉ាងល្អបំផុតរបស់លោក។

តាមការដឹកនាំរបស់លោក ជាដំបូងឲ្យធ្វើសមាធិ កាលណាចិត្តស្ងប់ចាកសេចក្តីត្រេកអរក្នុងកាម សេចក្តីរីករាយក្នុងអកុសលធម៌ទាំងឡាយហើយ ក្នុងខណៈនោះចិត្តរបស់យើងនឹងមានសេចក្តីស្ងប់តម្កល់នៅក្នុងអារម្មណ៍តែមួយ មានបីតិនិងសុខកើតឡើង។

ពាក្យថា «វិតក្កៈ» ក្នុងអង្គឈានដែលលោកពោលមកនេះ សំដៅយកសេចក្តីនឹក មិនមែនសំដៅយកសេចក្តីវិតក្កកង្វល់ទេ។ សេចក្តីនឹកដែលលោកឲ្យឈ្មោះថា វិតក្ក ក្នុងទីនេះ សំដៅយកការនឹកក្នុងអារម្មណ៍តែមួយ ដូចជានឹកដល់ខ្យល់ដង្ហើមចេញចូល ក៏នឹកតែត្រឹមខ្យល់ដង្ហើមចេញចូលប៉ុណ្ណោះ មិននឹកដល់អារម្មណ៍ដទៃណាមួយទៀតឡើយ។

ពាក្យថា ក្នុងអង្គឈានដដែលនេះ លោកសំដៅយកដំណើរចិត្ត ដែលត្រាច់ទៅជាមួយនឹងអារម្មណ៍តែមួយ មិនមែនសំដៅយកដំណើរចិត្តដែល



www.elibraryofcambodia.org

ពិចារណាដុះខាត់នូវអារម្មណ៍ទេ។

ចំណែកពាក្យថា "បីតិ" លោកសំដៅយកសេចក្ដីឆ្អែតចិត្ត។ ពាក្យថា "សុខៈ" លោកសំដៅយកសេចក្ដីស្រាលចិត្ត។ កាលណាចិត្តជាសមាធិ មានលក្ខណៈដូចនេះកើតឡើងហើយ តអំពីនេះលោកឲ្យពិចារណាដល់រូបនិងរាងកាយ ឬរូបគឺរបស់ដែលខ្លួនកំពុងនឹក ឬកំពុងសម្លឹងមើលដែលជារូបធម៌។ ហើយលោកឲ្យពិចារណាដល់វេទនា, សញ្ញា, សង្ខារ, វិញ្ញាណដែលកំពុងប្រាកដនៅក្នុងខណៈនោះឲ្យឃើញថា វាជារបស់មិនទៀង ជាទុក្ខ ជាអនត្តា។

កាលណាពិចារណាដូចនេះរឿយៗ មិនយូរប៉ុន្មាននឹងកើតសេចក្ដីចូលចិត្តយ៉ាងជ្រៅក្នុងត្រៃលក្ខណ៍; ក្នុងពេលនោះនិព្វានក៏ប្រាកដនៅក្នុងទីចំពោះមុខ ចិត្តរបស់បុគ្គលអ្នកចំរើនសមាធិ ក៏ចាប់អារម្មណ៍ចំពោះនិព្វានហើយ បញ្ចេញឧទានក្នុងចិត្តថា ៖

នេះជាសេចក្ដីស្ងប់មែន! នេះជាសេចក្ដីប្រណីតមែន! ទីនេះឯងជាទីស្ងប់នៃសង្ខារទាំងពួង! ជាទីលះបង់ស្រឡះនូវឧបធិទាំងពួង! ជាទីអស់ទៅនៃតណ្ហា! ជាទីរំលាយនូវកិលេស! ជាទីរលត់ដោយមិនមានសេសសល់! នេះគឺ**និព្វាន**។

ដែលថា និព្វាន មកប្រាកដនៅចំពោះមុខនោះ ព្រោះក្នុងកាលដែលអ្នកចំរើនសមថកម្មដ្ឋាននិងសមថវិបស្សនា មានសេចក្ដីចូលចិត្តយ៉ាងជ្រាលជ្រៅថា ៖

របស់ដែលហៅថា ខ្លួននៃមនុស្សយើង គឺវាត្រឹមតែជាបញ្ចក្ខន្ធប៉ុណ្ណោះ ត្រឹមតែជារបស់សន្មតឡើង មិនមែនជារបស់ពិតប្រាកដ ហើយប្រកាន់យកនូវរបស់មិនពិតប្រាកដនេះ ថាជារបស់ពិតដោយអំណាចអវិជ្ជានិងតណ្ហាគ្របសង្កត់។ កាលណាអវិជ្ជា តណ្ហាមិនមាន ឧបាទានក៏មិនមាន សេចក្ដីកត់សម្គាល់ក៏មិនមាន។ កាលណាសេចក្ដីសម្គាល់មិនមាន មនោសញ្ចេតនាខាងសេចក្ដីគិតនឹកក៏មិនមាន ចិត្តក៏រលត់ កាលណាចិត្តរលត់ នាមក៏រលត់ រូបក៏



www.elibraryofcambodia.org

រលត់ ព្រមគ្នាក្នុងពេលនោះ។

ក្នុងខណៈដែលអ្នកប្រតិបត្តិធម៌ ពិចារណាឃើញនាមរូបរលត់ដូច្នេះហើយ ក្នុងពេលជាមួយគ្នា គេក៏មើលឃើញភាពវាលទទេយ៉ាងទូលំទូលាយ ចិត្តរបស់គេក៏បានសម្ផស្សជាមួយនិងសេចក្ដីក្សេមយ៉ាងត្រជាក់ យ៉ាងថ្លាឈ្វេងដែលមិនធ្លាប់មានមកអំពីមុន នេះឯងគឺការសម្រេចដល់និព្វាន សមនឹងពុទ្ធភាសិតថា ៖

**"ផុស្សន្តិ ធីរា និព្វានំ យោគក្ខេមំ អនុត្តរំ"**

"អ្នកប្រាជ្ញទាំងឡាយរមែងពាល់ត្រូវនិព្វាន ជាធម៌ក្សេមចាកយោគៈ ជាធម៌ប្រសើរខ្ពង់ខ្ពស់ មិនមានអ្វីប្រៀបបាន"។

ការសម្រេចដល់និព្វាន នឹងកើតឡើងប្រាកដក្នុងមនោសញ្ចេតនាខាងគិតនឹកច្រើនឬតិច ស្រេចហើយតែអំពីសេចក្ដីចូលចិត្ត ក្នុងរឿងរបស់ជីវិតតាមគោលដៅនៃបដិច្ចសមុប្បាទជ្រៅរាក់ គឺអវិជ្ជាអស់ទៅប៉ុន្មាន បញ្ញាសេចក្ដីភ្លឺស្វាង ក៏កើតឡើងជំនួសប៉ុណ្ណោះ តណ្ហាអស់ទៅប៉ុន្មាន សេចក្ដីក្សេមយ៉ាងត្រជាក់ក៏កើតឡើងជំនួសប៉ុណ្ណោះ។

គប្បីចូលចិត្តថា ការពិចារណារឿងរបស់ជីវិតតាមមេរៀនត្រៃលក្ខណ៍ ឬតាមមេរៀនបដិច្ចសមុប្បាទ ប្រសិនបើចង់ចូលចិត្តសេចក្ដីយ៉ាងជ្រាលជ្រៅពិតៗនោះ ត្រូវធ្វើក្នុងខណៈដែលចិត្តមានសមាធិកើតហើយ ព្រោះចិត្តមានសមាធិជាចិត្តមានកិលេសស្ងប់ ជាចិត្តមានពន្លឺស្វាងស្វៃ ជាចិត្តជ្រកនៅក្រោមសេចក្ដីស្ងប់យ៉ាងប្រណីត ជាចិត្តមានភាពទន់ភ្លន់គួរដល់អរិយមគ្គអរិយផល មិនមែនដូចចិត្តក្នុងខណៈដែលនៅក្រោមអំណាចនៃនីវរណធម៌។ ដោយហេតុនេះ ព្រះសារីបុត្តទើបពោលថា :

"យើងនិយាយអំពីរឿងអស់ទៅនៃអាសវៈ ព្រោះអាស្រ័យបឋមជ្ឈាន...។



www.elibraryofcambodia.org

## អ្នកចេះដឹងធម៌អាថ៌
## ហេតុអ្វីទើបលះបង់កិលេសមិនបាន

បុគ្គលពួកខ្លះ សូម្បីចិត្តរបស់ខ្លួនបានដល់នូវសេចក្ដីស្ងប់ហើយ តែកិលេសមិនបានអស់ទៅចាកសន្ដានចិត្តនោះ ព្រោះគេមិនពេញចិត្តលះបង់កិលេសពិតៗ ជម្រៅចិត្តរបស់គេនៅមើលឃើញគុណតម្លៃរបស់កិលេស មិនទាន់ឃើញទោសរបស់កិលេសនៅឡើយ។ គេមានចិត្តនឿយណាស់ចំពោះតែកិលេសគ្រោតគ្រាត គេនៅពេញចិត្តក្នុងសភាពរបស់ជីវិត ក្នុងសភាពរបស់ចិត្តដែលកំពុងរស់នៅ។ កាលណានៅមានសេចក្ដីពេញចិត្ត អវិជ្ជាក៏មិនបានអស់ទៅចាកសន្ដាន។ កុំភ្លេចពិចារណាតាមលំដាប់មេរៀនក្នុងបដិច្ចសមុប្បាទថា "សេចក្ដីពេញចិត្តគឺតណ្ហា តណ្ហាជាបច្ច័យឲ្យកើតឧបាទាន ឧបាទានជាបច្ច័យឲ្យកើតអវិជ្ជា អវិជ្ជាក៏ជាបច្ច័យឲ្យកើតតណ្ហា តណ្ហាក៏ជាបច្ច័យឲ្យកើតឧបាទាន ។ល។ (មេរៀនក្នុងបដិច្ចសមុប្បាទ លោករៀងតាមលំដាប់ក៏មាន លោករៀងខុសលំដាប់ក៏មាន ព្រោះវាជាបច្ច័យដល់គ្នានឹងគ្នាបានទាំងអស់) ។ ដូចនេះព្រះសារីបុត្តទើបពោលថា "ភិក្ខុតាំងនៅក្នុងធម៌ គឺតាំងនៅក្នុងត្រៃលក្ខណញ្ញាណ ជាញាណដែលប្រកបព្រមដោយសមាធិ តែអាសវធម៌នៅមានមិនទាន់អស់ទៅចាកសន្ដាន ក៏ព្រោះចិត្តរបស់គេនៅជាប់ជំពាក់ក្នុងធម៌នោះ, នៅមានសេចក្ដីរីករាយភ្លើតភ្លើនក្នុងធម៌នោះ....។

## ចំណុចសំខាន់មួយទៀត
## ក្នុងការសម្រេចដល់និព្វាន

និព្វានសូម្បីជាធម៌វិសេស ជាធម៌មានសេចក្ដីទៀងទាត់ តែមិនត្រូវប្រកាន់យកនិព្វានថាជាខ្លួន ជាប្រាណ។ ពុទ្ធសាសនាហាមដោយដាច់ខាត មិនឲ្យ



www.elibraryofcambodia.org

ប្រកាន់យកនូវរបស់ណាមួយថាជារបស់ខ្លួនឡើយ ព្រោះរបស់ទាំងអស់សុទ្ធតែជាអនត្តា។ និព្វានក៏ជាអនត្តាផងដែរបើតាមមេរៀនក្នុងពុទ្ធភាសិតថា: «ធម៌ទាំងឡាយទាំងពួងជាអនត្តា» «ធម៌ទាំងឡាយទាំងពួងមិនគួរប្រកាន់យកថាជារបស់ខ្លួន» ក្រៅអំពីនេះមានពុទ្ធភាសិតថា ៖

**«យោបិ សោ ភិក្ខវេ ភិក្ខុ សេខោ អប្បត្តមានសោ**
**អនុត្តរំ យោគក្ខេមំ បត្ថយមានោ វិហរតិ។ សោបិ។ ល។**
**និព្វានំ និព្វានតោ អភិញ្ញាយ។ល។ និព្វានម្មេតិ នាមញ្ញី**
**និព្វានំ នាភិនន្ទិ។ តំ កិស្ស ហេតុ? បរិញ្ញេយ្យំ តស្សាតិ វទាមិ»។**

ម្នាលភិក្ខុទាំងឡាយ! ភិក្ខុណាជាសេខៈ នៅមិនទាន់បានសម្រេចជាព្រះអរហន្ត មានសេចក្តីប្រាថ្នាចង់បានធម៌ក្សេមចាកយោគៈដ៏ខ្ពង់ខ្ពស់។ ភិក្ខុនោះក្នុងកាលណាខ្លួនបានស្គាល់នូវនិព្វាន ដោយភាវៈជានិព្វាន ហើយកុំសំគាល់ថានិព្វានជារបស់ខ្លួន កុំត្រេកអររីករាយចំពោះនិព្វាននោះ គឺកុំត្រេកអរដោយប្រកាន់យកនិព្វានថាជារបស់ខ្លួន ព្រោះហេតុអ្វី? ព្រោះយើងពោលថា និព្វានជារបស់ដែលបុគ្គលគ្រាន់តែគប្បីស្គាល់ប៉ុណ្ណោះ។

**«យោបិ សោ ភិក្ខវេ ភិក្ខុ អរហំ ខីណាសវោ**
**វុសិត្វា កតករណីយោ ឱហិតភារោ អនុបត្តសទត្ថោ**
**បរិក្ខីណភវសំយោជនោ សម្មទញ្ញាវិមុត្តោ។ សោបិ**
**។ល។ និព្វានំ និព្វានតោ អភិញ្ញាយ។ល។ និព្វានម្មេតិ**
**ន មញ្ញតិ និព្វានំ នាភិនន្ទតិ។ តំ កិស្ស**
**ហេតុ? បរិញ្ញាតំ តស្សាតិ វទាមិ»។**

ម្នាលភិក្ខុទាំងឡាយ! ភិក្ខុណាជាអរហន្តខីណាស្រពមានធម៌ប្រព្រឹត្តចប់ហើយ មានកិច្ចដែលត្រូវធ្វើ ធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មាន



www.elibraryofcambodia.org

ប្រយោជន៍របស់ខ្លួនដល់ព្រមហើយ មានកិលេសជាគ្រឿងចង់ភ្ជាប់ឲ្យនៅក្នុងភពអស់ហើយ មានចិត្តរួចផុតហើយចាកកិលេស ព្រោះអាស្រ័យសេចក្តីចេះដឹង។ ភិក្ខុនោះកាលស្តាប់នូវនិព្វានដោយសេចក្តីថា ជានិព្វានហើយ រមែងមិនសម្គាល់ថានិព្វានជារបស់ខ្លួន រមែងមិនត្រេកអររីករាយចំពោះនិព្វាននោះ ព្រោះហេតុអ្វី ? ព្រោះយើងពោលថា និព្វាននោះជារបស់ គឺគេកំណត់ដឹងហើយ។

មេរៀនក្នុងពុទ្ធភាសិតទាំងអស់នេះ មានសេចក្តីថា **និព្វាន** មិនគួរប្រកាន់យកថាជា**អត្តា** មិនគួរត្រេកអររីករាយហើយប្រកាន់យកថាជា**អត្តា**។ ដូចជាធ្លាប់ប្រកាន់យករូបកាយនិងចិត្តវិញ្ញាណថាជា**អត្តា**។ ប្រសិនបើត្រេកអររីករាយហើយប្រកាន់យកថាជារបស់ខ្លួន ព្រោះឃើញថាជាធម៌មានសេចក្តីទៀងទាត់ឬជាធម៌បរិសុទ្ធ។ សេចក្តីត្រេកអរនិងសេចក្តីប្រកាន់នោះ រមែងបណ្តាលឲ្យកើតនូវកិលេសដ៏ប្រណីតបាន កាលណាមានកិលេសដ៏ប្រណីតកើតឡើង សេចក្តីទុក្ខដ៏ប្រណីតក៏រមែងកើតឡើងដែរ។

## ទ្រឹស្តីអំពីរឿងវិញ្ញាណ
## ជាមួយនឹងការសម្រេចនិព្វាន

ដើម្បីជាជំនួយដល់គំនិតរបស់អ្នកអានអំពីរឿងនិព្វាន ខ្ញុំសូមស្រង់យកទ្រឹស្តីនៃវិញ្ញាណ និងការសម្រេចនិព្វានរបស់លោកអ្នកប្រាជ្ញខ្លះមកនិយាយជាសេចក្តីបន្ថែមខ្លះទៀត, ដោយខ្ញុំយល់ឃើញថា មនុស្សយើងប្រសិនបើយល់អំពីរឿងវិញ្ញាណដោយច្បាស់លាស់ ក៏អាចយល់អំពីរឿងនិព្វានខ្លះជាមិនខាន។ ទ្រឹស្តីនៃវិញ្ញាណនិងការសម្រេចនិព្វាន មានដូចតទៅ។

វិញ្ញាណជា**ថាមពល**មួយបែបដែលជានាមធម៌ **ថាមពល**នេះមានកម្លាំងជ្រួតជ្រាបជ្រែកចូលទៅក្នុងរបស់ទាំងអស់ ជាប្រភពនៃច្បាប់ធម្មជាតិ ជាទីធ្វើឲ្យមានកំណើតនៃច្បាប់ធម្មជាតិ។ ដូចនេះ កាលណាបើមនុស្សយើងមានជ័យ



www.elibraryofcambodia.org

ជំនះលើវិញ្ញាណ ឬមានអំណាចលើវិញ្ញាណដោយដាច់ខាត យើងក៏អាចយកជ័យជំនះអំពីធម្មជាតិ នៅលើច្បាប់ធម្មជាតិបាន។

វិញ្ញាណជារបស់មួយដែលមាននៅដោយធម្មតា ដូចគ្នានឹងរូបធាតុថាមពលខាងវត្ថុដែរ។ រូបធាតុថាមពលចាប់កើតមានឡើងតាំងអំពីកាលណា កើតមកអំពីអ្វី សាបសូន្យអស់ទៅវិញក្នុងកាលណា។ សំនួរនេះមិនមានអ្នកវិទ្យាសាស្ត្រណាឆ្លើយបានទេ។ ទាំងអស់គ្នាដឹងត្រឹមតែថាសាកលចក្រវាលនេះ មានទំហំធំទូលាយ តែមិនដឹងដល់ទីបំផុតនៃសាកលចក្រវាល គឺរូបធាតុថាមពល។ ដឹងថារូបធាតុថាមពលមិនមានសេចក្តីសាបសូន្យ មានតែការផ្លាស់ប្តូរអំពីសភាពមួយ ទៅកាន់សភាពមួយទៀត តែអ្នកវិទ្យាសាស្ត្រខ្លះបាននិយាយថា “តាមការស្រាវជ្រាវថ្មីៗនេះធ្វើឲ្យគេចុលចិត្តជាថ្មីថា រូបធាតុថាមពលមានសេចក្តីសាបសូន្យទៅ” វិញ្ញាណថាមពលក៏ដូចជារូបធាតុថាមពលដែរ។ វិញ្ញាណថាមពលដែលមាននៅក្នុងរូបធាតុមិនមានជីវិត,បានវិវត្តមកជាមនោសញ្ចេតនាខាងគំនិត នៅក្នុងរបស់ដែលមានជីវិត, មនោសញ្ចេតនាក្នុងរបស់មានជីវិតនោះគឺប្រាកដការណ៍របស់ថាមពលវិញ្ញាណក្នុងវត្ថុក្នុងរូបផ្សេងៗនោះឯង។

ការណ៍រលត់និងការណ៍កើតនៃវិញ្ញាណ គឺជារបបនៃការផ្លាស់ប្តូររូបក្នុងពិភពលោកវិញ្ញាណ។ លោកនៃវិញ្ញាណ, ជាលោកធំទូលាយដូចអាកាសធាតុមនុស្សស្លាប់ហើយកើតថ្មីទៀតនោះ មានន័យថាគំនរនៃថាមពលវិញ្ញាណក្នុងរូបធាតុមួយ ដែលបណ្តាលឲ្យកើតជីវិតឡើងនោះ កាលណាជីវិតនោះរលត់ទៅវិញ គំនរនៃថាមពលវិញ្ញាណនោះនឹងបង្កើតជាចលនាឡើង ដោយអំណាចនៃការរុញច្រានរបស់កម្មនិងកិលេស នៅខាងក្នុងពិភពលោកនៃវិញ្ញាណ។ ចលនានៃរូបធាតុនោះ នឹងបញ្ជូនផលត្រឡប់អំពីរូបធាតុមួយទៅកាន់រូបធាតុមួយទៀតតៗគ្នាទៅកាន់ជីវិតណាមួយ ក្នុងពេលនោះក៏មានជីវិតថ្មីកើតឡើងក្នុងជីវិតចាស់ ដោយអំណាចនៃការរុញច្រានក្នុងរូបនោះ គឺក្នុងរូបធាតុរបស់វិញ្ញាណក្នុងខណៈដែលត្រូវស្លាប់។ ដោយហេតុនេះ មនុស្សស្លាប់និងមនុស្សកើតថ្មី សូម្បី



www.elibraryofcambodia.org

មិនមែនជាមនុស្សរូបដដែល តែក៏គង់មាននិស្ស័យសន្ដាន បុគ្គលិកលក្ខណៈប្រហាក់ប្រហែលគ្នា សឹងជាហេតុឲ្យយើងជឿបានថា មនុស្សនោះឯងស្លាប់ហើយមកកើតក្នុងទីនេះ។

ទ្រឹស្ដីអំពីរឿងវិញ្ញាណ ដែលបាននិយាយដោយសរុបមកនេះ អាចនាំឲ្យអ្នកអានចូលចិត្តថាវិញ្ញាណជារបស់ទៀតទាត់ ជារបស់ឋិតថេរ។ សេចក្ដីចូលចិត្តដូចនេះ ព្រះពុទ្ធបរមគ្រូយើងទ្រង់ហៅថា «**សស្សតទិដ្ឋិ**» តែតាមការណ៍ពិត ទ្រឹស្ដីនៃវិញ្ញាណ ដែលបាននិយាយមកនេះ មិនសង្គ្រោះចូលក្នុង**សស្សតទិដ្ឋិ**ទេ ព្រោះទ្រឹស្ដីនេះ បើអ្នកអានខំប្រឹងគិតឲ្យចូលចិត្តសេចក្ដីដោយល្អថាសភាពនៃវិញ្ញាណ បើពិនិត្យមើលដល់ការទាក់ទង ឬតំណនៃជាតិនោះ អាចធ្វើឲ្យយើងចូលចិត្តថា វិញ្ញាណជារបស់ទៀងទាត់ ឋិតថេរមែន តែកុំភ្លេចថា សភាពនៃវិញ្ញាណជារបស់កើតរលត់ ជារបស់មានការផ្លាស់ប្ដូរជានិច្ច ហើយត្រូវមើលឲ្យឃើញច្បាស់ថា វិញ្ញាណមិនមែនជារបស់កើតមានឬតាំងនៅបានដោយខ្លួនរបស់វាឡើយ។ សេចក្ដីប្រាកដការប្រព្រឹត្តទៅរបស់វា ត្រូវប្រាស្រ័យទាក់ទងជាមួយនឹងបច្ច័យច្រើន ក្នុងកាលណាអស់បច្ច័យទាំងឡាយហើយ វាក៏មិនប្រាកដតទៅទៀត។ បច្ច័យសំខាន់ដែលធ្វើឲ្យវិញ្ញាណមានប្រាកដការណ៍នោះគឺអវិជ្ជា, តណ្ហា, ឧបាទាន។

សេចក្ដីអធិប្បាយនេះ អាចធ្វើឲ្យអ្នកអានមានគំនិតគូសដៅថា៖ «ការណ៍ពិត, និព្វានក៏គឺវិញ្ញាណដ៏បរិសុទ្ធប្រាសចាកកិលេសនឹងមិនមានប្រាកដការណ៍នោះឯង»។

សូម្បីទ្រឹស្ដីតម្រូវឲ្យយើងគូសដៅដូចនេះក៏ដោយ តែអ្នកអានមេត្តាចូលចិត្តថា អ្នកប្រាជ្ញលោកមិនមានសេចក្ដីប្រាថ្នាសូម្បីបន្តិចបន្តួចសោះ ដើម្បីឲ្យយើងគូសដៅបែបនេះ មុនដែលខ្លួនយើងត្រូវបានសម្រេចជាព្រះអរហន្ត។ សេចក្ដីពិត, សភាពរបស់ព្រះអរហន្តក្រោយអំពីបរិនិព្វានហើយ លោកនឹងទៅជាយ៉ាងណា មិនមាននរណាអាចដឹងបាន ប្រសិនបើអ្នកនោះពុំទាន់បានជា



www.elibraryofcambodia.org

ព្រះអរហន្ត។ ព្រះពុទ្ធបរមគ្រូ ក៏ទ្រង់ហាមមិនឲ្យយើងគូសដៅសភាពរបស់ព្រះអរហន្ត ខាងក្រោយដែលលោកបរិនិព្វានហើយ។

ទ្រឹស្តីនៃវិញ្ញាណ ដែលនិយាយមកនេះ ជាទ្រឹស្តីដែលអាស្រ័យការដៅស្មាន តែជាទ្រឹស្តីផ្អែកលើសេចក្តីពិតផ្សេងៗ ផ្អែកលើមេរៀនក្នុងគម្ពីរនៃពុទ្ធសាសនា។ តែយ៉ាងណាក៏ដោយ ការដៅស្មានសេចក្តីនេះ ជារបស់ដែលអាចភ្លាត់ខុសបានដោយងាយ។

ដូច្នេះ អ្នកអានកុំប្រកាន់យកទ្រឹស្តីនេះ ទុកជាបានការជ្រុលហួសពេក ព្រោះទ្រឹស្តីទាំងអស់ត្រឹមតែជាធាតុមួយប្រៀបបាននឹងជណ្តើរឬបង្គោងសម្រាប់ឡើងសម្រាប់សង់ផ្ទះប៉ុណ្ណោះ វេលាឡើងហើយឬសង់ហើយ ក៏ដាក់ចេញឬស្រាយចោលទៅវិញ។ ប្រសិនបើនិយាយឲ្យបានច្បាស់លាស់ជាងនេះឬងាយស្តាប់ជាងនេះ ទ្រឹស្តីគឺជាធម្មធាតុមួយ ដែលគេត្រូវប្រើតែក្នុងខាងដើមប៉ុណ្ណោះ។ កាលណាអ្នកចំរើនធម៌បានឡើងទៅដល់ថ្នាក់លោកុត្តរភូមិហើយ ទ្រឹស្តីក៏អស់មុខងាររបស់ខ្លួន។ ពុទ្ធសាសនិកកុំព្យាយាមគូសដៅសេចក្តីដោយដាច់ខាត ឲ្យពិចារណាតែអំពីចំណុចនៃសេចក្តីពិតប៉ុណ្ណោះ ព្រោះការដែលត្រូវលះបង់កិលេសបានដោយដាច់ខាតនោះ ត្រូវអាស្រ័យបញ្ញាដែលមានជំនឿជួយគាំទ្រ របស់ណានាំឲ្យកើតសេចក្តីសង្ស័យត្រូវលះបង់ចោលដោយដាច់ខាត។ ចំពោះរឿងនេះអ្នកអានត្រូវរំពឹងគិតដល់ពុទ្ធភាសិតមួយ ដែលព្រះអរហន្តសម្មាសម្ពុទ្ធរបស់យើង ទ្រង់សំដែងឲ្យឧបសីវយុវជនស្តាប់មានសេចក្តីដូចនេះថា ៖

«ខ្លួនអ្នកជាបុគ្គលមានសេចក្តីខ្ជិលច្រើន មានសេចក្តីសង្ស័យច្រើន, អ្នកត្រូវលះបង់នូវវត្ថុធាតុដែលនាំឲ្យកើតសេចក្តីប្រាថ្នា វៀរចាកធម្មជាតិទាំងឡាយដែលនាំឲ្យកើតសេចក្តីសង្ស័យ ចូរសម្លឹងមើលតែធម៌ណាសម្រាប់ធ្វើឲ្យ តណ្ហាអស់ទៅ អ្នកត្រូវព្យាយាមធ្វើយ៉ាងនេះរឿយៗ ទាំងក្នុងពេលយប់ទាំងក្នុងពេលថ្ងៃចុះ»។

ការពិចារណាធម៌ ដើម្បីធ្វើឲ្យតណ្ហាអស់ទៅនោះ អ្នកអានត្រូវពិចារណា



www.elibraryofcambodia.org

ដល់មេរៀនមួយទៀត ដែលព្រះពុទ្ធបរមគ្រូយើង ទ្រង់ឆ្លើយសំនួរព្រះមោគ្គល្លាន មានសេចក្តីដូចនេះថា ៖

ព្រះមោគល្លាន ក្រោយអំពីថ្ងៃដែលបានចូលមកបួសក្នុងពុទ្ធសាសនា បានត្រឹម៧ថ្ងៃ ក្នុងយប់ថ្ងៃទី៧ គឺយប់ដែលលោកបានសម្រេចជាព្រះអរហន្ត នោះ លោកបានទូលសួរព្រះសម្ពុទ្ធថា ៖

"បពិត្រព្រះអង្គជាទីគោរព! សេចក្តីប្រតិបត្តិដោយសង្ខេបមានប៉ុន្មាន សម្រាប់ភិក្ខុដែលត្រូវបង្អោនចិត្តទៅក្នុងនិព្វាន ជាធម៌សម្រាប់ធ្វើឲ្យតណ្ហាអស់ទៅ ជាធម៌សម្រាប់ធ្វើឲ្យភិក្ខុបានដល់ទីបំផុត ជាធម៌ថ្លាស្អាតប្រាសចាកកិលេស ជាគ្រឿងចងភ្ជាប់ក្នុងភពដោយដាច់ខាត ជាព្រហ្មចារីខ្ពង់ខ្ពស់បំផុត ជាធម៌ធ្វើឲ្យមនុស្សដល់ទីបំផុតនៃសេចក្តីទុក្ខយ៉ាងសំបូណ៌ ជាធម៌ធ្វើឲ្យមនុស្សមានសេចក្តីថ្លៃថ្នូរជាងទេវតានិងមនុស្សទាំងឡាយ ?"

"ម្នាលមោគ្គល្លាន ភិក្ខុក្នុងធម្មវិន័យនេះ កាលណាបានរៀនចេះចាំថា បណ្តាធម្មធាតុទាំងពួង គឺភិក្ខុមិនគួរប្រកាន់យកថាជារបស់មាំមួន គេខំប្រឹងរៀនឲ្យចេះចាំធម្មធាតុទាំងពួង កាលណាចេះចាំហើយ គេខំព្យាយាមគិតឲ្យចូលចិត្តសេចក្តីច្បាស់លាស់នូវសេចក្តីមិនទៀង, ភាពជាទុក្ខ, ភាពជាអនត្តារបស់ធម្មធាតុទាំងពួង លោកចូលចិត្តច្បាស់លាស់តាមសេចក្តីពិតហើយ។ កាលណាគេសោយវេទនាយ៉ាងណាមួយ ជាសុខក្តី ជាទុក្ខក្តី មិនមែនជាសុខជាទុក្ខក្តី។ គេរមែងពិនិត្យពិចារណា មើលសេចក្តីមិនទៀងក្នុងវេទនាទាំងអស់នោះជានិច្ច គេពិចារណាដោយបញ្ញាដែលនាំឲ្យកើតសេចក្តីនឿងណាយ, ពិចារណាដោយបញ្ញាដែលធ្វើឲ្យកើតសេចក្តីរលត់កិលេស, ពិចារណាដោយបញ្ញាដែលធ្វើឲ្យលះបង់នូវសេចក្តីក្ដួចប្រកាន់ ក្នុងវេទនាទាំងអស់នោះ។

កាលណាគេពិចារណាដូចនេះរឿយៗ គេក៏រមែងមិនក្ដួចប្រកាន់ក្នុងរបស់ណាៗទាំងអស់ក្នុងលោក, កាលណាគេមិនក្ដួចប្រកាន់ ក៏រមែងមិនមានសេចក្តីភ័យញាប់ញ័រ កាលណាមិនមានសេចក្តីភ័យញាប់ញ័រ គេក៏រមែងចូលទៅដល់



www.elibraryofcambodia.org

សេចក្ដីស្ងប់យ៉ាងត្រជាក់ ក្នុងពេលនោះគេក៏បានដឹងច្បាស់ថាជាតិអស់ហើយ ការប្រព្រឹត្តធម៌ដ៏ប្រសើរបានចប់ហើយ កិច្ចដែលត្រូវធ្វើបានធ្វើស្រេចហើយ កិច្ចដទៃដែលត្រូវធ្វើដើម្បីសេចក្ដីយ៉ាងនេះមិនបានមានទៀតទេ។

"ម្នាលមោគ្គល្លាន ដោយសង្ខេប សេចក្ដីប្រតិបត្តិមានត្រឹមប៉ុណ្ណេះ ភិក្ខុទើបបង្អោនចិត្តរបស់ខ្លួនទៅក្នុងនិព្វាន ជាធម៌សម្រាប់ធ្វើឲ្យតណ្ហាអស់ទៅបាន ជាធម៌សម្រាប់ធ្វើឲ្យបានដល់ទីបំផុតនៃសេចក្ដីទុក្ខ ជាធម៌បរិសុទ្ធផុតចាកកិលេស គ្រឿងចង់ភ្ជាប់ក្នុងភព ជាព្រហ្មចារីខ្ពង់ខ្ពស់បំផុត ជាធម៌ធ្វើឲ្យអ្នកប្រព្រឹត្តបានដល់ទីបំផុតនៃភព ជាធម៌ធ្វើឲ្យអ្នកប្រព្រឹត្តមានគុណតម្លៃជាងទេវតា និងមនុស្សទាំងឡាយ"។

ព្រះមោគ្គល្លាន លោកបានប្រតិបត្តិតាមសេចក្ដីណែនាំ ដែលព្រះសាស្ដាទ្រង់ប្រទាន ក៏បានសម្រេចជាព្រះអរហន្តក្នុងពេលយប់នោះឯង។ ពុទ្ធឱវាទ, ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានព្រះមោគ្គល្លាន សូម្បីជាធម៌ខ្ពង់ខ្ពស់ តែក៏មិនខ្ពស់លើសវិស័យ មនុស្សប្រតិបត្តិតាមមិនបាន ព្រោះតាមធម្មតាមនុស្សទាំងអស់គ្នា ធ្លាប់ជួបប្រទះវេទនាបែបនេះជានិច្ចមកហើយ សូមគ្រាន់តែងាកមកយកចិត្តទុកដាក់ពិចារណាមើលសេចក្ដីសុខ សេចក្ដីទុក្ខក្នុងចំណុចនៃសេចក្ដីពិត ពោលគឺសេចក្ដីមិនទៀង សេចក្ដីសុខអាចក្លាយជាសេចក្ដីទុក្ខ សេចក្ដីទុក្ខអាចក្លាយជាសេចក្ដីសុខ និងភាវៈមិនមានខ្លួនប្រាណដ៏ពិតប្រាកដរបស់វេទនាទាំងអស់នេះ ព្រោះវេទនាទាំងឡាយត្រឹមតែជាផល ត្រឡប់ប្រាស់របស់ផស្សៈជារបស់ទាក់ទងមកចាកហេតុច្រើនយ៉ាងច្រើនប្រការប៉ុណ្ណោះ។ តែប៉ុណ្ណេះ ក៏អាចបានទទួលប្រយោជន៍សមគួរដល់កម្លាំងព្យាយាម ចិត្តរបស់អ្នកប្រព្រឹត្តធម៌ក៏សន្សឹមៗមានសេចក្ដីក្សេមត្រជាក់កើតឡើងតាមលំដាប់។ ការប្រតិបត្តិធម៌បែបនេះ មិនជាលំបាកប៉ុន្មានទេ សូមឲ្យអ្នកអានហាត់ធ្វើឲ្យកើតជានិស្ស័យ ក្នុងទីបំផុតអ្នកអាននឹងបានដឹងថាសេចក្ដីប្រតិបត្តិនេះ បានជាជំនួយក្នុងការស្រាយបញ្ហាជីវិតរបស់ខ្លួនមិនខានឡើយ។



www.elibraryofcambodia.org

# និព្វានគឺជាអ្វី ?

ការធ្វើឲ្យតណ្ហារលត់អស់ដោយមិនមានសេសសល់ ហៅថា «និព្វាន» ការរួចផុតស្រឡះចាកសេចក្តីសោកនិងសេចក្តីទុក្ខគ្រប់យ៉ាងក៏ហៅថា «និព្វាន»។ និព្វានជារបស់មាន តែខុសអំពីការមាននៃរបស់ដទៃៗ ព្រោះនិព្វានជារបស់មាន ដោយប្រាសចាកហេតុបច្ច័យ។ និព្វានជារបស់មិនមាន តែជារបស់មិនមានខុសអំពីការមិនមាននៃរបស់ដទៃៗ ព្រោះនិព្វានមិនមានទីកើតក្នុងខាងដើម និងមិនមានទីបំផុតក្នុងខាងចុង។ និព្វានជារបស់សូន្យ តែមិនមែនសូន្យដូចរបស់ដទៃៗ ព្រោះនិព្វានសូន្យកិលេសរូបធាតុនិងអរូបធាតុ តែពុំបានសូន្យភាវៈដែលហៅថានិព្វាននោះទេ។

តាមការសិក្សារបស់ខ្ញុំ និព្វានត្រូវតែមានពិតប្រាកដ មនុស្សត្រូវតែបាននិព្វានប្រសិនបើមនុស្សធ្វើការទាំងឡាយមានបុណ្យកុសលជាដើមដើម្បីនិព្វាន។ តែតាមសេចក្តីពិត «និព្វាន» ខ្ញុំមិនយល់ថា បានសម្រេចដោយសេចក្តីខ្និលច្រអូសរបស់មនុស្សទេ គឺបានសម្រេចដោយសេចក្តីឧស្សាហ៍ដែលមនុស្សម្នាក់ៗបានធ្វើការបំរើជីវិតរបស់ខ្លួននិងរបស់បុគ្គលដទៃចប់ហើយនុ៎ះឯង។ និព្វានដែលបានសម្រេចដោយចប់ការងារនោះ គឺជានិព្វានរបស់ព្រះសម្មាសម្ពុទ្ធក្នុងថ្ងៃបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណនិងព្រះអរហន្តទាំងឡាយ ដែលបានសម្រេចអរិយផលជាន់ខ្ពស់បំផុតហៅថា «ឧបាទិសេសនិព្វាន»។ និព្វានដែលបានសម្រេចក្នុងថ្ងៃអស់ជីវិតក្នុងបច្ឆិមជាតិនៃព្រះអរហន្តទាំងឡាយ មានព្រះពុទ្ធជាដើម ហៅថា «អនុបាទិសេសនិព្វាន» ដែលបានសម្រេចក្នុងពេលកំពុងប្រតិបត្តិការបានពាក់កណ្តាលឬជិតនិងចប់ គឺជានិព្វានរបស់ព្រះអរិយបុគ្គលថ្នាក់ទាបនិងកណ្តាលហៅថា «មគ្គនិព្វាន»[១] ចំណែលខាងមនុស្សធម្មតាដែលកំពុង

---

(១) និព្វានដើម្បីអ្នកសម្រេចនិព្វាន គឺអ្នកដែលធ្វើទាន. សីល. ភាវនាដើម្បីនិព្វាន មិនមែនដើម្បីស្ថានសួគ៌ឬស្ថានទេវតា។



www.elibraryofcambodia.org

កសាងសព្វថ្ងៃនេះ ពុំបានសម្រេចនូវនិព្វានទាំងអស់នេះទេ ប៉ុន្តែគេបានសម្រេចនូវនិព្វាន ដែលខ្ញុំឲ្យឈ្មោះថា "និព្វានដើម្បីឬដើម្បីនិព្វាន" នោះដែរ។ ដូចម្ដេចហៅថា "និព្វានដើម្បីឬដើម្បីនិព្វាន"? សំនួរនេះបើយើងចង់ឆ្លើយ យើងត្រូវលើកដល់អត្ថនៃនិព្វាន ដែលលោកអ្នកប្រាជ្ញបានពណ៌នាថា "មទនិម្មទនោ" និព្វានជាគុណធម៌ញាំញីនូវសេចក្ដីស្រវឹង **"បិបាសវិនយោ"** និព្វានជាគុណធម៌នាំចេញនូវសេចក្ដីស្រេកឃ្លាន **"អាលយសមុគ្ឃាតោ"** និព្វានជាគុណធម៌ដកចេញនូវសេចក្ដីអាល័យ **"វដ្ដូបច្ឆេទោ"** និព្វានជាគុណធម៌កាត់ផ្ដាច់នូវវដ្ដៈ គឺកិលេសជាគ្រឿងញាំងសត្វឲ្យវិលវល់កើតចាស់ឈឺស្លាប់ **"តណ្ហក្ខយោ"** និព្វានជាទីអស់ទៅនៃតណ្ហា **"វិរាគោ"** និព្វានជាទីប្រាសចាករាគ **"និរោធោ"** និព្វានជាទីរលត់បង់នូវគ្រឿងសៅហ្មង **"និព្វានំ"** និព្វានជាគុណធម៌នាំចេញនូវគ្រឿងជំពាក់របស់ធម្មជាតិទាំងអស់។ ដូច្នេះអ្នកធ្វើសីល, សមាធិ, បញ្ញា និងប្រកបអាជីវកម្មដោយសេចក្ដីបរិសុទ្ធ ក៏ឈ្មោះថាបានសម្រេចនូវនិព្វាន[១] ដើម្បីនេះដែរ ព្រោះអ្វី? ព្រោះការបរិសុទ្ធនាំឲ្យមានចិត្តស្ងប់។

និព្វាន គេមិនអាចស្គាល់បានដោយមេទន្ទេញទេ តែគេអាចស្គាល់បានដោយធ្វើការពិសោធន៍ តាមមេទន្ទេញ ប្រៀបបាននឹងអ្នកសិក្សាវិជ្ជាវិទ្យាសាស្ត្រដែលពុំអាចស្គាល់បាននូវធាតុ (បរមាណូ) ដោយមេទន្ទេញទេ តែគេអាចស្គាល់បានដោយធ្វើការពិសោធន៍តាមមេទន្ទេញ។ ដូច្នេះអ្នកចង់បាននិព្វានខាងក្រោយ ដែលបានធ្វើសីលសមាធិបញ្ញាចប់ហើយ បានស្គាល់អត្ថឬគុណធម៌នៃនិព្វានហើយ ត្រូវធ្វើការពិសោធន៍ក្នុងចិត្តរបស់ខ្លួនដើម្បីឲ្យដឹងថានិព្វាននាំឲ្យបាននូវសេចក្ដីសុខស្ងប់មែនឬទេ។ តាមការពិនិត្យរបស់ខ្ញុំ ខ្ញុំពុំដែលឃើញមនុស្សណាម្នាក់ បានសេចក្ដីសុខយ៉ាងស្ងប់ដោយត្រឹមតែមានប្ដីប្រពន្ធ ឪពុកម្ដាយ ទ្រព្យសម្បត្តិ យសស័ក្តិ។ល។ ទេ តែខ្ញុំឃើញគេបានសេចក្ដីសុខស្ងប់យ៉ាងអន់ឬសេចក្ដីសុខនេះ ដោយគេចេះប្រើសេចក្ដីស្នេហាក្នុងប្ដីប្រពន្ធ របស់

(១) មគ្គនិព្វានក្នុងគម្ពីរមិនមានទេ តែខ្ញុំឲ្យឈ្មោះដើម្បីឲ្យអ្នកអានងាយយល់។



www.elibraryofcambodia.org

គេ គឺមិនក្បត់សេចក្តីស្នេហា គេធ្វើសេចក្តីស្នេហារបស់គេ ឲ្យមានសេចក្តីបរិសុទ្ធ គេគោរពឪពុកម្តាយរបស់គេ គេមិនប្រើកម្លាំងទ្រព្យសម្បត្តិយសស័ក្តិ ជិះជាន់អ្នកដទៃ គេមានចិត្តមេត្តាដល់មនុស្សទូទៅ។

នៅក្នុងលោកយើងនេះ នរណាក៏សឹងតែបានដឹងហើយថាចម្បាំងតែងកើតឡើងអំពីសេចក្តីស្នេហា ដែលមនុស្សម្នាក់ៗបានប្រព្រឹត្តឲ្យហួសព្រំដែន។ សេចក្តីស្នេហាក្នុងទីនេះ មិនមែនដៅយកត្រឹមតែសេចក្តីស្នេហាក្នុងបុរសស្ត្រីប៉ុណ្ណោះទេ គឺដៅយកសេចក្តីស្នេហាក្នុងវត្ថុធាតុទាំងអស់ ទោះជាវត្ថុនោះមានជីវិតក្តី មិនមានជីវិតក្តី។

ម្យ៉ាងទៀតពាក្យថា "**ស្នេហា**" នេះជាគូគ្នានឹងពាក្យពីរម៉ាត់ទៀតគឺ "**រាគៈ**" និង "**តណ្ហា**" ពាក្យទាំងអស់នេះមានសម្លេងខុសគ្នា តែមានសេចក្តីត្រូវគ្នា គឺមានចំណង់ក្នុងផ្លូវកាមហ្នឹងឯង។ ពុទ្ធសាសនារបស់យើងបានបង្រៀនថា "តណ្ហាជាហេតុនៃសេចក្តីទុក្ខ" មេរៀននេះមិនមាននរណាអាចបដិសេធបានទេ ព្រោះតណ្ហាដែលគេប្រើឲ្យហួសព្រំដែន ឬដែលគេប្រើដោយគ្មានសំចៃនោះ រមែងតែនាំឲ្យមានសេចក្តីទុក្ខ។ បើតណ្ហានោះមានតិច ទុក្ខក៏មានតិច បើតណ្ហានោះមានល្មម ទុក្ខក៏មានល្មម បើតណ្ហានោះមានច្រើន ទុក្ខក៏មានច្រើន។ អ្នកអានគប្បីដឹងថា ចម្បាំងរវាងព្រះរាមនិងក្រុងរាពណ៍ក្តី ចម្បាំងរវាងព្រះឥន្ទនិង ស្តេចអសុរក្តី សង្គ្រាមលោកលើកទី១ក្តី សង្គ្រាមលោកលើកទី២ក្តី។ល។ សង្គ្រាមទាំងអស់នេះសុទ្ធតែកើតឡើងដោយតណ្ហា គឺការលួចប្រពន្ធ-កូនគេ ការវាតពង្រីកអំណាចខាងសេដ្ឋកិច្ច និងការស្វែងរកអាណានិគមរបស់ប្រទេសមហាអំណាចទាំងឡាយ។ល។ ក្នុងអនាគតកាលគេអាចទាយបានថា នឹងមានចម្បាំងថ្មីកើតឡើងដោយការផ្សាយអំណាចនៃលទ្ធិនយោបាយ និងការផ្សាយអំណាចនៃលទ្ធិសេដ្ឋកិច្ចទាំងពីយ៉ាងនេះយ៉ាងណាមួយជាមិនខានឡើយ។



www.elibraryofcambodia.org

# និព្វានប្រៀបធៀបជាមួយនឹងសិវៈ

ដោយនិព្វានតាមសេចក្ដីដៅនៃពុទ្ធសាសនាមានសេចក្ដីប្រហាក់ប្រហែលគ្នានឹងលក្ខណៈនៃព្រះសិវៈ ជាយ៉ាងក្រៃពេក។ ទាំងពុទ្ធសាសនា សោតទៀត ក៏បានលើកយកឈ្មោះ «**សិវៈ**» ដែលប្រែថា «ព្រះឥសូរ» មកធ្វើជាឈ្មោះនៃ**និព្វាន**។ ដូច្នេះ, យើងគួររៀនអំពីរឿងនេះឲ្យល្អិតបន្តិច ព្រោះមានបញ្ហាចោទឡើងថា និព្វានតាមមតិនៃពុទ្ធសាសនា មិនមែនជាអាកាសធាតុធម្មតា មិនមែនជាចិត្តឬវិញ្ញាណធម្មតាទេ។ បើយ៉ាងនេះសភាពរបស់និព្វាននឹងទៅជាយ៉ាងណា ? នឹងទៅជាតាវៈមួយមានលក្ខណៈដូចគ្នានឹងព្រះសិវៈនោះឬ ? ចំពោះបញ្ហានេះមានយោបល់អ្នកប្រាជ្ញខ្លះ លោកយល់ថា ៖

ក្នុងសម័យជិតពុទ្ធកាល មានមតិរបស់ឧបនិស័ទកើតឡើងស្រាវជ្រាវជួបប្រទះអាត្ម័ន ឬធម្មជាតិម្យ៉ាងមិនមានប្រាកដការណ៍ លំបាកនឹងគិតឲ្យយល់ព្រោះជារបស់កើតមានឡើងផ្ទុយអំពីរបស់ក្នុងលោក ជារបស់មិនមាននរណាសាងមិនមានបច្ច័យរចនាតាក់តែង តែជារបស់មាននៅគ្រប់កាលទាំងអស់របស់នេះមានសិកសៀនៅក្នុងរូបធាតុទូទៅ ហាក់ដូចជាដួងវិញ្ញាណនៃសាកលលោក បើនរណាធ្វើចិត្តរបស់ខ្លួនឲ្យអស់អវិជ្ជា នោះគេនឹងមើលឃើញអាត្ម័ននេះដោយបញ្ញាចក្ខុរបស់គេជាមិនខាន ក្នុងខណៈព្រមគ្នានេះ ចិត្តរបស់គេក៏បានដល់នូវសេចក្ដីសុខជាទីបំផុតមិនមានអ្វីប្រៀបបាន។ ខាងក្រោយអំពីការបានត្រាស់ដឹងនៃព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ស្រាវជ្រាវតទៅទៀតទ្រង់បានឃើញថា ធម្មជាតិដែលគេហៅថាអាត្ម័ននោះ ជាធម្មជាតិមានពិតមែនតែរបស់នោះមិនត្រូវហៅថាអត្តាឬអាត្ម័នទេ ព្រោះរបស់នេះជាអនត្តា មិនមែនខ្លួនអ្នកធ្វើឬតួកត្តុការក ដែលនឹងអាចធ្វើទៅជានេះជានោះបានឬតួធម្មការកដែលនរណាៗ អាចធ្វើទៅជាអ្វីៗបាន។ វាជាធម៌ឬជាធម្មជាតិសុទ្ធៗ មែនៗ កុំទៅសំគាល់យកវាថាជាតួខ្លួនឡើយ។ ឃោគាវចរក្នុងពុទ្ធសាសនាលោកមាន



www.elibraryofcambodia.org

ចំណុចទីដៅតែមួយគឺនិព្វាន ដ៏ជាទីរំលត់បង់នូវសេចក្ដីប្រកាន់ក្នុងខន្ធ ៥ ថាជាខ្លួនប្រាណ ជាទីរំលត់បង់នូវកិលេស ជាទីរំលត់បង់នូវកងទុក្ខប៉ុណ្ណោះ។ ក្នុងពេលនោះលោកបានដឹងនូវការអស់ទៅនៃកងទុក្ខផង នូវសភាវធម៌ដែលជាគ្រឿងធ្វើឲ្យកងទុក្ខអស់ទៅផង តែលោកមិនមានកំណាន់ មិនមានសំគាល់ថាសភាពនោះ ជាខ្លួនជាប្រាណឬជាអាត្មันឡើយ។

សភាពនោះត្រឹមតែជាធម្មជាតិសុទ្ធៗ ដែលបុគ្គលត្រូវការសេចក្ដីសុខជាទីបំផុត គប្បីលះបង់នូវទម្ងន់ធម្មជាតិទាំងអស់នេះចោលហើយ មិនគប្បីកាន់យកជាថ្មីទៀតកាលណាដាក់ចុះទម្ងន់ (គឺខន្ធ៥) បានហើយ សេចក្ដីបរិសុទ្ធក៏កើតមានឡើង ចិត្តយោគាវចរក៏បានឆ្លងផុតចាកលោក។ ចំពោះរឿងនេះ មានពុទ្ធភាសិតថា ៖

**«ភារា ហវេ បញ្ចក្ខន្ធា ភារហារោច បុគ្គលោ**

**ភារាទានំ ទុក្ខំ លោកេ ភារនិក្ខេបនំ សុខំ**

**និខិបិត្វា គរុំ ភារំ អញ្ញំ ភារំ អនាទិយ**

**សមូលំ តណ្ហំ អព្ភុយ្ហ និច្ឆាតោ បរិនិព្វុតោ»**

«ខន្ធ៥ ជាភារៈបុគ្គលដាក់ចុះនូវទម្ងន់ គឺខន្ធ៥ហើយ មិនកាន់យកនូវទម្ងន់ដទៃទៀត ដកចោលនូវតណ្ហាព្រមទាំងឫស ជាបុគ្គលឈ្មោះថាបានសម្រេចនូវនិព្វាន»។

ចំពោះការបដិសេធរបស់គ្រប់យ៉ាងថា មិនមែនជាអត្តា នោះមានពុទ្ធភាសិតថា ៖

**«សព្វេ ធម្មា អនត្តាតិ... »**

«ធម៌ទាំងឡាយទាំងពួងមិនមែនជាអត្តា គឺរបស់អ្វីៗទាំងអស់ក្នុងសកលពិភព មានការប្រព្រឹត្តទៅត្រឹមតែជាធម្មតាប៉ុណ្ណោះ»។

ពាក្យថាធម៌ក្នុងទីនេះសំដៅយករបស់ទាំងអស់ ជារូបធាតុក្ដី ជាអរូបធាតុក្ដី ជារបស់ដែលមានបច្ច័យរចនាតាក់តែងក្ដី ជារបស់ដែលមិនមានបច្ច័យ



www.elibraryofcambodia.org

របនាគាក់តែងដូចនិព្វាននេះក្តី។

មតិនៃឧបនិស័ទ មានអាត្ម័នប្រកដដោយលក្ខណៈ ជាអសង្ខតស្រដៀងនឹងនិព្វាននៃពុទ្ធសាសនា ព្រោះទស្សនវិជ្ជារបស់គេបានផ្តែកទៅលើគោលនៃខ្លួនមនុស្សយើង គឺកាលណាគេស្រាវជ្រាវឃើញថាៈ កាយនិងចិត្តនេះមិនមែនខ្លួនប្រាណរបស់យើងហើយ សេចក្តីអស្ចារ្យរមែងកើតមានឡើងថា បើយ៉ាងដូច្នេះ ខ្លួនរបស់យើងមាននៅក្នុងទីណាទៅវិញ។ ការដែលនិយាយថា រូបកាយនិងចិត្តមិនមែនជារបស់យើងនោះ ក៏ព្រោះរបស់ទាំងអស់នេះត្រូវរចនាតាក់តែងឡើងជាករបស់ផ្សេងៗ របស់ណាដែលកើតឡើងដោយគ្រឿងផ្សំ, គ្រឿងប្រកបច្រើនមុខ របស់នោះរមែងបែកចេញអំពីគ្នា ហើយត្រឡប់ចូលទៅរករបស់ធម្មតាវិញទើបលោកថាមិនមែនជារបស់ខ្លួន។ ការគិតគូរអំពីរឿងនេះ បានធ្លាក់ចុះក្នុងសភាពទាល់គំនិត ដោយរកមិនឃើញថា **អ្វីជាអត្តាឬអាត្ម័ន**។ ក្រោយមកការស្រាវជ្រាវបានជួបប្រទះប្រភេទធម៌ដែលជាអសង្ខតៈ ដែលគេអាចដឹងបានដោយអាស្រ័យសេចក្តីដៅស្មានថា មានលក្ខណៈផ្ទុយអំពីរូបកាយនិងចិត្តវិញ្ញាណ ជារបស់មានមាយា ជារបស់មាននៅក្នុងទីទូទៅ ព្រោះគេអាចស្រាវជ្រាវឃើញក្នុងសាកលរូបធាតុ ទើបគេដាក់ចុះនូវជំនឿយ៉ាងដាច់ខាតថា នេះហើយជាអត្ម័នឬអត្តា។ ខ្លួនយើងយ៉ាងណា ខ្លួនលោកក៏យ៉ាងនោះ ព្រហ្មយ៉ាងណាយើងក៏យ៉ាងនោះ ដោយន័យថា យើងមានខ្លួនយើង រួមគ្នាតែមួយ ឬយើងមានខ្លួនយើងរួមជាមួយនិងព្រហ្ម។ ព្រហ្មក្នុងទីនេះ សំដៅយកអាត្ម័នក្នុងទីទូទៅនោះឯង មតិនេះ ស្រដៀងនឹងពុទ្ធសាសនាជាទីបំផុត ផ្សេងគ្នាតែខាងព្រាហ្មណ៍ ឬខាងឧបនិស័ទ គេមានតួអាត្ម័នជាធាតុត្រូវវត្ថុធាតុទាំងឡាយ ឬធម្មធាតុទាំងឡាយខ្ទប់ ហើយក្នុងទីបំផុតកញ្ចប់ធម្មជាតិនេះ ត្រូវគេស្រាយចេញបានដោយសេចក្តីប្រតិបត្តិតបៈធម៌ ក្នុងពេលនោះចិត្តក៏ជាធាតុបានស្គាល់អាត្ម័នដែលបានចេញចាកកញ្ចប់ហើយ។ ចំណែកពុទ្ធសាសនា មិនមានតួអាត្ម័នដូចនោះទេ មានតែចិត្តដែលត្រូវកិលេសខ្ទប់វេច កាលណារួចចេញចាកកញ្ចប់



www.elibraryofcambodia.org

កិលេស ចិត្តក៏ដឹងថាបានរួចហើយ។ ចិត្តរួចចាកកញ្ចប់កិលេស សំដៅយកការបានសម្រេចនិព្វាន។ ក្នុងខណៈព្រមគ្នានេះ ចិត្តបានរំលត់នូវមនោសញ្ចេតនាខាងគំនិតទាំងអស់ មានកំណាន់ក្នុងខ្លួនជាដើម សេចក្តីទុក្ខក៏អស់ត្រឹមនេះ មិនមានកើតថ្មីទៀត។

នៅក្នុងមេរៀននេះ លោកបានបញ្ជាក់ថា ព្រះសម្មាសម្ពុទ្ធព្រមទទួលស្គាល់ថា អាត្ម័នរបស់ព្រាហ្មណ៍នោះមានពិតមែន តែមិនមែនជានិព្វានក្នុងពុទ្ធសាសនាទេ ព្រោះអាត្ម័នឬព្រហ្មឬសិវៈនោះ។ គេនិយាយថា ក្នុងខ្លួនយើងមានអាត្ម័ន សឹងជាបំណែកមួយនៃអាត្ម័នធំហើយ ក្នុងទីបំផុត កាលណាអាត្ម័នតូច បានធ្វើខ្លួនឲ្យដល់នូវសេចក្តីបរិសុទ្ធ អាត្ម័នតូចនេះក៏មានលក្ខណៈត្រូវគ្នានឹងអាត្ម័នធំ គឺព្រះព្រហ្មឬព្រះសិវៈនោះឯង។ យើងអាចដឹងរឿងនេះបានតាមគម្ពីរឧបនិស័ទ ដែលជាទស្សនវិជ្ជារបស់ព្រាហ្មណ៍ដូចតទៅនេះ ៖

“**អាត្ម័ន**” កាលណារួចផុតចាកលោកិយធម៌ មានឥស្សរភាពពេញទីហើយ ទោះជារបស់នរណាក៏ដោយរមែងមានសភាពដូចគ្នាឬមានលក្ខណៈដូចគ្នាទាំងអស់មិនមានចៅហ្វាយនាយ មិនមានទាសភាព មិនមានល្អ មិនមានអាក្រក់។ អាត្ម័ននោះ លោកប្រៀបដូចអាកាសដែលមាននៅក្នុងភាជនៈផ្សេងៗ ដែលត្រូវការភាជនៈក្តោបក្តាប់ទុកឲ្យទៅក្នុងកន្លែងមួយ ជាអាកាស ចំណែកមួយនៅឃ្លាតចាកអាកាសភាគធំក្នុងផ្ទៃមេឃនិងផ្ទៃពិភពលោក កាលណាភាជនៈត្រូវគេវាយបំបែកចោល អាកាសដែលមិនមានគ្រឿងក្តោប ក៏ត្រូវបានទៅនៅរួមជាមួយនឹងអាកាសភាគធំតាមធម្មតាវិញ ដូចកាលគេមិនទាន់ក្តោបដោយភាជនៈ»។

## ព្រះសិវៈជាប្រភពនៃវិញ្ញាណ
## ក្នុងរបស់ដែលមានជីវិតទាំងអស់

ខ្ញុំបាននិយាយមកហើយថា ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ហៅនិព្វានថា



www.elibraryofcambodia.org

"អាយតន" ពាក្យថា "អាយតន" ប្រែថា "អណ្ដូងជាទីកើត" ដូចជាភ្នែកក៏លោកហៅថា អាយតន ព្រោះភ្នែកជាទីកើតនៃចក្ខុវិញ្ញាណដូច្នេះជាដើម។ តែពាក្យថា **អាយតន** ដែលជាឈ្មោះរបស់និព្វាននោះលោកពុំបានសំដៅសេចក្ដីថា និព្វានជាទីកើតរបស់ចិត្តឬពន្លឺដែលចាំងចេញមកជាចិត្តឡើយ។ ប្រសិនបើយកសេចក្ដីថា **និព្វាន** ជាទីកើតត្រូវសំដៅសេចក្ដីថា ជាទីធ្វើឲ្យចិត្តកើតសេចក្ដីបរិសុទ្ធ។ ចិត្តបរិសុទ្ធជាទស្សនវិជ្ជាខាងពុទ្ធសាសនារបស់យើង។ ចំណែកទស្សនវិជ្ជារបស់ព្រាហ្មណ៍គេមានជំនឿថា ចិត្តគឺជាមនោសញ្ចេតនាខាងនឹកគិតផ្សេងៗ នេះជារបស់កើតមានជាប់ទាក់ទងមកចាកអាត្ម័ន ឬកើតមកចាកព្រះព្រហ្ម ឬព្រះសិវៈ សឹងទុកដូចជាដួងវិញ្ញាណនៃសាកលចក្រវាល ទុកដូចជាខ្លឹមនៃវត្ថុធាតុទាំងអស់ក្នុងសាកលពិភព។ ធម្មជាតុនេះឯង តាមទស្សនវិជ្ជារបស់ព្រាហ្មណ៍ គេប្រកាន់ថាជា **អាយតន** គឺជាកន្លែងជាទីកើតឬជាទីមកឬជាប្រភពនៃចិត្តវិញ្ញាណរបស់សព្វសត្វទាំងឡាយ។ តែព្រោះហេតុថា ក្នុងចិត្តរបស់មនុស្សសត្វមានអវិជ្ជា ទើបនាំឲ្យវង្វេងប្រកាន់យកចិត្តឯងថាជាខ្លួន ក្នុងកាលណាមនុស្សសត្វទាំងឡាយមានអវិជ្ជានោះអស់ហើយ ក្នុងពេលនោះចិត្តដែលគេយល់ច្រឡំនេះក៏រលត់ទៅ ហើយអាត្មន័ដែលមានសភាពជាអសង្ខតធម៌ ជាសព្វញ្ញូ ក៏មានភាពប្រាកដប្រច័ក្សឡើង។

ក្នុងចំណុចថា: ចិត្តមកចាកអាត្ម័ន យើងដឹងបានចាកពាក្យអធិប្បាយក្នុងឃ្លាមួយនៃទស្សវិជ្ជាយោគៈថា ៖

"អ្នកដែលទទួលយកឬអ្នកដែលឃើញវិស័យទាំងឡាយ បានដល់អាត្ម័នដែលតាំងនៅក្នុងរូបកាយ ចំណែកគ្រឿងទទួលឬតួអង្គនៃការទទួលបន្តនោះបានដល់ចិត្ត, ចិត្តត្រឹមតែជាតួការរបស់អាត្ម័ន, តួការធ្វើនាទី, ព្រោះអ្នកកការគឺអាត្ម័នធ្វើការយ៉ាងណា ចិត្តក៏ធ្វើនាទីតាមអាត្ម័នយ៉ាងនោះដែរ"។

ម្យ៉ាងទៀតលោកថា ចិត្តអាចធ្វើនាទីឬតាំងនៅក្នុងមុខងាររបស់ខ្លួនបានក៏ព្រោះអាត្ម័នតាំងនៅក្នុងឋានៈ ជាមេដឹកនាំ លោកប្រៀបដូចកម្លាំងមេដែក



www.elibraryofcambodia.org

ដែលបានបញ្ជូនកម្លាំងដើមរបស់ខ្លួនទៅកាន់ដែកដទៃៗ, កម្លាំងនោះរមែងធ្វើឲ្យដែកធម្មតានោះៗមានចលនាផ្សេងៗ ទោះបីមេដែកនោះនៅស្ងៀមៗក៏ដោយ ព្រោះអ្វី? ព្រោះកម្លាំងផ្សាយចេញចាកតួមេដែកចូលទៅក្នុងដែកដទៃៗ អស់កាលជានិច្ចនោះឯង។ កម្លាំងអាត្មន័ផ្សាយចូលទៅក្នុងចិត្តអស់កាលជានិច្ច ចិត្តទើបធ្វើនាទីជាតួការបាន។ បើតាមរឿងនេះ អាត្ម័ននិងចិត្តជាធម្ម ជាតុត្រូវតែញែកចេញអំពីគ្នា ដូចមេដែកនិងកូនដែក ឬដែកធម្មតា។ តែថាព្រោះអវិជ្ជាបង្គាប់ ទើបមានសេចក្តីសំគាល់ខុសកើតឡើងថា អាត្ម័នក៏គឺចិត្តនោះឯង។ គឺដោយមានអវិជ្ជាបិទបាំងបញ្ញាចក្ខុរបស់យើង ទើបយើងមើលមិនឃើញអាត្ម័ន។ ដូច្នេះព្រឹត្តិការណ៍ទាំងឡាយរបស់ចិត្តក៏គឺជាព្រឹត្តិការណ៍របស់អាត្ម័នផងដែរ ដូចជាយើងមើលមិនឃើញមេដែក ហើយយើងចូលចិត្តថាចលនាផ្សេងៗរបស់កូនដែកឬដែកធម្មតា គឺជាចលនាឬជាអំពើដែលកើតមានឡើងក្នុងដែកនុ៎ះឯង។ សេចក្តីសំគាល់ខុសក្នុងចំណុចថាព្រឹត្តិការណ៍របស់អាត្ម័ន ឬព្រឹត្តិការណ៍របស់អាត្ម័ននិងព្រឹត្តិការណ៍របស់ចិត្ត ជាព្រឹត្តិការណ៍តែមួយនោះហើយ ដែលលោកហៅថាជនមាន **អស្មិមានះ**។

**អស្មិមានះ** ប្រែថាការប្រកាន់យកបញ្ចក្ខន្ធថាជាខ្លួនយើង ខ្លួនគេ ឬប្រកាន់ថា ក្នុងបញ្ចក្ខន្ធមានអត្តា ឬប្រកាន់ថា យើងជានេះ ជានោះ សឹងតាមសេចក្តីពិតខ្លួនយើងមែនៗ មិនមានឡើយ។ តាមវិធីរបស់ព្រាហ្មណ៍គេបង្រៀនឲ្យស្រាវជ្រាវរកអាត្ម័ន តែវិធីរបស់ពុទ្ធសាសនា ហាមដាច់ខាតមិនឲ្យស្រាវជ្រាវរកថា ខ្លួនយើងដែលពិតប្រាកដនោះគឺជាអ្វី, ការស្វែងរកខ្លួនយើងមិនខុសគ្នានឹងការស្វែងរកភាពមាយាក្នុងថ្ងៃបណ្តើរកូនឡើយ។

ពុទ្ធសាសនា,បង្រៀនឲ្យពិចារណាអំពីរឿងត្រៃលក្ខណ៍ឬបដិច្ចសមុប្បាទ។ ការសំខាន់បំផុត អ្នករៀនពិចារណាត្រូវនឹករាល់ៗខណៈចិត្តថា បណ្តាមនោ-សញ្ចេតនាខាងគំនិតសតិបញ្ញាទាំងអស់ដែលប្រាកដមាននៅទាំងក្នុងវិថីចិត្តទាំងក្នុងភវង្គចិត្ត សុទ្ធតែជារបស់កើតឡើងចាកបច្ច័យផ្សេងៗ កាលណាបច្ច័យ



www.elibraryofcambodia.org

របស់វាអស់ហើយ ចិត្តក៏ត្រូវតែរលត់ផុតទៅ។ មានតែការពិចារណា បែបនេះ ប៉ុណ្ណោះទើបធ្វើឲ្យចិត្តបានរួចផុតចាកអវិជ្ជា បានដល់នូវសេចក្តីបរិសុទ្ធ ក្នុងពេល នោះឯង ដែលអ្នកប្រតិបត្តិធម៌សមថកម្មដ្ឋានឬសមថវិបស្សនា បានស្គាល់ថា និព្វានមានលក្ខណៈយ៉ាងណា, មានសេចក្តីសុខស្ងប់យ៉ាងដូចម្តេច។ ចំណែក បុគ្គលដែលទៅមិនទាន់ដល់ធម៌ទីបំផុត ឬមានអវិជ្ជាមិនទាន់អស់នៅឡើយ មិន អាចយល់បាននូវភាវៈដ៏ស្ងប់គឺនិព្វានបានទេ លោកប្រៀបថា ដូចបុគ្គលភ្នែក ខ្វាក់មិនអាចចូលចិត្តបាននូវរូបភាពផ្សេងៗដូចបុគ្គលមានភ្នែកភ្លឺដូច្នោះឯង។

## ការសម្រេចនិព្វាន

តាមសេចក្តីពិត, សាកលមនុស្សត្រូវការឲ្យខ្លួនម្នាក់ៗ មានសេចក្តីទុក្ខ អស់ទៅ, មានសេចក្តីសុខកើតឡើងជំនួសវិញ។ ដូច្នេះ, ដើម្បីឲ្យសមតាម បំណងនេះ ខ្ញុំសូមធ្វើសេចក្តីពំភ្លឺថា : សត្វទាំងឡាយដែលនឹងអាចបានដល់ នូវនិព្វាន ជាទីដែលមានតែសុខសុទ្ធ មិនមានលាយឡំដោយទុក្ខនោះ ទាំង អស់គ្នាត្រូវរៀនឲ្យស្គាល់នូវសេចក្តីទុក្ខ កំណត់សម្គាល់នូវសេចក្តីទុក្ខ ចងចាំនូវ សេចក្តីទុក្ខ ឲ្យបានគ្រប់គ្រាន់តាមផ្លូវចិត្តនៅក្រោមពន្លឺនៃបញ្ញារបស់អាត្មា។ បន្ទាប់ មកទៀត, ត្រូវព្យាយាមលះបង់សេចក្តីប្រាថ្នា (តណ្ហា) គ្រប់ប្រភេទដែលជា ហេតុនៃទុក្ខទាំងឡាយជាមួយនឹងសេចក្តីខំប្រឹងធ្វើឲ្យគំនិតរបស់ខ្លួនយល់ ច្បាស់នូវអ្វីដែលលោកហៅថា «**និព្វាន**» ឬ «**និរោធ**»។ ក្នុងទីបំផុត ត្រូវធ្វើ សេចក្តីសម្រេចចិត្តយ៉ាងដាច់ខាតថា : មានតែមគ្គ ៨ ប្រការប៉ុណ្ណោះទេ ដែល អាចធ្វើខ្លួនឲ្យសម្រេចនិព្វានបាន។ ក្រោយអំពីសេចក្តីសម្រេចចិត្តនេះ ត្រូវខំប្រឹង ដើរតាមផ្លូវ ៨ ប្រការ ដែលអ្នកធ្លាប់ចេះចាំមកថា «**អដ្ឋង្គិកមគ្គ**» នុ៎ះឯង។ ម្តង នេះទៀត, មុននឹងធ្វើសេចក្តីបោទឆ្លើយក្នុងសៀវភៅនេះ ខ្ញុំសូមធ្វើនូវសេចក្តី បញ្ជាក់អំពីអរិយសច្ចធម៌ គឺទុក្ខនិរោធជាអរិយសច្ចទី៣ ដែលជាពាក្យប្រើជំនួស



www.elibraryofcambodia.org

និព្វាន សឹងមានមកក្នុងបឋមទេសនា ( **ធម្មចក្កប្បវត្តនសូត្រ** )។

សច្ចៈទី ៣ នេះ បើបកស្រាយឲ្យបានច្បាស់លាស់តាមពុទ្ធបំណង ដែលទ្រង់ទេសនាក្នុងពេលនោះ គឺបានដល់ការជួយធ្វើសត្វទាំងឡាយ ឲ្យបានសម្រេចនូវឥស្សរភាព, នូវការរួចចាកទុក្ខទាំងពួង, នូវសេរីភាពខាងផ្លូវចិត្ត, នូវសន្តិភាព (ភាពបន្តនៃទុក្ខ) គឺជារបស់មួយតែងតែមានយ៉ាងពិតប្រាកដ។ ការរួចផុតស្រឡះចាកទុក្ខទាំងឡាយ ដែលមានចែងក្នុងទុក្ខអរិយសច្ចនោះលោកហៅថា "**ទុក្ខនិរោធ**" (ការរលត់ទុក្ខ) ជាឈ្មោះនៃនិព្វាន, ជាធម៌ដែលបានឮបានចេះចាំទាំងអស់គ្នាៈ តែគេពុំបានយល់ថាដូចម្ដេចឡើយ។

ដើម្បីបំបាត់ "ទុក្ខបំរុងសុខ" គេត្រូវខំប្រឹងព្យាយាមបំបាត់ឫសគល់នៃទុក្ខ បង្កើតឫសគល់នៃសុខ គឺត្រូវធ្វើយ៉ាងណាឲ្យខ្លួនអស់តណ្ហាឲ្យចិត្តនៃអាត្មាឋិតនៅក្នុងមគ្គមានអង្គ៨។ ដូចនេះ ព្រោះអ្វី? ព្រោះតណ្ហាវាជាធម៌ធ្វើឲ្យមានកំណើតក្នុងភពថ្មី, មគ្គមានអង្គ៨ ជាធម៌សម្រាប់ធ្វើអ្នកដើរតាមឲ្យដល់ទៅទីដៅគឺសេចក្ដីអស់ទុក្ខ ដូចយើងធ្លាប់ចេះចាំមកគ្រប់គ្នាហើយ។ អ្នកអានទាំងឡាយគប្បីដឹងថា និព្វានមានឈ្មោះហៅច្រើនបែប ច្រើនយ៉ាងណាស់ មិនមែនមានត្រឹមតែនិរោធៈប៉ុណ្ណោះទេ គឺមានតណ្ហក្ខយៈជាដើមទៀតផង។ ឈ្មោះទាំងឡាយនោះ ខ្ញុំបានរៀបរាប់ក្នុងខាងដើមខ្លះហើយ។ ដូចម្ដេចនិព្វានទើបមានឈ្មោះច្រើនម្ល៉េះ, ចំពោះសំណួរនេះ មិនមានចម្លើយឯណា ក្រៅអំពីថា ព្រោះព្រះសម្មាសម្ពុទ្ធទ្រង់ខំប្រឹងដាក់ឈ្មោះឲ្យច្រើន ក្នុងគោលបំណងដើម្បីឲ្យគេយល់អំពីនិព្វានប៉ុណ្ណោះ។

រៀងរាល់ពេល, សំនួរថានិព្វានគឺជាអ្វី? ជាសំនួរនៅពុំទាន់បានទទួលចម្លើយ គួរជាទីពេញចិត្តនៃពុទ្ធសាសនិកទាំងឡាយសោះឡើយ។ បញ្ហានិព្វាននេះ, មានក្បួនតម្រាច្រើនណាស់ ដែលលោកបានសរសេរ បានធ្វើសេចក្ដីពំភ្លឺឆ្លើយតបនិងបញ្ហាដ៏ល្អិតជ្រាលជ្រៅនេះ។ តែទោះណាជាចម្លើយរបស់លោកពោរពេញទៅដោយខ្លឹមសារ ត្រឹមត្រូវតាមច្បាប់ធម៌មួយរយភាគរយ ក៏អ្នកស្ដាប់



www.elibraryofcambodia.org

នៅតែស្តាប់មិនយល់សេចក្តីស្ទើរតែទាំងអស់។ ការមិនយល់នេះពុំមែនមានន័យថា អ្នកឲ្យចម្លើយមិនប៉ិនអធិប្បាយ, មិនមានសេចក្តីវៃវាង ឬមិនមានទេពកោសល្យនោះទេ គឺមកអំពីនិព្វានជាគុណធម៌មិនមានរូប, របស់ណាមិនមានរូប, របស់នោះ ត្រូវនៅក្រៅបញ្ញត្តិ, ក្រៅភាសាដែលមនុស្សនិយាយគ្នា ប្រែថាភាសាមនុស្ស ដែលគេយកមកប្រើសម្រាប់ពន្យល់អំពីនិព្វាននោះ វាត្រូវមិនចំលក្ខណៈមួយៗនៃនិព្វាន គឺថាពាក្យមនុស្សយើងមួយម៉ាត់ៗ ពុំអាចយកមកនិយាយឲ្យត្រូវន័យ របស់គុណធម៌ទាំងឡាយដែលលោកប្រមូលផ្តុំ ហើយដាក់ឈ្មោះថា “**និព្វាន**” នោះបានឡើយ។ តាមសេចក្តីពិត, ភាសាមនុស្សគេបង្កើតឡើងសម្រាប់តែប្រើក្នុងពិភពលោកនៃមនុស្សតែម្យ៉ាង គេពុំបានបង្កើតឡើងសម្រាប់និយាយស្តីអំពីនិព្វាន ដែលមានគុណភាពខ្ពស់ហួសការពិសោធន៍របស់មនុស្ស ឬនៅក្រៅសំគាល់ទាំងឡាយ ដែលគេបានជួបប្រទះក្នុងពិភពលោកនៃមនុស្ស ទើបគេចូលចិត្តបានដោយកម្រ។ អ្នកអានគប្បីដឹងថា នៅក្នុងលោកនៃមនុស្សមិនមានពាក្យមួយម៉ាត់សម្រាប់ពំភ្លឺអំពីការពិសោធន៍, ការធ្វើនិស្សន៍រកសេចក្តីពិត, ដែលជាសេចក្តីពិតបែបនិព្វាន, បែបអរិយសច្ចៈឲ្យមនុស្សយើងបានឃើញជាក់ស្តែងភ្លាមៗ តាមចំណង់បានទេ បើទុកណាជាយើងខំពំភ្លឺ ខំធ្វើនិទ្សន៍ យ៉ាងពិស្តារយ៉ាងណាក៏ដោយ ក៏គេនៅតែស្តាប់មិនបាន ស្តាប់មិនចូលដដែលៗ ហ្នឹងឯង។ ចំពោះការស្តាប់មិនយល់នេះ បើនិយាយជាពាក្យឧបមាក៏មិនខុសអំពីរឿងដំណាលមួយថា មានមនុស្សម្នាក់ មានភ្នែកខ្វាក់អំពីកំណើតថ្ងៃមួយ ពេលយប់ព្រះចន្ទពេញវង់ស្ថិតនៅកណ្តាលពពួកតារា មនុស្សទាំងឡាយដែលមានភ្នែកភ្លឺ នាំគ្នានិយាយរៀបរាប់សរសើរព្រះចន្ទ ថាយថា មានពន្លឺថ្លាស្រស់, មានមណ្ឌលមូលសក្តិសមតាមទំហំនិងតំណូចធំតូច។ អ្នកខ្វាក់លុះឮពាក្យសរសើរនេះ ក៏ដេញដោលសួរគេថា ភ្លឺយ៉ាងម៉េច, មូលយ៉ាងម៉េច, ល្អយ៉ាងណា។ ចំពោះ សំនួរដេញដោយរបស់បុរសខ្វាក់អំពីកំណើតនេះ មិនមានអ្នកណាអាចមានសមភាពពន្យល់ឲ្យយល់បានឡើយ, ដូចនេះព្រោះអ្វី? ព្រោះ



www.elibraryofcambodia.org

បុរសនោះមិនដែលឃើញនូវអ្វីៗទាំងអស់តាំងពីកំណើតមក; គេថាព្រះចន្ទ មានពន្លឺដូចភ្លើង, ដូចមាស បុរសនោះសួរគេថា មាសហ្នឹងជាអ្វី? ភ្លើងហ្នឹងជាអ្វី? អ្នកឆ្លើយក៏ទាល់ប្រាជ្ញត្រឹមប៉ុណ្ណឹងទៅ ឬម្យ៉ាងទៀតដូចមនុស្សណាម្នាក់ដែលមិនធ្លាប់បានទទួលទានស្ករ លុះឮគេថា ស្ករមានរសផ្អែម ក៏ដេញដោលសួរគេថា ស្ករមានរសផ្អែមដូចម្ដេច? សំនួរនេះក៏មិនមានអ្នកណាអាចឆ្លើយពន្យល់បានឡើយ។ ប្រសិនបើឲ្យអ្នកខ្វាក់និងអ្នកមិនធ្លាប់ស៊ីស្ករទាំងពីរនាក់នេះ ស្គាល់ពន្លឺព្រះចន្ទនិងរសផ្អែមរបស់ស្ករនេះ គេត្រូវធ្វើឲ្យវាមានភ្នែកភ្លឺសិន ជាមួយគ្នានេះត្រូវយកស្ករឲ្យវាស៊ីទៅ វាក៏បានស្គាល់ព្រះចន្ទ, ដឹងរសជាតិស្ករដោយស្វ័យប្រវត្តិក្នុងពេលនោះឯង។ សេចក្ដីនេះយ៉ាងណាមិញ និព្វានក៏យ៉ាងនុ៎ះដែរ កាលណាគេដើរតាមមគ្គមានអង្គ ៨ ប្រការ ប្រកបដោយសេចក្ដីព្យាយាមនិងសេចក្ដីក្លាហានយ៉ាងប្តូរផ្តាច់ ក្នុងទីបំផុតនៃទំរើរបស់គេ នោះ គេក៏បានស្គាល់និព្វានដោយស្វ័យប្រវត្តិដូច្នេះដែរ។

នៅក្នុងពិភពលោកនៃមនុស្សនេះ ដោយចំពោះក្នុងប្រទេសសាធារណរដ្ឋខ្មែរយើង មានពាក្យប្រកបដោយអង្គលក្ខណៈ ដែលវេយ្យាករណ៍យើងបានប្រាប់ឲ្យយើងស្គាល់។ ពាក្យទាំងឡាយនេះ បើពិចារណាវែកញែកដោយល្អិតល្អន់ទៅ ឃើញមានផ្សេងគ្នា១០ចំណែក ដែលខ្ញុំសូមរាប់ឲ្យអ្នកអានបានចេះចាំទុកដូចមានតទៅនេះ គឺ ៖

១- "**នាម**" ជាពាក្យសម្រាប់ប្រាប់ឈ្មោះមនុស្ស, សត្វ និងរបស់ទ្រព្យជាដើម ដូចជាមនុស្ស, គោ, ស្រូវ, ប្រាក់។ល។

២- "**គុណ**" ជាពាក្យសម្រាប់ធ្វើនាមនិងសព្វនាមឲ្យមានសេចក្ដីប្លែកផ្សេងទៅទៀត ដូចជា មនុស្សធំ, គោធាត់, ស្រូវស្រួយ, ប្រាក់ច្រើន។ល។

៣- "**គុណវិសេសនៈ**" ជាពាក្យសម្រាប់ធ្វើពាក្យគុណឲ្យមានសេចក្ដីប្លែកផ្សេងទៅទៀត ដូចជា សស្គុស, ខ្មៅឃ្លឹក, ខ្ពស់ច្រដោង, ទាបកន្ទុប។ល។

៤- "**សព្វនាម**" ជាពាក្យសម្រាប់ប្រើជួសឈ្មោះផ្សេងៗ ដូចជា គាត់,



www.elibraryofcambodia.org

វា, អ្នក, ឯង, អញ ។ល។

៥- «**កិរិយា**» ជាពាក្យសម្រាប់ប្រាប់អាការកិរិយារបស់នាម ដូចជា ដើរ,ហែល, ស៊ី, ទៅ។ល។

៦-«**កិរិយាវិសេសនៈ**»ជាពាក្យសម្រាប់ប្រកបពាក្យកិរិយាឲ្យមានសេចក្ដីផ្លែកផ្សេងទៅទៀត ដូចជាលឿន រហ័ស, យឺត, យូរ, ឆាប់។ល។

៧-«**កិរិយាកិរិយាវិសេសនៈ**»ជាពាក្យសម្រាប់ប្រកបពាក្យកិរិយាវិសេសនៈឲ្យមានសេចក្ដីផ្លែកជាងប្រក្រតី ដូចជា ផ្លែត, ភ្លាម, ប្រិច, ព្រិល, រវេ។ល។

៨- «**បុព្វបទ**» ជាពាក្យសម្រាប់នាំនាមនិងសព្វនាម... ដូចជា ដោយ, ដល់, ក្នុង, លើ, ក្រោម។ល។

៩- «**សន្ធាន**» ជាពាក្យភ្ជាប់សេចក្ដីឲ្យជាប់ទាក់ទងគ្នា ដូចជានិង, ជាមួយ, មួយអន្លើ, ដូចនេះ, ដូចនោះ។ល។

១០- «**ឧទាន**» ជាពាក្យសម្រាប់ប្រាប់សម្លេងផ្សេងៗ ដូចជា អឺត, អើ, ឱ, អឺយ, អើយ។ល។ ទោះណាជាភាសាទាំងឡាយរបស់មនុស្សលោក មានភាសាខ្មែរ, បាលី, បារាំង, សំស្ក្រឹតជាដើមជាភាសាមានរបៀប មានវេយ្យាករណ៍យ៉ាងពិស្ដារនិងយ៉ាងល្អិតជ្រៅជ្រះដែលមនុស្សយើងម្នាក់ៗរៀនស្ទើរតែមិនចេះឬមិនចប់ដូចនេះក៏ដោយក៏នៅតែជាពាក្យសម្រាប់ហៅ, សម្រាប់និយាយអំពីនិព្វានឲ្យបានគ្រប់ទាំងអស់ ឬឲ្យត្រូវចំន័យទាំងអស់ពុំបានឡើយ។ ដូចនេះព្រោះអ្វី? ព្រោះព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងអំពីនិព្វាន ដោយអរិយភាសាគឺភាសារបស់អរិយបុគ្គល ប្រែជាភាសានៃមនុស្សដែលមានចិត្តខ្ពស់, មានសេចក្ដីធុញទ្រាន់នឹងអ្វីៗទាំងអស់ដែលមនុស្សគេចូលចិត្ត។ ភាសាបែបនេះ បើមិនហៅថា អរិយភាសានឹងហៅថា ភាសាថ្មី គឺភាសាដែលមនុស្សយើងមិនដែលបានឮក៏បាន។ សេចក្ដីនេះ គួរយើងនឹកដល់ពំនោលខ្លះដែលមានក្នុងគម្ពីរមហាយានថា «មនុស្សលោកជាសត្វល្ងង់ ជាសត្វមានសេចក្ដីញៀនជាប់ស្អិតតែនឹងពាក្យពេចន៍ជាសម្មតិនាម គឺនាមដែលខ្លួននាំគ្នាសន្មតសម្រាប់ប្រើ, សម្រាប់



www.elibraryofcambodia.org

ហៅរបស់ទាំងឡាយក្នុងលោក មានពាក្យថាមនុស្ស, ទេវតា, ឥន្ទព្រហ្មជាដើម ។ ដោយអាស្រ័យសេចក្ដីញៀន សេចក្ដីធ្លាប់នេះហើយទើបយើងស្ដាប់ពាក្យពិត ពាក្យមែន ឬពាក្យបរមត្ថដែលនិយាយអំពីនិព្វានរបស់ព្រះសម្មាសម្ពុទ្ធនៃយើង ពុំសូវបាន»។

ក្នុងបច្ចុប្បន្នកាលនេះ, មនុស្សយើងនឹងធ្វើនូវអ្វីៗទាំងអស់មិនងាយបានសម្រេចទេ បើយើងនៅតែខ្វះភាសា ព្រោះភាសាជាគ្រឿងកំណត់សំគាល់នូវវត្ថុ, នូវចិត្តគំនិត, នូវឧត្តមគតិ, នូវទ្រឹស្ដី, នូវសេចក្ដីប្រតិបត្តិនិងរបស់អ្វីៗ ទៅទៀតដែលយើងត្រូវការប្រើជាចាំបាច់ខានមិនបាន។ តាមធម្មតានិព្វាន, លោកច្រើនប្រើពាក្យជាអវិជ្ជមានបញ្ញត្តិឬអវិជ្ជមានសព្ទដូចជាពាក្យថា ៖

**«មទនិម្មទនោ, បិបាសវិនយោ, អាលយ-**

**សមុគ្ឃាតោ, វដ្ដុបច្ឆេទោ តណ្ហក្ខយោ,**

**វិរាគោ, និរោធោ, និព្វានំ»។ល។**

ពាក្យទាំងអស់នេះ សុទ្ធតែជាពាក្យមានសម្លេងមិនប្រាកដដោយរូប ឬដោយអ្វីមួយដែលមនុស្សយើងធ្លាប់ជួបប្រទះ។

ដើម្បីឲ្យអ្នកអានបានពិចារណាអំពីរឿងនិព្វានឲ្យបានច្រើន ខ្ញុំសូមស្រង់យកពាក្យពន្យល់ដែលមានក្នុងគម្ពីរពុទ្ធសាសនា មកសរសេរជាថ្មីទៀត ទោះជាពាក្យទាំងអស់នោះមានមកក្នុងខាងដើមខ្លះហើយក៏ដោយក៏មិនឥតប្រយោជន៍ដល់អ្នកអានទាំងឡាយដែរ ព្រោះអ្វី? ព្រោះការសរសេរថ្មីនេះ ខ្ញុំទុកដាក់ជាមេរៀនមេពិចារណាប្រមូលដើម្បីឲ្យងាយស្រួលដល់ការចង់ចាំឬជាជំនួយស្មារតីនៃអ្នកអានទាំងឡាយមានដូចតទៅនេះ ៖

- ការរលត់តណ្ហាដោយមិនមានសេសសល់, ការបោះបង់តណ្ហា, ការលះបង់តណ្ហា, ការរលាស់តណ្ហាចេញ, ការផ្ដាច់តណ្ហាចោលចេញ នេះគឺជានិព្វាន។

ការបំបាត់ចោលនូវធម៌ទាំងឡាយជាគ្រឿងផ្សំផ្សំ; ការទាត់ចោលនូវធម៌



www.elibraryofcambodia.org

ទាំងឡាយជាគ្រឿងក្រាំ, ការជម្រះចិត្តឲ្យអស់តណ្ហា, ការរួចផុតស្រឡះចាកភព នេះជានិព្វាន។

ក្រៅអំពីពុទ្ធភាសិតខាងលើនេះ មានពុទ្ធតម្រាស់មួយកន្លែងទៀត ដែលព្រះសម្មាសម្ពុទ្ធទ្រង់ចោទសួរភិក្ខុទាំងឡាយ ហើយទ្រង់ឆ្លើយដោយព្រះអង្គឯងមានដូចនេះ ៖

“ម្នាលភិក្ខុទាំងឡាយ! អ្វីជាអង្ខតធម៌? ភិក្ខុទាំងឡាយ! ការអស់រាគៈ; ការអស់ទោសៈ, ការអស់មោហៈ នេះជាអសង្ខតធម៌គឺជានិព្វាន” ។ មានពុទ្ធតម្រាស់តែមួយបទគត់ ដែលទ្រង់សម្តែងទៅកាន់រាធៈថា ម្នាលរាធៈ! ការអស់តណ្ហាទាំងឡាយនេះឯងគឺជានិព្វាន។

ធម៌ពីរប្រការ គឺសង្ខតធម៌និងអសង្ខតធម៌ ព្រះសម្មាសម្ពុទ្ធទ្រង់ទុកដាក់អសង្ខតធម៌ថាជាធម៌ប្រសើរខ្ពង់ខ្ពស់បំផុត ដូចនេះពីព្រោះអ្វី? ព្រោះអសង្ខតធម៌ ជាវិរាគធម៌ ធម៌ប្រាសចាកសេចក្តីតម្រេកក្នុងភព។ សេចក្តីនៃពុទ្ធសម្រាស់នេះ មានន័យថា “ការមានសេរីភាព, ការរួចផុតស្រឡះចាកសេចក្តីប្រកាន់, ការបំបាត់មិនឲ្យមានសល់នូវសេចក្តីស្រេកឃ្លាន, ការរើលើងនូវឫសគល់ឧបាទាន, ការកាត់ផ្តាច់មិនឲ្យមានសេសសល់នូវសន្តតិធម៌គ្រឿងតភ្ជាប់គ្នា វដ៏កមិនមានចន្លោះ, ការអស់តណ្ហា, ការរួចផុតស្រឡះ, ការរលត់អស់រលីងនូវសង្ខត់ធម៌, នេះឯងហើយដែលហៅថា និព្វាន”។ អ្នកអានចូរសង្កេតមើលពុទ្ធភាសិតទាំងឡាយនេះតទៅទៀត ៖

ភិក្ខុទាំងឡាយ! ដែលតថាគតថា អសង្ខតធម៌ជាធម៌ប្រសើរខ្ពង់ខ្ពស់នោះព្រោះអ្វី? “ភិក្ខុទាំងឡាយ! ព្រោះវិរាគធម៌ការប្រាសចាករាគនេះ ជាធម៌ប្រសើរលើស ដោយសេចក្តីថា វិរាគធម៌ជាធម៌ញ៉ាំញីនូវសេចក្តីស្រវឹង, ជាធម៌បន្ទោរបង់នូវសេចក្តីស្រេកឃ្លាន, ជាធម៌រើលីងនូវសេចក្តីអាឡោះអាល័យ, ជាធម៌កាត់ផ្តាច់នូវវដ្តៈ, ជាធម៌អស់តណ្ហា, ជាធម៌ប្រាសចាកតម្រេក, ជាធម៌រលត់ដោយជុំវិញ ជានិព្វាន”។



www.elibraryofcambodia.org

ពំនោលខាងលើនេះ មានចម្លើយមួយរបស់ព្រះសារីបុត្តត្ថេរ ដែលលោកបានឆ្លើយនឹងសំនួរបរិព្វាជកម្នាក់ មានសេចក្តីត្រូវគ្នានឹងពុទ្ធតម្រាស់នេះដែរ គឺការរលត់អស់នូវរាគៈ, ទោសៈ, មោហៈ ហៅថា «និព្វាន»។

មានសេចក្តីមួយអន្លើទៀត ដែលសម្តែងដោយព្រះសារីបុត្តត្ថេរដដែលថា ការរំលត់បង់នូវតណ្ហា, ការកំចាត់បង់ឲ្យអស់នូវឧបាទានក្នុងខន្ធបញ្ចកៈ, នេះឯងហៅថាការរលត់ទុក្ខ គឺទុក្ខនិរោធ ឬនិព្វាន។

មតិខ្លះទៀតរបស់ព្រះថេរៈទាំងឡាយជាអ្នកប្រាជ្ញនៃពុទ្ធសាសនាថា ការរលត់នៃភពក៏ឈ្មោះថា «**និព្វាន**» ដែរ។

ក្រៅអំពីយោបល់ខាងលើនេះ មានពុទ្ធសម្រាប់អំពីរឿងនិព្វានជាច្រើន ដែលខ្ញុំបានសរសេរមកខ្លះហើយក្នុងខាងដើម ដើម្បីឲ្យអ្នកអានងាយគិតងាយពិចារណា ខ្ញុំសូមស្រង់យកសេចក្តីដើមនិងសេចក្តីថ្មីទៀត មកសរសេរម្តងទៀតដូចមានតទៅនេះ ៖

ភិក្ខុទាំងឡាយ! ទីណាមិនមានធាតុដី, ធាតុទឹក, ធាតុភ្លើង, ធាតុខ្យល់ ទីនោះគួរកត់សំគាល់ថា អាកាស, វិញ្ញាណ, សុខុម, គ្រោតគ្រាត, ល្អ, អាក្រក់ នាមនិងរូបក៏មិនមាន, ហើយទីដដែលនេះនឹងទុកដាក់ថា ជាលោកនេះក៏មិនមែន ជាលោកដទៃក៏មិនមែន និងថាមានព្រះអាទិត្យក៏មិនមែន មានព្រះចន្ទក៏មិនមែនដែរ។

ភិក្ខុទាំងឡាយ! តថាគតមិននិយាយដល់អ្វីទាំងអស់នោះថា ជារបស់មានដំណើរទៅ, មានដំណើរមក, មានភាពស្ថិតនៅ, មានភាពចុតិ កើតឡើងសោះឡើយ របស់ទាំងឡាយនោះវាមិនមានការស្លាប់ មិនមានការកើត មិនមានកាមារម្មណ៍ នេះឯងហើយជាទីបំផុតនៃទុក្ខ គឺនិព្វាន។

ភិក្ខុទាំងឡាយ! មានធម៌មិនមានកំណើត, មិនមានដំណុះ, មិនមានគ្រឿងផ្សំផ្សំ, មិនមានគ្រឿងតាក់តែងទៀតដែរ។ ភិក្ខុទាំងឡាយ! កាលណាបើមិនមានធម៌ទាំងឡាយនេះហើយ កំណើត ដំណុះ ដំណាំ តំណាក់តណែង ក៏



www.elibraryofcambodia.org

មិនមានជាពិតប្រាកដ នេះឯងគឺជាទីបំផុតនៃទុក្ខដែលយើងតថាគតហៅថា **«និព្វាន»**។

ទោះណាជាពុទ្ធភាសិតទាំងឡាយនេះ មានការវែកញែកសេចក្តីយ៉ាងល្អិតល្អន់យ៉ាងណាក៏ដោយ អ្នកស្តាប់ដែលមិនសម្បូណ៌ការសិក្សា ការស្រាវជ្រាវ ក៏នៅតែយល់មិនបានដដែល ប្រសិនបើគេនៅមានចិត្តជាប់ជំពាក់នឹងរបស់លោកិយ តែពុំទាន់បានប្រើបញ្ញាជាប់ខ្ពស់ គឺវិបស្សនាបញ្ញា។

ដោយមកអំពីនិព្វាន, លោកប្រើសំដីនិយាយជាអវិជ្ជមានដែលភាសាធម្មតាថាមិនមាន ដូចបាននិយាយមកហើយ ដូចនេះទើបមានមនុស្សភាគច្រើន មានការកត់សំគាល់ខុស ដោយមានយោបល់ថា និព្វានជាអវិជ្ជមានធម៌ជាធម៌សូន[១] សោះ ឬជាធម៌សូនខ្លួនឯងដូច្នេះទៅវិញ។

តាមការណ៍ពិត, **«និព្វាន»** មិនមែនសូនខ្លួនឯងទេ ដូចនេះព្រោះអ្វី? ព្រោះនិព្វានមិនមានខ្លួនឯង មិនមានកំណើត....សម្រាប់ធ្វើឲ្យកើតឲ្យសូនទេ ប្រសិនបើមានការសម្រាប់ធ្វើឲ្យអស់កើតឬឲ្យសូននោះ គឺអស់កំណើតមនុស្សសត្វ សូនអស់រាគៈ ទោសៈ មោហៈ ឯណោះទៅវិញទេ។

ជាការមិនមានហេតុផលត្រឹមត្រូវទេ ដែលយើងនាំគ្នានិយាយថា និព្វានជាអវិជ្ជមានឬជាវិជ្ជមាន។ សេចក្តីកត់សំគាល់ឬពាក្យនិយាយថា វិជ្ជមានឬអវិជ្ជមាននោះគ្រាន់តែជាសំដី ជាការកត់សំគាល់តែទៅលើរបស់ទាំងឡាយ នោះដែលមាននៅក្នុងលោកនេះប៉ុណ្ណោះ ពុំអាចនឹងយកទៅប្រើសម្រាប់ឲ្យយល់ន័យ យល់សេចក្តីថា និព្វានបានឡើយ ដូចនេះព្រោះអ្វី? ព្រោះនិព្វានជាធម៌មានកំពស់មានជម្រៅហួសផុតអំពីសភាវធម៌ទាំងអស់ ដែលមាននៅក្នុងលោក គឺជាធម៌ដែលព្រះអរិយបុគ្គលគប្បីត្រាស់ដឹងដោយលោកុត្តរបញ្ញារបស់ខ្លួន។ ដូច្នេះ, យោបល់ថា និព្វានមិនមាននិងយោបល់ថានិព្វានមាននោះ ជាយោបល់

---

(១) "សូន" ប្រើជាពាក្យខ្មែរ។ "សូន្យ" ប្រើតាមពាក្យបាលី ឬសំស្ក្រឹត។ "សូន" ពាក្យនេះជាគុណ បើនាម "សំនូន" តែសូន្យនេះពុំអាចចេញទៅជា "សំនូន" បានទេ។



www.elibraryofcambodia.org

ដែលគេមិនត្រូវបញ្ចេញមុន ដែលខ្លួនបានសម្រេចនិព្វានទេ ព្រោះនិព្វានគេត្រូវស្គាល់បាន ក្នុងពេលដែលខ្លួនគេបានដល់ដោយដើរតាមមគ្គ៨ ប្រការ ដូចជាមនុស្សយើងដែលបានស្គាល់ស្ករច្បាស់លាស់ ក្នុងពេលដែលបានយកវត្ថុធាតុនោះមកដាក់លើអណ្តាតរបស់ខ្លួន។ តែប្រសិនបើយើងចង់បញ្ចេញយោបល់ថានិព្វានមាន-មិនមាននោះ យើងត្រូវតម្កល់យោបល់របស់យើងឲ្យនៅក្នុងព្រំដែនគឺនិព្វានមានអ្វីដែលត្រូវមាន ព្រោះព្រះសម្មាសម្ពុទ្ធព្រះអង្គមិនទ្រង់ដែលទេសនាថា និព្វានជាធម្មធាតុមិនមានអ្វីសោះឡើយ ជាមួយគ្នានេះ ព្រះអង្គទ្រង់ទេសនាថា និព្វានជាធម្មជាតុរលត់ដោយមិនមានសេសសល់ តែសេចក្តីរលត់នេះ ក៏រលត់តែរបស់ណាដែលត្រូវរលត់ប៉ុណ្ណោះឯង។

ព្រះពុទ្ធត្រាស់ជាមួយនឹងព្រាហ្មណ៍ឈ្មោះបុក្កុសាតិ ហើយក្រោយមកគេបានយកមករៀបចំឲ្យមានរបៀបនៅក្នុងព្រះសូត្រមានសេចក្តីថា ៖

ភិក្ខុទាំងឡាយ! រូបកាយមនុស្សប្រកបដោយធាតុ៦ប្រការគឺ: **បឋវីធាតុ, អាបោធាតុ, តេជោធាតុ, វាយោធាតុ, វិញ្ញាណធាតុ,** និង**អាកាសធាតុ**។

ក្នុងបណ្តាធាតុទាំងឡាយនេះ បើចែករំលែកឲ្យល្អិតល្អន់ទៅ មិនឃើញមានធាតុអ្វីនៅសល់ទេ មានតែវិញ្ញាណធាតុមួយតែប៉ុណ្ណោះដែលជាធាតុអាស្រ័យនៅ។ បុគ្គលកាលបើបានពិចារណាឲ្យឃើញភាពពិតតាមសភាវពិតដោយបញ្ញាថ្នាក់ខ្ពស់។ សេចក្តីពិចារណាដោយបញ្ញាដ៏ប្រសើរនេះរបស់គេ នឹងឃើញតាមសេចក្តីពិតថា នុ៎ះមិនមែនជារបស់អាត្មាអញទេ នុ៎ះមិនមែនជាអត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អត្មាអញទេ។ ក្រៅអំពីនេះ, ដំណឹងទាំងឡាយ ដែលគេកំណត់សំគាល់ថាជាសុខខ្លះ, ទុក្ខខ្លះ មិនមែនជាសុខ, ជាទុក្ខខ្លះ គឺគេដឹងដោយអាស្រ័យវិញ្ញាណនោះឯង។

ភិក្ខុទាំងឡាយ! ប្រៀបដូចជាកំដៅដែលអ្នកទាំងឡាយបានប៉ះពាល់សព្វថ្ងៃនេះ បើកំដៅមាន ភ្លើងក៏មានដោយការពួតការបង្កាត់ដែលធ្វើឡើងដោយមនុស្សឬដោយធម្មជាតិ បើកំដៅដែលកើតមានឡើងដោយគ្រឿងពួត, គ្រឿង



www.elibraryofcambodia.org

បង្កាត់នេះរលត់ទៅវិញ, ស្ងប់បាត់ទៅវិញព្រោះតែមិនមានការពួតបង្កាត់ ដែលធ្វើឡើងដោយមនុស្សឬដោយធម្មជាតិនោះ សេចក្ដីនេះមានឧមាយ៉ាងណា។

ភិក្ខុទាំងឡាយ! សុខវេទនាដែលកើតឡើង ព្រោះអាស្រ័យជាមួយនឹងផស្សៈ ដែលជាហេតុនៃសុខវេទនា បុគ្គលកាលណាបានដឹងនូវសុខវេទនា គឺដឹងថាអត្មាអញមានសុខវេទនា ហើយសុខវេទនានោះរលត់ទៅវិញព្រោះរលត់នៃផស្សៈ ដែលជាហេតុនៃសុខនោះ ក៏មានឧបមេយ្យយ៉ាងនោះឯង។

ភិក្ខុទាំងឡាយ! ប្រៀបដូចជាជាងមាស ដែលជាអ្នកប៉ិនប្រសប់ខាងដុតមាស, លុះគេដុតមាសនោះមានកំដៅដល់កម្រិតហើយ គេក៏យកមាសផ្ទិននោះទៅដំធ្វើជាគ្រឿងលង្ការផ្សេងៗ តាមសេចក្ដីត្រូវការរបស់គេ សេចក្ដីនេះមានឧបមាយ៉ាងណា។

ភិក្ខុទាំងឡាយ! ឧបេក្ខាចិត្ត ដែលកើតឡើងនៅក្នុងលក្ខណ្ឌនៃសេចក្ដីបរិសុទ្ធផូរផង់, ជាធម្មជាតិមានភាពទន់គួរដល់មុខងារ, ហើយបុគ្គលបានបង្អោនឧបេក្ខាចិត្តនេះទៅកាន់អាកាសានញ្ចាយតនជ្ឈាន, វិញ្ញាណញ្ចាយតនជ្ឈាន, អាកិញ្ចញ្ញាយតនជ្ឈាន, នេវសញ្ញានាសញ្ញាយតនជ្ឈាន។ កាលណាបុគ្គលបានអរូបជ្ឈានទាំង ៤ នេះហើយ, ឈាននោះក៏នៅជាសង្ខតជ្ឈាន បុគ្គលនោះឈប់លែងតាក់តែង លែងរំពឹងត្រិះរិះដើម្បីចម្រើន ឬមិនចម្រើនទៀតហើយ លែងប្រកាន់យកនូវរបស់អ្វីមួយក្នុងលោកនេះទៀតហើយ ចិត្តរបស់គេក៏មិនមានសេចក្ដីតក់ស្លុត គេរំលត់កិលេសទាំងឡាយបានដោយអស់ជើងហើយ គេដឹងច្បាស់ថា ខ្លួនគេមានជាតិអស់ហើយ មានព្រហ្មចរិយធម៌បានប្រព្រឹត្តចប់ហើយ មានសោឡសកិច្ចបានធ្វើស្រេចអស់ហើយ កិច្ចដទៃទៀតដែលខ្លួនត្រូវធ្វើពុំមានទៀតឡើយ។ កាលណាគេបានទទួលសុខវេទនា, ទុក្ខវេទនា, អសុខមទុក្ខវេទនា គេក៏ដឹងច្បាស់ថា វេទនាទាំងឡាយនេះមិនមានសេចក្ដីទៀងទាត់ មិនគួរបើនឹងធ្វើចិត្តឲ្យជាប់ជំពាក់ឡើយ មិនគួរនឹងអាក់អន់ មិនគួរនឹងត្រេកអរឡើយ ដូចនេះហើយចិត្តរបស់គេក៏មាន សេចក្ដីនឿយណាយអស់កាលជានិច្ច។



www.elibraryofcambodia.org

កាលណាគេបានវេទនាត្រឹមតែផ្លូវកាយ គេក៏ដឹងថា អាត្មាអញបានទទួលវេទនាត្រឹមតែផ្លូវកាយ បើបានទទួលវេទនាត្រឹមតែដោយជីវិត ក៏ដឹងច្បាស់ថា អាត្មាអញបានទទួលវេទនាត្រឹមតែដោយជីវិត។ គេដឹងទៀតថា កាលណាបើរាងកាយបែកធ្លាយទៅ បន្ទាប់អំពីការអស់ទៅនៃជីវិតនោះ វេទនាទាំងឡាយ ដែលអាត្មាអញមិនគួរនឹងត្រេកអរក្នុងលោកនេះនឹងរលត់សោះសូនទៅឥតមានសេសសល់ឡើយ។ ដូចនេះចិត្តរបស់អ្នកពិចារណាធម៌, ក៏មានសភាពគួរដល់អរិយមគ្គអរិយផលយ៉ាងនោះដែរ។

ភិក្ខុទាំងឡាយ! ទុក្ខនិរោធនេះ មានសេចក្ដីប្រៀបធៀបដូចប្រទីប ដែលឆេះចេញជាអណ្ដាតភ្លើងដោយអាស្រ័យគ្រឿងផ្សំទាំងឡាយមានប្រេងនិងប្រឆេះជាដើម។ កាលណាបើអណ្ដាតភ្លើងនៃប្រទីបខ្វះគ្រឿងផ្សំ វាតែងតែរលត់បាត់ទៅ ព្រោះអស់ប្រេង, អស់ប្រឆេះ, ដែលជាគ្រឿងធ្វើឲ្យប្រទីបឆេះ ហើយមិនមានការបន្ថែមនូវវត្ថុធាតុទាំឡាយនេះមកទៀត សេចក្ដីនេះមានឧបមាយ៉ាងណា។

ភិក្ខុទាំងឡាយ! កាលបើបុគ្គលបានទទួលនូវវេទនាត្រឹមតែតាមផ្លូវកាយ ត្រឹមតែតាមផ្លូវជីវិត ឯវេទនាទាំងឡាយដែលគេមិនគួរនឹងត្រេកអរក្នុងលោកនេះនឹងជាភាពរលត់អស់ទៅពុំមានសេសសល់ឡើយ សភាពនៃសោកុត្តរចិត្ត ខាងក្រោយបែកធ្លាយនៃខន្ធបញ្ចកៈ មានឧបមេយ្យយ៉ាងនោះឯង។

ភិក្ខុទាំងឡាយ! បុគ្គលដែលមានចិត្តប្រកបដោយគុណធម៌ដូចពោលមកនេះ ឈ្មោះថាជាបុគ្គលមានគុណធម៌ប្រកបដោយសេចក្ដីចេះដឹងដោយឧត្តម នៅក្នុងថ្នាក់ជាបញ្ញាធិដ្ឋាន។

ភិក្ខុទាំងឡាយ! ដោយសេចក្ដីចេះដឹងក្នុងធម៌ថ្នាក់ខ្ពស់ជាថ្នាក់អរហត្តផល ជាទីអស់ទៅនៃទុក្ខទាំងឡាយទាំងពួងណា ការចេះដឹងនោះហើយដែលអញតថាគតឲ្យឈ្មោះថា បុគ្គលមានបញ្ញាប្រសើរបំផុត។ វិមុត្តិរបស់បុគ្គលនោះក៏ជាវិមុត្តិតាំងនៅក្នុងសច្ចៈ គឺជាវិមុត្តអស់មានសេចក្ដីកម្រើក។



www.elibraryofcambodia.org

ភិក្ខុទាំងឡាយ! បុគ្គលទាំងឡាយដូចបានពោលមកនេះ គេបានគាស់រំលើងរស់រលីង ហើយនូវឧបធិទាំងឡាយគឺ ខន្ធ, កិលេស, អភិសង្ខារ និងបញ្ចកាមគុណ។ ធម៌ទាំងឡាយ គឺឆន្ទរាគៈ ព្យាបាទៈ អវិជ្ជា មោហៈ។ល។ ក៏បុគ្គលនោះបានគាស់រំលើងចោល ហើយធ្វើឲ្យនៅសល់តែទីនៅឥតមានចលនាប្រៀបបាននឹងដើមត្នោតកំបុតចុង មានសភាពមិនដុះដើមជាថ្មីទៀត។ សេចក្ដីសម្គាល់, សេចក្ដីប្រែប្រួល, សេចក្ដីវិលវល់, មិនកើតមាន, មិនប្រព្រឹត្តទៅក្នុងបុគ្គលដែលឋិតនៅក្នុងអធិដ្ឋានធម៌បែបនេះទេ បើអស់មានសេចក្ដីសំគាល់, សេចក្ដីប្រែប្រួល, សេចក្ដីវិលវល់ បុគ្គលនោះក៏មានឈ្មោះថា ជាមុនី ប្រែថា បុគ្គលមានចិត្តស្ងប់, មានចិត្តដឹងស្គាល់នូវភាពស្ងប់ តាមសេចក្ដីពិត។

ភិក្ខុទាំងឡាយ! បុគ្គលដែលមានសេចក្ដីកត់សំគាល់កន្លងបង់អស់ហើយនោះ គេទាំងឡាយក៏បានជាមុនី មានចិត្តស្ងប់ស្ងាត់ មិនមានកំណើត មិនមានចំណាស់ មិនមានសម្លាប់ (សេចក្ដីស្លាប់) មិនមានសេចក្ដីញាប់ញ័រ មិនមានសេចក្ដីកម្រើក។ បើមិនមានសេចក្ដីកើត, សេចក្ដីចាស់, សេចក្ដីឈឺ, សេចក្ដីស្លាប់, សេចក្ដីញាប់ញ័រ, សេចក្ដីកម្រើក ក៏មិនដឹងជាបានទុក្ខមកអំពីណាទៀតទេ។

ភិក្ខុទាំងឡាយ! ចូរអ្នកចងចាំទុកកុំភ្លេច នូវចំណែកនៃធាតុទាំងឡាយ ៦ យ៉ាង ដែលយើងនឹងប្រាប់អ្នកតទៅដោយសេចក្ដីសង្ខេប។ កាលណាបើអ្នកធ្វើនិទស្សន៍ឃើញថា សុខវេទនា ទុក្ខវេទនា អសុខមទុក្ខវេទនាជាសភាវធម៌មានសេចក្ដីប្រែប្រួល, មិនមានសេចក្ដីទៀតទាត់។ សុខ, ទុក្ខ, អសុខមទុក្ខ នេះជាភាពមិនមានជាប់ទាក់ទង ដោយវេទនាទាំងឡាយទេ ប្រែថា ជាធម៌រួចផុតស្រឡះចាកវេទនាទាំងអស់ហើយនោះ។ អ្នកទាំងឡាយនឹងបានដឹងច្បាស់ថា វេទនានោះមានសេចក្ដីរលត់ទៅព្រមជាមួយនឹងកាយ ដូចជាអណ្ដាតប្រទីបរលត់ទៅព្រមមួយអន្លើ ដោយការអស់ទៅនៃប្រេងនិងប្រឆេះដូច្នោះឯង។

ពំនោលខាងលើនេះ បានសេចក្ដីសង្ខេបថា មនុស្សសត្វទាំងឡាយ មាន



www.elibraryofcambodia.org

ធាតុ ៦ ប្រការគឺ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ អាកាសធាតុ និងវិញ្ញាណធាតុ។ យោគាវចរ កាលណាបានធ្វើការវែកញែកធាតុទាំងឡាយនេះមើលហើយ, នឹងឃើញច្បាស់ថា នុ៎ះមិនមែនអញ នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាខ្លួនប្រាណរបស់អញ ហើយនិងដឹងតទៅទៀតថា វិញ្ញាណកើតមានឡើងដូចម្តេច, រលត់ទៅវិញដូចម្តេច, សុខវេទនា ទុក្ខវេទនា អសុខមទុក្ខវេទនា មានការកើតឡើងដូចម្តេច មានការរលត់ទៅវិញដូចម្តេច។ ដោយអាស្រ័យការដឹងច្បាស់នេះ ចិត្តនឹងរួចផុតស្រឡះចាកអ្វីៗទាំងអស់ ហើយយោគាវចរ ក៏បានដល់នូវឧបេក្ខាចិត្តបរិសុទ្ធផូរផង់ ជាចិត្តគួរដល់ការងារ ជាចិត្តមានពន្លឺភ្លឺថ្លា ទើបបង្អោនឧបេក្ខាចិត្តនេះទៅកាន់សមាធិដែលកំពុងចម្រើន ដើម្បីឲ្យសម្រេចនូវឈានជាន់ខ្ពស់តទៅទៀត។ ក្នុងពេលនោះគេបានដឹងថា ឧបេក្ខាចិត្តនេះឋិតនៅអស់កាលយ៉ាងយូរ ហើយក្នុងពេលនោះគេក៏រំពឹងគិតក្នុងចិត្តថា :

១- បើអាត្មាអញទាញតម្រង់ឧបេក្ខាចិត្តដ៏បរិសុទ្ធភ្លឺថ្លានេះ ទៅកាន់អាកាស ហើយចំរើនអាកាសានញ្ចាយតនជ្ឈាន គឺធ្វើចិត្តរបស់អាត្មាឲ្យប្រព្រឹត្តទៅតាមឈាននេះ ( លទ្ធផលនឹងដឹងថា ) ភាពនេះជារបស់តាក់តែងឡើងតាមផ្លូវចិត្ត ជាសង្ខតធម៌មិនមែនជានិព្វាន... ទេ;

២-អាត្មាអញទាញតម្រង់ឧបេក្ខាចិត្តដ៏បរិសុទ្ធភ្លឺថ្លានេះ ទៅកាន់វិញ្ញាណ ហើយចម្រើនវិញ្ញាណញ្ចាយតនជ្ឈាន គឺធ្វើចិត្តឲ្យប្រព្រឹត្តទៅក្នុងឈាននេះរឿយៗ ( លទ្ធផលនឹងដឹងថា ) នេះក៏ជារបស់មួយតាក់តែងឡើងដោយចិត្ត ជាសង្ខតធម៌ មិនមែនជាសច្ចធម៌ មិនមែនជានិព្វាន... ទេ;

៣- បើអាត្មាអញដាក់តម្រង់ឧបេក្ខាចិត្តដ៏បរិសុទ្ធភ្លឺថ្លា ទៅកាន់ភាពបន្តិចបន្តួចស្ទើរតែគ្មានអ្វីសោះ ពិតៗ នឹងភាពទទេ ហើយចម្រើនអាកិញ្ចញ្ញាយតនជ្ឈាន គឺធ្វើចិត្តឲ្យត្រាច់ទៅក្នុងឈាននេះរឿយៗ ( លទ្ធផលនឹងដឹងច្បាស់ថា ) នេះក៏ជារបស់តាក់តែងឡើងដោយចិត្ត ជាសង្ខតធម៌ មិនមែនជាសច្ចធម៌



www.elibraryofcambodia.org

មិនមែនជានិព្វាន...ទេ;

៤- បើអាត្មាអញឃិតតម្រង់ឧបេក្ខាចិត្តដ៏បរិសុទ្ធមានពន្លឺថ្លាស្អាតទៅកាន់ភាពមួយថា មានក៏មិនមែន ថាមិនមានក៏មិនមែន បានដល់ភាពកត់សម្គាល់យ៉ាងល្អិតបំផុត រកប្រៀបប្រដូចទៅនឹងអ្វីៗពុំបាន ហើយចំរើននេវសញ្ញានាសញ្ញាយតនជ្ឈាន គឺធ្វើឲ្យចិត្តរបស់ខ្លួនជ្រកនៅក្នុងឈាននេះអស់កាលជានិច្ច (លទ្ធផលគង់នឹងដឹងថា) នេះក៏ជារបស់មួយទៀត ដែលតាក់តែងដោយចិត្តជាសង្ខតធម៌ មិនមែនសច្ចធម៌ មិនមែននិព្វាន... ទេ។

ក្នុងលំដាប់នេះ យោគាវចរពុំបានយកចិត្តរបស់ខ្លួនទៅបង្កើតជាអ្វីៗមិនបន្តឲ្យមានកំណើតថ្មីទៀត មិនធ្វើឲ្យចិត្តវិលមកកាន់ភពឬវិភវភព។ បើយោគាវចរណាមានចិត្តបែបនេះហើយ យោគាវចរនោះ នឹងមិនកោះថ្កក់ មិនជក់ញៀននឹងអ្វីៗទាំងអស់ក្នុងលោកទាំងឡាយ។

បើមិនមានចិត្តកោះថ្កក់. មិនមែនចិត្តជក់ញៀន យោគាវចរនោះក៏អស់មានសេចក្តីកង្វល់ បើមិនមានសេចក្តីកង្វល់ សេចក្តីស្ងប់ស្ងាត់ សេចក្តីសូនឈឹងនូវអ្វីៗដែលជាបច្ច័យនៃទុក្ខក៏កើតឡើងព្រមគ្នាក្នុងពេលនោះ។ ក្នុងទីបំផុតនៃការប្រតិបត្តិធម៌ យោគាវចរទាំងឡាយ ក៏បានដឹងច្បាស់ថា កំណើតនៃអាត្មាអញអស់ហើយ ព្រហ្មចរិយធម៌អញបានប្រព្រឹត្តចប់ហើយ កិច្ចទាំងឡាយដែលអញត្រូវធ្វើបានធ្វើស្រេចអស់ហើយ កិច្ចអ្វីដទៃទៀតដែលអញត្រូវធ្វើដើម្បីប្រយោជន៍ដូចនេះមិនមានទៀតឡើយ។

ដូចនេះ, បុគ្គលទាំងឡាយណាដែលបានធ្វើសមាបត្តិនេះឲ្យកើតក្នុងសន្តាននៃខ្លួន បុគ្គលទាំងឡាយនោះឈ្មោះថា ជាអ្នកបានប្រកបដោយធម៌ដ៏ប្រសើរ ឈ្មោះថាបានដឹងច្បាស់នូវការរលត់ទុក្ខ ដែលពុទ្ធសាសនាហៅថា «**ទុក្ខនិរោធ**» ឬ «**និព្វាន**» ។

ការរួចផុតស្រឡះចាកអ្វីៗទាំងអស់ ឬការបានសម្រេចមោក្ខធម៌ ដែលមានសច្ចធម៌ជាគ្រឹះនេះ មិនមានសេចក្តីកម្រើកញាប់ញ័រទេ សេចក្តីនេះ អ្នក



www.elibraryofcambodia.org

អានគប្បីដឹងតាមពុទ្ធភាសិតថា :

ភិក្ខុទាំងឡាយ! អ្វីដែលមិនពិតប្រាកដ យើងឲ្យឈ្មោះថា មោសធម៌ ជាធម៌ខុស អ្វីដែលពិតប្រាកដយើងឲ្យឈ្មោះថា អមោសធម៌ប្រែថា ធម៌ត្រូវឬធម៌ពិត គឺជានិព្វានហ្នឹងឯង។

ភាសិតនៃពុទ្ធសាសនា, យើងបានឃើញស្ទើរតែគ្រប់កន្លែងថា ព្រះសម្មាសម្ពុទ្ធទ្រង់តែងតែលើកយកសច្ចធម៌នេះ ទៅធ្វើជាឈ្មោះនៃនិព្វាន ដោយទ្រង់មានព្រះតម្រាស់ថា: «តថាគតប្រាប់អ្នកទាំងឡាយរឿយៗថា សច្ចៈនិងមគ្គៈ ធម៌ទាំងពីរនេះជាធម៌នាំទៅកាន់ធម៌ ដែលហៅថា «អរិយសច្ច» សច្ចត្រង់នេះ តាមពុទ្ធបំណងសំដៅយក «និព្វាន» ។

អ្វីជាសច្ចៈ? បញ្ហានេះ ពុទ្ធសាសនានោះលោកបានធ្វើសេចក្តីបំភ្លឺថា នៅក្នុងលោកយើងនេះ មិនមានអ្វីជារបស់ពិតតាមគំនិតដែលគេដៅស្មាននោះទេព្រោះថា អ្វីៗទាំងអស់សុទ្ធតែជាសង្ខតធម៌ ជាធម៌កើតមានឡើងដោយគ្រឿងផ្សំ របស់ណាកើតឡើងដោយគ្រឿងផ្សំ របស់នោះមិនមែនជាមិនចេះប្រែប្រួល មិនចេះផ្លាស់ប្តូរ ព្រមទាំងមិនមានអ្វីជាខ្លឹមសារពិតប្រាកដ ដែលតាំងនៅក្នុងភាពមិនចេះប្រែប្រួល ដែលមានភាពជានិច្ច ដូចជាពាក្យដែលគេនាំគ្នាសន្មតថា «ខ្លួនឯង» «ព្រលឹង» ឬ «អាត្មន» ដែលជារបស់មាននៅក្នុងខ្លួនយើង ឬក្រៅខ្លួនយើងនោះទេ។ អ្វីៗទាំងអស់ វាពិតជាត្រូវប្រែប្រួលតាមកាលតាមសម័យឬតាមហេតុតាមបច្ច័យ និងតាមសភាវធម៌ដែលតែងមានជាធម្មតា។ សេចក្តីពិតនេះ, ជាសេចក្តីពិតដែលគេមើលឃើញដោយបញ្ញាជាន់ខ្ពស់ ទើបលោកឲ្យឈ្មោះថា «អរិយសច្ចៈ»។ អរិយសច្ចនេះ មិនមែនជាមិនមានទេ។ ដើម្បីលុះសច្ចៈដ៏ប្រសើរខ្ពង់ខ្ពស់នេះ មនុស្សទាំងឡាយត្រូវតែដឹងនូវសេចក្តីពិតឲ្យបានច្បាស់លាស់ ត្រូវតែខំព្យាយាមធ្វើឲ្យខ្លួនបានចាក់ធ្លុះនូវអ្វីៗដែលពិតដែលមែនទៅតាមសភាវៈពិត ឬសេចក្តីពិតរបស់ធម្មជាតិ ប្រកបដោយបញ្ញាពិសេសដែលលោកឲ្យឈ្មោះថា វិបស្សនាបញ្ញា មិនមែនប្រកបដោយមោហៈឬ



www.elibraryofcambodia.org

អវិជ្ជាយ៉ាងគ្រោតគ្រាតឬយ៉ាងល្អិត បានដល់ការរលត់អស់រលីងនូវតណ្ហា និងការរលត់ដោយមិនមានសេសសល់នូវទុក្ខទាំងឡាយ ដែលពុទ្ធសាសនាហៅថា "ទុក្ខនិរោធ"។ នេះឯងឈ្មោះថា "និព្វាន"។

ន័យមួយវិញទៀត, ពុទ្ធសាសនិកមិនគួរនឹងមានយោបល់ថា និព្វានជាលទ្ធផលនៃសង្ខតធម៌, ជាធម៌តាក់តែងឡើងឬផ្សំផ្គុំឡើងដោយអ្វីៗនោះទេ។ ដូចនេះព្រោះអ្វី? ព្រោះនិព្វាននឹងសង្គ្រោះចូលក្នុងធម៌ជាហេតុក៏មិនមែន និងសង្គ្រោះក្នុងធម៌ជាផលក៏មិនមែន តែយោបល់ថា សីល, សមាធិ, បញ្ញា ឬសេចក្ដីប្រតិបត្តិធម៌ជាហេតុឲ្យបានសម្រេចនិព្វាននោះ យោបល់នេះមិនខុសទេ ព្រោះទំរើទាំងអស់នេះវាជាហេតុនៃសេចក្ដីសម្រេច ដែលយើងទម្លាប់និយាយថា ជាផលនោះមែន។ "និព្វាន" មិនមានហេតុ មិនមានផល នៅក្នុងខ្លួនឯងទេ ដោយហេតុថា សច្ចធម៌ទាំងឡាយក៏មិនមានលទ្ធផលឬមិនមានអ្វីទេ។ និព្វានមិនបានផលិតចេញនូវវត្ថុជាតុដ៏មានអាថ៌កំបាំង ដូចជាឈានឬសមាធិជាដើមទេ។ សច្ចធម៌វាមានសេចក្ដីពិតនៅជាសច្ចធម៌ និព្វានវាមានសេចក្ដីពិតនៅនិព្វាន វាមិនមានការប្រែប្រួលផ្លាស់ប្ដូរអ្វីទេ។ ការដែលគួរធ្វើគឺខំព្យាយាម ប្រព្រឹត្តយ៉ាងណាឲ្យឃើញនិព្វាន ហើយបានសម្រេចនូវនិព្វានប៉ុណ្ណោះ, ព្រមជាមួយនេះ កុំសន្និដ្ឋានថា និព្វានគឺជាលទ្ធផលនៃមាគ៌ាទាំងឡាយ ដែលខ្លួនបានដើរនោះឡើយ ព្រោះអ្វី? ព្រោះនិព្វានជាអសង្ខតធាតុមិនត្រូវបានសម្រេចដោយសង្ខតធាតុឡើយ។ មនុស្សទាំងឡាយគេឡើងទៅដល់កំពូលភ្នំខ្ពស់ៗដោយអាស្រ័យផ្លូវ ប៉ុន្តែកំពូលភ្នំមិនមែនជាលទ្ធផល ឬមិនមែនជាផលនៃផ្លូវនោះទេ។ គេអាចមើលពន្លឺភ្លើងឃើញបាន ប៉ុន្តែភ្លើងក៏មិនមែនជាលទ្ធផល របស់ភ្នែកឡើយ។

មានសំនួរមួយដែលកើតមានជារឿយៗ ក្នុងចំណោមពុទ្ធសាសនិកថា នៅខាងក្រោយនៃការបរិនិព្វានរបស់ព្រះអរហន្តទាំងឡាយមាននៅសល់អ្វីខ្លះទេ? សំនួរនេះ មិនគួរនឹងលើកយកមកចោទទេ ព្រោះនិព្វានជាសច្ចធម៌, ជាអវសាន, ជាធម៌ទីបំផុត; ជាធម៌ចុងចប់ទៅហើយ។ ជាធម្មតា របស់ណាដែល



www.elibraryofcambodia.org

គេទុកជាទីបំផុត គេទុកជាចុងចប់របស់នោះមិនមានអ្វីនៅខាងក្រោយទៀតទេ ប្រសិនណាបើមានអ្វីនៅពីក្រោយទៀត អ្វីនោះក៏គឺសច្ចធម៌ជាអវសាន មិនមែនជានិព្វានទេ។ សេចក្ដីក្នុងចំណុចត្រង់នេះ មានសំនួររបស់ភិក្ខុឈ្មោះរាធៈ ដែលលោកបានធ្វើចំពោះព្រះសម្មាសម្ពុទ្ធដូចមានតទៅនេះ ៖

«សូមទ្រង់មេត្តាប្រោស! និព្វានមានអ្វីជាប្រយោជន៍, មានទីបំផុតដូចម្ដេច ?»

សំនួរក្នុងចំណុចនេះ គឺរាធភិក្ខុចង់ដឹងថាអ្វីទៅដែលមាននៅខាងក្រោយនោះ, ចង់ដឹងថា តើនិព្វានមានទីបំផុតដូចម្ដេច។ ចំពោះសំនួរនេះ ព្រះសម្មាសម្ពុទ្ធទ្រង់មានចម្លើយថា :

«នែរាធ! បញ្ហានេះមិនគួរអ្នកកាន់យកទុកជាបញ្ហានៅក្នុងព្រំដែនទេ គឺជាបញ្ហានៅហួសព្រំដែន»។ នែរាធ! ព្រោះអ្វី? ព្រោះថាការប្រព្រឹត្តព្រហ្មចរិយធម៌របស់អ្នក មាននិព្វានជាទីបំផុតទៅហើយ។

## ការចូលនិព្វាន

មានពុទ្ធសាសនិកជាច្រើនណាស់ដែរ ដែលចូលចិត្តនិយាយថា «**ព្រះពុទ្ធចូលនិព្វាន**» ឬ «**ព្រះអរហំចូលនិព្វាន**» ពាក្យនេះក៏មិនឃើញជាខុសធំដុំអ្វីទេ ប៉ុន្តែពាក្យនេះមានន័យលំបាកនឹងស្ដាប់ឲ្យចូលចិត្តពន់ពេកណាស់។ ដូចនេះព្រោះអ្វី? ព្រោះនិព្វានគេស្គាល់គ្រប់គ្នាថា ជាអសង្ខតធម៌ ជាធម៌មិនមានអ្វីៗទាំងអស់ ជាពិសេសគឺមិនមានបច្ច័យតាក់តែង ប្រែថា មិនមានរបស់អ្វីសម្រាប់ទទួលអ្នកចូល។ កាលណាយើងនិយាយថា «**ចូល**» ពាក្យចូលនេះគេអាចកត់សំគាល់បានថា និព្វាននៅមាន «រូប» ឬនៅមាន «អ្វីមួយ» សម្រាប់ឲ្យគេ «ចូល» ឬថាមានលំនៅសម្រាប់ឲ្យគេ «នៅ» ដូចនេះពាក្យចូលនេះ នឹងនាំឲ្យមនុស្សយើង មានមនោគតិចំពោះនិព្វាននោះថា និព្វានជានគរមួយ, ជារដ្ឋ



www.elibraryofcambodia.org

មួយ, ជាអាណាចក្រមួយ, ជាប្រទេសមួយ, ជាភពមួយ, ជាឋានមួយ។ល។ សម្រាប់ជាទីទទួល ជាទីនៅរបស់អ្នកដំណើរឬអ្នកចូល។ មិនតែប៉ុណ្ណោះ សំដីនេះអាចធ្វើយើងទាំងឡាយឲ្យមានការស្រាវជ្រាវមនោគតិរបស់ខ្លួនថា: រដ្ឋ, នគរ, ប្រទេស, អាណាចក្រ, ភព, ឋាន។ល។ របស់នោះមានទ្រង់ទ្រាយដូចម្តេច មានលក្ខណៈយ៉ាងណា របស់ទាំងឡាយដែលមានទាំងនិព្វានរួមផងនោះ វាមានលក្ខណៈបែបភាពគ្រប់យ៉ាងដូចគ្នានឹងរបស់ទាំងឡាយ ដែលមាននៅក្នុងលោកយើងនេះដែរឬទេ? ចំពោះបញ្ហានេះមិនមានក្នុងគម្ពីរពុទ្ធសាសនាយើងទេ ប្រសិនបើមានខ្លះ ក៏គ្រាន់តែជាពាក្យឧបមាដូចជាលោកយកធម៌នេះទុកជាធម៌នោះ យកធម៌នោះទុកជានេះនៃនិព្វាន ឧទាហរណ៍យកសីលធ្វើជាកំពែង; យកផលនៃបញ្ញាធ្វើជាក្លោងទ្វារ យកផលនៃសមាធិធ្វើជាសើន យកផលនៃមេត្តាធម៌ធ្វើជាស្នាមក្លោះ យកផលនៃកម្មដ្ឋានធ្វើជាផ្លូវថ្នល់ យកផលនៃពោធិបក្ខិយធម៌ធ្វើជាផ្សារលក់ដូរ, យកផលនៃព្រះអភិធម្ម៧គម្ពីរធ្វើជាប្រាសាទកែវមានជាន់ ៧, នេក្ខម្មៈជាទីដំណេក វិមុត្តិញ្ញាណជាបល្ល័ង្ក វិមុត្តិញ្ញាណទស្សនៈជាប្រទីប។ល។ ក្នុងគម្ពីរពុទ្ធសាសនារបស់យើង លោកបានប្រើពាក្យថា «**បរិនិព្វុតោ**» ពាក្យនេះលោកនិយាយទៅលើការបរិនិព្វានរបស់ព្រះសម្ពុទ្ធ និងព្រះអរហន្តទាំងឡាយ ដែលយើងត្រូវបកស្រាយពាក្យនេះថា ព្រះសម្ពុទ្ធឬព្រះអរហន្តទាំងឡាយ ដែលសម្រេចនិព្វាន បានចាក់ធ្លុះនិព្វាន បានលុះនិព្វាន មិនមែនត្រូវបកស្រាយថា: «ចូលទៅនៅក្នុងនិព្វាន» ឬ «ចូលទៅនៅក្នុងស្ថាននិព្វាន» ឬ «ចូលទៅកាន់ឋាននិព្វាន» តាមដូចអ្នកផងខ្លះយល់នោះឡើយ។ ដូចនេះព្រោះអ្វី? ព្រោះនិព្វានមិនមែនជាផ្ទះ ឬជាឋានសម្រាប់ទទួលអ្នកចូលទេ ទាំងព្រះសម្ពុទ្ធនិងព្រះអរហន្តទាំងឡាយ ក៏លោកបានរំលាយបោលនូវអ្វីៗទាំងអស់ដែលសម្រាប់កត់សម្គាល់តាមផ្លូវចេះដឹងនៃមនុស្សទាំងឡាយអស់រលីងទៅហើយ។ ពាក្យថា«**បរិនិព្វុតោ**» មានន័យត្រឹមតែថា : «រលត់អស់រលីងឥតមានសេសសល់» តែប៉ុណ្ណោះឯង ព្រោះថាព្រះសម្ពុទ្ធក្តី ព្រះអរហន្ត ទាំងឡាយ



www.elibraryofcambodia.org

ក្តី កាលណាតែនិព្វានហើយ លោកមិនត្រឡប់មកកើតទៀត ប្រែថា លោកមិនមានភពថ្មីទៀតទេ ខាងក្រោយការបែកធ្លាយនៃកាយរបស់លោកទៅហើយ។

នៅមានសំនួរមួយទៀត, ដែលគេចូលចិត្តសួរគ្នាជាញឹកញាប់ណាស់ដែរ សំនួរនោះមានសេចក្តីថាៈ «ចុះមានអ្វីខ្លះឬទេដែលត្រូវកើតមានដល់ព្រះសម្ពុទ្ធ និងព្រះអរហន្តទាំងឡាយខាងក្រោយបរិនិព្វានរបស់លោក? បញ្ហានេះរាប់ចូលក្នុងអព្យាកតបញ្ហា ជាបញ្ហាដែលព្រះសម្ពុទ្ធមិនទ្រង់ឆ្លើយ។ លុះត្រូវគេជជីកសួរដដែលៗព្រះអង្គទ្រង់ធ្វើសេចក្តីបញ្ជាក់ថា មិនមានភាសាមនុស្សលោកតែមួយម៉ាត់សម្រាប់និយាយដល់អ្វីៗដែលព្រះអរហន្តត្រូវមានក្នុងខាងក្រោយនៃការបរិនិព្វានរបស់លោកទេ។ មានចម្លើយមួយដែលព្រះអង្គទ្រង់ធ្វើចំពោះសំនួររបស់បរិព្វាជកឈ្មោះ វច្ឆគោត្រនោះ មានសេចក្តីដូចនេះថាៈ

សំដីថា «កើត» ឬ «មិនកើត» នេះនឹងយកទៅប្រើក្នុងរឿងរបស់ព្រះអរហន្តបរិនិព្វានមិនបានទេ ដូចនេះព្រោះអ្វី? ព្រោះពាក្យថា «រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ» និងពាក្យថា «កើត» «មិនកើត» ឬ «កើតទៀត» «មិនកើតទៀត» «នោះសុទ្ធតែជាសង្ខតធម៌, ជាធម៌ផ្សេងៗ; ធម៌ទាំងអស់នេះព្រះអរហន្តទាំងឡាយបានកំចាត់បង់ចោលអស់រលីងទៅហើយ បានគាស់រំលើងចោលទាំងអស់ ហើយមិនមានសេសសល់អ្វី ដែលអាចឲ្យយើងធ្វើសេចក្តីកត់សម្គាល់បាន នៅខាងក្រោយបរិនិព្វានរបស់លោកទៀតទេ។ សេចក្តីនេះ, ក្នុងគម្ពីរពុទ្ធសាសនា លោកប្រៀបថាដូចជាត្នោតកំបុតចុង, ដូចភ្លើងរលត់ដែលមិនមានដំណុះថ្មី មិនប្រាកដដោយពន្លឺក្នុងទីណាមួយទៀតឡើយ។

ពាក្យបំភ្លឺខាងលើនេះ មានសេចក្តីច្បាស់លាស់ល្មមយល់បានហើយ ប្រសិនបើយើងប្រើបញ្ញាត្រិះរិះឲ្យច្រើនបន្តិច ព្រោះអ្វី? ព្រោះថាធម្មជាតុទាំងឡាយដែលប្រៀបធៀបនឹងអណ្តាតភ្លើង ឬភ្លើងរលត់នោះ ធម្មជាតុនេះ វាមិនមែនជានិព្វានទេ គឺវាជារូបកាយរបស់មនុស្សសត្វដែលផ្សំផ្គុំគ្នាកើតទៅជា



www.elibraryofcambodia.org

ខន្ធបញ្ចកៈទេតើ ទើបកើតទៅជាមាននាមថា “សត្វ” “បុគ្គល” នោះ ហើយ របស់នេះឯងហើយ ដែលត្រូវរលត់តាមសភាវធម៌ធម្មតា។ ចំណែកនិព្វានមិនមានរលត់ មិនមានកើតទេ ព្រោះធម្មធាតុនេះមិនមានទីកើត មិនមានទីរលត់ គឺជារបស់មួយកើតមានឡើងអំពីកាលណា, មានមកអំពីកាលណា, នៅក្នុងទីណា, រលត់ឬមិនរលត់, រលត់ក្នុងពេលណា, ក្នុងទីណា មិនមានអ្នកណាម្នាក់ដឹងដល់ឡើយ សូម្បីព្រះសម្មាសម្ពុទ្ធដែលព្រះអង្គទ្រង់សម្បូណ៌បញ្ញា មានទំហំនិងជម្រៅរាស់មិនបាន ក៏ព្រះអង្គពុំទ្រង់ដែលនិយាយដល់និព្វានថាមានកំណើតមកអំពីកាលណា ដល់ពេលណាទើបធម្មធាតុនេះរលត់ទៅវិញឡើយ។ សេចក្ដីនេះយើងត្រូវបកស្រាយថា រំលត់ឬរលត់នោះ ពុំមែនរំលត់និងរលត់ខ្លួនឯងទេ គឺរំលត់ឬរលត់ធម៌ជាសត្រូវនឹងខ្លួននៃនិព្វាន បានដល់ភ្លើងទុក្ខ ភ្លើងកិលេស ឬបញ្ចក្ខន្ធហ្នឹងឯង។ ដូចនេះ ពាក្យថា ភ្លើងរលត់, ប្រទីបរលត់នោះ មិនមែនជាពាក្យព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រៀបឧបមាទៅលើនិព្វានទេ គឺព្រះអង្គទ្រង់ប្រៀបធៀបទៅលើធម៌ ដែលជាសត្រូវនឹងនិព្វាននោះវិញទេ។ ការណ៍ពិត, និព្វានមិនមែនត្រូវរលត់, ត្រូវឆេះដូចភ្លើង ដូចប្រទីបនោះសោះឡើយ ព្រោះ(១) ខ្លួននៃនិព្វាននោះ មិនមានកើត, មិនមានរលត់ដូចបាននិយាយមកហើយ។

## និព្វានមិនមានអ្វី

ចម្ងល់អំពីរឿងនិព្វានមិនទាន់ចប់ទេ មានសំនួរដែលលេចឮឡើងក្នុងចំណោមពុទ្ធសាសនិកខ្លះថា: “បើនិព្វានមិនមានអ្វីជាខ្លួនឯង, ជាអាត្មា, ជាអាត្មន, ជាវិញ្ញាណជាចិត្ត, ព្រលឹង” ទេ ចុះអ្វីទៅដែលត្រូវលុះនិព្វាន សម្រេចនិព្វាននោះ ? សំនួរនេះជាសំនួរត្រូវបានទទួលសេចក្ដីលំបាកយ៉ាងខ្លាំងហើយ

(១) “ខ្លួននៃនិព្វាន” ពាក្យនេះជាពាក្យសាមញ្ញ ពាក្យខ្ពស់ថា ភាពនៃនិព្វាន។ បានជាសរសេរថា “ខ្លួននៃនិព្វាន” ដូចនេះ ព្រោះចង់ឲ្យមនុស្សធម្មតាស្ដាប់បាន។



www.elibraryofcambodia.org

តែមុននឹងសងចម្លើយ ទៅអ្នកសួរហូតទៅដល់ «**និញ្វាន**» នោះ ខ្ញុំសូមឲ្យម្ចាស់សំនួរខ្លួនឯង ឲ្យចម្លើយមកខ្ញុំវិញសិនថា :

«ចុះអ្នកណាជាអ្នកគិត បើមិនមែនអាត្មាខ្លួនឯងទេ?» អ្នកអានបានដឹងមកហើយថា អ្នកគិតមិនមានអ្នកណាដទៃក្រៅអំពីគំនិតទេ គឺតាមសេចក្ដីពិត, មិនមានអ្នកគិតនៅក្រៅគំនិតសោះឡើយ សេចក្ដីនេះមានឧបមាយ៉ាងណា មានឧបមេយ្យដូចជាបញ្ញានៃមនុស្សយើង បញ្ញានេះឯងដែលលោកទុកដាក់ថាជាការលុះ, ការដល់, ការសម្រេច ប្រែថាជាអ្នកលុះ, អ្នកដល់, អ្នកសម្រេចនិញ្វាន មិនមានអ្វីជាខ្លួនឯងនៅខាងក្រៅការលុះ, ការដល់, ការសម្រេចនេះទៀតទេ។ ក្នុងចំណុចនេះ, យើងធ្លាប់គិតគួរពិចារណាវែកញែកមកខ្លះហើយ អំពីកំណើតនៃ «ទុក្ខ» ថាអ្វីៗទាំងអស់ជា «សត្វ» ជា «មនុស្ស» ជា «វត្ថុ» ប្រសិនបើមានធម្មជាតិណាមួយដែលជាពន្លក ជាដំណុះ ជាប្រភព ឬជាដែនកើត ត្រូវកើតត្រូវមានឡើង ធម្មជាតិនោះក៏តែងតែមានពន្លក, មានដំណុះ... បែបគ្នានេះ រលត់ទៅវិញនៅក្នុងខ្លួនរបស់វានោះ ព្រមជាមួយគ្នានេះ វាក៏មានការសាបសូន្យ ទៅក្នុងទីបំផុតនៅក្នុងខ្លួនរបស់វាហ្នឹងទៀតដែរ។ រីឯ «ទុក្ខ, សង្សារវដ្ដ» ដែលជាធម៌តែងអន្ទោលទៅអន្ទោលមកនេះ ក៏ជាធម្មជាតុមានពន្លក, មានដំណុះ, មានប្រភព មានដែនកើតឡើងដូចគ្នា, ធម្មជាតុទាំងឡាយនេះនឹងត្រូវមានការរលត់, ការអស់, ការសូនទៅវិញដែរ។ សេចក្ដីទុក្ខគ្រប់យ៉ាងកើតឡើង ព្រោះអាស្រ័យតណ្ហា ហើយសេចក្ដីទុក្ខដដែលនេះ ត្រូវរលត់ទៅវិញព្រោះអាស្រ័យបញ្ញា។ ចំណែកតណ្ហានិងបញ្ញាធម៌ទាំងពីរនេះ មាននៅក្នុងខន្ធបញ្ចកៈ នៃសត្វទាំងឡាយ ដូចធ្លាប់ចេះចាំគ្រប់គ្នាមកហើយ។

សេចក្ដីខាងលើនេះ នាំឲ្យយើងយល់បានថា ពន្លកឬដំណុះ ប្រភពឬដែនកើតនៃការកើតមានឡើង របស់ធម៌ទាំងឡាយនេះ ក៏មិនខុសគ្នានឹងពន្លកដំណុះ ប្រភពឬដែលកើតនៃការកើតមានឡើង នៃការរលត់សោះសូន្យទៅវិញរបស់ធម៌ទាំងឡាយនោះដែរ។ ធម៌ទាំងឡាយពីរប្រការ គឺដែនកើតមានឡើងនៃ



www.elibraryofcambodia.org

កំណើតនិងដែន កើតមានឡើងនៃសំនូននេះ វាជារបស់មាននៅក្នុងខន្ធបញ្ចកៈនៃមនុស្សយើងដដែលហ្នឹងឯង។ រឿងនេះអ្នកប្រាជ្ញពុទ្ធសាសនារបស់យើងលោកបានដឹងតាមគម្ពីរបាលីជាទូទៅថា នៅក្នុងរូបកាយនៃមនុស្សយើង មានទំហំមានប្រវែងដូចដែលយើងបានស្គាល់សព្វថ្ងៃនេះ ធម្មតាបានបញ្ចុះដោយវេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ... គួរគប្បីយើងទាំងអស់គ្នាខំព្យាយាមរាវរកលោកមានភាពដូចនេះ, កំណើតនៃលោកមានភាពបែបនេះ ការរលត់ទៅនៃលោកមានភាពបែបនេះ, បដិបទាផ្លូវប្រតិបត្តិ ដែលនាំខ្លួនយើងទៅកាន់ការរលត់លោក តាមពុទ្ធភាសិតដែលព្រះសម្មាសម្ពុទ្ធនៃយើងទ្រង់ត្រាស់ទុកថា :

"ភិក្ខុទាំងឡាយ! លោក, អញតថាគតបានត្រាស់ដឹងហើយ, អញតថាគតរួចផុតស្រឡះហើយចាកលោក. កំណើតនៃលោក អញតថាគតបានស្គាល់ច្បាស់ហើយ ការកើតឡើងនៃលោកនេះ អញតថាគតមានលះបង់អស់ហើយ ការរលត់នៃលោកនេះ អញតថាគតបានត្រាស់ដឹងច្បាស់ហើយ ការរលត់ទៅវិញនៃលោកនេះ អញតថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ បដិបទាដែលនាំសត្វទៅកាន់ការរលត់នៃលោក អញតថាគតបានចំរើនចប់ហើយ។

ពុទ្ធសម្រាស់នេះ គឺជាអរិយសច្ចៈ៤ប្រការជាធម៌ដែលបុគ្គលឃើញភ័យគប្បីរាវរកក្នុងរូបកាយនៃអាត្មាគ្រប់គ្នាដែលឈ្មោះថាខន្ធបញ្ចកៈនេះឯង មិនមែនជាធម៌ត្រូវខំប្រឹងដើរទៅស្វែងរកក្នុងទីណាដទៃទៀតឡើយ។ នៅក្នុងពុទ្ធភាសិតនេះ អ្នកអានគង់សង្កេតឃើញព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ប្រើពាក្យថា "លោក"។ (លោក) សព្ទនេះព្រះសម្ពុទ្ធទ្រង់កាន់យកន័យថា **"ទុក្ខ"** ដូចជាពុទ្ធតម្រាស់ក្នុងទីទៃទៀត ដែលទ្រង់សម្តែងថា **"ទុក្ខទុក្ខ; សមុទយ, ទុក្ខនិរោធៈ, ទុក្ខនិរោធ គាមិនីបដិបទា"** នោះដែរ។ ដូច្នេះអ្នកអានទាំងឡាយគប្បីធ្វើសេចក្តីកត់សម្គាល់ ព្រមមួយអន្លើដោយសេចក្តីចងចាំថា ធម៌ទាំងឡាយនេះមិនមានអានុភាពអ្វីដទៃ ក្រៅអំពីផលិតឡើងនូវការកើតនិងការរលត់ទៅនៃទុក្ខទាំងឡាយនោះទេ។ ក្នុងរឿងដដែលនេះ ព្រះអង្គទ្រង់ធ្វើសេចក្តីបញ្ជាក់ជាញយដង



www.elibraryofcambodia.org

ទៀតថាមានតែ "តណ្ហា" មួយប៉ុណ្ណោះទេដែលផលិតទុក្ខ ហើយមានតែ "បញ្ញា" តែមួយនេះឯងទៀតដែរ ដែលធ្វើឲ្យរលត់ទុក្ខទៅវិញ។

កាលណាយើងបានអប់រំហ្វឹកហាត់បន្ថំបញ្ញាបារមីធម៌កើតឡើងតាមផ្លូវអរិយសច្ចធម៌ទាំងឡាយ៤ប្រការ ជាពិសេសគឺ **ទុក្ខនិរោធ គាមិនីបដិបទា** នោះយើងមុខជានឹងបានឃើញនូវរបស់ដែលជាអាថ៌កំបាំងនៃជីវិតដែលជាសេចក្ដីពិត នៃសភាវធម៌ទាំងឡាយដោយប្រាកដជាក់ស្ដែងមិនខានឡើយ។ លុះការជាអាថ៌កំបាំងនៃជីវិតៈ យើងបានរកវាឃើញហើយ បើភាពពិតនៃសច្ចធម៌ទាំងឡាយនេះ យើងក៏បានរកឃើញក្នុងពេលព្រមគ្នានេះដែរ ពលៈឬថាមពលគឺ**អវិជ្ជា**; **តណ្ហា**, **ឧបាទាន**, **កម្ម** ដែលផលិតទុក្ខទាំងអស់ ដែលវាធ្វើឲ្យមានការតភ្ជាប់អំពីភពមួយទៅភពមួយ ដែលពុទ្ធសាសនារបស់យើងហៅ **សង្សារវដ្ដ** នោះវានឹងគាំងឈប់លែងដើរទៅទៀត ហើយវានឹងនៅឈប់ស្ងៀមឈឹង មិនមានការផលិតកំណើតទៅទៀតបានឡើយ។ ការនៅស្ងៀមឈឹងដែលមានសទិសពាក្យថា **សន្តិវរបទ** សម្រាប់ប្រើជំនួសពាក្យ ស្ងប់ស្ងៀមឈឹង នេះគឺជានិព្វានហ្នឹងហើយ ព្រោះមិនមានអ្វីចង់ភ្ជាប់បន្តទៅទៀតបានតាមដូចធម្មតាឡើយ។

ធម៌ទាំងអស់នេះ បើលើកឡើងធ្វើជាសេចក្ដីប្រៀបឧបមា លោកប្រៀបដូចជា[១] ជម្ងឺរូបកាយ ដែលលោកគ្រូពេទ្យបានព្យាបាលឲ្យបានជាសះស្បើយអស់រលីង ហើយដោយហេតុថា សមុដ្ឋាននៃរោគ ឬអាថ៌កំបាំងនៃជម្ងឺនោះលោកគ្រូពេទ្យបានខំព្យាយាមពិនិត្យរកឃើញជាក់ច្បាស់ហើយ ហើយបានប្រកបឱសថត្រឹមត្រូវតាមវិជ្ជសាស្ត្រ។ សេចក្ដីនេះមានឧបមាយ៉ាងណា មានឧបមេយ្យដូចរោគចិត្តនៃសត្វទាំងឡាយដែលត្រូវបានជាសះស្បើយ លែងមានរោគចិត្តដដែលនេះទៀត ដោយការព្យាបាលរបស់ព្រះសម្មាសម្ពុទ្ធ ដែលទ្រង់ជាអគ្គមហាវេជ្ជបណ្ឌិតខាងព្យាបាលរោគចិត្តនៃសត្វលោកទាំងឡាយយ៉ាងនោះដែរ។

---

[១] "ជម្ងឺ" ជាពាក្យវេយ្យាករណ៍ ពាក្យទម្លាប់ជាជម្ងឺ ,ពាក្យទាំងពីរនេះប្រើបានដូចគ្នា។



www.elibraryofcambodia.org

# និព្វានក្នុងជីវិតបច្ចុប្បន្ន

និព្វានដែលយើងទុកដាក់ថា ជាធម៌មានកំពស់ជាទីបំផុត, ធម៌នេះមានជំនឿច្រើន, មានលទ្ធិសាសនាច្រើនចូលចិត្តនិយាយថា ការធ្វើខ្លួនឲ្យបានដល់កំរិតខ្ពង់ខ្ពស់បំផុតនេះ ជាធម៌ដែលគេត្រូវបានទទួលបន្ទាប់អំពីមរណកាលទៅ។ តែផ្ទុយទៅវិញ, និព្វានតាមមតិពុទ្ធសាសនាលោកថាបុគ្គលអាចនឹងបានសម្រេចនៅក្នុងជីវិតសព្វថ្ងៃនេះ មិនបាច់នៅរង់ចាំទទួលរហូតដល់ពេលស្លាប់ហើយទេ អស់លោកអ្នកទាំងឡាយណា ដែលសម្រេចនូវសច្ចធម៌ឬនិព្វានក្នុងលោកនេះហើយ អស់លោកអ្នកទាំងឡាយនោះ មានឋានៈជាបុគ្គលប្រសើរបំផុតនៅក្នុងពិភពលោកយើងនេះ ជាបុគ្គលរួចផុតស្រឡះអំពីសេចក្តីកង្វល់គ្រប់យ៉ាង សេចក្តីលំបាកគ្រប់ប្រការ ដែលគេបានស្គាល់ថាទុក្ខព្រួយចលាចលខ្វល់ខ្វាយក្នុងចិត្តក្នុងវិញ្ញាណ ដែលកើតមកអំពីការបៀតបៀនគ្នា ហើយក្នុងពេលព្រមគ្នានេះសុខវេទនាខាងផ្លូវចិត្តក៏បានទទួលគុណភាពខ្ពស់បំផុតមិនមានវិប្បដិសារធម៌ គឺធម៌ធ្វើឲ្យមានកំដៅ, មានកង្វល់, មានសំដាយក្នុងអតីតកាលឬធម៌ធ្វើឲ្យមានសេចក្តីព្រួយបារម្ភនៅក្នុងអនាគតកាល។ គេមានជីវិតរស់នៅប្រកបដោយសេចក្តីរីករាយ ក្នុងបច្ចុប្បន្នភាពនេះអស់កាលជានិរន្តរ៍។ សេចក្តីជ្រះថ្លារីករាយចំពោះចិត្តបរិសុទ្ធរបស់ខ្លួន បានបង្កើតជាគុណធម៌ សម្រាប់ធ្វើចិត្តមិនឲ្យមានសេចក្តីអណ្តែតអណ្តូង គេជាបុគ្គលមានចិត្តជ្រះថ្លារីករាយ ត្រេកអរចំពោះជីវិតបរិសុទ្ធនៃអាត្មា គេមានឥន្ទ្រិយស្រគត់ស្រគំ មានចិត្តរួចស្រឡះចាករោគទាំងពួង មានចិត្តថ្លាស្អាតផូរផង់មានជម្រកនៅក្នុងសេចក្តីក្សេមក្សាន្ត។ បុគ្គលទាំងឡាយមានគុណធម៌ដូចពោលមកនេះ ឈ្មោះថាជាបុគ្គលមានពន្លឺក្នុងគំនិត មានការរួចផុតចាកអ្វីៗទាំងអស់ មានគំហើញថា ខ្លួនឯងបានរួចស្រឡះអំពី **តណ្ហា**, **ព្យាបាទ**, **អវិជ្ជា**, **លោភៈ**, **ទោសៈ**, **មានៈ** ព្រមទាំងធម៌ជាគ្រឿងធ្វើចិត្តឲ្យសៅហ្មងទាំងឡាយមាននីវរណៈ៥ជាដើម ជាបុគ្គលមានខ្លួនបរិសុទ្ធ ជាសប្បុរស មាន



www.elibraryofcambodia.org

ចិត្តប្រកបដោយព្រហ្មវិហារធម៌ ជាទីស្រឡាញ់រាប់រកនៃមនុស្ស, សត្វ, ទេវតា, ឥន្ទ្រព្រហ្មទូទៅ។ មិនតែប៉ុណ្ណោះ បុគ្គលទាំងឡាយនេះ ជាមនុស្សមានចិត្តស មានមេត្រី ចេះយោគយល់, ចេះសន្ដោសប្រណី, ចេះធ្វើការឲ្យជាប្រយោជន៍សាធារណៈ ដោយទឹកចិត្តបរិសុទ្ធ មិនមានគំនិតគិតតែប្រយោជន៍សុខចំរើនខ្លួនឯងឡើយ។ ក្នុងពេលជាមួយគ្នានេះ លោកមានចិត្តល្អដល់ថ្នាក់ចប់ត្រឹមហ្នឹងហើយ លោកធ្វើបុណ្យក៏មិនបានផល ធ្វើបាបក៏មិនបានផលដូចគ្នា។ សន្ដានចិត្តរបស់លោកមានពណ៌ថ្លាស្អាតបរិសុទ្ធ មិនមានជាប់ជំពាក់នឹងឧបក្កិលេស និងទ្រិស្ដិទាំងឡាយណាៗមួយឡើយ ដូចនេះព្រោះអ្វី? ព្រោះអស់លោកទាំងឡាយនេះ មានចិត្តរួចស្រឡះហើយ **ចាក រាគៈ ទោសៈ មោហៈ** ដោយមិនមានសេសសល់ឡើយ។

អ្នកអានសូមធ្វើសេចក្ដីកត់សំគាល់ថា និព្វានមិនមែនជាធម៌មានភាពពីរឬលក្ខណៈដែលជាគូ, មិនមែនគ្មានសច្ចភាពនៅខាងក្នុងពិត, ប្រែថាមិនមានការងាកបេរទៅតាមការពិចារណា ឬសេចក្ដីសន្និដ្ឋានរបស់មនុស្សម្ដងដូច្នេះ ម្ដងដូច្នោះ មិនមែនជាធម៌ដែលមានអ្វីៗទាំងអស់ ដែលមនុស្សយើងពុំមែនជាអរិយធ្លាប់ទុកដាក់ ធ្លាប់ដៅស្មានថាល្អយ៉ាងនេះ អាក្រក់យ៉ាងនោះ ខុសដូចនេះ ត្រូវដូចនោះ ជាពិសេសបំផុត គឺមិនមែនជាភពនេះ ភពនោះ លោកនេះ លោកនោះ គឺជាអ្វីមួយដែលព្រះអរហន្តបានសម្រេចហើយយកមកនិយាយប្រាប់មនុស្សដែលមិនមែនជាអរិយៈមិនកើត ដោយខ្វះភាសាហ្នឹងឯង។ ពាក្យថាសេចក្ដីសុខដែលលោកខ្ចីយកទៅប្រើសម្រាប់និយាយសម្រាប់ហៅ «និព្វាន» នោះ វាជាធាតុមួយមានសេចក្ដីប្លែកផ្សេងស្រឡះអំពីសេចក្ដីសុខដែលយើងបានស្គាល់នៅក្នុងលោកសព្វថ្ងៃនេះ។ ដូចនេះព្រោះអ្វី? ព្រោះនិព្វានពុំមែនជា**កាមលោក រូបលោក អរូបលោក**; របស់ទាំងឡាយទោះបីមានយ៉ាងតិចត្រឹមតែមួយក្តី មានយ៉ាងមធ្យមល្មមបង្គួរក្ដី មានយ៉ាងច្រើនជាអតិបរមាក្ដី ដែលលោកកំណត់ថាជារបស់នៃនិព្វាននោះ វាមិនមែនជារបស់ដែលយើងធ្លាប់ស្គាល់ ធ្លាប់ប្រើក្នុងលោកទាំងឡាយនេះទេ ប្រែថា និព្វានបានកំចាត់បង់ចោលឬបានផ្លាស់ចេញអស់



www.elibraryofcambodia.org

រលឹងនូវរបស់ដែលគេធ្លាប់ស្គាល់ ធ្លាប់ប្រើ ធ្លាប់ប្រកាន់យកថាជានេះជានោះ ដែលជាសង្ខតធាតុ ហើយដាក់ចូលឬដាក់ជំនួសមកវិញនូវ របស់ដែលជាអសង្ខតធាតុ។ ដូចនេះ ទើបព្រះអរហន្តទាំងឡាយរកពាក្យមកនិយាយពន្យល់ប្រាប់មនុស្សមិនមែនព្រះអរិយមិនបាន។ ចំណែកមនុស្សបុថុជ្ជនទោះណាជាបានស្តាប់សេចក្តីបំភ្លឺរបស់ព្រះអរហន្តទាំងឡាយ ក៏ស្តាប់ពុំយល់ឬពុំទាន់ ដូចនេះព្រោះអ្វី? ព្រោះព្រះអរហន្តមានភាសាសម្រាប់ពន្យល់ស្តួចស្តើងផង, បុថុជ្ជនយើងមានចិត្តគំនិតជាប់ញៀននឹងភាសារបស់លោកមួយអន្លើដោយវត្ថុធាតុទាំងឡាយក្នុងលោកនេះ យ៉ាងស្វិតស្វាញពេកណាស់ផង។ សេចក្តីដ៏មានអាថ៌កំបាំងក្នុងចំណុចនេះ ព្រះថេរៈឈ្មោះសារីបុត្ត លោកបានឆ្លើយសំនួររបស់ព្រះថេរៈឈ្មោះឧទាយិមានដូចនេះថា៖

«សារីបុត្តដ៏មានអាយុ! នៅក្នុងធម្មវិន័យនៃព្រះសម្មាសម្ពុទ្ធរបស់យើងខ្ញុំបានឃើញបានឮថា «**និព្វាន**» ជា «**សុខ**» «**និព្វាន**» ជា «**សុខ**» ដូចនេះស្ទើរតែរាល់កន្លែង។ សារីបុត្តដ៏មានអាយុ! ចុះសុខកើតមានដូចម្តេចទៅ បើនិព្វានមិនហានវេទនា? នេះជាសំនួររបស់ព្រះឧទាយិ។

ចំពោះសំនួរនេះ, ព្រះសារីបុត្ត លោកបានឆ្លើយតាមបែបទស្សនវិជ្ជាជាន់ខ្ពស់ ដែលខ្លួនលោកបានគិតបានស្គាល់បានថា : ព្រោះតែ «និព្វាន» ជាធម្មធាតុមិនមានវេទនាហ្នឹងឯង ទើបមាន «**សេចក្តីសុខ**» ។ ចម្លើយនេះមិនមាននរណាស្តាប់បានងាយៗភ្លាមៗទេ ប្រសិនបើអ្នកនោះមិនមែនជាអរិយជន ឬមិនធ្លាប់មានគំនិតខ្ពស់ តែបើយកមកពិចារណារឿយៗទៅគេគង់យល់បានក្នុង ១-២ ភាគរយដែរ។

## និព្វានមិនមែនជាតក្កធម៌

និព្វានមិនមែនជាតក្កធម៌, មិនមែនជាវចនធម៌ទេ និព្វានជាធម្មធាតុមាន



www.elibraryofcambodia.org

កំពស់ហួសផុតអំពីតក្កធម៌និងអំពីវចនធម៌ ប្រែថាខ្ពស់ហួសអំពីគំនិតត្រិះរិះពិចារណាស្រាវជ្រាវ តាមផ្លូវគំនិតបញ្ញាផ្ទាល់ខ្លួននៃបុគ្គលបុថុជ្ជន។ តែនិព្វានជាធម្មជាតុ មានកំពស់ល្មមដល់គំនិតបញ្ញានៃមនុស្សបុថុជ្ជន ដែលបានស្គាល់មគ្គមានអង្គ៨ ហើយត្រិះរិះពិចារណាជាមួយនឹងការប្រតិបត្តិតាមមគ្គទាំង៨ ដូចបានពោលមកក្នុងខាងដើម។

ការសិក្សាអំពីនិព្វានរបស់យើងតាំងអំពីខាងដើមរហូតមកដល់នេះ យើងបានជួបប្រទះនឹងពាក្យលំបាកស្ដាប់លំបាកយល់កាន់តែច្រើនឡើងៗ។ និព្វាននេះ, គេចូលចិត្តជជែកព្រវែកគ្នាណាស់ តែការជជែកឆ្លើយឆ្លងរបស់គេច្រើនតែទាល់ច្រករកទ្វារចេញមិនរួច ដូចជាគេនាំគ្នាខំប្រឹងវែកផ្លូវដើរកណ្ដាលយប់ងងឹតមិនសូវបានប្រយោជន៍អ្វីសោះ ព្រោះជើងជជែកទាំងអស់នេះ ពួកមួយមានទស្សនវិជ្ជាទាបពេក រុករកមិនដល់កំពស់នៃនិព្វាន។ ពួកមួយទៀត, មានទស្សនវិជ្ជាខ្ពស់ដែរ តែមិនត្រូវនឹងកំពស់របស់និព្វាន ពួកក្រោយឬពួកទី២នេះទោះណាជាទុកដាក់នូវការជជែករបស់ខ្លួនដោយសំអាងទៅលើកំពស់ឬជម្រៅនៃបញ្ញារបស់ខ្លួនម្នាក់ៗនៅក្នុងគំនិតថា អាចនឹងរកច្រកចេញរួចឬអាចនឹងពន្យល់គ្នាឲ្យយល់បាន ឬស្ដាប់បានយ៉ាងណាក៏ដោយ ក៏នៅតែធ្វើការយល់ការស្ដាប់នោះឲ្យទៅជាងាយមិនកើត។ សេចក្ដីនេះ, មិនមានខុសគ្នានឹងគ្រូទាំងឡាយដែលចង់ឲ្យកូនសិស្សរបស់ខ្លួន មានសេចក្ដីយល់អំពីវិទ្យាសាស្ត្រខ្ពស់ៗឬគណិតសាស្ត្រខ្ពស់ៗ, ហើយព្យាយាមលើកយកវិទ្យាសាស្ត្រ និង គណិតសាស្ត្រដ៏មានកំពស់ឬមានជម្រៅនោះ ទៅពន្យល់កូនសិស្សក្នុងថ្នាក់មធ្យមសិក្សា ទៅពន្យល់កូនសិស្សក្នុងបឋមសិក្សា។ កម្រិតវិជ្ជាដែលគ្រូបង្រៀនសិស្សមិនត្រូវ ជជែកជាមួយនឹងសិស្សមិនត្រូវនេះ វាពុំអាចធ្វើឲ្យកូនសិស្សចេះដឹងបានឬយល់បានយ៉ាងណាមិញ។ ពាក្យជជែកព្រវែកគ្នាអំពីរឿងនិព្វាននៃពុទ្ធសាសនិក ដែលមានដំណើរខុសបែបខុសផ្លូវ ដែលទ្រង់ត្រាយទុកដោយព្រះសម្មាសម្ពុទ្ធ ក៏ពុំអាចនឹងចេញរួចយ៉ាងនោះដែរ។ និព្វាន, ពុទ្ធសាសនាបានធ្វើសេចក្ដីបញ្ជាក់ថា ជា



www.elibraryofcambodia.org

ធម៌ដែលវិញ្ញូជនគប្បីដឹង គប្បីឃើញច្បាស់ដោយខ្លួនឯង ដែលមានបាលីជាសំអាងថា «**បច្ចត្តំ វេទិតព្វោ វិញ្ញូហិ**» ស្រាប់។ ដូច្នេះ, បើកាលណាយើងខំប្រឹងសិក្សា, ខំប្រឹងដើរតាមមជ្ឈិមបដិបទានៃព្រះពុទ្ធសាសនា, ខំប្រឹងហាត់ហ្វឹកហ្វឺនទូន្មានចិត្ត, ធ្វើចិត្តឲ្យបរិសុទ្ធដោយខ្លួនឯង ហើយបានលុះដល់ធម៌ជាន់ខ្ពស់ក្នុងថ្ងៃណាមួយយើងនឹងបានឃើញនិព្វានដោយខ្លួនឯងជាមិនខាន ក្នុងខណៈជាមួយគ្នានេះយើងនឹងដឹងថា និព្វានជាធម៌មិនចាំបាច់ត្រូវទិញដូរ មិនចាំបាច់ត្រូវទៅរាវរកក្នុងទីណា មិនចាំត្រូវទៅរកពាក្យសម្រាប់ពន្យល់សម្រាប់បំភ្លឺ ដែលជាពាក្យមាននៅក្នុងវចនានុក្រមនៃភាសាមនុស្សដូចដែលយើងធ្លាប់រៀនសូត្រសព្វថ្ងៃនេះឡើយ។

## បរមត្ថបដិបទា

បរមត្ថប្រយោជន៍ឬបរមត្ថបដិបទា ក្រៅអំពីសិក្សាជាបែបអរិយសច្ច៤ប្រការ ដូចដែលខ្ញុំបានចេញឈ្មោះជាមួយនឹងអធិប្បាយបំភ្លឺត្រង់ប្រការខ្លះមកហើយនោះ អ្នកសិក្សាគប្បីពិចារណាត្រិះរិះជាបែបស្រាវជ្រាវពិនិត្យសង្កេតឲ្យឃើញកាន់តែច្បាស់លាស់ឡើងទៀត តាមន័យដែលខ្ញុំឲ្យឈ្មោះថា «**ធម្មវិចារណៈ**» មានដូចតទៅនេះ។

និព្វិទា សេចក្ដីនឿយណាយ

«**ឯថ បស្សថិមំ លោកំ ចិត្តំ រាជរថូបមំ**

**យត្ថ ពាលា វិសីទន្តិ នត្ថិ សង្គោ វិជានតំ**»

«អ្នកទាំងឡាយចូលមកមើលលោកនេះ ដែលប្រៀបបាននឹងរាជរថ (ព្រោះមានលំអយ៉ាងចម្លែក) ដែលជនល្ងង់តែងតែមានចិត្តជាប់ជំពាក់ តែជនមានបញ្ញាពុំបានមានចិត្តជាប់ជំពាក់ឡើយ»



www.elibraryofcambodia.org

«យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា»

«ជនទាំងឡាយណាមានការសង្រួមចិត្ត ជនទាំងឡាយនោះនឹងបានរួចផុតចាកអន្ទាក់នៃមារ»។

## សេចក្តីអធិប្បាយ

ពាក្យ «លោក» បើនិយាយដោយត្រង់តាមសេចក្តី បានដល់ផែនដីជាទីនៅអាស្រ័យរបស់មនុស្សសត្វ, បើនិយាយដោយន័យបានដល់មនុស្សសត្វ ដែលជាអ្នកនៅជ្រកកោនអាស្រ័យ។ ផែនដីនេះជារបស់កើតឯងមានឯងតាម ធម្មតាធម្មជាតិនេះមានកំណើតមានភាពផ្សេងៗគ្នា កន្លែងខ្លះមានផ្ទៃទាប, កន្លែងខ្លះមានផ្ទៃខ្ពស់, កន្លែងខ្លះមានផ្ទៃទាប មានភ្នំ, ទន្លេ, ស្ទឹង, បឹង, ត្រពាំង, មានព្រៃឈើ, មានវាលស្មៅ, មានវាលខ្សាច់, វាលសើម, វាលស្ងួត, មានភ្លៀងតិច, ភ្លៀងច្រើន, មានទឹកកកធ្លាក់, មិនមានទឹកកកធ្លាក់, មានសីតុណ្ហភាពតិច, មានសីតុណ្ហភាពមធ្យម, មានសីតុណ្ហភាពខ្ពស់។ល។ របស់ទាំងឡាយនេះរបស់មួយៗសុទ្ធតែមានលក្ខណៈប្លែកៗ មុខគួរឲ្យយើងចង់ឃើញចង់មើល ព្រោះធម្មតាបានរៀបចំឡើងតាមរបៀបបច្ចេកទេសយ៉ាងប៉ុនប្រសប់។ ខាងផែនដី, ធម្មតាបានរចនាតុបតែងឲ្យមានពណ៌សម្បុរច្រើនបែបច្រើនយ៉ាង មានស, មានក្រហម, មានខ្មៅ, មានលឿង... មានស្មៅ, មានរុក្ខជាតិគ្រប់ពូជ, គ្រប់ពណ៌ដុះគ្របផែនដី តម្រៀបគ្នាជាជួរ, ជាក្រុមជាពួក។ល។ មានភ្នំដាក់រាយគ្នា ជាខ្សែបន្ទាត់ជាកំពែង, ជាកំពូល ... មិត្តរួមលោក! វត្ថុធាតុទាំងឡាយដែលខ្ញុំបានរាប់ឈ្មោះមកដោយសង្ខេបនេះ កាលណាខ្ញុំទាញខ្សែភ្នែកគយគន់មើលប្រកបដោយគំនិតត្រិះរិះ ខ្ញុំដូចជាសន្និដ្ឋានថា របស់ទាំងឡាយនេះពុំមែនកើតមានឡើងដោយធម្មតាដែលគេកំណត់សំគាល់ថាមិនមានចិត្តវិញ្ញាណសាងឡើងទេ។ អ្នកទាំងឡាយប្រសិនបើអ្នកបើកភ្នែកមើលពិភពលោក ព្រមជាមួយនឹងធម្មជាតុទាំងឡាយដែលមាននៅលើពិភពលោក, នៅក្រោមសេចក្តីត្រិះរិះ ពិចារណារបស់យើងទាំងឡាយ អ្នកគង់នឹងធ្វើសេចក្តីសន្និដ្ឋានដូចសេចក្តីសន្និដ្ឋានរបស់



www.elibraryofcambodia.org

ខ្ញុំ, បើមិនទាំងអស់ក៏ខ្លះដែរ ដូចនេះព្រោះអ្វី? ព្រោះសេចក្ដីគយគន់នៅក្រោមគំនិតត្រិះរិះរបស់យើងនោះ វាហាក់ដូចជាមានសំណួរជាពាក្យនិយាយប្រាប់យើងថាមើលមើល៍! ផែនដីទាំងមូលខាងគុណភាពមានសាច់ល្អិត, មានសាច់គ្រោតគ្រាត... មានពណ៌សម្បុរក្រហមស... មានកំពស់, មានទំនាប... ខាងគមនាគមន៍មានស្ទឹង, មានព្រែក, មានទន្លេ, មានអូរ, មានប្រឡាយសម្រាប់ធ្វើការចរាចរណ៍...ខាងទម្ងន់, ទម្រនិងកំពែង, មានដំបូកដីស្អិត, ដម្បូកដីខ្សាច់ដម្បូកដីក្រួស... ប្រកបដោយកំពស់, ទំនាប, ទំហំ, តំណូចផ្លែកៗគ្នា, មានដីភ្នំ, ភ្នំថ្ម, ភ្នំថ្មសំលៀង, ភ្នំថ្មក្រួស, ភ្នំថ្មបាយក្រៀម... ប្រកបដោយកំពស់, ទំនាប, ទំហំ, តំណូច, ផ្លែកៗគ្នាដូចជាជាដម្បូកដែរ។ របស់ទាំងអស់នេះ មានសម្រាប់សង្កត់, សម្រាប់ទ្រ, សម្រាប់របង ដើម្បីឲ្យមានទម្ងន់ស្មើ, មានទម្រមាំមួន, មានរបាំងការពារអន្តរាយ។ នៅខាងលើស្បែកដី ឬផ្ទៃដីខាងលើមានតិណជាតិប្រកបដោយឈ្មោះរាប់ស្ទើរមិនអស់មានតាំងពីពូជតូចបំផុតដែលគេស្គាល់ថាក្រវាញជ្រូក, ចិញ្ចៀន, ផ្ទី, អំពៅ, ឫស្សីៗល។ មានវល្លិជាតិ ប្រកបដោយឈ្មោះដែលគេស្គាល់ថា សណ្ដែកទ្រើង, ត្រឡាច, ត្រសក់, ល្ពៅ, ដម្លូង, ផ្ដៅ, វំពាក់, ត្រកួន, ព្រលិត, ឈូក, ស្លន់, វល្លិប្រេង, វល្លិស្រមោច, វល្លិត្រី, វាយ, ដក់ពាយ, រុនៗល។ មានរុក្ខជាតិប្រកបដោយពូជពន្ធ៍ពណ៌សម្បុរ ដែលមនុស្សយើងម្នាក់ៗពុំអាចនឹងស្គាល់អស់ ដែលអ្នកវិទ្យាសាស្ត្រចែកចេញជាប្រភេទ ឈើស្រាយឈើខ្លឹម, ឈើសំណង់, ឈើលំអឬឈើសួន, ឈើផ្កា, ឈើស្លឹក, ឈើផ្លែៗល។ ឈើទាំងឡាយនេះ ខ្លះមានពូជជាឈើពុល, ខ្លះមានពូជជាឈើឯម, ខ្លះមានពូជជាឈើល្វីង...។ នៅខាងក្រោមផ្ទៃដី មានធាតុត្រជាក់, ធាតុក្ដៅ, ធាតុដែក, ធាតុត្បូងថ្ម, ធាតុប្រេង, ធាតុសំណ, ធាតុស្ពាន់...នៅជុំវិញផែនដី, មានអាកាសធាតុប្រកបដោយកំដៅតិច, ច្រើន, ខ្លាំង, ខ្សោយ, មានសុរិយា, មានចន្ទ្រា, មានភាពរាប់មិនអស់។ របស់ទាំងអស់នេះមើលយូរៗ ប្រកបដោយសេចក្ដីសង្កេតទៅដូចជាកើតឡើងដោយនរណាម្នាក់ឬច្រើនអ្នកសាងឡើង ប្រែអ្នកសាងនោះ



www.elibraryofcambodia.org

គឺជាស្ថាបត្យករមួយមានការប៉ិនប្រសប់យ៉ាងខ្លាំង មានវិជ្ជាចំណេះយ៉ាងខ្ពស់រក បុគ្គលប្រៀបផ្ទឹមពុំបាន ពុំមែនជាកើតឯង, មានឯង តាមធម្មតាសាងឡើងដូច ដែលយើងចូលចិត្តគ្រប់គ្នាសោះឡើយ។

ដូចនេះហើយបានជាមានជំនឿជាប្រពៃណីខ្លះ ជំនឿក្នុងលទ្ធិសាសខ្លះ បានធ្វើសេចក្ដីថ្លែងការណ៍ បញ្ជាក់អំពីសេចក្ដីចូលចិត្តរបស់ខ្លួន ដោយផ្អែកទៅលើជំនឿទាំងអស់នោះថា មានព្រះអាទិទេពបង្កើតពិភពលោក ( ទឹក, ដី, ភ្លើង, ខ្យល់) បព្វតាព្រឹក្សា លតាវល្លិ មនុស្សសត្វគ្រប់ប្រភេទ, បង្កើតព្រះអាទិត្យ, ព្រះចន្ទ, តារា, មេឃា, ភាពភ្លឺ, ភាពងងឹត, ភ្លៀង, ផ្គរ, រន្ទះ, ផ្លេកបន្ទោរ, មហារីក ។ល។ សេចក្ដីចូលចិត្តរបស់គេនេះក៏ម្យ៉ាងទៅដែរ ព្រោះព្រះអាទិទេព ព្រះអង្គទ្រង់មានព្រះវិញ្ញាណដ៏បរិសុទ្ធ, ទ្រង់មានព្រះវិញ្ញាណមានពន្លឺធំទូលំទូលាយ ដែលមិនមាននរណាអាចគិតឲ្យយល់បាន តាមដែលមានសំដែងក្នុងព្រះគម្ពីររបស់គេ ដែលយើងបានស្គាល់ឈ្មោះថា ប៊ីប្លិ៍, វេទ, កូរ៉ង់, ក្នុងសាសនាគ្រិស្ត, ព្រាហ្មណ៍, ឥស្លាម។ នេះជាជំនឿមួយបែប មិនងាយនរណានឹងឲ្យខុសឬបដិសេធបានឡើយ ព្រោះពិភពលោក មួយអន្លើដោយរបស់ទាំងឡាយដែលកើតឡើង នៅលើពិភពលោក និងធម្មជាតុទាំងឡាយដទៃទៀត ដែលនៅជុំវិញពិភពលោក ដែលយើងមើលឃើញដោយភ្នែក របស់ទាំងនេះវាមានលក្ខណៈផ្សេងអំពីគ្នា មានបរិមាណមិនស្មើគ្នា មានគុណភាពខុសគ្នា ដូចខ្ញុំបានរៀបរាប់មកខ្លះហើយក្នុងខាងដើម ប្រសិនបើមាននរណាមួយទាត់ចោលថាជំនឿបែបនេះខុស, សំនួរនឹងកើតមានឡើងដល់អ្នកនោះឥតមានចប់ ព្រោះអ្វី? ព្រោះរបស់មួយៗមានលក្ខណៈច្រើនពន់ពេកណាស់ មិនងាយអ្នកណានឹងរៀបចំចម្លើយព្រមជាមួយនឹងសេចក្ដីពន្យល់ឲ្យម្ចាស់សំនួរយល់បានដោយងាយទេ ឧទាហរណ៍ដូចសំនួរថា បើមនុស្សសត្វកើតឯងៗទទេៗ មិនមានអ្នកមានបញ្ញាបង្កើតដោយប្រើសេចក្ដីប៉ិនប្រសប់របស់គេទេនោះ ដូចម្ដេចទើបរូបកាយខ្លួនប្រាណមនុស្ស សត្វ មានគ្រឿងប្រដាប់ ដូចសក់, រោម, ស្បែក, សរសៃ, ធ្មេញ,



www.elibraryofcambodia.org

ភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, បេះដូង, ថ្លើម, សួត។ល។ មានលក្ខណៈទ្រង់ទ្រាយភាពលំនាំបែបបទក្បាច់ក្បូរ ទំហំ, តំណូច, ទំនាប, កំពស់...ប្រកបទៅដោយភាពសមសួន មានចលនា, មានសកម្មភាពកំរើកបាន, ក្រោកដើរបាន, ធ្វើការអ្វីៗទោះជាការធម្មតាក្តី ការខាងវិទ្យាសាស្ត្រក្តី។ល។ ក្រៅអំពីមនុស្សសត្វ ដើមឈើទាំងអស់ក៏មានលក្ខណៈផ្លែកៗខុសគ្នា វាមានដើម, មានសាច់ខ្លឹម, មានសាច់ស្រាយ, សំបក, ធាង, មែក, ស្លឹក, ផ្កា, ផ្លែ។ល។ ក្នុងបណ្តាគ្រឿងប្រដាប់របស់វាទាំងអស់ គ្រឿងប្រដាប់មួយៗមិនងាយនរណានឹងធ្វើតាមកើត ក្នុងផ្ការបស់វាមួយទងៗ ប្រសិនបើយើងយកមកហែកហើយវែកមើលដោយម៉ត់ចត់ យើងនឹងឃើញថា នៅក្នុងនោះមានក្បាច់ក្បូររចនាយ៉ាងវិចិត្រពិស្តារ ដែលដៃមនុស្សយើងធ្វើតាមមិនកើតឬបើកើត ក៏ពុំបានដូចរបស់វាគ្មានខុសសូម្បីបន្តិចនោះសោះឡើយ។ ពិសេសជាងនេះទៅទៀត, ទាំងមនុស្ស សត្វទាំងរុក្ខជាតិគ្រប់ពូជពន្ធ៍, គ្រប់ពណ៌សម្បុរ សុទ្ធតែមានចលនា មានសកម្មភាពដូចជាស៊ីអាហារ, ដកដង្ហើម, ស្រូបអាកាស, យកពន្លឺ, យកកំដៅ។ល។ មកបំរើការរស់នៅរបស់ខ្លួន។

ពិភពលោកយើងនេះ, យើងកើតជាមួយ, នៅជាមួយកាន់តែយូរ យើងកាន់តែធ្លាប់, កាន់តែញៀន, កាន់តែមានសេចក្តីស្នេហាចាប់ចិត្តច្រើនឡើងៗព្រោះគំនិតនិងគំហើញរបស់យើង វាទុកដាក់ពិភពលោកនិងវត្ថុជាតុដែលកើតនៅលើពិភពលោកនេះថាជារបស់ល្អប្រសើរ វាសន្មតតែងតាំងឡើងថា ពិភពលោកនេះជាសួនមួយយ៉ាងធំមានលំអរកប្រៀបពុំបាន ប្រៃថាមានលំអលើសសួនដែលសាងឡើងដោយមនុស្សរាប់ពាន់ភាគ ព្រោះសួនដែលសាងឡើងដោយមនុស្សវាមិនមានសម្ភារៈបរិក្ខារគ្រប់គ្រាន់ ដូចសួនពោលគឺពិភពលោកនេះឡើយ។ សួននៃពិភពលោក វាមានដីគ្រប់ពណ៌, មានទឹកគ្រប់រស, មានភ្លើងគ្រប់កំដៅនិងពន្លឺ, មានខ្យល់គ្រប់កម្លាំង, មានមេឃប្រកបដោយពណ៌ផ្សេងៗ, មានព្រះអាទិត្យឲ្យពន្លឺនិងកំដៅ, មានព្រះចន្ទឲ្យពន្លឺជាមួយនឹងភាព



www.elibraryofcambodia.org

ត្រជាក់, មានតារាជាប្រទីបផ្ទាលា ប្រកបទៅដោយផ្លូវ ដោយសង្កាត់ ដែលអ្នកណានោះសាងឡើងសម្រាប់មនុស្សបណ្ដែតអារម្មណ៍ មានពពកចម្រុះពណ៌, មានសមុទ្រប្រកបដោយមច្ឆាគ្រប់ជាតិព័ន្ធហិចហែលពន្លេងគ្នា ដែលគួរឲ្យគេទុកដាក់ដូចជាល្ហោននៃសត្វទឹក, មានអាកាសប្រកបដោយសត្វបក្សីគ្រប់សម្បុរគ្រប់ភាសា ហិចហើរយំស្រែកឆាបឆក់សំនឹងជាមួយនឹងការពន្លេងគ្នា នៅក្នុងភាពលំនាំដូចល្ហោននៃបក្សី; មានផែនដីប្រកបទៅដោយរុក្ខជាតិ, តិណជាតិ, វល្លិជាតិគ្រប់ពណ៌គ្រប់ពូជព័ន្ធដុះតម្រៀបគ្នាជាផ្លូវសង្កាត់មានត្រួយ, មានទង, មានដើម, មានដៃ, មានបន្លា, មានផ្កា, មានផ្លែ... មានសត្វម្រឹគគ្រប់ពូជព័ន្ធគ្រប់ភាសាគ្រប់ពណ៌សម្បុរ កៀងគូពន្លេងគ្នាវិស័យដូចល្ហោននៃសត្វម្រឹគ ; មានមនុស្សគ្រប់ជាតិសាសន៍ ប្រកបដោយរូបកាយមានពណ៌សម្បុរផ្សេងៗគ្នា; មនុស្សទាំងឡាយនេះខំរៀន. ខំរក, ខំរស់, ខំធ្វើ, គ្រឿងប្រដាប់តុបតែងជីវិត, ខំធ្វើខ្លួនឲ្យបានល្អស្អាតដោយគ្រឿងសំលៀកបំពាក់សំអាងផ្សេងៗ ប្រកបដោយលំអមុខគួរឲ្យសង្គមផ្អែមភ្នែកផ្អែមអារម្មណ៍, កាយវិការ វចីវិការនៃមនុស្សទាំងឡាយដែលរស់នៅក្នុងលោកនៃមនុស្សយើងជាធម្មជាតុគួរកត់សំគាល់បាននៅក្នុងន័យថា មានសេចក្ដីសប្បាយរីករាយដែលយើងអាចទុកដាក់ជាល្ហោននៃគ្រួសារផងល្ហោននៃពិភពលោកផង។ ចំណែកឯរបស់ទាំងឡាយដទៃទៀតជាភ្នំក្ដី, ជាសមុទ្រក្ដី, ជាស្ទឹងក្ដី, ជាទន្លេក្ដី, ជាព្រៃកក្ដី, ជាអូរក្ដី, ជាស្មៅក្ដី, ជាព្រៃឈើស្បាតក្ដី, ជាព្រៃឈើរបាស់ក្ដី, ជាព្រៃឈើស្រោងក្ដី, ជាដំណាំទាំងឡាយក្ដី, ជាសន្ទូងទាំងអស់ក្ដី។ ធម្មជាតុទាំងនេះ វាក៏ខំប្រឹងធ្វើខ្លួនរបស់វា ឲ្យបានសមរម្យដោយមណ្ឌល, ដោយទម្រង់, ដោយសម្រស់, ដោយទំហំ, ដោយកំពស់, ដោយតំណូច, ដោយទំនាប ប្រែថារបស់ទាំងឡាយនេះ ក៏វាប្រឹងបញ្ចេញសកម្មភាព ដើម្បីជួយទំនុកបំរុងឲ្យសួននៃពិភពលោកយើងនេះ កាន់តែមានសម្រស់ល្អឡើងៗ តាមលំដាប់។

របស់ទាំងអស់នេះ វានិយាយស្ដីពុំបានទេ ប៉ុន្តែតាមការសង្កេតរបស់



www.elibraryofcambodia.org

យើងឃើញថាវាមានចលនា មានសកម្មភាពខំប្រឹងធ្វើខ្លួនរបស់វាឲ្យចូលទៅនៅក្នុងលក្ខណៈដែលមនុស្សយើងស្រឡាញ់រាប់អានវា គឺជាភ្នំវាចង់ឲ្យយើងនិយាយជំនួសវាថា ខ្លួនវានៅក្នុងលក្ខណៈល្អជាងគេ ព្រោះវាមានជើង, មានកំពូល, មានខ្លួនស្លៀកពាក់តុបតែងដោយស្មៅ, វល្លិ, ឈើ... មានពណ៌សម្បុរផ្លែកៗគ្នា ដែលវាទុកដាក់ថាជាគ្រឿងអលង្ការរបស់វា ជាពិសេសគឺវាចង់ឲ្យយើងហៅវាថា ជាមកុដឬជាម្កុកនៃផែនដី... សមុទ្រក៏វាចង់ឲ្យយើងឲ្យពិន្ទុវាច្រើនជាងគេ ព្រោះវាខំសំអាងខ្លួនវា, ខំប្រឹងតុបតែងឲ្យមានទឹកគ្រប់ពណ៌គ្រប់រសជាតិ, ខំប្រឹងចិញ្ចឹមត្រីគ្រប់ជាតិពន្ធ៍ឲ្យរស់នៅក្នុងទឹករបស់វា, មានរតនវត្ថុគ្រប់បែបកើតនៅក្នុងបាតរបស់វា, ជាពិសេសជាងនេះទៅទៀត គឺវាចង់ឲ្យយើងតបស្នងសងគុណដោយវាទុកខ្លួនវាថា វាជាអាងសម្រាប់ទទួលទឹកជំនន់ដែលធ្លាក់ចុះអំពីមេឃមកលើផែនដី កុំបានវាមនុស្សយើងស្លាប់អស់គ្មានសល់ទេ។ ដោយខ្លួនវាខំប្រឹងតុបតែងលំអស្ងួនពិភពលោកផង ខំផឹកទឹកមិនឲ្យលង់លិចមនុស្សស្លាប់ផង ទើបវាចង់បានពិន្ទុច្រើន។ ស្ទឹង, ទន្លេ, ព្រែក, អូរ, បឹង, ត្រពាំង, ស្រះ... ក៏វាចង់ឲ្យយើងនិយាយជំនួសវាអំពីលំអដែលវាខំប្រឹងតាក់តែង ដូចជាវាខំប្រឹងបឺតទឹក, ខំប្រឹងដាំដំណាំទឹកនិងបង្កើតមច្ឆាទាំងឡាយ មានត្រកួន, កញ្ឆែត, ព្រលិត, សារាយ, កំពឹងពួយ, ចក, កំផ្លោក, ត្រកៀត, ស្លង, ឈូកស, ឈូកក្រហម, ត្រីរ៉ស់, ត្រីឆ្តោរ, ត្រីព្រួល...: ប្រែថា វាចង់សុំពិន្ទុច្រើន អំពីមនុស្សយើងដោយវាសំអាងថា ខ្លួនវាបានជួយដាំបន្លែគ្រប់យ៉ាងផង បង្កើតត្រីគ្រប់ជាតិពន្ធ៍ផង សម្រាប់ជួយឲ្យមនុស្សរស់នៅយ៉ាងស្រួល ប្រហាក់ប្រហែលគ្នានឹងសមុទ្រដែរ។ ចំណែកខាងរុក្ខជាតិគ្រប់ជាតិព័ន្ធក៏វាប្រឹងសាងដើម, មែក, ធាង, សន្លឹក, ផ្កា, ផ្លែ...សម្រាប់ជាបន្លែ, ជាម្លប់, ជាអាហារ, ជាកម្លាំងស្រូបទឹកភ្លៀង, ជារបាំងទប់ទឹកជំនន់ឲ្យមានកម្លាំងខ្សោយ, ជាតម្រងត្រងយកខ្សាច់, គ្រួស, កំទេចថ្មល្អិតៗ មិនឲ្យរមៀលទៅកាន់ផ្ទៃដីស្រែ, ចម្ការ,...ជាកំពែងការពារកម្លាំងខ្យល់ខ្លាំងៗ មិនឲ្យវាយបំបាក់ផ្ទះនិងផលដំណាំរបស់មនុស្សយើង



www.elibraryofcambodia.org

។ល។ ពិសេសជាងនេះទៅទៀត គឺវាខំប្រឹងបញ្ចេញផ្កាគ្រប់ពណ៌, ផ្លែគ្រប់សម្បុរ សម្រាប់ទាក់ទាញភ្នែកយើងឲ្យគយគន់ ដោយអាស្រ័យគំនយគំនន់នេះ មនុស្ស យើងទាំងអស់គ្នាក៏បានរស់នៅយ៉ាងសប្បាយ មានអាយុវែងៗ ដោយអាស្រ័យ សំរស់និងលំអនិងជីវជាតិខ្លះ ដែលវាបានផ្តល់ឲ្យជីវិតរបស់យើង។ ដូចនេះ, ទើបវាចង់ឲ្យយើងនិយាយសរសើរវា ក្នុងន័យថា សួននៃពិភពលោកនេះ កុំមាន វាជួយតុបតែងផង ក៏ពុំបានល្អប៉ុន្មានឡើយ។ រុក្ខជាតិទាំងឡាយវាចង់សុំឲ្យបាន ពិន្ទុច្រើនជាងរបស់ទាំងឡាយដទៃទៀត ព្រោះខ្លួនរបស់វាទាំងឡាយបានធ្លាក់ មកជាសម្បត្តិនៃសួនផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗដែលយើងហៅថា "សួនឯក ជន" ឬ "សួនគ្រួសារ" សព្វថ្ងៃនេះ។

ក្រៅអំពីការតុបតែងរបស់ធម្មជាតិនៃពិភពលោកមានសមុទ្រ មានកោះ ជាដើមនោះមានការដែលគួរឲ្យយើងចាប់អារម្មណ៍ជាមួយនឹងសេចក្តីរីករាយ សប្បាយចិត្តជាងនេះទៅទៀត គឺការតុបតែងសួននៃពិភពលោក ក្នុងសម័យនៃ វិទ្យាសាស្ត្រ។ មិត្តរួមលោកទាំងឡាយ! ចូរអ្នកបើកភ្នែកសម្លឹងមើលជាមួយ នឹងមនោសញ្ចេតនាមួយអន្លើដោយវិចារណញ្ញាណរបស់អ្នកនូវពិភពលោក ព្រម ទាំងមនុស្សទាំងឡាយ ដែលរស់នៅក្នុងពិភពលោកសព្វថ្ងៃនេះ ដោយអាស្រ័យ ការបើកភ្នែកមើលប្រកបដោយគំនិតត្រិះរិះនៅក្នុងនោះផង អ្នកទាំងឡាយនឹង កើតមានមនោសញ្ចេតនាផ្លែកៗ ជាសប្បាយ, ជាកោតស្ញើច, ជាអស្ចារ្យ, ជា ចម្លែក ដែលជារបស់គឺខ្លួនរបស់អ្នកពុំធ្លាប់ដែលបានជួប, ពុំធ្លាប់ដែលបាន ឃើញ ពុំធ្លាប់ដែលបានប្រើប្រាស់ក្នុងពេលមុន។

មនុស្សក្នុងពិភពលោកមានលក្ខណៈផ្សេងៗពីគ្នា ដោយជាតិ, ដោយ សញ្ជាតិ, ដោយភាសា, ដោយរូប, ដោយទម្រង់, ដោយសម្បុរ... ព្រមជាមួយ នឹងរូបនេះទៀត មនុស្សផ្សេងគ្នាដោយចិត្ត, ដោយអធ្យាស្រ័យ, ដោយគុណ សម្បត្តិសម្រាប់ចិត្ត, ដោយគុណធម៌ទូទៅក្នុងចិត្តរបស់មនុស្ស...។ សេចក្តីផ្លែក ផ្សេងនៃមនុស្ស មិនមែននឹងតាមធម្មតាទាំងអស់ទេ គឺស្រេចនឹងកម្មគឺការងារ



www.elibraryofcambodia.org

របស់មនុស្សក្នុងបច្ចុប្បន្នកាលផង ក្នុងអតីតកាលផង ចាត់ចែងឲ្យមនុស្សមានលក្ខណៈផ្សេងគ្នាមួយជាប់ទៀត ដែលយើងស្គាល់ថា អ្នកមាន, អ្នកក្រ, អ្នកល្អ, អ្នកអាក្រក់, អ្នកមានស័ក្តិខ្ពស់, អ្នកមានស័ក្តិទាប, អ្នកមានកំណើតថោកទាប, អ្នកមានកំណើតខ្ពង់ខ្ពស់, អ្នកមានសេចក្តីចម្រើន, អ្នកមានសេចក្តីវិនាស, អ្នកមានសំពត់អាវស្លៀកពាក់តុបតែងខ្លួនឲ្យមានសម្រស់បន្ថែមលំអនៃរូបសម្បត្តិដែលកើតឡើងតាមធម្មជាតិ, អ្នកមានគ្រឿងអលង្ការមាសប្រាក់ពេជ្រត្បូងកែវនិល... សម្រាប់ផ្ទៃរូបកាយឲ្យមានលំអរិតតែវិសេសឡើង នៅក្នុងលក្ខណៈដែលអ្នកផងកត់សំគាល់ថា ឆើតឆាយ, អ្នកមិនមានគ្រឿងអលង្ការវត្ថាភរណៈសម្រាប់តែងខ្លួន។ល។ នៅក្នុងសតវត្សរ៍នេះ, វិទ្យាសាស្រ្តបានធ្វើវិភាគទាន មួយភាគធំដល់ពិភពលោកព្រមទាំងមនុស្ស, សត្វ, រុក្ខជាតិ... ឲ្យកាន់តែមានលំអ, មានសម្រស់, មានទម្រង់យ៉ាងខ្ជង់, យ៉ាងខ្ពស់បន្ថែមទៅលើលំអ, សម្រស់ទម្រង់ដែលធម្មជាតិ, ដែលប្រពៃណីបានឲ្យកាលពេលមុន។ មិត្តរួមលោកទាំងឡាយ ! ដូចខ្ញុំបាននិយាយមកហើយក្នុងខាងដើមនៃរឿងនេះថា ការតុបតែងសួននៃពិភពលោកក្នុងសម័យនៃវិទ្យាសាស្រ្តចំរើនជាការរួមធ្វើឲ្យយើងមានចិត្តរំភើបជាមួយនឹងសេចក្តីសប្បាយរីករាយ រកនិយាយមិនកើត ដូចនេះព្រោះអ្វី ? ព្រោះប្រទេសទាំងឡាយក្នុងពិភពលោកវាមានសមិទ្ធិសំណង់ជាគេហដ្ឋាន, ជាប្រាសាទ, ជាវិមាន, ជាផ្សារលក់ទំនិញ, ជារោងភាពយន្ត ជារោងរបាំ, ជារោងល្ខោន, ជាភត្តដ្ឋាន, ជាភោជនីយដ្ឋាន, ជាវិថី, ជាផ្លូវ, ជាថ្នល់,... របស់ទាំងអស់នេះ មានកំពស់តាំងអំពីជាន់មួយ រហូតទៅដល់មួយរយជាន់ ពីតូចរហូតទៅដល់ធំល្វឹងល្វើយ ពីខ្លីរហូតដល់ទៅវែងប្រវែងរាប់ពាន់គីឡូម៉ែត្រ។ វត្ថុធាតុដែលគេយកមកធ្វើសំណង់ទាំងអស់នេះ មានដែក, ស្ពាន់, សំណ, ស៊ីម៉ងត៍, ថ្ម, គ្រួស, ខ្សាច់, ឥដ្ឋ, ថ្មកែវ, ថ្មពពាល, ប្លាស្ទិក, ជ័រកៅស៊ូ, មាស, ប្រាក់, ពេជ្រ។ល។ សំណង់ទាំងអស់នេះមានគុណភាពខាងល្អ, ខាងជាប់, ខាងមាំមួនប្រៀបបាននឹងសមិទ្ធិ ដែលមាននៅក្នុងស្រុកទេវតា ដែលយើងបានឃើញក្នុងគម្ពីរ



www.elibraryofcambodia.org

និងបានពុតាមរឿងព្រេង។ ខ្ពស់ជាងនេះទៅទៀត សមិទ្ធិនៃវិទ្យាសាស្ត្រមិនមែនមានត្រឹមតែប៉ុណ្ណោះទេ ប្រដាប់ប្រើប្រាស់តូចៗល្មមៗ មានកែវ, ចាន, ថ៉ាន់, ពែង, សំពត់ជាដើម ក៏គេសង់ឡើងដោយប្លាស្ទិក, ជ័រកៅស៊ូ, កំទេចថ្ម, ក្រដាស ... ប្រហែលៗគ្នានឹងសមិទ្ធិធំៗនោះដែរ។ ហើយមានរបស់មួយទៀតដែលខ្ពស់ជាទីបំផុតមិនមានអ្វីយកមកប្រៀបធៀបបាននោះ គឺអ្នកវិទ្យាសាស្ត្រផ្នែកខាងអវកាស កំពុងសង់ស្ពាន, សង់ស្ថានីយ៍, សង់វិថី, សង់យន្តហោះនិងរថយន្តដើម្បីដឹងជញ្ជូនយកមនុស្សទៅនៅក្នុងពិភពនៃព្រះចន្ទ លុះនៅក្នុងពិភពព្រះចន្ទបានហើយគេនឹងសាងគមនាគមន៍បន្តដំណើរទៅពិភពនៃព្រះអង្គារ។ល។ ទៀតក្នុងសតវត្សរ៍ទី២០ នេះឯង។

ពិភពលោកនិងរបស់ទាំងឡាយដែលកើតមាននៅក្នុងពិភពលោករួមទាំងមនុស្សយើងផងនោះ ជំនឿក្នុងលទ្ធិខ្លះក្នុងទំនៀមទំលាប់ខ្លះថា កើតឡើងដោយមានអ្នកសាងដូចខ្ញុំបានសរសេរមកហើយក្នុងឃ្លាដែលស្តីអំពីរឿងនេះ។ តែព្រះពុទ្ធសាសនារបស់យើងព្រះសម្មាសម្ពុទ្ធមិនទ្រង់បានសម្តែងអំពីរឿងកើតឡើងនៃពិភពលោក ដោយមានម្ចាស់បង្កើតទេ កាលណាមានគេធ្វើសំនួរអំពីរឿងនេះ ព្រះអង្គទ្រង់គ្រាន់តែឆ្លើយជាមួយនឹងសេចក្តីពន្យល់ថា កុំចង់ដឹងអំពីកំណើតនៃពិភពលោកធ្វើអ្វី ពិភពលោកកើតឯងក្តី កើតដោយមានម្ចាស់បង្កើតក្តី របស់នេះវាមានមកយូរយារណាស់ ហើយដឹងទៅក៏វាគ្មានប្រយោជន៍អ្វីដែរ មុខងារធំបំផុតដែលអ្នកទាំងឡាយត្រូវស្គាល់ ត្រូវធ្វើជាចាំបាច់នោះ គឺត្រូវរៀនឲ្យស្គាល់ថា ពិភពលោកដែលអ្នកកំពុងរស់ជាមួយសព្វថ្ងៃនេះជារបស់មានភាពទៀងទាត់ មានភាពសុខស្រួល, មានភាពជាខ្លឹមសារឬមួយវាជារបស់ឋិតនៅក្នុង **អនិច្ចំ ទុក្ខំ អនត្តា**ទេ។ ព្រះសម្មាសម្ពុទ្ធទ្រង់ធ្វើសេចក្តីបញ្ជាក់បន្ថែមព្រមជាមួយនឹងសេចក្តីដាស់តឿនស្មារតីថា បើអ្នកទាំងឡាយខំប្រឹងរៀន កើតបានជាពន្លឺនៃគំនិតយោលទៅក្នុងន័យថា លោកព្រមទាំងមនុស្ស, សត្វ មានភាពជា **អនិច្ចំ, ទុក្ខំ, អនត្តា** តាមដែលអញតថាគតបានបង្រៀន, បានពន្យល់ជារឿយៗ



www.elibraryofcambodia.org

មកហើយ អ្នកត្រូវដោះចិត្តចេញចាកលោកនេះ កុំគប្បីធ្វើចិត្តឲ្យមានសេចក្តីវង្វេងជាប់ជំពាក់នៅក្នុងលោកដែលភ្នែកធម្មតាមើលទៅឃើញល្អ, ឃើញចម្លែក ដូចរាជរថមានក្បាច់រចនាយ៉ាងត្រកាលនោះឲ្យសោះ ព្រោះលំអនៃពិភពលោក, នៃសត្វគ្រប់ប្រភេទនោះ វាគ្រាន់តែជាភាពល្អបោកប្រាស់បញ្ឆោតគំនិតឲ្យយល់ច្រឡំ ដោយសេចក្តីល្ងង់ខ្លៅរបស់ខ្លួន វាមិនមែនជាល្អរហូតឥតមាន **អនិច្ចំ, ទុក្ខំ**, **អនត្តា** មកបំផ្លិចបំផ្លាញនោះសោះឡើយ។ លំអទាំងឡាយនៃពិភពលោក, នៃមនុស្ស, នៃសត្វ.... ជាលំអត្រូវប្រែប្រួលទៅជាមួយនឹងពេលវេលា ដែលវិលដែលដើរទៅជានិច្ច ជនល្ងង់ទាំងឡាយពុំបានដឹងនូវអាថ៌កំបាំងរបស់ធម្មតាក្នុងចំណុចនេះឡើយ។ ដូចនេះហើយ ទើបគេមានចិត្តជាប់ ជំពាក់លិចលង់នៅក្នុងលោកនេះ ចំណែកសាវ័កនៃអញ្ញតថាគត ដែលមានគំនិតភ្លឺហើយ, មានស្មារតីភ្ញាក់រលឹកហើយ ពុំបានមានចិត្តជាប់ជំពាក់នៅក្នុងលោកនេះទេ។

ព្រះសម្មាសម្ពុទ្ធទ្រង់បន្តសេចក្តីថា បុគ្គលណាសង្រួមចិត្តមិនបណ្តោយឲ្យចិត្តសប្បាយរីករាយ ភ្លើតភ្លើននៅក្នុងរបស់បោកប្រាស់នេះ បុគ្គលនោះនឹងរួចផុតចាកអន្ទាក់នៃមារ។ វិធីសង្រួមចិត្តក្នុងទីនេះ ពុទ្ធសាសនារបស់យើងចែកចេញជា៣យ៉ាងគឺ :

១- សង្រួមឥន្ទ្រិយ មិនឲ្យកើតសេចក្តីត្រេកអរនិងសេចក្តីថ្នាំងថ្នាក់ក្នុងពេលភ្នែកឃើញរូប, ត្រចៀកឮសម្លេង, ច្រមុះធុំក្លិន, អណ្តាតប៉ះពាល់ត្រូវរស, កាយចាប់កាន់ឬទង្គិចរូប, ចិត្តគិតនឹកដល់ធម្មារម្មណ៍។

២- ធ្វើចិត្តឲ្យមានមនសិការៈក្នុងកម្មដ្ឋានធម៌សម្រាប់កំចាត់សត្រូវពោលគឺកិលេសទាំងឡាយមានកាមឆន្ទៈជាដើម បានដល់អសុភនិងកាយគតានុស្សតិ ឬញុំាងចិត្តឲ្យមានសេចក្តីតក់ស្លុតចំពោះសេចក្តីស្លាប់គឺមរណស្សតិ។

៣- ចម្រើនវិបស្សនាគឺពិចារណាសង្ខារវែកញែកចេញជា**ខន្ធៈ**, **អាយតនៈ**, **ធាតុ**, **ឥន្ទ្រិយ**, **បដិច្ចសមុប្បាទ**... ព្រមជាមួយនឹងធ្វើសេចក្តីសន្និដ្ឋានថាធម្មធាតុទាំងឡាយនេះ ជាភាពមិនទៀតទាត់, ជាទុក្ខ, ជាអនត្តា។ កិលេសកាម



www.elibraryofcambodia.org

បានដល់ចិត្តមានគ្រឿងសៅហ្មង ដឹកនាំឲ្យកើតសេចក្ដីត្រេកអរ ឲ្យចង់បានជានេះជានោះ ជារូប, សម្លេង, ក្លិន, រស, ផ្សព្វ, ភព និងវិភវភព ដែលយើងធ្លាប់ស្គាល់ថា **“តណ្ហា”** **“រាគ”** សេចក្ដីត្រេកអរ, **អរតិ** សេចក្ដីមិនត្រេកអររីករាយ និងព្រះសទ្ធម្មប៉ុណ្ណោះជាដើម លោកឲ្យឈ្មោះថា **“មារ”** ព្រោះវាជាទោសដុតបំផ្លាញនូវសេចក្ដីល្អ វាធ្វើឲ្យខូចគុណសម្បត្តិល្អរបស់មនុស្ស។ វត្ថុកាមបានដល់រូប, សម្លេង, ក្លិន, រស, ផ្សព្វ ជារបស់ដឹងនាំចិត្តឲ្យមានសេចក្ដីត្រេកអរត្រេអកត្រអាលលោកហៅថាជាអន្ទាក់នៃមារ ព្រោះជាអារម្មណ៍ ជាគ្រឿងចងចិត្តឲ្យជាប់ជំពាក់។ អន្ទាក់នៃមារហ្នឹងឯងហើយ ដែលចងសត្វឲ្យជាប់នៅក្នុងភពមិនឲ្យបានសម្រេចនិព្វាន។

## បដិបទានៃនិព្វិទា

**“សព្វេ សង្ខារា អនិច្ចាតិ........................**
**សព្វេ សង្ខារា ទុក្ខាតិ..........................**
**សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ**
**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា”។**

“កាលណាគេឃើញដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួងមិនទៀង ជាទុក្ខ ធម៌ទាំងឡាយទាំងពួង ជាអនត្តា កាលនោះគេរមែងនឿយណាយក្នុងទុក្ខ នេះជាផ្លូវនៃវិសុទ្ធិ (សេចក្ដីបរិសុទ្ធ)។

### សេចក្ដីអធិប្បាយ

“សង្ខារបាននិយាយក្នុងបទនៃភាវនា ក្នុងទីនេះនឹងនិយាយបន្ថែមខ្លះទៀតតាមសមគួរដល់ដំណើរនៃសេចក្ដី។ សង្ខារក្នុងបទនេះម្ដងទៀត បានដល់ខន្ធបញ្ចកៈគឺរូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ។ រូបបានដល់រាងកាយដែលសង្គ្រោះដោយធាតុ ៤ ដី, ទឹក, ភ្លើង, ខ្យល់, វេទនាធម្មជាតិសោយនូវអារម្មណ៍



www.elibraryofcambodia.org

**សុខ, ទុក្ខ, ឧបេក្ខា, សញ្ញា**. ធម្មជាតិកត់សំគាល់នូវអារម្មណ៍, សង្ខារ បានដល់ចេតនាសម្រាប់រុញច្រានចិត្ត ធម្មជាតិនេះមានការកើតរលត់ជាមួយនឹងចិត្ត, វិញ្ញាណ ធម្មជាតិសម្រាប់ដឹងសម្រាប់ស្គាល់នូវអារម្មណ៍ដែលកើតឡើងតាមទ្វារទាំង៦ "**ចក្ខុ, សោតៈ, ឃានៈ, ជិវ្ហា, កាយៈ, ធម្មារម្មណ៍**" ខន្ធទាំងឡាយ៥នេះ មានវិញ្ញាណក្ខន្ធជាប្រធាន។ សង្ខារក្នុងបទមុន លោកសំដៅយកសភាពដែលធម្មតាបានតុបតែងឡើងតាមតែអ្វីក៏ដោយ។ សង្ខារក្នុងបទនេះលោកសំដៅយកសភាព សម្រាប់រុញច្រានចិត្តឲ្យប្រព្រឹត្តទៅក្នុងមុខការផ្សេងៗ តែលោកហៅថា "**សង្ខារ**" ដូចគ្នា។ សង្ខារប្រភេទនេះទោះណាជាមានសេចក្ដីដៅផ្សេងគ្នា មានការប្រព្រឹត្តទៅខុសគ្នា ដោយអំណាចនៃការចាត់ចែងរបស់កម្ម តែគង់មានលក្ខណៈត្រូវគ្នា គឺនៅក្នុងភាពជាអនិច្ចតា, ទុក្ខតា, អនត្តាហ្នឹងដែរ។

**អនិច្ចតា** បានដល់ភាពមិនទៀង, ភាពនេះគេអាចកំណត់អាចសំគាល់បានយ៉ាងងាយ ដោយវាមានកំណើតនៅខាងដើម, មានចំណាស់នៅក្នុងកណ្ដាល, មានសេចក្ដីស្លាប់ ឬចំណាស់នៃជីវិតនៅខាងចុងបំផុត។ សេចក្ដីក្នុងចំណុចនេះ លោកបានបញ្ជាក់ដោយសាសនភាសិតថា ៖

"**អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ**"

សង្ខារទាំងឡាយមិនទៀងសោះហ្ន៎! មានកំណើតហើយ "មានអំណស់វិញជាធម្មតា **ឧប្បជ្ជិត្វា និរុជ្ឈន្តិ**" មិនរើសថា សង្ខារថ្នាក់ណាបែបណាទេ ប្រណីតក៏ដោយ ថោកទាបក៏ដោយ កើតឡើងហើយត្រូវរលត់ទៅវិញជាធម្មតា។ សង្ខារទាំងឡាយណាកើតក្នុងអតីត សង្ខារទាំងឡាយនោះរលត់ក្នុងអតីត។ សង្ខារទាំងឡាយណាកើតក្នុងបច្ចុប្បន្ន សង្ខារទាំងឡាយនោះរលត់ក្នុងបច្ចុប្បន្ន។ សង្ខារទាំងឡាយណាកើតក្នុងអនាគតសង្ខារទាំងឡាយនោះរលត់ក្នុងអនាគត។ រយៈកាលអំពីកើតទៅរលត់ដោយសេចក្ដីសន្មតនោះ បើជាមនុស្សលោកកំណត់តិចជាង១០០ឆ្នាំឬលើសពី១០០ឆ្នាំមានខ្លះដែរ ប៉ុន្តែមានតិចជាទីបំផុត មិនដល់មួយភាគរយផងទេ។ នេះជាសេចក្ដីរលត់ជិតតាមអាយុខ័យឬ ស្លាប់តាម



www.elibraryofcambodia.org

កាល ឯការរលត់នៃជីវិតដែលមិនត្រូវតាមកាលកំណត់នៃអាយុខ័យ ឬស្លាប់មិនត្រូវតាមកាលនោះ មានច្រើនពន់ពេកណាស់។ ក្នុងធម៌ជាន់ខ្ពស់ ដែលមានស្តីអំពីរឿងនេះដដែល លោកបានណែនាំឲ្យកំណត់ដឹងនូវសេចក្តីប្រែប្រួល ចាប់តាំងពីកើតឡើងរហូតដល់រលត់ទៅវិញតាមពុទ្ធភាសិតនេះ ៖

**“អច្ចេន្តិ កាលា តរយន្តិ រត្តិយោ**

**វយោគុណា អនុបុព្វំ ជហន្តិ”**

“កាលទាំងឡាយដើរទៅដូចមានជើង រាត្រីទាំងឡាយហើរឆ្លងទៅដូចមានស្លាប វ័យគឺអាយុនៃសត្វទាំងឡាយ លះបង់បោលជីវិតទៅបន្តិចម្តងៗ ហាក់ដូចមានសេចក្តីស្អប់ខ្ពើម”។

វ័យតាមធម្មតាលោកចែកចេញជា៣យ៉ាងគឺៈ **បឋមវ័យ១, មជ្ឈិមវ័យ១, បច្ឆិមវ័យ១,** លោកបែងភាគវ័យមានចំនួនស្មើគ្នា ដោយកំណត់យករយៈកាល១០០ឆ្នាំជាមូលដ្ឋាន។ ការបែងភាគរបស់លោកដោយកំណត់យករយៈកាល១០០ឆ្នាំជាអាយុខ័យឬជាមូលដ្ឋាននោះ គឺថាការបែងភាគដែលមានការកត់សំគាល់ មានប្រើជាផ្លូវការនៃពុទ្ធសាសនាក្នុងពេលដែល ព្រះសម្មាសម្ពុទ្ធកំពុងមានព្រះជន្មនៅ។ យោបល់ខ្ញុំក្នុងរឿងនេះ, ខ្ញុំសូមធ្វើសេចក្តីបញ្ជាក់ជូនអ្នកអានថា ការបែងកាលនៃអាយុ ដែលលោកកំណត់យកសេចក្តីប្រែប្រួលមកធ្វើជាកំរិត ហើយទុកដាក់នូវកំរិតឲ្យមានចំនួនឬទំហំប៉ុនគ្នាឬស្មើគ្នានោះ បំណែងនេះឬកំរិតនេះឃើញថា ពុំសូវត្រឹមត្រូវតាមសេចក្តីពិត ដែលទ្រង់សម្តែងអំពីអរិយសច្ចធម៌ ដោយព្រះសម្មាសម្ពុទ្ធនៃយើងឡើយ។ តែជារបស់ងាយនឹងធ្វើសេចក្តីកត់សំគាល់របស់លោកម្យ៉ាងដែរ ដូចនេះគួរទុកការកំរិត និងបំណែងនេះ តាមទម្លាប់ដែលបានជាមានមកហើយ ក្នុងពុទ្ធសាសនានៃយើងទៅចុះ។ អាការប្រែប្រួលនៃសង្ខារធម៌ក្នុងខាងដើម វាជាសេចក្តីប្រែមែនពិត តែប្រែនៅក្នុងភាពផ្នែកចម្រើន។ ក្នុងចំណុចនេះ អ្នកអានគប្បីឃើញក្នុងរយៈកាលតាំង



www.elibraryofcambodia.org

អំពីកើតរហូតលុះចូលវ័យកម្លោះ[១] កម្មុំដែលយើងទម្លាប់និយាយថា **«វ័យពេញ»** ឬ **«ពេញវ័យ»** ។ នៅក្នុងរវាងនេះ រូបកាយកំពុងជាត់ធំរីកចំរើន នាមកាយឬចិត្តវិញ្ញាណនៃយើងកំពុងឆ្លាតវៃវាង គឺថាទាំងរូបទាំងចិត្តកំពុងរីកចម្រើនពេញទី រយៈកាលនេះលោកចាត់ទុកជាបឋមវ័យ មានកំណត់មិនលើសពី២៥ឆ្នាំ រាប់តាំងពីឆ្នាំកំណើតមកទល់នឹងឆ្នាំបច្ចុប្បន្ន។ ប្រពៃណីបានកំណត់យកអាយុ២៥ឆ្នាំជាអភិលក្ខិតកាល មួយថ្នាក់ឬមួយគ្រា បានដល់វ័យក្មេងហ្នឹងឯង។ ចាប់តាំងអំពីនេះទៅមុខ សង្ខារធម៌ឈប់លែងចម្រើន, តែសង្ខារខំពង្រីកនិងពង្រឹងជំហររបស់ខ្លួនឲ្យឋិតនៅក្នុងភាពជាប្រក្រតី ប្រែថាទប់នូវតំណោងមិនឲ្យមានការតោងទៅមុខនិងទប់នូវតំហយ មិនឲ្យមានការថយទៅក្រោយវិញ។ ក្នុងរវាងនេះ អ្នកអានគប្បីឃើញថារូបកាយរបស់យើងកំពុងមានទំហំពេញសម្រាប់ធ្វើការ, ចិត្តវិញ្ញាណរបស់យើងកំពុងមានពន្លឺពេញសម្រាប់គិតគូរ។ រយៈកាលនេះ លោកចាត់ទុកជាមជ្ឈិមវ័យ មានកំណត់មិនលើសពី៥០ឆ្នាំ រាប់តាំងពីឆ្នាំទី២៦មក។ ប្រពៃណីបានកំណត់យកអាយុ៥០ឆ្នាំ ជាអភិលក្ខិតកាលម្តងទៀត បានដល់វ័យកណ្តាលហ្នឹងឯង។ ចាប់តាំងអំពីនេះទៅមុខ សង្ខារធម៌មានសេចក្តីទ្រុឌទ្រោមចុះទៅបន្តិចម្តងៗ លុះត្រាកើតមានភាពប្រាកដជាក់ស្តែងដល់ភ្នែកអ្នកផង គឺមានធ្មេញបាក់, សក់ស្កូវ, ភ្នែកអន់ពន្លឺ, ត្រចៀកអន់សំនៀង, ច្រមុះអន់កម្លិន, អណ្តាតអន់ដំណឹងរស, កាយអន់ពំនាល់, ចិត្តអន់គំនិត, អវយវៈទាំងអស់អនរបីក...។

រយៈកាលនេះលោកចាត់ទុកជាបច្ឆិមវ័យ រាប់តាំងពីអាយុ៥០ឆ្នាំរៀងរហូតដល់ជីវិតត្រូវរលត់។ ចំណែកខាងប្រពៃណីបានកំណត់យកអាយុជាខាងដើមមជ្ឈិមវ័យ ថាជាមនុស្សអស់ធំ ខាងចុងបច្ឆិមវ័យថាជាមនុស្សចាស់ គឺពី៣០ឆ្នាំទៅទល់នឹង៦០ឆ្នាំ។ ចំណែកខាងបរមត្ថធម៌លោកកំណត់យកការចាប់

[១] «កម្មុំ» ជាពាក្យនាម ចេញមកអំពីពាក្យគុណថា ខ្ចុំ ដូចគ្នានឹងពាក្យកម្លោះដែលជាពាក្យនាម ចេញមកអំពីពាក្យគុណថា ខ្លោះ។



www.elibraryofcambodia.org

មានកំណើតថាជាភាពមានចំណាស់តាំងតែអំពីកាលនោះមក ដូចមានចែងក្នុងលក្ខណៈរូប ៤ “**ឧបចយៈ, សន្តតិ, ជរតា, អនិច្ចតា**” ស្រាប់។

ដូច្នេះ អ្នកអានគប្បីធ្វើសេចក្ដីសន្និដ្ឋានដោយខ្លួនឯងចុះ និងសន្និដ្ឋានតាមមតិណា ឬយោបល់ណាក៏បាន ព្រោះព្រំដែននៃវ័យលោកកំណត់មិនត្រូវគ្នាដូចខ្ញុំបាននិយាយមកហើយ។ នៅក្នុងរឿងនេះប្រសិនបើយើងកំណត់យកវ័យប៉ុណ្ណេះប៉ុណ្ណោះថាជាក្មេង, ជាកណ្ដាល, ជាចាស់ សេចក្ដីសន្និដ្ឋានរបស់យើងនេះ ឈ្មោះថាបានផ្អែកទៅលើប្រពៃណីនិងហោរាសាស្ត្រ ឬមានប្រពៃណីនិងហោរាសាស្ត្រជាមូលដ្ឋាន តែបើយើងកំណត់ថា ចំណាស់ចាប់ផ្ដើមមានឡើងតាំងអំពីកំណើត សេចក្ដីសន្និដ្ឋានរបស់យើងនេះ ឈ្មោះថាបានផ្អែកទៅលើបរមត្ថធម៌ ឬមានបរមត្ថធម៌ជាមូលដ្ឋាន ព្រោះកំឡាំងនៃសេចក្ដីប្រែ ឬភាពប្រែដែលធម្មតាបានតាក់តែងឡើង ពោលគឺអាយុឬជីវិតនៃមនុស្ស, សត្វនេះ វាមានបរិមាណមិនស្មើគ្នា តាមការកំណត់ដូចជាកំពុងកើត ដែលយើងធ្លាប់ធ្វើសេចក្ដីប៉ាន់ស្មានថា មិនទាន់មានចំណាស់នោះ ការពិតកំណើតវាស្ថិតនៅក្នុងលក្ខណៈប្រែភាព ប្រែថាវាកំពុងរីកដុះដាលចម្រើនឡើង ហើយរបីករបស់វានេះ ក្នុងបរមត្ថធម៌លោកឲ្យឈ្មោះថា “ចំណាស់” តែជាចំណាស់ដែលមានភាពយ៉ាងល្អិតជាអតិបរមា ដែលលោកឲ្យឈ្មោះម្យ៉ាងទៀតថា “ចាស់មានអាថ៌កំបាំង” បានដល់ចាស់ដែលយើងមិនស្គាល់ឬមិនដឹង ប្រែថាចាស់មានដំណើរដើរទៅជាមួយនឹងដំណើរវិលទៅនៃពេលវេលា។ ចលនានេះឋិតនៅក្នុងភាពសន្សឹមៗតិចតួចពន់ពេកណាស់ ទើបវាធ្វើឲ្យវិស័យនៃការសង្កេតរបស់យើងវិលមិនទាន់ឬមើលមិនឃើញ។ សេចក្ដីត្រង់ចំណុចនេះ ត្រូវតាមពុទ្ធសាសនភាសិតទាំងឡាយពីរដូចតទៅនេះ ៖

“**បឋមំ កលលំ ហោតិ កលលា ហោតិ អព្ពុទំ**
**អព្ពុទា ជាយតេ បេសិ បេសិយា ជាយតេ ឃនោ**
**ឃនា ជាយន្តិ សាខាបិ កេសា លោមា នខាបិច**”។



www.elibraryofcambodia.org

វិតក្កៈ, វិចារៈ រមែងប្រែទៅតាមចិត្តដែលប្រារព្ធដល់អារម្មណ៍នោះៗ។ ការផ្លាស់អារម្មណ៍របស់ចិត្ត ក្នុងលក្ខណៈបែបណា ឬត្រាច់ទៅយ៉ាងណា, ការប្រែភាពរបស់រូបក៏មានលក្ខណៈ មានដំណើរដូចគ្នានឹងចិត្តអីចឹងដែរ តែដឹងបានដោយកម្រណាស់។ អ្នកអានគប្បីដឹងអំពីរឿងធ្មេញមួយទុកជាឧទាហរណ៍ ធ្មេញធម្មជាតិរបស់យើង, ដែលយើងប្រើការទំពាអាហាររាល់ថ្ងៃ ដូចម្តេចទើបវាមិនសឹកមិនរេចដូចធ្មេញវិទ្យាសាស្ត្រ ឬធ្មេញដែលយើងដាក់ចូលថ្មី។

ចំពោះបញ្ហានេះ ខ្ញុំសូមធ្វើសេចក្តីបញ្ជាក់ជាមួយនឹងចម្លើយថា ធ្មេញទាំងពីរបែបនេះវាមានការសឹករេចដូចគ្នា តែធ្មេញធម្មតាវាមានធាតុមួយមានឈ្មោះជាអណូកើតជំនួសឬចូលមកបំពេញ ទើបវាមានភាពប្រាកដដូចជាមិនមានសឹករេច ភាពនេះយើងសង្កេតបានដោយកម្រណាស់ក្នុងរយៈពេលយ៉ាងខ្លី ប្រែថាយើងមិនងាយនឹងដឹងនូវចលនាសឹករេច និងចលនាប៉ះបន្ថែមក្នុងពេលខ្លីពេកបានឡើយ។ អាស្រ័យហេតុដូចពោលមកនេះ ទើបអ្នកប្រាជ្ញខាងបរមត្ថធម៌លោកនិយាយថា ភាពកើតឡើងនៃសភាវធម៌ទាំងឡាយមានត្រឹមតែមួយខណៈប៉ុណ្ណោះ ហើយរលត់ទៅ, តែមានភាពដទៃថ្មីទៀតកើតជំនួសតទៅ ទើបវាត្រូវមាននៅជាប់មិនដាច់ ហើយបន្លះថ្មីនេះ ក៏បានជាធាតុមានភាពប្រាកដជាក់ស្តែងដល់ភ្នែកជាមួយនឹងគំនិតរបស់យើងផង។ កិរិយាដែលកើតជាប់តគ្នាយ៉ាងនេះ លោកហៅថា «**សន្តតិ**» ក្នុងកាលណាដែលសន្តតិមានដំណាច់, ក្នុងកាលនោះភាពរលត់ ភាពអស់រមែងប្រាកដដល់សេចក្តីសង្កេតរបស់យើង សេចក្តីស្លាប់លោកកំណត់សម្គាល់ដោយដំណាច់នៃសន្តតិ ការកើតហើយរលត់ទៅវិញ ព្រមទាំងភាពប្រែនៃសង្ខារធម៌ទាំងឡាយ ដូចបាននិយាយមកនេះ សង្គ្រោះចូលក្នុងបាលីភាសិតថា ៖

«**ឧប្បជ្ជតិ ចេវ វេតិ ច អញ្ញត្ថ ច ភវតិ**»

«រមែងកើតឡើងផង, រមែងសាបសូនទៅវិញផង រមែងកើតក្នុងទីដទៃទៀតផង» ជាអនិច្ចលក្ខណៈ, ជាគ្រឿងកំណត់ថា មិនមានសេចក្តីទៀងទាត់



www.elibraryofcambodia.org

ឋិតថេរនៃសង្ខារទាំងឡាយ។

អនិច្ចលក្ខណៈនេះប្រព្រឹត្តទៅលើរូបធម៌ផង, នាមធម៌ផង, រូបធម៌បានដល់ធម្មជាតិដែលលោកសន្មតថា មនុស្ស, សត្វ, ដើមឈើ, ទេព, ឥន្ទ្រ, ព្រហ្ម... ដែលនៅក្នុងរូបនៃមនុស្ស, នៃសត្វ, នៃដើមឈើ, នៃទេព, នៃឥន្ទ្រ, នៃព្រហ្ម ... ទាំងអស់នេះ មានចិត្តវិញ្ញាណដែលលោកញែកឲ្យឈ្មោះថា នាមធម៌ផងដែរ។ អរូបធម៌ឬនាមធម៌ បានដល់អរូបព្រហ្ម, ផ្ទះ, ប្រសាទ, វិមាន, ដី, ទឹក, ភ្លើង, ខ្យល់, ចាន, ពែង, ចាន, ឆ្នាំង, កែវ, រទេះ, ទូក, កប៉ាល់។ល។ ដែលលោកញែកឲ្យឈ្មោះថា រូបធម៌ផងដែរ, នាមធម៌និងរូបធម៌នេះ មានទម្លាប់មួយទៀតនិយាយថា "ឧបាទិន្នកសង្ខារ អនុបាទិន្នកសង្ខារ" សេចក្ដីបកប្រែនៃសង្ខារទាំងពីរនេះ អ្នកអានធ្លាប់ចេះចាំមកហើយ។

**ទុក្ខតា** ភាពជាទុក្ខនៃសង្ខារធម៌ទាំងឡាយ លោកបានធ្វើសេចក្ដីកត់សម្គាល់ជាមួយនឹង គំហើញរបស់លោកមានដូចនេះ៖

១- **សភាវទុក្ខ** ឬទុក្ខមាននៅប្រចាំសង្ខារ បានដល់ជាតិ, ជរា, មរណៈ....។

២- **បកិណ្ណកទុក្ខ** ឬទុក្ខគ្រាច់ចរបានដល់ **សោកៈ**, **បរិទេវៈ**, **ទុក្ខៈ**, **ទោមនស្សៈ**, **ឧបាយាសៈ**....។

ទុក្ខទាំងពីរពួកនេះមាននិយាយក្នុងគម្ពីរបាលីទូទៅ ចំណែកទុក្ខក្នុងនិទ្ទេសនៃអរិយសច្ចៈ លោកបន្ថែមទុក្ខដទៃទៀតមកលើទុក្ខក្នុងពួកទី ២ គឺៈ **អប្បិយេហិ សម្បយោគោទុក្ខ បិយេហិ វប្បយោគោទុក្ខ, យម្បិច្ឆំ នលភតិ តម្បិទុក្ខ** (សេចក្ដីប្រែនៃទុក្ខទាំងអស់នេះ អ្នកអានធ្លាប់ចេះចាំមកហើយ)។

**ទុក្ខពួកទី១** បើតាមសេចក្ដីត្រិះរិះ ពិចារណារបស់ខ្ញុំឃើញថា សេចក្ដីទុក្ខនេះ ទំនងជាលោកដៅយកការសម្រាលឬការកើតចាកផ្ទៃនៃមាតារបស់ទារកទាំងឡាយ ដែលលោកសង្កេតឃើញថា ទារកមានសេចក្ដីលំបាកយ៉ាងនេះគួរខ្លាច គួរភ័យ ចំពោះអន្តរាយគ្រប់យ៉ាងនោះ នេះគឺជាតិទុក្ខ។ សេចក្ដីទ្រុឌ



www.elibraryofcambodia.org

ទ្រទ្រាមស្រេកស្រុតនៃសង្ខារធម៌ទាំងឡាយ វាធ្វើឲ្យមនុស្សមានចំណាស់ មានសេចក្ដីលំបាកយ៉ាងនេះ យ៉ាងនោះ នេះគឺជរាទុក្ខ។ សេចក្ដីអស់ជីវិតនៃសត្វទាំងឡាយ វាបង្កើតឲ្យមានវេទនាយ៉ាងខ្លាំងក្លា ដូច្នេះ ដូច្នោះ នេះគឺជាមរណទុក្ខ។ អ្នកសិក្សាខ្លះ ចូលចិត្តអំពីជាតិទុក្ខដោយសេចក្ដីយ៉ាងទូលំទូលាយ ជាងដែលលោកយល់ឃើញហើយបានចាត់ទុកមក គឺចូលចិត្តថា ទុក្ខនេះមានសេចក្ដីជ្រាបចូលទៅក្នុងកំណើត, មានកំណើតជាមូលដ្ឋាន ប្រែថា មានទុក្ខតាំងពីនៅក្នុងផ្ទៃម្ដាយ រហូតដល់ពេលកំពុងសម្រាលចេញនិងពេលជាបន្តបន្ទាប់មកទៀត។ សេចក្ដីចូលចិត្តនេះមិនមាននរណាបដិសេធបានទេ ព្រោះសេចក្ដីទុក្ខក្នុងអរិយសច្ចៈនោះ មានកំពស់ មានជម្រៅពន់ពេកណាស់ បើតាមសេចក្ដីកត់សម្គាល់ជាមួយនឹងគំហើញរបស់បរមត្ថវិទូនេះ លោកបានធ្វើនូវសេចក្ដីបញ្ជាក់អំពីរឿងទុក្ខនេះថា ការកើតមិនមែនដោយកត្រឹមតែការសម្រាលចេញចាកផ្ទៃម្ដាយទេ គឺដោយកការខំធ្វើឲ្យកំណើតរីកចំរើននៅក្នុងផ្ទៃម្ដាយនិងខំប្រឹងអត់ទ្រាំនៅក្នុងផ្ទៃម្ដាយនោះឯង។ គំហើញនេះត្រូវហើយតែគ្រាន់តែលំបាកនិយាយវែកញែក ដើម្បីឲ្យអ្នកមិនទាន់យល់, មិនទាន់ភ្លឺ ក្នុងរឿងនេះមានយោបល់ មានពន្លឺបានតាមលំដាប់នៃទុក្ខដែលចែកចេញជាប្រភេទ។ ចំពោះរឿងជាតិទុក្ខនេះក៏ដូចជារឿងមរណទុក្ខ ដែលគេចូលចិត្តថា ទុក្ខនេះមានឡើងព្រោះភ័យតក់ស្លុតខ្លាចសេចក្ដីស្លាប់ នេះជាយោបល់មួយ។

យោបល់មួយទៀតថា ទុក្ខកើតឡើងព្រោះលំបាកទ្រាំមុននឹងចុតិ។ សេចក្ដីត្រង់ចំណុចនេះ អ្នកអានទាំងឡាយ សូមចាំសង្កេតពិចារណាជាមួយនឹងសំណេររបស់ខ្ញុំ ដែលនឹងមានទៅខាងមុខខ្លះទៀត។

**ទុក្ខពួកទី២** ក្រៅអំពីទុក្ខជាចំណែកចេតសិក ដែលមាននិយាយទុកទៅក្នុងគម្ពីរបាលីនោះ, មានទុក្ខកើតព្រោះព្រាត់ប្រាសចាកអារម្មណ៍ជាទីស្រឡាញ់ ព្រោះជួបប្រទះនឹងអារម្មណ៍មិនជាទីប្រាថ្នា ព្រោះចង់បានអ្វីមិនបានដូចបំណង...។

**ទុក្ខពួកទី៣ និព្វទ្ធទុក្ខ** គឺទុក្ខជាប់ជានិច្ចកាលឬទុក្ខមានប្រចាំរូបកាយ



www.elibraryofcambodia.org

បានដល់ភាពក្ដៅ, ភាពត្រជាក់, គំលាន, សម្រេក, បន្ទោបង់ឧច្ចារ, បស្សាវៈ ...។ ទុក្ខប្រភេទនេះ មិនសូវមានអ្នកណានឹកនាដល់ទេ ព្រោះវាមានជាប់ជានិច្ចកាល, វាក្លាយទៅជាទម្លាប់ ហើយវាជាទុក្ខដែលគេអាចព្រានចោលបានដោយងាយផង តែមានពេលខ្លះ ដែលទុក្ខនេះមានកម្លាំងខ្លាំងក្លាលើសធម្មតាគេក៏ទ្រាំពុំបាន គេក៏ហៅគេហៅឯងជួយកំចាត់បង់ដែរ។

**ទុក្ខពួកទី៤ ព្យាធិទុក្ខ** ឬទុក្ខវេទនាមានប្រភេទផ្សេងៗ បានដល់ជម្ងឺ (ជម្ងឺ) ទាំងឡាយ ដែលកើតឡើងតាមសមុដ្ឋាននានា ព្រោះអវយវៈឬនគរកាយ ធ្វើការពុំបានប្រក្រតី។

ទុក្ខពួកទី៣និងទី៤ មានមកក្នុងគិរិមានន្ទសូត្រត្រង់ចំណុចដែលស្ដីអំពីអាទីនវសញ្ញា សេចក្ដីកត់សម្គាល់នូវទោសដែលកើតមានឡើងព្រោះរូបកាយ។

**ទុក្ខពួកទី៥ សន្តាបទុក្ខ** ទុក្ខគឺសេចក្ដីក្ដៅក្រហាយ បានដល់សេចក្ដីក្រវល់ក្រវាយ (ខ្វល់ខ្វាយ) ក្នុងចិត្តព្រោះត្រូវភ្លើងពោលគឺកិលេស ដែលយើងធ្លាប់ស្គាល់ថា **រាគៈ**, **ទោសៈ**, **មោហៈ** ដុតរោល។

ទុក្ខប្រភេទនេះមានមកក្នុងអាទិត្តបរិយាយសូត្រ, ដែលមាននិយាយរាលដាលដល់បកិណ្ណកទុក្ខផង តែលោកពុំបានហៅថាភ្លើងដូចកិលេស លោកប្រើត្រឹមតែកិរិយថាដុតប៉ុណ្ណោះ។

**សោកៈ**, **បរិទេវៈ**, **ឧបាយាសៈ** បើនិយាយតាមផលដែលកើតឡើងឃើញថាជាប់ទាក់ទងមកអំពីរាគៈក្នុងពេលដែលមិនបានទទួលបិយារម្មណ៍សមតាមប្រាថ្នាឬក្នុងពេលដែលបានសមតាមសេចក្ដីសង្ឃឹមហើយ តែត្រឡប់បាត់បង់ទៅវិញ។ ទោមនស្សៈបើសង្កេតតាមផល ទំនងដូចជាកើតឡើងអំពីទោសៈ។ **ទុក្ខៈ**បើនឹងសម្រេចថាជាផលកើតមកអំពី**មោហៈ** ឃើញថាសមណាស់ដែរ តែអ្នកដែលមានការសិក្សាតិចស្ដាប់ពុំសូវយល់។ដូចនេះ, ឃើញថាការសង្គ្រោះបកិណ្ណកទុក្ខទៅជាភ្លើងមួយភ្នក់ទៀត ទើបមានសេចក្ដីមិនសូវសមនិងក្រសែនៃទុក្ខ តែពុំអាចនឹងបដិសេធថាខុសស្រឡះបានឡើយ។ ដើម្បីឲ្យ



www.elibraryofcambodia.org

ងាយស្តាប់ងាយយល់ គួរចាត់សេចក្តីទុក្ខទាំងឡាយឲ្យនៅតាមក្រុមដើមដែលលោកបញ្ជាក់ថា កើតព្រោះត្រូវកិលេសដុត ដូចគ្នានឹងកំដៅដែលកើតព្រោះភ្លើង។

**ទុក្ខពួកទី៦ វិបាកទុក្ខ** បានដល់សេចក្តីក្តៅក្រហាយក្នុងចិត្តព្រោះត្រូវទណ្ឌកម្ម ត្រូវអាជ្ញាធរកាត់ទោស ត្រូវធ្លាក់ខ្លួនជាមនុស្សក្រលំបាក ត្រូវធ្លាក់ទៅកើតក្នុងអបាយភូមិ។ល។ ទុក្ខនេះមានសម្តែងក្នុងគម្ពីរបាលីទូទៅស្រាប់ហើយ។

**ទុក្ខពួកទី៧ បានដល់សហគតទុក្ខ** ទុក្ខកើតព្រោះនៅរួមគ្នាព្រោះធ្វើដំណើររួមគ្នា. ទុក្ខប្រភេទនេះ ក្នុងលោកធម្មសូត្រ លោកបាននិយាយព្រមទាំងធ្វើសេចក្តីបញ្ជាក់ថា លាភៈ យសៈ បសំសៈ សុខៈ របស់ទាំងនេះវាកើតមកពីបុណ្យកុសលដែរ តែបើអ្នកទទួលផលនេះមិនចេះ ប្រើប្រាស់ឬប្រើប្រាស់មិនត្រូវ វាក៏ត្រឡប់ផ្តល់ទុក្ខឲ្យវិញដែរ។ អ្នកខ្លះយល់ថារបស់ទាំងឡាយនេះ គួរចាត់ជាវិបរិណាមទុក្ខ សំដៅសេចក្តីថា ព្រោះវាមានសេចក្តីប្រែប្រួល វាមិនមែនជារបស់មានភាពទៀងទាត់។ យោបល់មួយទៀត អ្នកមានទ្រព្យគឺលាភ ត្រូវមានទុក្ខព្រោះលំបាករក្សាថែទាំ ព្រោះការរក្សានេះវាធ្វើឲ្យខានដេក ខានទៅណាមកណាតាមដែលចិត្តចង់ ចួនកាលមានស្លាប់ខ្លួនព្រោះរក្សាការពារទ្រព្យ។ មានយសបានទទួលតំណែងធំដុំ ក៏មានសេចក្តីព្រួយលំបាកក្នុងមុខការរបស់ខ្លួន។ បានទទួលសេចក្តីសរសើរអំពីអ្នកដទៃ ធម្មជាតុនេះក៏មានពិសដូចគ្នានឹងពិសសុរាដែរ តែសប្បាយនឹងពាក្យសរសើររបស់គេភ្លេចខ្លួន ក៏នាំឲ្យមានទុក្ខដោយសារតែកំហុសណាមួយ ដែលវាឆ្លៀតយកឱកាសចូលមកក្នុងពេលដែលខ្លួនកំពុងតែស្រវឹងនឹងពាក្យសរសើរនោះ។សេចក្តីសុខក៏វាមានគូរបស់វាជាមួយសេចក្តីទុក្ខ តែយើងភ្លេចស្មារតីមិនបានប្រុងប្រយ័ត្នក្នុងពេលសោយសុខ សេចក្តីទុក្ខវាក៏លបចូលមកដណ្តើមយកសេចក្តីសុខរបស់យើងជាមិនខាន។

**ទុក្ខពួកទី៨ បានដល់អាហារបរិយេដ្ឋិទុក្ខ** គឺទុក្ខកើតមានឡើងព្រោះប្រកបអាជីវកម្មគ្រប់ប្រភេទ។ ជីវិតសត្វទាំងឡាយ វាជាគូប្រណាំងប្រជែងគ្នា,



www.elibraryofcambodia.org

ដណ្ដើមចេះ, ដណ្ដើមមាន, ដណ្ដើមធំ។ ការប្រណាំងប្រជែងនេះ វាជាហេតុនាំឲ្យមានការរុញច្រានគ្នាទម្លាក់ដើម្បីយកជោគជ័យតែរៀងខ្លួននេះក៏ជាទុក្ខ ព្រោះចូលក្នុងការបៀតបៀនធ្វើបាបដល់គ្នានិងគ្នា។ ក្រៅអំពីនេះ អាជីវកម្មមួយមុខៗរបស់មនុស្សយើងនោះទៀតសោត ក៏មានឧបសគ្គច្រើនបែបច្រើនយ៉ាងជាសត្វសាហាវក៏មាន ជាធម្មជាតិក្ដៅត្រជាក់ក៏មាន។ល។ ដូចនេះទើបលោកឲ្យឈ្មោះថាទុក្ខព្រោះស្វែងរកអាហារ។

**ទុក្ខពួកទី៩ បានដល់វិវាទមូលកទុក្ខ** ទុក្ខកើតឡើងព្រោះជម្លោះ ព្រោះចម្បាំង។ ទុក្ខប្រភេទនេះអ្នកអានអាចសិក្សាខ្លួនឯងបានយ៉ាងពិស្ដារវែងឆ្ងាយណាស់ ប្រសិនបើអ្នកអានបានយល់ថា ពិភពលោកនេះ មនុស្សទាំងឡាយមានចិត្តបំរើតណ្ហា។ សេចក្ដីទុក្ខបែបនេះ លោកសំដែងក្នុងបាលីទូទៅថាជាកាមាទីនវទុក្ខក៏មាន។

**ទុក្ខពួកទី១០ បានដល់ទុក្ខខន្ធ** ទុកនេះមានចែងច្បាស់ក្នុងនិទ្ទេសនៃអរិយសច្ចៈស្រាប់ហើយ។ អ្នកអានប្រសិនណាបើចង់ដឹងសេចក្ដីពិស្ដារ គប្បីតាមមើលក្នុងទីនោះផងចុះ។

ការពិចារណាឃើញសង្ខារទាំងឡាយថាជាទុក្ខនោះ លោកសំដៅយកទុក្ខដែលបានចាត់ជាពួកដូចពោលមកហើយនេះផង ទុក្ខទាំងឡាយដែលមានក្នុងនិទ្ទេសនៃអរិយសច្ចៈផង ដូចនេះព្រោះអ្វី? ព្រោះទុក្ខទាំងអស់នេះ មានទុក្ខខ្លះគេអាចស្គាល់បាន ដឹងបានដោយមិនចាំបាច់ប្រើបញ្ញាពិចារណា មានទុក្ខខ្លះ មនុស្សលោកពុំបានស្គាល់ពុំបានដឹងទ ប្រសិនបើគេមិនបានចម្រើនវិបស្សនាបញ្ញាឬពុំបានសិក្សាអំពីការកត់សំគាល់។ ដោយអាស្រ័យហេតុនេះទើបមានពុទ្ធសាសនភាសិត សម្ដែងដាស់តឿនស្មារតីនៃមនុស្សយើង ដែលខ្ញុំសូមសរសេរខ្លះមុននឹងឈប់និយាយអំពីទុក្ខដូចមានតទៅនេះ ៖

**«ទុក្ខមេវ ហិ សម្ភោតិ ទុក្ខំ តិដ្ឋតិ វេតិ**

**ច នាញ្ញត្រ ទុក្ខា សម្ភោតិ នាញ្ញំ ទុក្ខា និរុជ្ឈតិ»។**



www.elibraryofcambodia.org

“មានតែទុក្ខទេដែលកើតឡើង មានតែទុក្ខទេដែលតាំងនៅ មានតែទុក្ខទេដែលប្រែភាពផ្លាស់ប្តូរទៅ ក្រោយអំពីទុក្ខមិនមានអ្វីដទៃកើត, ក្រៅអំពីទុក្ខមិនមានអ្វីដទៃរលត់”។

ភាសិតនេះបញ្ជាក់ឲ្យឃើញថា អ្វីៗទាំងអស់នៅក្រោមអំណាចទុក្ខគ្របសង្កត់, នៅក្នុងអំណាចនៃទុក្ខធ្វើឲ្យប្រែប្រួលដូរផ្លាស់។ ដូច្នេះទើបមានសេចក្តីបញ្ជាក់ក្នុងនិទ្ទេសនៃអរិយសច្ចៈថា “ទុក្ខសច្ចៈ”។

**“ទុក្ខមេវ ហិ ន កោចិ ទុក្ខិតោ**

**ការកោ ន កិរិយាវ វិជ្ជតិ**

**អត្ថិ និព្វុតិ ន និព្វុតោ បុមា**

**មគ្គោ អត្ថិ គមកោ នវិជ្ជតិ”។**

“សេចក្តីទុក្ខមានមែនពិត ឯបុគ្គលសោយទុក្ខមិនមានទេ, ទំរើមាន ឯអ្នកធ្វើមិនមានទេ សេចក្តីរលត់មាន ឯអ្នករលត់ពុំមានទេ ផ្លូវដើរមាន ឯអ្នកដើរមិនមានទេ”។

ភាសិតនេះបញ្ជាក់សេចក្តីឲ្យយើងឃើញថាទុក្ខមាន ប៉ុន្តែមិនមានអ្នកស្គាល់, មិនមានអ្នកសោយ ក្នុងន័យថា មិនមានអ្នកធុញទ្រាន់, ទំរើធ្វើឲ្យអស់ទុក្ខមាន ប៉ុន្តែពុំមានអ្នកណាធ្វើ, សេចក្តីរលត់ទុក្ខមាន, ប៉ុន្តែមិនមានអ្នករលត់ក្នុងន័យថាមិនមានអ្នកណាធ្វើឲ្យទុក្ខរលត់ ផ្លូវដើរទៅកាន់ទីរលត់ទុក្ខមាន, ប៉ុន្តែមិនមានអ្នកដើរ។

ទុក្ខលក្ខណៈនេះ យោបល់ខ្លះថា មានចំពោះតែមនុស្ស, សត្វ, ដើមឈើដែលមានចិត្តវិញ្ញាណ។ ចំណែកខាងទឹក, ដី, ភ្លើង, ខ្យល់, ផ្ទះ, ប្រាសាទ, វិមាន, ចាន, ឆ្នាំង, ពែង។ល។ ដែលមិនមានចិត្តវិញ្ញាណ ពុំមានទុក្ខទាំងឡាយនេះទេ យោបល់នេះក៏សមម្យ៉ាងដែរ តែបើតាមអត្ថន័យឬតាមសព្ទថា “**ទុក្ខ**” នេះ អ្វីៗទាំងអស់សុទ្ធតែមានទុក្ខដូចគ្នា ព្រោះពាក្យថា “ទុក្ខៈ” ប្រែថា “អត់ទ្រាំមិនបាន” ។ ដូចនេះ ធម្មជាតុទាំងអស់មិនថាអ្វីជាអ្វីទេ វាជារបស់ទ្រាំរស់,



www.elibraryofcambodia.org

ទ្រាំកើត, ទ្រាំពុកែ, ទ្រាំជាប់, ទ្រាំតាំងខ្លួននៅក្នុងភាពមួយៗពុំបានដូចគ្នាទាំងអស់ បើយ៉ាងដូចនេះហើយ ដីបាក់, ដីស្រុត... ទឹករីង, ទឹកស្ងួត ... ភ្លើងរលត់, ភ្លើងរលាយ...ខ្យល់ស្ងប់, ខ្យល់បាត់, ផ្ទះរលំ, ភ្នំរលើង។ល។ ក៏ត្រូវបានឈ្មោះថាមានទុក្ខដូចមនុស្ស, សត្វ, ដើមឈើ...អីចឹងដែរ។

**អនត្តតា** ភាពជាអនត្តានៃសង្ខារ ភាពនេះអ្នកអានគប្បីកត់សម្គាល់ដោយអាការៈទាំងឡាយនេះគឺ ៖

១- ដោយមិននៅក្នុងអំណាច, មិនស្តាប់បង្គាប់, មិនលុះក្នុងសេចក្តីប្រាថ្នា ដូចមានសេចក្តីបញ្ជាក់ក្នុងអនត្តលក្ខណសូត្រថា «បើបញ្ចក្ខ័ន្ធនៅក្នុងសេចក្តីកត់សំគាល់របស់យើងថាជា**អត្តា** បញ្ចក្ខន្ធនឹងមិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធ សត្វទាំងឡាយនឹងមានសិទ្ធិក្នុងបញ្ចក្ខ័ន្ធ ដោយដាក់ឲ្យបញ្ចក្ខ័ន្ធនៅជាយ៉ាងនេះ, នៅជាយ៉ាងនោះ, កុំទៅជាដូចនេះ កុំទៅជាដូចនោះ ហេតុតែបញ្ចក្ខ័ន្ធជាអនត្តា បញ្ចក្ខ័ន្ធទើបប្រព្រឹត្តទៅដើម្បីអាពាធ សត្វទាំងឡាយមិនមានសិទ្ធិដឹងនាំបញ្ចក្ខ័ន្ធឲ្យប្រព្រឹត្តទៅតាមបំណងរបស់ខ្លួនបានឡើយ។

២- ដោយមានការប្រកែងចំពោះអត្តា ដូចមានសម្តែងក្នុងអនត្តលក្ខណសូត្រថា «របស់ណាមិនទៀង, ជាទុក្ខ, មានសេចក្តីប្រែប្រួលជាធម្មតា វាគួរដែរឬ! ដែលយើងទាំងឡាយមានគំហើញក្នុងរបស់នោះថា នេះជារបស់យើង, នោះជារបស់យើង ទាំងអស់នេះវាជាខ្លួនរបស់យើង។

៣- ដោយធម្មជាតុនេះ មានភាពមិនមានអ្នកណាជាម្ចាស់ មិនមានអ្នកណាត្រួតត្រាបានដូចសម្តែងក្នុងសូត្រទាំងឡាយ មានអនត្តលក្ខណសូត្រជាដើមថា “**នេតំមម**” នោះមិនមែនរបស់យើង “**នេសោហមស្មិ**” នោះមិនមែនជាយើង “**ន មេ សោ អត្តា**” នោះមិនមែនជាខ្លួនរបស់យើង។

៤- ដោយមានភាពជាសភាពសូនសោះ គឺជារបស់ទទេ ឬជារបស់តែងបាត់ទៅ, អស់ទៅតាមធម្មតានៃសភាវធម៌ ដូចមានសេចក្តីបញ្ជាក់របស់ព្រះសម្មាសម្ពុទ្ធជាមួយនឹងចម្លើយរបស់ព្រះអង្គ ចំពោះសំនួរមោឃរាជមាណព ក្នុង



www.elibraryofcambodia.org

បរាយនវគ្គ សុត្តនិបាតថា ៖

**«សុញ្ញតោ លោកំ អវេក្ខស្សុ មោឃរាជ សទា សតោ**

**អត្តានុទិដ្ឋឹ ឱហច្ច ឯវំ មច្ចុត្តរោ សិយា**

**ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ»។**

«នែមោឃរាជ! ចូរអ្នកមានសតិគ្រប់កាល ចូរឃើញលោកដោយភាពជារបស់សោះសូន ចូរដកចេញឲ្យអស់នូវ **អត្តានុទិដ្ឋិ** គឺគំហើញ ដែលខ្លួនអ្នកធ្លាប់ឃើញធ្លាប់ចូលចិត្តថាជាអត្តា បើអ្នកធ្វើបានដូចនេះ ខ្លួនអ្នកនឹងត្រូវបានជាបុគ្គលឆ្លងផុតចាកមច្ចុរាជ, មច្ចុរាជពុំអាចមើលជន ដែលមានបញ្ញាឃើញលោកដូចនេះបានឡើយ» ។

សង្ខារជារបស់មានភាពទទេនោះ អ្នកអានអាចនឹងស្គាល់បានយ៉ាងនេះ ក្នុងកាលណាបុគ្គលពិចារណាឃើញឬធ្វើនូវសេចក្ដីកត់សំគាល់នូវសង្ខារៈ ដោយវិធីបំបែកចេញជាចំណែកផ្សេងៗគ្នា ឬជាចំណែកតូចៗគឺធ្វើរបស់ដុំឲ្យទៅជារបស់រាយ ប្រៀបរុះរើចេញនូវខ្លួនប្រាណទាំងមូលឲ្យទៅជាសក់ រោម, ក្រចក, ធ្មេញ, ស្បែក...ហើយខំប្រឹងពិនិត្យមើលរបស់ដែលរុះរើចេញនោះ ឲ្យឃើញថាជាដី, ទឹក, ភ្លើង, ខ្យល់ ...លុះបានដកចេញនូវឃនសញ្ញា (ភាពដែលធ្លាប់កំណត់ថាជាដុំ) ជាមួយនឹងកំណាន់ដែលធ្លាប់មានក្នុងនិមិត្តថាយើង, ថាគេ, ថាអ្នកនេះ, ថាអ្នកនោះ...ដូចមានបញ្ជាក់ក្នុងបាលីថា ៖

**«យថា ហិ អង្គសម្ភារា ហោតិ សទ្ទោ រថោ ឥតិ**

**ឯវំ ខន្ធេសុ សន្តេសុ ហោតិ សត្តោ រថោ ឥតិ»។**

«សេចក្ដីមានថា ព្រោះតែមានការដាក់ចូលនូវសម្ភារៈទាំងឡាយឲ្យនៅក្នុងទីជាមួយគ្នា សម្លេងថារថទើបត្រូវកើតមានឡើង សេចក្ដីនេះយ៉ាងណាមិញខ័ន្ធទាំងឡាយកាលណានៅរួមគ្នាក្នុងទីតែមួយ ពាក្យសន្មតឬការកត់សំគាល់ថាមនុស្ស, ថាសត្វ, ថាបុគ្គល...ក៏រមែងត្រូវមានយ៉ាងនោះដែរ»។

**«យថា យថា និជ្ឈាយតិ យោនិសោ ឧប្បរក្ខតិ**



www.elibraryofcambodia.org

**វិត្តកំ តុច្ឆកំ ហោតិ យោនំ បស្សតិ យោនិសោ»។**

“បុគ្គលពិចារណា មើលឃើញលោកប្រកបដោយបញ្ញាណា ដោយមធ្យោបាយណាៗ ដែលធ្វើឲ្យខ្លួនគេឃើញនូវភាពប្រាកដជាក់ស្ដែងថា លោកជាមួយនិងរបស់ទាំងអស់ជាភាពទទេ ជាភាពសោះសូន បុគ្គលណាឃើញដូចនេះ បុគ្គលនោះឈ្មោះថា មានឧបាយក្នុងការរំដោះខ្លួនចេញចាកលោក»។

ដែលថាសង្ខារជារបស់អស់ទៅ សូនទៅនោះ អ្នកអានគប្បីដឹង, គប្បីស្គាល់. តាមសេចក្ដីដែលមានមកក្នុងជរាសូត្រថា :

**“សុបិនេន យថាបិ សង្គតំ**

**បដិពុទ្ធោ បុរិសោ ន បស្សតិ**

**ឯវម្បិ បិយាយិតំ ជនំ**

**បេតំ កាលកតំ ន បស្សតិ»។**

“បុគ្គលដែលភ្ញាក់ឡើងហើយ រមែងមើលមិនឃើញនូវរបស់ទាំងឡាយជាអារម្មណ៍ ដែលខ្លួនបានឃើញកាលកំពុងដំណេកលក់ ដែលយើងធ្លាប់បានស្គាល់ធ្លាប់បានហៅថាយល់សប្ដិយ៉ាងណាមិញ បុគ្គលដែលមានជីវិតរស់នៅរមែងមិនឃើញនូវបុគ្គលជាទៅស្រឡាញ់របស់ខ្លួន ដែលអស់ជីវិតទៅហើយយ៉ាងនោះដែរ»។

៥- ដោយភាពជាសភាវធម៌ប្រព្រឹត្តទៅតាមហេតុបច្ច័យ, ជាលក្ខណ រួមប្រមូលនៃអាការទាំងឡាយ៤ ដែលយើងហៅថា “អត្តា” ឬ “ខ្លួនប្រាណ” សព្វថ្ងៃនេះ។ ភាពដូចនេះមានសេចក្ដីដៅបញ្ជាក់ក្នុងបាលីពុទ្ធឧទានថា ៖

**“យទា ហវេ បាតុភវន្តិ ធម្មា**

**អាតាបិនោ ឈាយតោ ព្រាហ្មណស្ស**

**អថស្ស កង្ខា វបយន្តិ សព្វទា**

**យតោ បជានាតិ សហេតុធម្មំ**

**យតោ ខយំ បច្ចយានំ អវេទិ»។**



www.elibraryofcambodia.org

«ក្នុងកាលណាធម៌ទាំងឡាយកើតមានប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាមពិចារណាស្រាវជ្រាវរកសេចក្ដីពិតក្នុងសភាវធម៌ ក្នុងកាលនោះ សេចក្ដីសង្ស័យទាំងអស់របស់គេ រមែងអស់ទៅឥតមានសេសសល់ ព្រោះអ្វី? ព្រោះគេស្គាល់ថា ធម៌ទាំងឡាយកើតឡើងហើយប្រព្រឹត្តទៅជាមួយនឹងហេតុ ព្រមជាមួយគ្នានេះ គេបានដឹង, បានស្គាល់នូវបច្ច័យ ឬផលដែលត្រូវអស់សោះសូន្យទៅជាមួយគ្នានឹងហេតុនេះឯង គឺជាអនត្តលក្ខណៈជាគ្រឿងកត់សំគាល់ថាជាអនត្តា នៃសង្ខារធម៌ទាំងឡាយ»។

ក្នុងចំណុចថាអនត្តានេះ បើសង្កេតតាមតួព្យញ្ជនៈ នឹងឃើញដូចជាមតិមួយ ដែលគេទុកថាជាមតិប្រឆាំងប្រជែងជាមួយនឹងអាត្មានៃលទ្ធិព្រាហ្មណ៍។ លទ្ធិព្រាហ្មណ៍និងលទ្ធិទាំងឡាយដទៃទៀត គេមានជំនឿថាជីវិតអន្ទោលកើតស្លាប់ រមែងមានអត្តានៅក្នុងរូបកាយនេះជាធម្មជាតុសម្រាប់គិតនឹក សម្រាប់សោយវេទនា និងសម្រាប់សម្រេចកិច្ចការទាំងឡាយ។ គេមានយោបល់ថាសេចក្ដីស្លាប់របស់មនុស្សយើង ដូចជាមនុស្សត្រូវផ្លាស់ផ្ទះអ៊ីចឹងដែរ គឺជាធម្មតាអ្នកនៅក្នុងផ្ទះចាស់ លុះផ្ទះនោះបាក់បែក ម្ចាស់ផ្ទះត្រូវចុះចេញទៅរកផ្ទះថ្មីនៅទៀត។ អាត្មន៍ដែលពុទ្ធសាសនាយើងហៅថា អត្តានោះ ក៏ត្រូវចុះចេញចោលរូបចាស់ទៅរករូបថ្មីទៀត ក្នុងពេលដែលរូបត្រូវបែកធ្លាយដែលយើងធ្លាប់ហៅថា «ស្លាប់» ហ្នឹងឯង។ ជម្រកថ្មីទៀតនោះ, ទោះល្អក្ដី អាក្រក់ក្ដី គេយល់ថារបស់នេះស្រេចនឹងបុណ្យបាបចាត់ចែង។ យោបល់ត្រង់ចំណុចនេះបានស្របគ្នានឹងយោបល់នៃពុទ្ធសាសនារបស់យើង។ អត្តាឬអាត្មន៍នេះក្នុងមិលិន្ទបញ្ហាលោកហៅថា «ជីវោ» ស្រដៀងនឹងជីវិត ខ្មែរយើងហៅថា «ភូត» ឬ «ចេតភូត» ស្រដៀងនឹងព្រលឹង។

ចំណែកខាងពុទ្ធសាសនាក្នុងរឿងនេះ មានមតិមិនស្របគ្នានឹងមតិទាំងឡាយ មានមតិព្រាហ្មណ៍ជាដើមទេ, មតិមិនស្របគ្នានេះ គេអាចហៅម្យ៉ាងទៀតថា «មតិប្រជែង» ឬ «មតិប្រឆាំង» ដូច្នេះវិញក៏បាន ព្រោះអ្វី ? ព្រោះ



www.elibraryofcambodia.org

យោបល់ពុទ្ធសាសនាថាមិនមានអាត្មនទេ របស់ទាំងអស់ត្រឹមតែជាសភាវធម៌ កើតឡើងព្រោះហេតុ រលត់សូន្យទៅវិញ ព្រោះអស់ហេតុ សេចក្តីនេះស៊ីគ្នានឹង ភាថានៃអស្សជិថេរៈថា ៖

**“យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ**

**តេសញ្ច យោ និរោធោ ច ឯវំ វាទី មហាសមណោ”។**

“ធម៌ទាំងឡាយណា មានហេតុជាដែនកើតព្រះតថាគតទ្រង់ត្រាស់ដល់ ហេតុនៃធម៌ទាំងឡាយនោះ (ព្រមគ្នានេះ) ព្រះអង្គទ្រង់ត្រាស់ដល់ភាពរលត់ នៃធម៌ទាំងឡាយនោះ ព្រមមហាសមណៈទ្រង់ត្រាស់យ៉ាងនេះឯង»។

ចំពោះរឿងនេះ, ខ្ញុំអាចធ្វើសេចក្តីបញ្ជាក់ថា កំណើតនៃធម៌ទាំងឡាយ មានដំណើរជាប់ទាក់ទងគ្នាជាហូរហែទំនងគ្នានឹងខ្សែទឹក ដូចមាននិយាយពី កំណើតនៃវិថីចិត្តជាអាស្រ័យអាយតនៈខាងក្នុងមានចក្ខុជាដើម ទើបត្រូវប៉ះ ទង្គិចអាយតនៈខាងក្រៅមានរូបជាដើម, ដោយអាស្រ័យជំនួបនៃរបស់ទាំងពីរ នេះ វិញ្ញាណទើបកើតឡើង តែវិញ្ញាណកើតឡើងហើយ ផស្សៈ វេទនា, សញ្ញា, សញ្ចេតនា, តណ្ហា, វិតក្កៈ វិចារ...ក៏កើតឡើងព្រមតាមលំដាប់។

**“យំកិញ្ចិ សមុទយធម្មំសព្វន្តំ និរោធធម្មំ”**

“របស់ណាមានសេចក្តីកើតឡើងជាធម្មតា របស់នោះសុទ្ធតែមាន សេចក្តីរលត់ទៅវិញជាធម្មតា”។ សេចក្តីគិតអាន, សេចក្តីសោយវេទនា ព្រម ទាំងអាការៈទាំងឡាយដទៃទៀត វាជាកិច្ចរបស់ចិត្តនិងចេតសិក វាមិនមែនជា អត្តាឬអាត្មនឡើយ។ បើនិយាយត្រឹមតែប៉ុណ្ណេះ, ដូចជាមិនសូវលំបាកស្តាប់ ប៉ុន្មានទេ។ តែប្រសិនណាយើងទទួលស្គាល់ថាមានចុតិចិត្ត ក្នុងចំណុចនៃ ភាសិតថា ៖

**“ចិត្តេ សង្កិលិដ្ឋេ ទុគ្គតិ បាដិកង្ខា”**

កាលណាចិត្តសៅហ្មង ទុគ្គតិនឹងមានប្រាកដ (ក្នុងភពខាងមុខ)»។

**“ចិត្តេ អសង្កិលិដ្ឋេ សុគតិ បាដិកង្ខា”**



www.elibraryofcambodia.org

កាលណាចិត្តមិនសៅហ្មង សុគតិនឹងមានប្រាកដ (ក្នុងភពខាងមុខ) ជាមួយគ្នានេះទៀត យើងព្រមទទួលស្គាល់នូវបដិសន្ធិចិត្ត ដោយអាស្រ័យភាសិតថា :

**«វិញ្ញាណប្បច្ចយា នាមរូបំ»**

«នាមរូបរមែងកើតមាន ព្រោះមានវិញ្ញាណជាបច្ច័យ ក្នុងទីបំផុតយើងទទួលស្គាល់នូវការអន្ទាលកើតស្លាប់នៃជីវិតផងទៀត ដូចនេះ រឹងរឹតតែលំបាក និងចូលចិត្តខ្លាំងឡើងទៀត ព្រោះអាស្រ័យហេតុនេះទេដឹង! ទើបគម្ពីរបាលីរបស់យើង បានបរិយាយព្រមមួយអន្លើដោយសេចក្ដីបញ្ជាក់អំពីអនត្តាថា វាគ្រាន់តែជាសភាវធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុបច្ច័យ, ដូចបានពោលមក។ ដោយអាស្រ័យពាក្យថា **«អនត្តា»** មានសេចក្ដីតាមព្យញ្ជនៈជាមិនមែនជាខ្លួន មិនមែនជាប្រាណនោះ ឃើញថាពាក្យនេះមានសេចក្ដីប្រជែងជាមួយនឹងពាក្យថា **«ឧបាទាន»**។ បាលីដែលលោកសម្ដែងអំពីអនត្តលក្ខណៈ មានសេចក្ដីផ្លែកថា «ធម៌ទាំងឡាយទាំងពួងជាអនត្តា» មិនថាសង្ខារទាំងឡាយទាំងពួងដូចក្នុងអនិច្ចលក្ខណៈ ក្នុងចំណុចនេះនាំឲ្យយើងមានគំនិតចង់រកពាក្យអធិប្បាយយ៉ាងច្រើន។ បញ្ហានេះ អ្នកប្រាជ្ញមុនៗ លោកធ្លាប់គិតដល់ ធ្លាប់អធិប្បាយថា អនិច្ចលក្ខណៈនិងទុក្ខលក្ខណៈប្រព្រឹត្តទៅបានចំពោះតែសង្ខារ ទើបលោកធ្វើសេចក្ដីបញ្ជាក់ថា «សង្ខារទាំងឡាយទាំងពួងមិនទៀង, សង្ខារទាំងឡាយទាំងពួងជាទុក្ខ»។ ចំណែកអនត្តលក្ខណៈ លោកថាប្រព្រឹត្តទៅបានក្នុងសង្ខារផង ក្នុងវិសង្ខារផង។ **«វិសង្ខារ»** ប្រែថា «មិនមែនសង្ខារ» ដែលលោកដៅយកនិព្វាន ដូចនេះទើបលោកធ្វើសេចក្ដីបញ្ជាក់ថា «ធម៌ទាំងឡាយទាំងពួងជាអនត្តា» ដើម្បីប្រមូលនូវសភាវធម៌ទាំងអស់នោះមកសម្ដែងរួមគ្នាក្នុងបទខាងចុងនេះ ព្រោះបទថាធម៌សំដៅយកសង្ខារផង វិសង្ខារផង ។ ហេតុដូចម្ដេចទើបលោកចាត់និព្វានចូលក្នុងវិសង្ខារ? ចំពោះសំនួរនេះអ្នកអានសូមរង់ចាំចម្លើយរបស់ខ្ញុំទៅខាងមុខ គឺក្នុងបទដែលស្ដីដល់រឿងនិព្វានម្ដងទៀត។ ឥឡូវនេះខ្ញុំ



www.elibraryofcambodia.org

សូមធ្វើសេចក្តីបរិយាយ ជាមួយនឹងសេចក្តីបញ្ជាក់ឲ្យបានច្បាស់លាស់ ដើម្បីផ្ទៀបមតិពុទ្ធសាសនា ជាមួយនឹងលទ្ធិសាសនាដែលមានព្រះអាទិទេព ហើយដែលមានលទ្ធិព្រាហ្មណ៍នៅក្នុងនោះផង មនុស្សដែលមានកំណាន់ក្នុងលទ្ធិទាំងឡាយនោះតែងមានជំនឿថា ពិភពលោកយើងជាមួយនិងរបស់ដែលមាននៅក្នុងពិភពលោកនេះ ជារបស់គឺព្រះអាទិទេពទ្រង់បង្កើត ព្រះជាម្ចាស់សួគ៌នោះកាលណាយើងនឹកដល់ ហើយយើងទុកដាក់ថាជាមានរូប ជាបែបបុគ្គលាធិដ្ឋាន ប្រែថាមានរូបកាយ. នាមកាយដូចមនុស្សយើង តែទុកដាក់ព្រះអង្គថា មានគុណធម៌ខ្ពស់ខ្ពស់ជាងមនុស្សសត្វដែលព្រះអង្គបង្កើត មានមេត្តាករុណា មានកំរោធ, កំហឹងដែរ តែមានឫទ្ធិពិសេសជាងវិស័យនៃសត្វគ្រប់ប្រភេទដែលព្រះអង្គទ្រង់បង្កើត គំហើញរបស់យើងនេះ ក៏ប្រហែលជាពុំខុសអំពីគំនិតអ្នកមានជំនឿក្នុងសាសនាទាំងឡាយនោះប៉ុន្មានទេ : តែមានគំនិតមួយទៀតដែលយើងមិនមាន គឺគំនិតថា ព្រះជាម្ចាស់នោះព្រះអង្គកើតឯង, មានឯងមុនអ្វីៗទាំងអស់ មិនមានអ្នកណាបង្កើតព្រះអង្គមិនមានខាងដើម គឺមិនប្រាកដថាមានមកអំពីកាលណា មិនមានទីបំផុត គឺមិនដឹងជាអស់ទៅវិញក្នុងកាលណា ជាព្រះមានសេចក្តីទៀតទាត់មិនមានសេចក្តីប្រែប្រួលដូចធម្មជាតិទាំងអស់រួមទាំងពិភពលោកផង។

កាលណាយើងត្រួតពិនិត្យមើលមតិនេះដោយល្អិតល្អន់ទៅ យើងនឹងឃើញថា យោបល់ដែលថាព្រះកើតឯង ហើយកើតមុនអ្វីៗទាំងអស់នោះ ប្រហែលជាកើតឡើងដោយគំនិតស្រាវជ្រាវឬបញ្ញត្តិហេតុនៃសង្ខារទាំងឡាយនោះៗថយទៅក្រោយឆ្ងាយទៅៗវែងទៅៗ ក្នុងទីបំផុតវាទាក់គំនិតឬវាទាល់ច្រករកផ្លូវចេញមិនរួចក៏ឈប់ត្រឹមនោះទៅ ទើបនាំគ្នាលើកយកគំនិតទាល់ឬទីបំផុតនៃគំនិតនោះ មកសន្មតឲ្យមានជាសភាពមួយដែលមានឈ្មោះថា ព្រះអាទិទេពនោះឡើង។

ដូចនេះព្រោះអ្វី ? ព្រោះសេចក្តីសន្និដ្ឋានថា សភាពដែលខ្លួនមើលឃើញ



www.elibraryofcambodia.org

ដោយភ្នែក... នោះមិនមែនមានឯង. កើតឯងទេ ប្រាកដជាមានអ្វីមួយបង្កើតឡើង អ្វីនោះក៏គឺរបស់មួយដែលគំនិតរបស់ខ្លួននឹកទៅមិនដល់, ភ្នែករបស់ខ្លួនមើលមិនឃើញនោះឯង។ គំនិតនេះអាចនឹងស្របជាមួយគ្នានឹងទ្រឹស្តី ឬនឹងសូត្រនៃបដិច្ចសមុប្បាទ នៃពុទ្ធសាសនារបស់យើងក្នុងបទបដិលោម ដែលមានសេចក្តីថា សេចក្តីស្លាប់មានព្រោះចំណាស់ ចំណាស់មានព្រោះកំណើត, កំណើតមានព្រោះភព, ភពមានព្រោះកំណាន់, កំណាន់មានព្រោះតម្រេកឬព្រោះចំណង់, ចំណង់មានព្រោះសំណោយ, សំណោយមានព្រោះប៉ុណះ, ប៉ុណះមានព្រោះអាយតនៈ, អាយតនៈកន្លែងសម្រាប់ប៉ះឬកន្លែងសម្រាប់ទទួលអារម្មណ៍ មានព្រោះនាមរូប នាមរូបមានព្រោះវិញ្ញាណ, វិញ្ញាណមានព្រោះចេតនាឬសង្ខារ, សង្ខារមានព្រោះអវិជ្ជា។ ពុទ្ធសាសនាបានបញ្ចប់បដិច្ចសមុប្បាទជាបដិលោមត្រឹមអវិជ្ជា ប្រែថាមិនដឹងដោយន័យថា ទីបំផុតខាងដើមនិងទីបំផុតខាងចុងនៃកំណើតទាំងអស់មិនដឹងជាអ្វីទេ, ដើមកំណើតនិងចុងកំណើតនៃរបស់ទាំងឡាយនេះ រកប៉ាន់ពុំបាន. ស្មានពុំត្រូវឡើយ។

ជំនឿក្នុងលទ្ធិដទៃ, គេយករបស់ដែលប៉ាន់មិនបាន ស្មានមិនត្រូវ នេះមកសន្មតថាជាព្រះអាទិទេព គឺជាដើមបង្អស់នៃធម្មជាតិ ហើយក្នុងពេលជាមួយគ្នា គេចូលចិត្តថា ធម្មជាតិទាំងអស់រួមទាំងមនុស្សសត្វផង, មានធម្មធាតុដើមដែលគេឲ្យឈ្មោះថាអាទិទេពនោះព្រះអង្គទ្រង់បង្កើត។ ចំណែកពុទ្ធសាសនារបស់យើងពុំបានយករបស់ដឹងមិនដល់ មើលមិនឃើញមកសន្មតថាជាព្រះអាទិទេពទេ គ្រាន់តែធ្វើសេចក្តីបញ្ជាក់ក្នុងទ្រឹស្តី នៃបដិច្ចសមុប្បាទថា របស់ដើមបំផុតនៃកំណើតទាំងអស់ មិនដឹងថាអ្វីដែរ។

ពុទ្ធសាសនាមិនត្រឹមតែមិនបញ្ញត្តឲ្យមានព្រះអាទិទេពនិងការបង្កើតលោកដោយព្រះអាទិទេពប៉ុណ្ណោះទេ គឺបានទាំងធ្វើសេចក្តីបញ្ជាក់ថា សង្ខារទាំងឡាយទាំងពួងជាហេតុ, ជាធម្មធាតុតុបតែងបង្កើតលោក។ ក្នុងទីបំផុតនៃសេចក្តីបញ្ជាក់នេះ, បើមានគេធ្វើសំនួរថា ចុះមានអ្វីទៅទៀតដែលនៅខាងដើម



www.elibraryofcambodia.org

សង្ខារ ដែលជាអ្នកមានហ៊ុន មានចំណែកក្នុងការសាងលោកនេះ ព្រះសម្មាសម្ពុទ្ធ ច្រើនតែទ្រង់ប្រទានចម្លើយថា កុំចង់ដឹងធ្វើអ្វី រយៈកាលកន្លងទៅយូរណាស់ហើយ ដឹងទៅក៏ពុំមានប្រយោជន៍អ្វីដែរ. មុខងាររបស់អ្នករាល់គ្នា គឺនាំគ្នាខំប្រឹងធ្វើការ ខំប្រឹងប្រតិបត្តិធម៌ ដើម្បីកំចាត់បង់នូវកងទុក្ខ ដែលតែងតែបៀតបៀនជីវិតឲ្យអស់ទៅ ជាការស្រេចប៉ុណ្ណឹងហើយ កុំរកមុខអ្នកណាសាងលោកធ្វើអ្វី។

ចំពោះបញ្ហាដោជដែលនេះ. មើលមានអ្នកស្តាប់មិនបាននៅតែទទូចសួរព្រះសម្មាសម្ពុទ្ធទ្រង់ឲ្យចម្លើយថា មិនដឹងដែរ។ នៅក្នុងបញ្ហាដ៏មានសេចក្តីស្មុគស្មាញនេះ បើដោះស្រាយតាមមតិជាទូទៅ នៃពុទ្ធសាសនារបស់យើងនោះ ខ្ញុំអាចប្រមូលមកធ្វើចម្លើយថា អ្វីៗ ទាំងអស់កើតឡើងព្រោះមានហេតុ ឯហេតុនោះគឺរបស់ដែលមាននៅដោយធម្មតា ជារបស់ដែលយើងធ្វើសម្រាវជម្រាវទៅឃើញថា របស់នោះវាមានជំនាប់មានដំណើតជាមួយគ្នា រកដើមបំផុតនិងចុងបំផុតមិនឃើញ ទើបលោកបញ្ញត្តហេតុដែលជាប់ទាក់ទងជាមួយនោះថា "**អវិជ្ជា**" ប្រែថាមិនដឹងជាវាជាប់ទាក់ទងគ្នាតាំងអំពីកាលណាមកទេ។

ដូចនេះ, ពាក្យពន្យល់អំពីធម្មជាតុដែលមានឈ្មោះថាមិនដឹងឬអវិជ្ជានោះទោះណាជាយើងខំប្រឹងពន្យល់យ៉ាងណាទៅទៀត, សេចក្តីពន្យល់និងការស្រាវជ្រាវរបស់យើងក៏នៅតែក្នុងភាពដឹងមិនដល់ ឆ្លើយមិនរួចដដែល។ ដូច្នេះ ទើបចាត់ទុកអវិជ្ជាជាដើមដម្បូងបង្អស់នៃកំណើតទាំងឡាយ ប្រែថារាងដើមនៃ កំណើតនិងខាងចុងនៃកំណើតរបស់ពិភពលោក ជាមួយនឹងរបស់ទាំងឡាយក្នុងពិភពលោក យើងទាល់បញ្ញាប៉ុណ្ណឹងហើយ។ តែយើងមាននិព្វានមួយសម្រាប់ផ្តាច់នូវចំណង នៃការទាក់ទងរបស់កំណើតទាំងឡាយ គឺធ្វើឲ្យជីវិតអន្ទោលអស់ទៅ។

ក្នុងចំណុចនេះ, ឃើញថាពុទ្ធសាសនាយើង មានលក្ខណៈខុសគ្នា អំពីសាសនាទាំងឡាយដទៃ ដែលខ្ញុំនឹងនិយាយខ្លះទៀតទៅក្នុងខាងមុខ។ មាន



www.elibraryofcambodia.org

ចំណុចមួយទៀត, ដែលខ្ញុំសូមធ្វើសេចក្តីបំភ្លឺជាបន្ទាន់ ដើម្បីឲ្យអ្នកអានមិនបានដឹងសោះនិងចង្អៀតចិត្តយូរពេក; ចំណុចនោះគឺកាលណាបើយើងប្រមូលយកហេតុដែលជាធម្មជាតិ មានការទាក់ទងដល់គ្នានឹងគ្នាដាក់ចូលមកជារបស់ធម្មតា ដើម្បីឲ្យមានសេចក្តីខ្លីងាយរៀន, ងាយចាំនោះ, យើងមុខជានឹងស្រាវជ្រាវ រកហេតុនៃធម្មតាដទៃទៀតមិនឃើញឡើយ, ដូច្នេះទើបត្រូវចាត់ធម្មតាទៅជាសង្ខារវិញ។

ដោយអាស្រ័យហេតុនេះពាក្យថា "ធម៌ទាំងឡាយទាំងពួងជាអនត្តា" នោះ ពាក្យនេះដៅដល់ធម្មតាផងដែរ។

ការពិចារណាឃើញសង្ខារថាជាអនត្តា ដោយប្រាសចាកយោនិសោមនសិការៈនោះ អាចនឹងក្លាយទៅជានត្ថិកទិដ្ឋិក៏សឹងមាន។ មនុស្សដែលមានទិដ្ឋិយ៉ាងនេះ, គ្របសង្កត់ហើយ រមែងឃើញថាផលបុណ្យផលបាបមិនមាន.... ដោយយល់ថា របស់ណាៗទាំងអស់នោះគ្រាន់តែជារបស់ដែលមនុស្សសន្មតតែងតាំងឡើងប៉ុណ្ណោះ ទិដ្ឋិយ៉ាងនេះ, មិនញុំាងប្រយោជន៍ឲ្យសម្រេចទេ, ពុទ្ធសាសនាយើងចាត់ជាមិច្ឆាទិដ្ឋិដ៏មានជម្រៅ កម្រអ្នកណានឹងដកចេញបាន។ អ្នកឃើញអនត្តាតាមផ្លូវវិបស្សនាបញ្ញានឹងបានកំណត់ដឹងនូវសច្ចៈទាំងឡាយពីគឺសម្មតិសច្ចៈ ពិតដោយសន្មតដូចជាសង្ខារអ្នកឲ្យនូវកំណើតបុរសសន្មតថាបិតា ស្ត្រីសន្មតថាមាតាដូច្នេះជាដើម។

សេចក្តីពិតដូចនេះ មិនមានអ្នកណាបដិសេធបានទេ ព្រោះថាបើបដិសេធសេចក្តីច្រឡំក្នុងការប្រើភាសាក៏កើតមានឡើងផងដែរ។ ឧទាហរណ៍ រទេះ ផ្ទះ ... ជាពាក្យសន្មត បើយើងមិនហៅដូចនេះ ក៏មិនដឹងជានឹងនិយាយថាម៉េចទៅវិញទេ។

**បរមត្ថសច្ចៈ**, ពិតដោយបរមត្ថ គឺជម្រៅនៃអត្ថ ដូចជារូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណជាដើម របស់ទាំងឡាយនេះ បើបំបែកហើយធ្វើសេចក្តីអធិប្បាយកាន់តែច្រើន, ជម្រៅក៏កាន់តែមានច្រើនឡើងទៀតនេះគឺជាសេចក្តី



www.elibraryofcambodia.org

ពិតតាមបរមត្ថ។ មាតាបិតាជាបុគ្គលគ្រងរក្សាខន្ធធាតុអាយតនៈ...នៃកូនរបស់ខ្លួន ដូចជាតួរថឬផ្ទះដែលគ្រប់គ្រងសម្ភារៈទាំងឡាយរបស់វា ប្រសិនបើយើងបដិសេធថា មិនមានមាតាបិតា, មិនមានរថ, មិនមានផ្ទះ; មានតែខន្ធធាតុអាយតនៈ...មានតែសម្ភារៈទាំងឡាយ មានដែកគោល និងឈើជាដើម ដែលគេយកមកធ្វើជាសំណង់នោះ។ ភាសាដែលយើងនិយាយគ្មានសម្មតិសច្ចៈនេះក៏មិនមានអ្នកណាគេស្ដាប់បានឡើយ ដូច្នេះ, ការស្គាល់និងការប្រើសច្ចៈទាំងពីរ ទើបជាការចាំបាច់របស់មនុស្សយើង។

ការឃើញ **អនត្តា** ប្រកបដោយបញ្ញា ទើបញុំាងប្រយោជន៍របស់យើងឲ្យសម្រេច។ ដោយអាស្រ័យហេតុនេះ ទើបពុទ្ធសាសនាធ្វើសេចក្ដីបញ្ជាក់ថា "**អនត្តា**" រមែងមានភាពប្រាកដច្បាស់លាស់ ដល់បុគ្គលណាដែលពិចារណាឃើញដោយឧបាយនៃបញ្ញា។ នៅក្នុងគាថាដែលសម្ដែងអំពីត្រៃលក្ខណ៍ ក៏លោកបានណែនាំដូចគ្នានេះដែរ។

បុគ្គលកាលណាឃើញដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួងមិនទៀង, ជាទុក្ខ, ជាអនត្តា, ដោយអាការដូចបាននិយាយមកហើយ រមែងនឿយណាយធុញទ្រាន់ក្នុងទុក្ខខ័ន្ធ មិនមានសេចក្ដីត្រេកអរឆ្អើតឆ្អើនជ្រក់ជ្រេញក្នុងសង្ខារដែលជាប្រភពនៃសេចក្ដីស្នេហាទៀត។ ក្នុងអនត្តលក្ខណសូត្រ លោកចែកទុក្ខខ័ន្ធចេញជា ៥ តាមប្រភេទនៃខ័ន្ធទាំងឡាយ៥ប្រការ ហើយលោកបានធ្វើសេចក្ដីបញ្ជាក់ថា "អរិយសាវ័កក្នុងពុទ្ធសាសនា លោកបានស្ដាប់បានរៀនយល់សេចក្ដីនៃទុក្ខ ដែលកើតអំពីខ័ន្ធទាំងឡាយហើយ លោកមានចិត្តនឿយណាយធុញទ្រាន់ក្នុងរូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ អស់កាលជានិច្ច"។ សេចក្ដីនឿយណាយនេះ ពុទ្ធសាសនាឲ្យឈ្មោះថា "**និព្វិទា**" ជាធម្មធាតុកើតឡើងដោយអាស្រ័យបញ្ញា ហៅថា "**និព្វិទាញាណ**" នេះគឺជា **បដិបទានៃវិសុទ្ធិ** ខាងពុទ្ធសាសនារបស់យើង។



www.elibraryofcambodia.org

# វិភតៈមិនមានតម្រេក

**"និព្វិន្ទំ វិរជ្ជតិ"** "ចិត្តនឿយណាយ រមែងអស់តម្រេក"។

**"វិរាគោ សេដ្ឋោ ធម្មានំ"** "**វិរាគធម៌** ជាធម៌ប្រសើរជាងធម៌ទាំងឡាយ"។

**"សុខាវិរាគតា លោកេ កាមានំ សមតិក្កមោ"** "វិរាគធម៌គឺភាពកន្លងផុតកាមទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក"។

ក្នុងអគ្គប្បសាទសូត្រ មាននិយាយថា វិរាគធម៌ជាកំពូលនៃធម៌ទាំងពួងទាំងផ្នែកសង្ខតៈ ទាំងផ្នែក**អសង្ខតៈ** មានសទិសវចនៈ គឺពាក្យសម្រាប់ប្រើជំនួសឬពាក្យស្មើគ្នា ដូចនេះគឺ **"មទនិម្មទនោ"** **"បិបាសវិនយោ"** **"អាលយសមុគ្ឃាតោ"** **"វដ្ដូបច្ឆេទោ"** **"តណ្ហក្ខយោ"** **"វិរាគោ"** **"និរោធោ"** **"និព្វានំ"** (សេចក្តីប្រែដូចមុន)។

ពាក្យថាញាំញីនូវសេចក្តីស្រវឹងក្នុងទីនេះ លោកសំដៅយកសេចក្តីស្រវឹងក្នុងអារម្មណ៍ទាំងឡាយ ដែលលោកទុកជាធម្មជាតិញុំាងចិត្តមនុស្សឲ្យកើត សេចក្តីស្រវឹងគ្រប់ប្រការ។

សម្បត្តិ, ជាតិ, ត្រកូល, បរិវារ, ឥស្សរិយយសក្តិ, លាភ, យស, បសំសៈ, សុខក្តី យុវវ័យក្តី ភាពមិនមានរោគក្តី, ជីវិតកំពុងរស់នៅក្តី ក៏លោកសង្គ្រោះចូលក្នុងអារម្មណ៍ទាំងឡាយ ៥ មានរូបារម្មណ៍ជាដើមនោះដែរ។ ធម៌ជាគ្រឿងញុំាងសេចក្តីស្រវឹងឲ្យអស់ទៅ ឬធម៌ជាគ្រឿងធ្វើចិត្តឲ្យស្វាងចាកសេចក្តីស្រវឹងក្នុងអារម្មណ៍ទាំងឡាយ ឈ្មោះថា **"វិរាគធម៌"**។

សេចក្តីស្រេកឃ្លាន សំដៅយកសេចក្តីក្រវល់ក្រវាយឬភាពអន្ទះសាផ្លេផ្លាដែលជាហេតុឲ្យកើតចំណង់ទៅក្នុងរបស់ផ្សេងៗដែលប្រៀបបាននឹងការឃ្លានបាយ ស្រេកទឹក ជាធាតុធ្វើឲ្យមនុស្សយើងមានសេចក្តីរសាប់រសល់នៅមិនសុខប្រសិនបើមិនបានស៊ីបាយផឹកទឹក ប្រែថា សម្រេកគំលានធម្មតានៃមនុស្ស គេបំបាត់បានដោយស៊ីបាយ ផឹកទឹក យ៉ាងណាមិញ សម្រេកគំលាននៃ



www.elibraryofcambodia.org

ចិត្ត ក៏គេត្រូវបំបាត់បានដោយវិរាគធម៌យ៉ាងនោះដែរ។

សេចក្តីអាល័យ សំដៅយកសេចក្តីជាប់ជំពាក់, សេចក្តីហួងហែងរបស់ចិត្តក្នុងបិយារម្មណ៍ទាំងឡាយ: ការដកចេញនូវសេចក្តីអាល័យ គឺធ្វើចិត្តឲ្យឃ្លាតចេញចាកបិយារម្មណ៍នោះក៏បានឈ្មោះថា «**វិរាគធម៌**» ដែរ។ «**វដ្តៈ**» ដៅយកជីវិតអន្ទោលកើតស្លាប់ ដោយអំណាចកិលេស, កម្ម និងវិបាក។

សត្វទាំងឡាយធ្វើការណា ការនោះលោកឲ្យឈ្មោះថា «**កម្ម**» កម្មជាធម្មជាតុធ្វើឲ្យមានភពថ្មីគឺវិបាក កាលណាមានវិបាកកិលេសក៏កើតឡើងទៀត, ធ្វើកម្មថ្មីទៀត, វិបាកថ្មីកើតទៀត, សោយវិបាកទៀត, កិលេសកើតទៀត អុចអាលឲ្យធ្វើកម្មទៀត វិលវល់នៅក្នុងភព មិនមានទីបំផុត។ បើយើងពិចារណាឲ្យជិតដល់អំពីរឿងអន្ទោលនៃជីវិត យើងនឹងឃើញថា ការអន្ទោលមាននៅក្នុងភពនេះផង, ក្នុងភពដទៃផង។

នៅក្នុងភពនេះ កិច្ចការទាំងឡាយនៃមនុស្សវិលប្រទាក់ប្រតោងគ្នាពីមួយទៅមួយ ឧទាហរណ៍ រៀនជាកម្ម, កើតផលជាចេះ, ចេះកើតបានជាកិលេស ចង់ធំ ចង់ខ្ពស់ កិលេសកើតបានជាកម្មគឺរៀនទៀត កម្មកើតបានជាផល គឺចេះទៀត ផលកើតបានជាចំណង់គឺប្រាថ្នាយកធំ យកខ្ពស់ទៀត។

ក្នុងភពដទៃឬសកលពិភព ទំរើទាំងឡាយរបស់មនុស្សយើង ក៏មានការប្រទាក់ប្រតោងជាប់គ្នារដឹកអឺចឹងដែរ ឧទាហរណ៍ ធ្វើបុណ្យគឺជាកម្ម បានទៅកើតនៅស្រុកទេពជាផល កើតចិត្តចង់ធំចង់ខ្ពស់មុខជាងគេជាកិលេស កិលេសរុញច្រានឲ្យធ្វើកម្មថ្មីទៀត កម្មថ្មីឲ្យផលថ្មីទៀត ផលថ្មីនាំចិត្តឲ្យកើតកិលេសថ្មីទៀត។

តំណដែលប្រទាក់ជាប់គ្នាមិនមានចន្លោះនេះ ពុទ្ធសាសនារបស់យើងលោកបានឲ្យឈ្មោះថា «**វដ្ត**» ឬ «**សង្សារវដ្តៈ**» ដែលខ្ញុំឲ្យឈ្មោះថា «ការវិលវល់នៃជីវិត» ឬ «ជីវិតអន្ទោល»។

ចំពោះភាពនៃការប្រទាក់ប្រតោងគ្នានៃរបស់ទាំង៣នេះ ( **កម្ម**, **វិបាក**,



www.elibraryofcambodia.org

**កិលេស**) ខ្ញុំយល់ថា គួររៀងគ្នាឲ្យមានកិលេសនៅដើម, កម្មបន្ទាប់, វិបាកឬផលក្រោយបំផុត, តែត្រឡប់ជាឃើញកម្មនៅដើម, វិបាកនៅទី២, កិលេសជាទី៣វិញ។ ការរៀងលំដាប់ដែលលោកបានធ្វើនេះ ដូចជាខុសអំពីអភិធម្ម, ព្រោះអភិធម្មលោកទុកដាក់កិលេសាតិ: **លោភៈ, ទោសៈ; មោហៈ;** ជាអកុសលមូល ; **អលោភៈ; ទោសៈ; អមោហៈ;** ជាកុសលមូល មានសេចក្ដីថា កិលេសកើត, ទើបមានកម្ម, កម្មកើតទើបមានវិបាក...។

តែយ៉ាងណាក៏ដោយចុះ ខ្ញុំហាក់ដូចជាមានយោបល់ថា បានជាលោករៀងកម្មនៅដើម, វិបាកកណ្ដាល, កិលេសចុងឬកម្មដើម, កិលេសកណ្ដាល, វិបាកចុងនោះ ប្រហែលជាលោកមានគំនិតមួយថា របស់ទាំង៣នេះ ត្រូវបំព្រួញឲ្យខ្លីនៅត្រឹម២ទៅវិញ ដើម្បីឲ្យមានសេចក្ដីងាយស្ដាប់, ងាយយល់ គឺលោកសង្គ្រោះកិលេសចូលក្នុងកម្ម។

គំហើញនេះ, លោកអាចនឹងពន្យល់យើងថាប្រសិនបើមានតែកម្មទទេ មិនមានកិលេសនៅក្នុងកម្មនោះផងទេ គឺនឹងនៅត្រឹមតែជាកិរិយាប៉ុណ្ណោះ ដូចដែលអភិធម្មបានសំដែងថា កុសល, វិបាក, កិរិយានោះឯង។

កាលណាគេលះកិលេសបាន ទំរើទាំងឡាយរបស់គេក៏មិនទៅជាកម្ម, មិននាំវិញ្ញាណទៅកាន់បដិសន្ធិ ប្រែថា កម្មនោះនៅត្រឹមតែជាកិរិយា។ វដ្ដនៃជីវិតរបស់គេក៏ត្រូវដាច់ធ្លាក់ មិនមានមុខតំណ គឺពុំអាចនឹងតភ្ជាប់ទៀតបាន ការកាត់ផ្ដាច់នូវវដ្ដៈ ដូចខ្ញុំបានធ្វើសេចក្ដីបញ្ជាក់មកនេះ ក៏លោកឲ្យឈ្មោះថា «**វិភគធម៌**» ដែរ។

ចំណង់របស់សត្វទាំងឡាយឈ្មោះថា «**តណ្ហា**» ចំណង់ក្នុងកាមារម្មណ៍ជាកាមតណ្ហា, ចំណង់ក្នុងភព ជាភវតណ្ហា, ចំណង់ក្នុងវិភវភព ជាវិភវតណ្ហា។ តណ្ហាមួយខាងដើមគឺកាមតណ្ហា មានសេចក្ដីងាយស្ដាប់, ងាយចូលចិត្ត; តែតណ្ហាពីរខាងចុងមានសេចក្ដីលំបាកស្ដាប់, លំបាកចូលចិត្តណាស់។

ដើម្បីឲ្យមានសេចក្ដីធូរស្រាលខាងផ្លូវគំនិតក្នុងរឿងនេះ ខ្ញុំសូមទាញ



www.elibraryofcambodia.org

អារម្មណ៍អ្នកអានឲ្យមានគំនិតពិចារណាជាមួយនឹងខ្ញុំថា មនុស្សលោកទោះជាមានជាតិ, សាសន៍, ត្រកូល, វណ្ណៈ, ពណ៌សម្បុរច្រើនបែបក៏មែន តែចំណង់ដែលមានក្នុងចិត្តរបស់មនុស្សទាំងឡាយមានត្រឹមតែ៣ គឺ: ចង់បានរូប, សម្លេង, ក្លិន, រស, សម្ផស្ស... មកបំរើសេចក្តីត្រូវការរបស់ខ្លួន។ ចង់បានកេរ្តិ៍ឈ្មោះ, យ័សសក្តិ, សេចក្តីសរសើរ, អំនួត, កំណោត, ទំហំ, កំពស់...មកពង្រីកសេចក្តីថ្លៃថ្នូររបស់ខ្លួន។ ចង់ធ្វើឲ្យអស់នូវអ្វីៗទាំងអស់ ប្រែថា ចង់បានកំពស់ខាងមិនមានអ្វីៗនោះទៅវិញ។

នេះគឺជាយោបល់របស់ខ្ញុំ ដែលដាក់ចូលមកឲ្យអ្នកអានងាយស្តាប់, ងាយយល់, ក្នុងបញ្ហាដ៏មានអាថ៌កំបាំងនេះ។

ដទៃអំពីនេះ, ខ្ញុំសូមធ្វើសេចក្តីបញ្ជាក់ជាមួយនឹងពាក្យពន្យល់របស់ពុទ្ធសាសនានៃយើងម្តងទៀត ដើម្បីឲ្យអ្នកអានកាន់តែមានពន្លឺបានច្រើនបែបច្រើនយ៉ាង។

ក្នុងខុទ្ទកវត្ថុវិភង្គនៃវិភង្គប្បករណៈ លោកកែសេចក្តីថា**ភវតណ្ហា** បានដល់រាគៈដែលសហគតទៅដោយ **ភវទិដ្ឋិ**, **វិភវតណ្ហា** បានដល់រាគៈដែលសហគតទៅដោយ **ឧច្ឆេទទិដ្ឋិ**។ គំហើញជាប់ជំពាក់ក្នុងភពឬគំនិតយល់ឃើញថាកើតទៀត, មានទៀតស្រួល លោកឲ្យឈ្មោះថា «**ភវទិដ្ឋិ**» ប្រែជាចំណង់ ដែលចង់កើត, ចង់មានអ្វីទាំងអស់ ដូចបាននិយាយមកហើយក្នុងខាងដើម។

**ភវទិដ្ឋិ** នេះ ជួនកាលលោកហៅថា «សស្សតទិដ្ឋិ»។

**សស្សតទិដ្ឋិ** បានដល់គំហើញថា លោកទៀង ត្រូវគ្នានឹងយោបល់ថាមានអត្តាឬអាត្ម័ន ជាធម្មជាតុមិនចេះប្រែប្រួល។

សត្វទាំងឡាយដែលលង់លិចក្នុងទិដ្ឋិនេះ រមែងមានចិត្តចង់កើតក្នុងភពថ្មីទៀត។ គំហើញថាលោកសូន្យឬយោបល់ថា មនុស្សសត្វមានសេចក្តីសូន្យនៅក្នុងទីបំផុត លោកឲ្យឈ្មោះថា «ឧច្ឆេទទិដ្ឋិ» សេចក្តីត្រង់ឃ្លានេះលំបាកស្តាប់បន្តិច តែបើយើងប្រកាន់យកសេចក្តីនៃឧច្ឆេទទិដ្ឋិដូចគ្នានឹងវិភវទិដ្ឋិ



www.elibraryofcambodia.org

ក៏មានសេចក្ដីងាយស្ដាប់, ងាយយល់ទៅវិញ។

ពុទ្ធសាសនិកខ្លះ ចូលចិត្តវិភវសព្ទថា ភពមានសេចក្ដីចម្រើន ដោយយកសេចក្ដីប្រៀបធៀបទៅនឹងស័ព្ទថា «វិភវោ» ដែលតាមទម្លាប់ប្រែថា «សម្បត្តិ» អាស្រ័យពាក្យប្រែនេះ ទើបប្រកាន់យកពាក្យអធិប្បាយថា ភវតណ្ហា បានដល់ចំណង់ដែលចង់កើតក្នុងរូបភព គឺលោកនៃព្រហ្មមានរូប, វិភវតណ្ហា, បានដល់ចំណង់ដែលចង់កើតក្នុងអរូបភព គឺលោកនៃព្រហ្មមិនមានរូប ដែលជាភពជាន់ខ្ពស់ជាន់ល្អិត ហើយអធិប្បាយអំពីកាមតណ្ហាថា បានដល់សេចក្ដីប្រាថ្នាចង់កើតចង់នៅក្នុងកាមភព គឺមនុស្សលោកនិងទេវលោក គំរប់ជាភពមាន៣ ដូចយើងធ្លាប់ចេះចាំមក។

សេចក្ដីចូលចិត្តនេះ, ក៏មានទំនងម្យ៉ាងដែរ តែមិនសូវមានហេតុផលគ្រប់គ្រាន់ទេ ដូចនេះព្រោះអ្វី? ព្រោះ «វិ» ឧបសគ្គៈ ប្រព្រឹត្តទៅបានក្នុងអត្ថផ្សេងៗ ក្នុងទីនេះលោកពុំបានសម្លឹងយកអត្ថថា «ចម្រើន» ទេ គឺលោកសម្លឹងយកអត្ថដែលមានលក្ខណៈផ្ទុយអំពីសព្ទថា «**ភវោ**» ដែលមានសេចក្ដីប្រែថា **ភព** គឺលោកជាទីកើត, ទីនៅ។

ស័ព្ទថា **វិភវោ** ក្នុងទីនេះគួរប្រែថា ក្នុងភាវៈមិនមែនជាភពឬក្នុងភាវៈមិនមែនជាទីកើតទីនៅ ដូចគ្នានឹងស័ព្ទថា **វិរាគោ** ដែលប្រែថា មានតម្រេកមិនមានឬប្រាសចាកតម្រេក ផ្ទុយគ្នាអំពីស័ព្ទថា **រាគោ** ដែលប្រែថា «សេចក្ដីត្រេកអរ» ឬ «មានចិត្តតម្រេក»។

ដោយអាស្រ័យន័យនេះ ទើបមានមតិថា បុគ្គលដែលប្រាថ្នាឲ្យខ្លួនបានសម្រេចនិព្វាននោះ គឺជាវិភវតណ្ហាហ្នឹងឯង។

យោលបល់នេះ បើយើងពិនិត្យចំពោះអត្ថថាជាធម៌មិនមានកំណើតថ្មីទៀតឬមិនកើតទៀត ឃើញថាគំនិតនេះមានសេចក្ដីត្រឹមត្រូវគួរទុកជាបានការក្នុងរឿងប្រតិបត្តិធម៌ដើម្បីឲ្យអស់ជាតិ។ តែពុទ្ធសាសនារបស់យើងពុំបានធ្វើសេចក្ដីបញ្ញត្ត ឬសេចក្ដីប្រកាសថានិព្វានសូនទេ។



www.elibraryofcambodia.org

ចំពោះរឿងនេះ, យើងទាំងអស់គ្នា គប្បីឃើញក្នុងពាក្យថា **“អត្ថិ ភិក្ខវេ តទាយតនំ...”** ដែលខ្ញុំបានសរសេរមកហើយក្នុងខាងដើម។

ដូច្នេះ, **វិភវតណ្ហា** ទើបមិនត្រូវយកមកប្រើធ្វើជាឈ្មោះជំនួសនិព្វាន ឡើយ ចំណែកអ្នកដែលប្រាថ្នាឲ្យខ្លួនសម្រេចនិព្វាន ក៏មិនមែនជាវិភវតណ្ហាទេ។

នៅក្នុងរឿងដដែលនេះ បើស្ដីតាមល័ខខ័ណ្ឌនៃវិជ្ជាឃើញដូចជាភវតណ្ហា សំដៅយកចំណង់របស់មនុស្សដែលចង់កើត, ចង់នៅក្នុងភព ដែលខ្លួនធ្លាប់និយមរាប់អាន, ដែលខ្លួនធ្លាប់មានជំនឿក្នុងជីវិតអន្ទោល ឧទាហរណ៍ដែលត្រូវលើកយកមកប្រៀបធៀបក្នុងរឿងនេះ ដូចជាបុគ្គល ធ្វើបុណ្យហើយអធិដ្ឋានសូមឲ្យខ្លួនបានទៅកើតក្នុងភព ដែលខ្លួនជ្រើសរើសឬពេញចិត្ត។

**វិភវតណ្ហា**. សំដៅយកចំណង់របស់មនុស្សដែលចង់ចេញទៅឲ្យផុតចាកភព គឺជាចំណង់របស់មនុស្សដែលពុំមានជំនឿក្នុងជីវិតអន្ទោល។ អ្នកមិនមានអស្សាសៈក្នុងជីវិត អ្នកឃើញផ្លូវធ្វើអត្តឃាត គឺបំបាត់ជីវិតខ្លួនឯងថាជាឧបាយរំដោះទុក្ខរបស់ខ្លួន។

តែតាមដំណើរនៃការប្រព្រឹត្តទៅ, ភវតណ្ហាអាចនឹងមិនទាក់ទងដោយជំនឿនៃជីវិតអន្ទោលក៏មានដែរ ស្រេចហើយតែនៅមានអស្សាសៈក្នុងជីវិត, ក៏នៅតែចង់កើត, ចង់នៅក្នុងភព, នៅតែសប្បាយ នៅតែមានសេចក្ដីហួងហែងលោកជានិច្ចកាល។

ចំណែកវិភវតណ្ហា អាចនឹងមិនទាក់ទងដោយជំនឿថា មិនកើតទៀតឬមិនមានជីវិតអន្ទោលក៏មាន ស្រេចហើយតែមានសេចក្ដីចង្អៀតចង្អល់ក្នុងជីវិតក៏មានចំណង់មិនចង់កើតក្នុងភព; មិនចង់រស់នៅក្នុងភព; បើទម្ងន់នៃចិត្តចង្អៀតចង្អល់នេះ កាន់តែមានទំហំធំឡើង អត្តឃាតរមែងកើតមានក្នុងពេលនោះឯង។

ទិដ្ឋភាពទាំងពីរយ៉ាងនេះ, គេតែងបានជួបប្រទះក្នុងសង្គមជនសព្វថ្ងៃនៅក្នុងភូមិភាគនៃពិភពលោក បើមិនត្រង់នេះ ក៏ត្រង់ណោះដែរ។

តណ្ហាទាំង៣នេះលោកចែកទុកក្នុងនិទ្ទេសនៃទុក្ខសមុទ័យ, តែក្នុងបាលី



www.elibraryofcambodia.org

ដទៃលោកសម្តែងអំពីតណ្ហាដែលមានការទាក់ទងជាមួយនឹងអាយតនៈខាងក្រៅមានរូបជាដើម។

ក្នុងយ៉ាងមួយៗ ដូចជាមានកំណត់ព្រំដែនត្រឹមតែកាមតណ្ហា ដែលតែងកើតមានក្នុងបិយារម្មណ៍ ដូចដែលយើងធ្លាប់ចូលចិត្តជាធម្មតាមក។ ការលះតណ្ហាបានទាំងអស់, បានឈ្មោះថាមានវិរាគធម៌។

«**វិរាគៈ**» មានសេចក្តីផ្ទុយគ្នាអំពី «**រាគៈ**» គឺបានដល់ការអស់តម្រេក ឬប្រាសចាកសេចក្តីស្នេហា សំដៅយកចិត្តដែលអស់គ្រឿងជ្រលក់ ពោលគឺកិលេសកាម។

«**និរោធ**» ប្រែថារលត់ ដែលនាំឲ្យមានសំនួរថា រលត់អ្វី ? ចម្លើយ, រលត់នូវធម៌ដែលជាហេតុនៃការកើត ឬជាប្រភពនៃកំណើតត្រូវនឹងភាសិតថា ៖

«**តេសញ្ច យោ និរោធោ ច...**»

ដូចបាននិយាយដល់ម្តងហើយនឹងភាសិតថា ៖

«**យំកិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មំ**»

ដែលបាននិយាយមកហើយដូចគ្នាដែរ។

«**ឯវមេតស្ស កេវលស្ស ទុក្ខខន្ធស្ស និរោធោ ហោតិ**» «សេចក្តីរលត់នៃទុក្ខខ័ន្ធទាំងអស់រមែងមាន, មិនមែនជាមិនមានទេ»។

ម្យ៉ាងទៀត «**និរោធៈ**» លោកសំដៅយកការរលត់ គឺរម្ងាប់ចិត្តចេតសិកទាំងអស់ ដែលមាននៅក្នុងលំដាប់នៃសមាបត្តិទី៨ ដែលយើងធ្លាប់ហៅថា «**និរោធសមាបត្តិ**» មាននិយាយក្នុងចូឡវេទល្លសូត្រ។

ជាមួយគ្នានេះ លោកសំដៅយកសេចក្តីរលត់ទុក្ខដែលកើតមកអំពីតណ្ហា ដូចមានសម្តែងក្នុងនិទ្ទេសនៃទុក្ខនិរោធអរិយសច្ចៈ។

បើតាមន័យនេះ, ការរលត់តណ្ហាដោយមិនមានសេសសល់ ប្រែថាមិនមានទុក្ខកើតឡើងព្រោះចិត្តនិងចេតសិកក៏បានឈ្មោះថា «**វិរាគៈ**» ក្នុងទីនេះ។ អ្នកអានគប្បីដឹងថា និព្វានដែលបាននិយាយមកហើយ ហើយនឹងនិយាយទៅ



www.elibraryofcambodia.org

ខាងមុខទៀតនោះ ក៏លោកឲ្យឈ្មោះថា «**វិរាគៈ**» ផងដែរ។

«**វិរាគៈ**» បើនិយាយក្នុងលំដាប់នៃនិព្វិទា លោកថាបានដល់អរិយមគ្គ។ ចំណែកក្នុងអត្ថប្បសាទសូត្រលោកថា វិរាគៈជាធម៌ប្រសើរបំផុត ហើយជាសទិសៈជាមួយនឹងធម៌ទាំងឡាយដទៃមាននិព្វានជាដើម។

យ៉ាងណាក៏ដោយ, អ្នកប្រតិបត្តិធម៌ដើម្បីហាត់ចិត្ត, គប្បីកំណត់ចងចាំនូវសទិសពាក្យនោះៗ ដើម្បីញុំាងសេចក្តីប្រតិបត្តិរបស់ខ្លួនឲ្យទៅជាបរមត្ថបដិបទា, ព្រមគ្នានេះ, សូមកុំភ្លេចយោនិសោមនសិការៈ ដែលត្រូវតែមានជាមួយនឹងការប្រព្រឹត្តធម៌របស់ខ្លួន។

មានសេចក្តីមួយអន្លើទៀត, ដែលយើងគប្បីធ្វើសេចក្តីសង្កេតថា បរមត្ថបដិបទាទាំងប៉ុន្មាន ដែលបាននិយាយមកហើយក្តី ដែលនឹងមាននិយាយទៅក្នុងខាងមុខក្តី លោកសម្តែងចំពោះតែក្នុងផ្លូវលះកិលេសកាម, ពុំបានសម្តែងដល់ការលះកិលេសជាចំណែកបដិឃៈឡើយ; សម្តែងយ៉ាងនេះ, យើងស្តាប់ទៅដូចជាមិនសព្វគ្រប់ឬពុំទាន់អស់ជើង។

តែការណ៍ពិត, មានសេចក្តីសព្វគ្រប់របស់លោកហើយ ដូចនេះព្រោះអ្វី? ព្រោះកិលេសកាម វាជាមូលដ្ឋាននៃកិលេសទាំងឡាយមានបដិឃៈជាដើម, មាននិទស្សនៈដូចជាសេចក្តីព្យាបាទដែលវានឹងកើតមាននោះ ក៏ព្រោះតែជួបប្រទះនឹងសេចក្តីទាក់ទើស ដែលនាំឲ្យសេចក្តីប្រាថ្នាក្នុងកាមារម្មណ៍ពុំបានសម្រេចដូចបំណងនោះឯង។

## វិមុត្តិ សេចក្តីរួចផុត

«**វិរាគា វិមុច្ចតិ**» សេចក្តីរួចផុត (រមែងកើតឡើង) ព្រោះអស់តម្រេក»។

«**កាមាសវាបិ ចិត្តំ វិមុច្ចិត្ថ ភវាសវាបិ ចិត្តំ វិមុច្ចិត្ថ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចិត្ថ**» ចិត្តរួចផុតស្រឡះចាក**កាមាសវៈ** ចិត្តរួចផុតស្រឡះចាកភវាសវៈ ចិត្តរួចផុត



www.elibraryofcambodia.org

ស្រឡះចាកអវិជ្ជាសវៈ។

«**វិមុត្តស្មិំ វិមុត្តមិតិ ញាណំ ហោតិ**» កាលណាចិត្តរួចផុតស្រឡះចាកអាសវក្កិលេសទាំងឡាយហើយ ប្រាជ្ញញាណរមែងកើតឡើង»។

## សេចក្តីអធិប្បាយ

កាលណាបុគ្គលមានចិត្តអស់តម្រេកហើយ អាសវគឺកិលេសជាគ្រឿងត្រាំចិត្តក៏អស់ព្រមគ្នាក្នុងពេលនោះ។

ពាក្យថា «អាសវ» នេះ ជួនកាលលោកប្រើទៅជាឈ្មោះនៃមេរ័យក៏មានដូចជា «ផលាសវោ» ទឹកស្រវឹងដែលកើតអំពីតម្រាំនៃផ្លែឈើ។ ជាឈ្មោះនៃកិលេសក៏មានដូចជា «កាមាសវោ» ដែលមាននិយាយក្នុងទីនេះ ឬកិលេសទាំងឡាយដទៃទៀត ក៏លោកឲ្យឈ្មោះថាអាសវៈដែរ។

សេចក្តីនេះ នាំឲ្យយើងចូលចិត្តដល់ទៅកិលេសានុស័យ គឺកិលេសដែលដេកជ្រកនៅក្នុងសន្តានចិត្តរបស់សត្វទាំងឡាយ ក៏បានឈ្មោះថាអាសវផងដែរ។

ដូចនេះ, ពាក្យថាកិលេស, និងពាក្យថា "អាសវ" គឺជាសទិសពាក្យបាលីហៅថា «អាសវ» ក្នុងអត្ថកថា លោកច្រើនហៅថា: កិលេស។ កាមាសវៈប្រៀបធៀបទៅនឹងកាមតណ្ហា ភវាសវៈប្រៀបធៀបទៅនឹងភវតណ្ហា អវជ្ជាសវៈបានដល់តួអវិជ្ជាហ្នឹងឯង ដែលយើងធ្លាប់ប្រែថា ភាពមិនដឹង, មិនស្គាល់, គឺសេចក្តីល្ងង់ខ្លៅ។

អ្នកអានគួរធ្វើសេចក្តីកត់សំគាល់ក្នុងទីនេះថា អវិជ្ជាសវ និងភវាសវៈទាំងពីនេះ មានសេចក្តីផ្សេងគ្នា តែមានន័យត្រូវគ្នា ព្រោះអវិជ្ជានាំសត្វឲ្យជាប់ជំពាក់នៅក្នុងភព។ មោហៈជាកិលេសមួយយ៉ាងធំនៅក្នុងអកុសលមូល ក៏កើតមានឡើងព្រោះអវិជ្ជា កិលេសនេះវាធ្វើមិនឲ្យដឹងនូវសេក្តីពិតតាមសភាវធម៌។

ដោយអាស្រ័យសេចក្តីមិនដឹងនេះ, ជំនឿថាមានព្រះអាទិទេពសាង



www.elibraryofcambodia.org

លោក ក៏កើតមានឡើងដែរ. ជំនឿនេះនាំឲ្យមានការបន់ស្រន់បួងសួង រហូតដល់ប្រកាន់យកនូវសីលព្វតបរាមាសៈ ។ កំណាន់ក្នុងសេចក្ដីស័ក្ដិសិទ្ធិនៅក្នុងគំនិតថា របស់នេះមានការជាប់ទាក់ទងមកអំពីព្រះអាទិទេព លោកសង្គ្រោះចូលក្នុងអវិជ្ជាសវទាំងអស់។

**វិមុត្តិ**. បើនៅក្នុងលំដាប់នៃវិរាគៈ លោកថាបានដល់អរិយផល បើនៅក្នុងលំដាប់នៃញាណ លោកថាបានដល់ការដឹងច្បាស់នូវអរិយសច្ចៈ៤។

ក្នុងកន្លែងខ្លះ. លោកបញ្ជាក់ថា ញាណកើតចាកវិមុត្តិក្នុងទីដទៃទៀត, លោកហៅថា “**វិមុត្តិសញ្ញាណទស្សនៈ**”។

“**វិមុត្តិ**” ក្នុងបាលីលោកពុំបានបញ្ជាក់ច្បាស់លាស់ថា កើតមានក្នុងខណៈនៃមគ្គកើតឬខណៈនៃផលកើតទេ តែមានសេក្ដីបញ្ជាក់ច្បាស់លាស់ត្រង់លោកចែកចេញជាពីរគឺ **វិមុត្តិ១**, **វិមុត្តិញ្ញាណទស្សនៈ១** បើតាមន័យនេះ ដូចជាគួរឲ្យយើងចូលចិត្តថា “**វិមុត្តិ**” ជា **អរិយមគ្គ** “**វិមុត្តិញ្ញាណទស្សនៈ**” ជា **អរិយផល**។ **វិមុត្តិ** ទាំងពីរប្រភេទនេះ “**វិមុត្តិ**” មានមកក្នុងបាលីថា “**វិរាគា វិមុច្ចតិ**” គួរទុកដាក់ថា វិមុត្តិនេះជាកិច្ចនៃចិត្ត គឺជា**អរិយមគ្គ**។ **វិមុត្តិញ្ញាណទស្សនៈ** មានមកក្នុងបាលីថា **វិមុត្តស្មឹ វិមុត្តមីតិ ញាណំ ហោតិ** វិមុត្តិនេះគួរទុកដាក់ថាជាកិច្ចនៃបញ្ញា គឺជា **អរិយផល**។

ក្នុងន័យនេះ **វិរាគៈ**លោកពុំបានពោលដល់ទេ, លោកនិយាយតែអំពី **វិមុត្តិ** និង **វិមុត្តិញ្ញាណទស្សនៈ**ព្រមគ្នាតែម្ដង។

ចំពោះរឿងនេះ យើងត្រូវបកស្រាយសេចក្ដីថា **វិមុត្តិ** បានដល់ **អរិយមគ្គ**; **វិមុត្តិញ្ញាណទស្សនៈ** បានដល់ **អរិយផល**។ ប្រសិនបើមានតែវិមុត្តិ មិនមាន **វិមុត្តិសញ្ញាណទស្សនៈ** យើងគួរធ្វើសេចក្ដីសន្និដ្ឋានថា បានដល់ **អរិយមគ្គ**ផង, និង**អរិយផល**ផង។ ចំណែក “**ចេតោវិមុត្តិ**” និង “**បញ្ញាវិមុត្តិ**” ដែលមាននិយាយក្នុងនិទ្ទេសនៃបដិបទារបស់ព្រះអរហន្តនោះ ទំនងជាបានផលវិមុត្តិ



www.elibraryofcambodia.org

ទាំងពីរនេះ ចេតោវិមុត្តិបានដល់បដិបទានៃព្រះអរហន្តដែលបានសម្រេចអរិយមគ្គ ដោយបំពេញសមថភាវនានិងវិបស្សនាភាវនា។

បញ្ញាវិមុត្តិបានដល់បដិបទា នៃព្រះអរហន្តដែលបានសម្រេចអរិយមគ្គដោយចំរើនវិបស្សនាតែម្យ៉ាង។ ចំណុចត្រង់នេះ យើងលំបាកនឹងចូលចិត្ត ព្រោះមានសេចក្តីមិនស្រមតាមលំដាប់នៃវិសុទ្ធិ៧ប្រការ តែជាយោបល់មួយដែលធ្វើឲ្យយើងមានពន្លឺក្នុងការប្រតិបត្តិធម៌ជាន់ខ្ពស់ដែរ។

**វិមុត្តិ**នេះ. យើងចាត់ចូលថាជា**លោកុត្តរធម៌** តែក្នុងបាលីដែលសម្តែងអំពី **អសេខធម្មក្ខន្ធ** លោកប្រើពាក្យថា **អសេខ:** គ្រប់អន្លើថា “**អសេខេន វិមុត្តិក្ខន្ធេន, អសេខេន វិមុត្តិញ្ញាណទស្សនក្ខន្ធេន សមន្នាគតោ**” “ប្រកបព្រមហើយដោយកងនៃវិមុត្តិរបស់ព្រះអសេខ:” ។

អ្នកអានសូមធ្វើសេចក្តីសង្កេតថា បើតាមបាលីនេះដូចជាលោកចង់និយាយថា វិមុត្តិជារបស់ព្រះអេសខ: វិមុត្តិញ្ញាណទស្សនៈជារបស់ព្រះអសេខ: គឺថាវិមុត្តិរបស់ព្រះសេខ:ក៏មាន. របស់ព្រះអសេខ:ក៏មាន, តែមិនដឹងជាយ៉ាងដូចម្តេចទើបលោកប្រើស័ព្ទថា “អសេខ:” ទាំងពីរអន្លើទៅវិញ។ ម្យ៉ាងទៀត, ក្នុងបាលីដែលសម្តែងអំពីបដិបទានៃព្រះអរហន្ត លោកប្រើពាក្យថា “អនាសវៈ” បានដល់បាលីថា “**អនាសវំ, ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ**” ប្រែថា (ធ្វើឲ្យច្បាស់លាស់) **នូវចេតោវិមុត្តិ**, **នូវបញ្ញាវិមុត្តិ** ដ៏មិនមានអាសវៈ ត្រង់ចំណុចនេះ ដូចជាលោកចង់និយាយថា វិមុត្តិជាសាសវៈក៏មានដែរ។

ក្នុងធម៌ចក្កប្បវត្តនសូត្រមានបាលីថា “**អកុប្បាមេវិមុត្តិ**” “វិមុត្តិរបស់យើងមិនមានកម្រើក” ត្រង់នេះស្តាប់មើលទៅ ក៏ដូចជាមានវិមុត្តិមួយទៀតមានកម្រើក។

ប្រសិនបើវិមុត្តិជាលោកិយមិនមានទេ, ដូចម្តេចក៏ចាំបាច់ត្រូវដាក់ពាក្យមានគូនេះមកធ្វើអ្វី, តើវាមានប្រយោជន៍យ៉ាងណាក្នុងរឿងនេះ។

ប្រហែលជាដោយន័យនេះទេដឹង! បានជាអាចារ្យជាន់ក្រោយ នាំគ្នា



www.elibraryofcambodia.org

ចែកវិមុត្តិ ទៅជា ៥ គឺ “**តទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និស្សរណវិមុត្តិ**” (សេចក្ដីប្រែមាននៅក្នុងទីទូទៅស្រាប់ហើយ) ការដាក់តទង្គវិមុត្តិចូលមកឬការមានតទង្គវិមុត្តិ ដូចជានាំឲ្យយើងចូលចិត្តថា វិមុត្តិមិនមែនមានតែព្រះអសេខៈទេ, ព្រះសេខៈនិងបុថុជ្ជនក៏មានវិមុត្តិនេះផងដែរ។

ការបញ្ញត្តឲ្យមាន**វិក្ខម្ភនវិមុត្តិ** ក៏ដូចជានាំឲ្យយើងមានយោបល់ថា **ចេតោវិមុត្តិ ជាសាសវ** ក៏មានដែរ។

ការបញ្ញត្តឡើងនូវ **សមុច្ឆេទវិមុត្តិ** និង **បដិបស្សទ្ធិវិមុត្តិ** ក៏ដូចជានាំឲ្យយើងធ្វើសេចក្ដីសន្និដ្ឋានថា វិមុត្តិ ក៏ប្រព្រឹត្តទៅបានទាំង**អរិយមគ្គទាំងអរិយផល** ដូចដែលបាននិយាយមកហើយ។ ការបង្កើតឲ្យមាននិស្សរណវិមុត្តិ បើពិចារណាមើលទៅ ក៏មិនឃើញមានប្រយោជន៍អ្វី ក្រៅអំពីបំពេញចំនួននៃគុណភាពរបស់លោកុត្តរធម៌ទាំង៣ខាងចុង ឲ្យមានកំពស់ជាងលោកុត្តរមួយខាងដើមប៉ុណ្ណោះ។

ចំណែកអ្នកប្រតិបត្តិធម៌ ក៏មិនមានប្រយោជន៍អ្វីក្រៅអំពីធ្វើចិត្តឲ្យរួចផុតចាកកិលេសកាមវត្ថុកាមនិងអកុសលវិតក្កៈទាំងឡាយដទៃទៀតដែលរាំងរាបិទផ្លូវមិនឲ្យបានសម្រេចនិព្វាន ដែលទាំងអស់គ្នាមានយោបល់ថា មានតែនិព្វានទេ ទើបធ្វើឲ្យមនុស្សអស់ទុក្ខបានសេចក្ដីសុខយ៉ាងទៀងទាត់។

# វិសុទ្ធិ សេចក្ដីបរិសុទ្ធ

“**បញ្ញាយ បរិសុជ្ឈតិ**” “សេចក្ដីបរិសុទ្ធ (កើតមាន) ដោយអាស្រ័យបញ្ញា”។

“**ឯស មគ្គោ វិសុទ្ធិយា**” “នេះ (គឺជានិព្វិទា) ជាផ្លូវនៃសេចក្ដីបរិសុទ្ធ។



www.elibraryofcambodia.org

## សេចក្ដីអធិប្បាយ

លទ្ធិព្រាហ្មណ៍គេមានជំនឿថា បាបដែលបុគ្គលធ្វើហើយអាចបណ្តែតបោលបាន ដោយធ្វើពិធីងូតទឹកលាងជម្រះ ដូចយើងងូតទឹកជម្រះកំអែលអីចឹងដែរ។

លទ្ធិគ្រីស្តនិងលទ្ធិឥស្លាមគេមានជំនឿថា ការបួងសួងអង្វរសុំអភ័យទោសអំពីព្រះជាម្ចាស់សួគ៌ ដើម្បីទ្រង់ប្រោសប្រទាន ក៏រួចចាកបាបទំនងដូចគ្នានឹងព្រះរាជាទ្រង់លើកទោសឲ្យប្រជារាស្ត្រ ដែលមានកំហុសចំពោះព្រះអង្គ។ ចំណែកព្រះពុទ្ធសាសនារបស់យើង ពុទ្ធសាសនិកមានជំនឿថា :

**«អត្តនាវ កតំ បាបំ អត្តនា សង្កិលិស្សតិ**
**អត្តនា អកតំ បាបំ អត្តនាវ វិសុជ្ឈតិ**
**សុទ្ធិ អសុទ្ធិ បច្ចត្តំ អញ្ញោ នាញ្ញំ វិសោធយេ»**

«ធ្វើបាបខ្លួនឯង រមែងសៅហ្មងខ្លួនឯង មិនធ្វើបាបខ្លួនឯង រមែងបរិសុទ្ធខ្លួនឯង សេចក្តីបរិសុទ្ធនិងសេចក្តីសៅហ្មងកើតព្រោះខ្លួនធ្វើ អ្នកដទៃពុំអាចឲ្យសេចក្តីបរិសុទ្ធសេចក្តីសៅហ្មងដល់ខ្លួនបានទេ»។

ក្នុងន័យនេះ យើងត្រូវតែប្រកាន់យកថា សេចក្តីបរិសុទ្ធខាងក្នុង រមែងត្រូវកើតមានដោយបញ្ញា។ បុគ្គលពិចារណាឃើញដោយបញ្ញាថា សង្ខារទាំងឡាយកើតហើយរលត់, នេះចាត់ជាឧទយព្វយញ្ញាណ។ ឃើញសេចក្តីប្រែប្រួលរាល់ខណៈ, ចាត់ជាភង្គញ្ញាណ។ ឃើញទោសនិងទុក្ខព្រួយ, ចាត់ជាអាទីនវញ្ញាណ។

ឃើញថាជាអនត្តាឬឃើញភ័យក្នុងការប្រកាន់ថាមានអត្តា, ចាត់ជាភយតូបដ្ឋានញ្ញាណ។

ឃើញថាគួរនឿយណាយធុញទ្រាន់, ចាត់ជានិព្វិទាញាណ។

ឃើញឧបាយដកចេញនូវឧបាទាន, ចាត់ជាមុញ្ចិតុកម្យតាញាណ។

ឃើញផ្លូវប្រតិបត្តិឬឃើញឧបាយរំដោះទុក្ខ, ចាត់ជាបដិសង្ខារញាណ។

ភាពព្រងើយកន្តើយក្នុងសង្ខារធម៌ ដោយអាស្រ័យបញ្ញាពិចារណា, ចាត់



www.elibraryofcambodia.org

ជាសង្ខារុបេក្ខាញាណ។

ឃើញអរិយសច្ចៈ, ចាត់ជាសច្ចានុលោមញ្ញាណ។ រួមត្រូវជាវិបស្សនាញាណ៩ប្រការ។ ដល់មកត្រង់នេះអ្នកចម្រើនវិបស្សនា មានចិត្តបិតនៅក្នុងភាពប្រផុតប្រផើយ ប្រែថា នៅក្នុងភាវៈនៃបុថុជ្ជននិងភាវៈនៃអរិយៈ គឺថាមិនទាន់លះបង់សន្តានបុថុជ្ជនបាននៅឡើយ តែជិតៗនឹងបានហើយ។

ត្រង់នេះលោកឲ្យឈ្មោះថា «**គោត្រភូញាណ**» ប្រែថា ញាណគ្របសង្កត់គោត្រ ដោយន័យថាគ្របសង្កត់គ្រោតនៃបុថុជ្ជនហ្នឹងឯង។ បើអ្នកវិបស្សនាចេះតែចម្រើនជាបទអនុលោម, បដិលោមរឿយៗទៅ គោត្របុថុជ្ជននឹងអស់ទៅ គោត្រអរិយៈក៏កើតឡើងក្នុងពេលនោះឯង។

នេះគឺជាសេចក្ដីប្រតិបត្តិធម៌ជាន់ខ្ពស់ ដើម្បីសម្រេចនូវអរិយមគ្គ, អរិយផលតាមលំដាប់ថ្នាក់នៃវិបស្សនាញាណ ដែលមានវិសុទ្ធិ៧ប្រការជាមូលដ្ឋាន។

ក្នុងរឿងជាមួយគ្នានេះ លោកមានសម្ដែងម្យ៉ាងទៀតថា :

**«មគ្គានដ្ឋង្គិកោ សេដ្ឋោ ..........................**

**ឯសេវ មគ្គោ នត្ថញ្ញោ ទស្សនស្ស វិសុទ្ធិយា»។**

«ផ្លូវមានអង្គ៨ ជាផ្លូវប្រសើរបំផុតជាងផ្លូវទាំងឡាយដទៃ ផ្លូវនេះឯងជាផ្លូវបរិសុទ្ធ ដើម្បីទស្សនៈនៃបេក្ខបុគ្គលដែលមាននិព្វានជាបេក្ខភាព ក្នុងន័យថាជាផ្លូវប្រសើរ វិសេសសម្រាប់អ្នកសម្លឹងយកនិព្វានឬមាននិព្វានជាអារម្មណ៍»។

## សេចក្ដីអធិប្បាយ

ផ្លូវ៨ប្រការនេះ, ក្នុងនិទ្ទេសនៃទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈលោករាប់ដូចនេះគឺ ៖

«សម្មាទិដ្ឋិ ធំហើញត្រូវ

សម្មាសង្កប្បៈ តម្រិះត្រូវ,

សម្មាវាចា ពំនោលត្រូវ



www.elibraryofcambodia.org

សម្មាកម្មន្ត ទំរើត្រូវ
សម្មាអាជីវៈ ចិញ្ចឹមជីវិតត្រូវ
សម្មាវាយាមៈ ព្យាយាមត្រូវ
សម្មាសតិ រលឹកត្រូវ
សម្មាសមាធិ តាំងចិត្តត្រូវ»។

ក្នុងអត្ថប្បសាទសូត្រ, លោកពោលលើកមគ្គ៨នេះ ថាជាកំពូលនៃសង្ខតធម៌។

ផ្លូវនេះ, ជាផ្លូវប្រតិបត្តិប្រសើរបំផុត, ជាផ្លូវដឹកនាំអ្នកប្រតិបត្តិឲ្យដល់ទីបំផុតនៃទុក្ខឬជាផ្លូវនាំអ្នកប្រតិបត្តិឲ្យដល់នូវភាពបរិសុទ្ធនៃទស្សនៈរបស់ខ្លួន។

ផ្លូវនេះលោកសង្គ្រោះចូលក្នុងសង្ខតធម៌ តែជាផ្លូវជូនអ្នកដើរឲ្យដល់ទៅអសង្ខតធម៌គឺនិព្វាន។

មគ្គ៨នាំអ្នកប្រតិបត្តិឲ្យដល់នូវសេចក្តីបរិសុទ្ធនៃទស្សនៈរបស់ខ្លួនយ៉ាងដូចម្តេចខ្លះ ?

សំនួរនេះ, លោកបានឲ្យចម្លើយថា ព្រោះមគ្គ៨ ត្រូវចូលជាមួយនឹងវិសុទ្ធិ៧ប្រការដែលលោកទុកជាមូលដ្ឋាននៃវិបស្សនាញាណគឺ : **សម្មាវាចា, សម្មាកម្មន្តៈ សម្មាអាជីវៈ** សង្គ្រោះចូលក្នុង**សីលវិសុទ្ធិ**។ **សម្មាវាយាមៈ, សម្មាសតិ, សម្មាសមាធិ** សង្គ្រោះចូលក្នុង**ចិត្តវិសុទ្ធិ**។ **សម្មាទិដ្ឋិនិងសម្មាសង្កប្បៈ** សង្គ្រោះចូលក្នុង**ទិដ្ឋិវិសុទ្ធិ**, **កង្ខាវិតរណវិសុទ្ធិ**, **មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ**, **បដិបទាញាណទស្សនវិសុទ្ធិ**។

សម្មាសង្កប្បៈ មានការពិចារណាស្រាវជ្រាវជាកិច្ច សម្មាទិដ្ឋិ មានការធ្វើសេចក្តីសន្និដ្ឋានជាកិច្ច។

បុគ្គលពិចារណាឃើញសង្ខារប្រកបដោយត្រៃលក្ខណ៍ ចាត់ជាទិដ្ឋិវិសុទ្ធិភាពស្អាតនៃគំហើញ។

ពិចារណាឃើញសេចក្តីប្រព្រឹត្តទៅនៃសង្ខារជាមួយនឹងហេតុ តាមលំអាន



www.elibraryofcambodia.org

នៃបាលីថា :

**«យថាហិ អញ្ញតរំ ពីជំ ខេត្តេ វុត្តំ វិរូហតិ**

**បឋវី រសេញ្ច អាគម្ម សិនេហញ្ច តទូភយំ**

**ឯវំ ខន្ធា ច ធាតុយោ ឆ ច អាយតនា ឥមេ**

**ហេតុំ បដិច្ច សម្ភូតា ហេតុភង្គា និរុជ្ឈរេ»។**

«សេចក្តីថា ពូជនៃរុក្ខជាតិណាមួយ ដែលគេដាំក្នុងស្រែចម្ការ ពូជនោះវាអាស្រ័យនូវរសផែនដីផង នូវជីវជាតិផង របស់ទាំងពីរយ៉ាងនេះ ជាធាតុធ្វើឲ្យពូជក្នុងស្រែចំការដុះបានល្អ យ៉ាងណាមិញ។

**ខន្ធ ធាតុ អាយតនៈ** ទាំងឡាយឯណានេះ វេលាកើតឡើងក៏ព្រោះអាស្រ័យហេតុដែលនាំឲ្យកើត វេលារលត់ទៅវិញក៏ព្រោះរលត់ហេតុដែលជាប្រភពនៃកំណើតយ៉ាងនោះដែរ»។ គំហើញបែបនេះ លោកចាត់ជាកង្ខាវិតរណវិសុទ្ធិ ភាពស្អាតនៃវិញ្ញាណជាគ្រឿងឆ្លងចាកសេចក្តីសង្ស័យ។ បន្ទាប់មកទៀត, គេពិចារណាឃើញសង្ខារតាមលំអាននៃបាលីថា :

**«អថស្ស កង្ខា វបយន្តិ សព្វា**

**យតោ បជានាតិ សហេតុធម្មំ**

**យតោ ខយំ បច្ចយានំ អវេទិ»។**

«ក្នុងកាលនោះ សេចក្តីសង្ស័យគ្រប់យ៉ាងរបស់ព្រាហ្មណ៍នោះ រមែងអស់ទៅព្រោះតែគេបានស្គាល់នូវធម៌ ដែលប្រព្រឹត្តទៅជាមួយនឹងហេតុ, និងព្រោះគេបានដឹងនូវភាពអស់ទៅនៃបច្ច័យទាំងឡាយ (ដែលជាប្រភពនៃកំណើត)»។

ការពិចារណាឃើញសង្ខារក្នុងទំនងដូចពោលមកនេះ ជាមួយនឹងយោនិសោមនសិការៈ ដែលបុគ្គលធ្វើឲ្យកើត, ហើយរក្សាទុកអស់កាលជានិច្ច, ក្នុងខណៈនេះគេក៏នឹងបានដឹងថា ការតម្កល់ចិត្តរបស់គេយ៉ាងណាត្រូវ, យ៉ាង



www.elibraryofcambodia.org

ណាខុស ដូចបាននិយាយមកហើយក្នុងអនត្តលក្ខណៈ នេះចាត់ជាមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ភាពស្អាតនៃញាណទស្សនៈ ក្នុងន័យជាផ្លូវឬមិនមែនផ្លូវ។

ពិចារណាឃើញសង្ខារព្រមជាមួយនឹងភាពសម្រេចនៃអរិយមគ្គ, លោកចាត់ជាបដិបទាញាណទស្សនវិសុទ្ធិ សេចក្ដីបរិសុទ្ធម៉ត់ចត់នៃញាណទស្សនៈខាងមគ្គ។ ពិចារណាឃើញសង្ខារជាមួយនឹងភាពកើតឡើងនៃអរិយផល លោកចាត់ជាញាណទស្សនវិសុទ្ធិ ភាពស្អាតនៃញាណទស្សនៈ។ ក្នុងលំដាប់នោះបុគ្គលអ្នកប្រតិបត្តិធម៌នឹងបានដឹងច្បាស់ថា :

**«ឯសេវ មគ្គោ នត្ថញ្ញោ ទស្សនស្ស វិសុទ្ធិយា»**

«ផ្លូវនេះឯង ជាផ្លូវត្រូវ, មិនមានផ្លូវឯណាដទៃដើម្បីសេចក្ដីបរិសុទ្ធម៉ត់ចត់ដូចផ្លូវនេះឡើយ»។

ក្នុង **រថវិនីតសូត្រ មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ** លោកសម្ដែងអំពីវិសុទ្ធិ៧ប្រការថា ធម្មជាតុនេះជាធម្មជាតុជូនដំណើរអ្នកប្រតិបត្តិ អំពីដំណាក់មួយទៅកាន់ដំណាក់មួយទៀត ប្រែថាសីលវិសុទ្ធិ បញ្ជូនទៅឲ្យចិត្តវិសុទ្ធិ... បញ្ជូនតៗគ្នារហូតដល់អនុបាទាយបរិនិព្វាន។

លោកឲ្យសេចក្ដីប្រៀបថា ដូចអ្នកធ្វើដំណើរតាមផ្លូវឆ្ងាយ ដែលត្រូវតែផ្លាស់យានជំនិះជាច្រើនបន្ទាស់ ទើបអាចទៅដល់ទីដៅរបស់ខ្លួននោះឯង។

ក្នុង **វិសុទ្ធិ៧**ប្រការនេះ, វិសុទ្ធិពីរខាងចុង លោកចាត់ចូលក្នុងលោកុត្តរធម៌ ដូចគ្នានឹងវិមុត្តិដែរ; តែសេចក្ដីដៅត្រូវកំណត់យកត្រឹមតែភាពបរិសុទ្ធនៃទស្សនៈ។ វិសុទ្ធិដទៃទៀត, ដែលមានថ្នាក់ទាបជាងវិសុទ្ធិទាំងពីរនេះ លោកថាជាកិច្ចរបស់ចិត្ត ដូចបាននិយាយមកម្ដងហើយ។ ក្នុងរឿងដដែលនេះទៀត, លោកធ្វើសេចក្ដីបញ្ជាក់ថា វិសុទ្ធិដែលចាត់ជាកិច្ចរបស់ចិត្តនិងជាកិច្ចរបស់បញ្ញានោះ គឺគ្រាន់តែចាត់ឲ្យឃើញតាមបរិមាណរបស់បញ្ញានិងចិត្ត ដែលមានច្រើនតិចជាងគ្នាប៉ុណ្ណោះទេ; ឯគុណភាពឬកំពស់នៃធម៌នេះ នៅតែជាប់ទាក់ទងគ្នាដដែល មិនអាចនឹងញែកចេញឲ្យដាច់ពីគ្នាបានទេ។



www.elibraryofcambodia.org

ឧទាហរណ៍ ដូចជាចិត្តវិសុទ្ធិក៏គង់មានបញ្ញានៅក្នុងនោះ ទិដ្ឋិវិសុទ្ធិក៏គង់មានចិត្តនៅក្នុងនោះ; ដែលលោកពោលថា “**បញ្ញាយបរិសុជ្ឈតិ**” រមែងបរិសុទ្ធដោយបញ្ញា ពាក្យនេះបើមានសំនួរថាអ្វីជាបទកត្តាឬជាបទការកៈ គឺអ្វីជាអ្នកបរិសុទ្ធ? ចម្លើយក៏ត្រូវឲ្យថា ចិត្តជាបទកត្តាឬជាបទការកៈឬចិត្តជាអ្នកបរិសុទ្ធ។

មានសេចក្តីមួយអន្លើទៀត ដែលយើងមានចម្ងល់ គឺលោកលើកយកចេតោវិមុត្តិទុកជាធម៌ មានកំពស់ជាងចិត្តវិសុទ្ធិ, យោបល់របស់លោកក្នុងរឿងនេះ ខ្ញុំមិនសូវយល់ទេ។

ចំណែកយោបល់របស់ខ្ញុំ, ខ្ញុំយល់ថាមិនខ្ពស់ទាបជាងគ្នាទេធម៌ទាំងពីរនេះ ប្រសិនបើទុកដាក់ឲ្យមានកំពស់ជាងគ្នា វានឹងមានទំនាស់ក្នុងផ្លូវអធិប្បាយដូចនេះព្រោះអ្វី? ព្រោះវិមុត្តិ ប្រែថាចិត្តរួចផុតចាកសេចក្តីសៅហ្មង, ចិត្តវិសុទ្ធិប្រែថា ចិត្តបរិសុទ្ធ សេចក្តីនេះមានន័យត្រូវគ្នាមិនមែនខុសគ្នាទេ។ យ៉ាងណាក៏ដោយចំពោះបញ្ហាលើកកំពស់នេះ អ្នកអានទាំងឡាយ សូមធ្វើសេចក្តីសន្និដ្ឋានខ្លួនឯងចុះ។

វិសុទ្ធិនេះ, ក្នុងទីទូទៅលោកពុំបានរៀងលំដាប់ក្នុងទីបំផុតនៃវិមុត្តិទេ តែបើយើងគិតពិចារណាតាមខ្សែធម៌ឬគិតតាមន័យរបស់ធម៌, វិសុទ្ធិត្រូវនៅបន្ទាប់អំពីវិមុត្តិ។ រឿងនេះ អ្នកអានគប្បីយល់តាមសេចក្តីប្រៀបធៀបថា សំពត់ដែលត្រូវគេបោកគក់ហើយ រមែងជ្រះអស់មន្ទិល។

កាលណាមន្ទិលអស់ សំពត់ក៏មានពណ៌សម្បុរសស្អាតយ៉ាងណាមិញ ចិត្តដែលគេបានធ្វើឲ្យមានសម្រស់អស់គ្រឿងសៅហ្មង គឺកិលេសកាមឬអាសវៈហើយ រមែងរួចផុតចាកមន្ទិល, រមែងបរិសុទ្ធស្អាតយ៉ាងនោះដែរ។

ដោយអាស្រ័យហេតុនេះ, ទើបខ្ញុំសរសេរអំពីវិសុទ្ធិឲ្យនៅក្នុងលំដាប់នៃវិមុត្តិ។ ប្រសិនបើមិនសរសេរដូច្នេះទេ ពាក្យទាំងពីរឬនាមទាំងពីរនេះ នឹងទៅជាសមូហនាម ជាឈ្មោះរួមគ្នាគឺ វិមុត្តិនិងវិសុទ្ធិឬអាចនឹងរួមគ្នាជាសមូហនាមដល់ទៅ៣ គឺ វិរាគៈ, វិមុត្តិ និងវិសុទ្ធិដូចបានពោលមកហើយក្នុងខាងដើម ឬ



www.elibraryofcambodia.org

ម្យ៉ាងទៀតអាចនឹងទៅជាសទិសពាក្យនៃវិមុត្តិទាំងវិរាគៈ ទាំងវិសុទ្ធិ។

ចំណែកអ្នកប្រតិបត្តិធម៌វិញ, ការហ្វឹកហាត់ចិត្តទៅតាមផ្លូវនៃវិសុទ្ធិ គឺជាការល្អវិសេសមួយ ក្នុងផ្នែកបរមត្ថបដិបទានេះ។

## សន្តិ សេចក្តីស្ងប់

**«សន្តិមគ្គមេវ ព្រូហយ»** ចូរអ្នកបណ្តុះពូននូវផ្លូវនៃសេចក្តីស្ងប់»។

**«នត្ថិ សន្តិ បរំ សុខំ»** សុខដទៃក្រៅអំពីសេចក្តីស្ងប់មិនមាន»

**«លោកាមិសំ បជហេ សន្តិបេក្ខោ»** «បេក្ខបុគ្គលនៃសេចក្តីស្ងប់ គប្បីលះបង់នូវអាមិសក្នុងលោកនេះ»។

### សេចក្តីអធិប្បាយ

ព្រះពុទ្ធភាសិតក្នុងចំណុចនេះ, តម្រូវឲ្យយើងបណ្តុះពូននូវផ្លូវនៃសេចក្តីស្ងប់គឺសាងផ្លូវស្ងប់ លះបង់ផ្លូវសប្បាយភ្លើតភ្លើនតាមផ្លូវកាម ផ្លូវតណ្ហា។ សន្តិធម៌ ជាធម៌ប្រព្រឹត្តទៅក្នុងត្រៃទ្វារ អ្នកអានគប្បីដឹងតាមន័យដែលមានមកក្នុងបាលីថា :

**«សន្តំ តស្ស មនំ ហោតិ**

**សន្តា វាចា ច កម្ម ច»។**

«ចិត្តរបស់បុគ្គលនោះជាធម្មជាតុស្ងប់ហើយ វាចានិងកាយរបស់គេ ក៏ជាធម្មជាតុស្ងប់ផងដែរ។ ស្ងប់កាយស្ងប់វាចាលោកចាត់ជាសន្តិខាងក្រៅ, ស្ងប់ចិត្តលោកចាត់ជាសន្តិខាងក្នុង។ ទំរើ, ពំនោល, គំនិតឯណាប្រព្រឹត្តទៅដើម្បីសន្តិ គឺវៀរចាកការបៀតបៀនគ្នា, ដឹកនាំគ្នាឲ្យមានសាមគ្គីធម៌។ វៀរចាកជម្លោះ, ដឹកនាំគ្នាឲ្យរស់នៅជាមួយនឹងព្រហ្មវិហារធម៌; វៀរចាកពំនោលអាក្រក់, ដឹកនាំគ្នាឲ្យមានពំនោលល្អ; វៀរចាកគំនិតអាក្រក់; ដឹកនាំគ្នាឲ្យមានគំនិតល្អ។



www.elibraryofcambodia.org

ដើម្បីពង្រឹងសន្តិធម៌ ឲ្យឋិតនៅក្នុងភាពប្រក្រតី កុំឲ្យធ្លាក់ចុះទៅវិញ; សន្តិបុគ្គលមិនមែនត្រូវប្រព្រឹត្តត្រឹមតែប៉ុណ្ណោះទេ គឺត្រូវខំហាត់, ខំទាញចិត្តរបស់ខ្លួនឲ្យចូលទៅជ្រកក្នុងបរមត្ថបដិបទា ដែលជាជម្រកមួយយ៉ាងមាំនោះទៀតផង។

ហេតុដូចម្ដេចទើបព្រះសម្ពុទ្ធទ្រង់បំភ្លឺនិងតម្រូវយ៉ាងនេះ? ព្រោះតាមការពិសោធន៍របស់ព្រះអង្គដែលធ្លាប់មានមកហើយនោះ មិនមានសុខដទៃមានកំពស់ជាងសុខដែលកើតអំពីសន្តិនេះឡើយ។ កាមសុខជាសុខលាយទៅដោយកំដៅនៃកិលេស។ សុខព្រោះបានលោភយសនិងសេចក្ដីសរសើរ ជាសុខលាយទៅដោយទុក្ខ ដូចបាននិយាយមកម្ដងហើយ។ សុខព្រោះជំនះ ជាសុខលាយទៅដោយពៀរដោយសេចក្ដីព្យាបាទ។

ចំណែកសុខកើតអំពីសេចក្ដីស្ងប់ត្រឹមតែខាងក្រៅ គឺសេចក្ដីសុខកើតអំពីផ្លូវកាយ ផ្លូវវាចា ក៏ពុំបានស្ថិតស្ថេរយឺនយូរ មានតែសេចក្ដីសុខដែលកើតអំពីផ្លូវចិត្ត ដែលលោកឲ្យឈ្មោះចិត្តស្ងប់មួយប៉ុណ្ណឹងទេ ដែលជាសុខមានកំពស់មានស្ថិរភាពជាងសុខទាំងអស់ក្នុងលោក ដូចនេះព្រោះអ្វី? ព្រោះចិត្តស្ងប់មានន័យថា ចិត្តអស់កិលេស ចិត្តអស់កិលេសគឺជាចិត្តមិនមានតម្រេកក្នុងឥដ្ឋារម្មណ៍ មិនមានកំហឹងក្នុងអនិដ្ឋារម្មណ៍ មិនមានសេចក្ដីភ័ន្តច្រឡំក្នុងឥដ្ឋានិដ្ឋារម្មណ៍ (អារម្មណ៍ជាទីស្រឡាញ់និងមិនជាទីស្រឡាញ់)។ បុគ្គលជាបេក្ខភាពនៃសន្តិ (អ្នកសម្លឹងយកនូវសន្តិ) គប្បីលះបង់លោកាមិសឲ្យអស់។

អ្វីជាលោកាមិស? បញ្ចពិធកាមគុណគឺរូប សម្លេង ក្លិន រស ផ្សព្វ (ផោដ្ឋព្វៈ) ជាទីប្រាថ្នាជាទីគាប់ចិត្ត ឈ្មោះថា «លោកាមិស» ព្រោះជាគ្រឿងល្បួង គ្រឿងបញ្ឆោតចិត្ត ឲ្យជាប់ជំពាក់នៅក្នុងលោកនេះ ការធ្វើចិត្តមិនឲ្យជាប់ជំពាក់នៅក្នុងបញ្ចពិធកាមគុណ លោកចាត់ជាបដិបទារបស់បុគ្គលអ្នកសម្លឹងយកនូវសេក្ដីស្ងប់។ ការធ្វើចិត្តឲ្យអស់សេចក្ដីជំពាក់ លោកបានសម្ដែងជាមួយនិងសេចក្ដីបញ្ជាក់របស់លោកក្នុងជរាសូត្រថា :



www.elibraryofcambodia.org

**"ឧទពិន្ទុ យថាបិ បោក្ខរេ**

**បទុមេ វារិ យថា ន លិប្បតិ**

**ឯវំ មុនិ នោបលិប្បតិ**

**យទិទំ ទិដ្ឋសុតំ មុតេសុ វា"។**

"តំណក់នៃទឹក មិនដែលដក់នូវលើស្លឹកនៃឈូកយ៉ាងណា, ទឹកមិនដែលជ្រាបចូលក្នុងផ្កានៃឈូកយ៉ាងណា មុនិមិនដែលមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ទាំងឡាយ ដែលឃើញដោយភ្នែក ដែលឮដោយត្រចៀក ដែលនឹកឃើញដោយចិត្តយ៉ាងនោះដែរ"។

សន្តិធម៌លោកសង្គ្រោះចូលក្នុងលោកិយធម៌ផង ក្នុងលោកុត្តរធម៌ផង ដូចគ្នានឹងវិសុទ្ធិដែរ។ ដែលជាលោកិយធម៌បានដល់បាលីថា :

**"នហិ រុណ្ណេន សោកេន សន្តឹ បប្បោតិ ចេតសោ"**

"បុគ្គលបានដល់នូវសេចក្តីស្ងប់នៃចិត្ត មិនមែនបានដោយយំ, ដោយសោក (ដែលមនុស្សទាំងឡាយធ្លាប់ប្រកាន់យក) នោះទេ"។ ប្រែជាសន្តិធម៌នេះ គឺគេត្រូវបានដោយការមិនមានយំ, មិនមានសោក។

ដែលជាលោកុត្តធម៌ បានដល់បាលីថា

**"លោកាមិសំ បជហេ សន្តិបេក្ខោ"**

"បុគ្គលអ្នកសម្លឹងយកនូវសន្តិ គប្បីលះបង់ចោលនូវលោកាមិសទាំងអស់។ សន្តិខ្ញុំសរសេររៀងក្នុងលំដាប់នៃវិសុទ្ធិ ដើម្បីឲ្យមានដំណើរសេចក្តីល្អងាយស្តាប់, ងាយយល់ គឺថាមនុស្សយើងកាលណាមានចិត្តបរិសុទ្ធហើយ សេចក្តីស្ងប់ក៏កើតមានផងដែរ ដូចជាសំពត់កាលណាបោកគក់ស្អាតហើយ សាច់ម៉ត់សាច់ល្អិតនៃវត្ថុនេះ ក៏មានប្រាកដក្នុងពេលនោះដែរ។

ចំណែកអ្នកប្រតិបត្តិធម៌ ដើម្បីសន្តិលោកចាត់ជាសេចក្តីប្រតិបត្តិ មានគុណភាពខ្ពស់បំផុត រកអ្វីប្រៀបផ្ទឹមឲ្យស្មើពុំបានឡើយ។



www.elibraryofcambodia.org

# និព្វាន

“**និព្វានំ បរមំ វទន្តិ ពុទ្ធា**” “ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថា និព្វានមានគុណភាពខ្ពស់បំផុត”។

“**និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ**”

“(អ្នកប្រាថ្នាសុខពិត) គប្បីប្រញាប់ប្រញាល់សំអាតផ្លូវទៅនិព្វាន”។

“**និព្វានំ បរមំ សុខំ**” “និព្វានជាបរមសុខ (សុខខ្ពស់រកសុខដទៃប្រៀបស្មើពុំបាន)”។

## សេចក្តីអធិប្បាយ

“**និព្វាន**” សព្ទ ប្រែបានច្រើនន័យ ក្នុងទីនេះសូមប្រែត្រឹមតែពីរន័យ។

**ន័យទី១** “និព្វាន” ប្រែថា “រលត់” ដោយន័យថារលត់ភ្លើងទុក្ខ, ភ្លើងកិលេស, មកអំពីធាតុ “វា” មាន “និ” ជាបទនាំមុខ “យុ” បច្ច័យ ដែលលោកផ្លាស់ជា “អន”។

**ន័យទី២** “និព្វាន” ប្រែថា “មិនមានគ្រឿងចាក់ដោត” ឬ “មិនមានគ្រឿងដោតក្រង” ដោយន័យថា “មិនមានកូនសរពោលគឺកិលេស” ឬ“ មិនមានតណ្ហា” ជាគ្រឿងបាញ់, គ្រឿងដោតក្រង, មកអំពី “វាន” សព្ទមាន“និ” ជាបទនាំមុខ ប្រាប់សេចក្តីបដិសេធ ជាបញ្ចមី ឬ ឆដ្ឋិពហុព្វិសមាស ធៀបបានជាមួយនឹងបទថា “អព្ពុឡ្ហសល្លោ” មានកូនសរ ឬមានគ្រាប់សរដកចេញហើយជាគុណបទរបស់ព្រះអរហន្ត។

ដើម្បីឲ្យអ្នកអានមានពន្លឺច្រើនក្នុងរឿងនេះ ខ្ញុំសូមធ្វើសេចក្តីបញ្ជាក់អំពីមតិនៃលទ្ធិខាងក្រៅជាមុន។ ក្នុងសាសនាព្រាហ្មណ៍គេមានមតិថា នៅក្នុងពិភពលោកយើងនេះមានរបស់មួយដែលគេចាត់ទុកដាក់ជាដើមបង្អស់ គឺជារបស់កើតមុនសកលចក្រវាល; របស់នោះគេឲ្យឈ្មោះថា “បរមាត្ម័ន” ពាក្យនេះបើធៀបទៅនឹងពាក្យបាលីគឺជា “បរមត្តា” ។



www.elibraryofcambodia.org

ពាក្យថា "បរមត្ថោ" ដែលយើងហៅកាត់ថា **"បរមត្ថ"** នោះក៏ប្រហែលជាកើតមកជាមួយនឹងពាក្យនេះដែរ។

**បរមាត្ម័ន** នេះបានបំបែកខ្លួនទៅជាចំណែកតូចៗ ហើយឲ្យចំណែកតូចៗនេះចូលទៅអាស្រ័យនៅក្នុងរូបកាយដែលជាសំណង់មានលក្ខណៈផ្សេងៗគ្នា។ ភាគតូចៗនៃធម្មជាតុនេះគេឲ្យឈ្មោះថា "អាត្ម័ន" ជាពាក្យសំស្ក្រឹត ដែលគេនិយមប្រើក្នុងសាសនារបស់គេ។ បាលីថា **"អត្តា"** មតិនេះស្រដៀងគ្នានឹងមតិរបស់អ្នកប្រាជ្ញខាងតារាសាស្ត្រនិងហោរាសាស្ត្រ ដែលធ្វើសេចក្តីសន្និដ្ឋានថា ពិភពលោកទាំងឡាយ រួមទាំងពិភពលោកដែលយើងកើត យើងនៅសព្វថ្ងៃនេះផង គឺជាបំណែកមួយៗដែលខ្ទាតចេញចាកដួងអាទិត្យដែលជាពិភពភ្លើង ឬជាពិភពមានកំដៅយ៉ាងខ្លាំងក្លា។ ក្រោយមកបំណែកដ៏មានកំដៅឬបំណែកភ្លើងទាំងឡាយនេះ ក៏ចាប់រលត់, ចាប់ត្រជាក់បន្តិចម្តងៗ រហូតដល់បានជាទីកើត, ទីនៅអាស្រ័យរបស់យើងគេក្នុងបច្ចុប្បន្នភាពនេះ។

**"អាត្មន័"** របស់ពួកព្រាហ្មណ៍ មិនមែនជារបស់បិតនៅដាច់ឡែកតែឯងជាឯកភាពទេ គឺវាមានរបស់ដទៃចូលមកអាស្រ័យផង, របស់នោះគេហៅថា "កម្ម" ដែលកើតមានព្រមគ្នាជាមួយនឹងអាត្ម័ន ឬថាជាលក្ខណៈ, ជាទំរើរបស់អាត្ម័នឯងតែម្តងក៏បាន។

កាលណាអាត្ម័នមានកម្មចូលរួមផងឬអាត្ម័នសាងកម្ម, អាត្ម័នក៏មានខ្លួនជាទ្វិភាពទៅ។ កម្មនោះគេចែកចេញទៅជាពីរគឺកម្មអាក្រក់, កម្មល្អ ឬបុណ្យបាប។

គេបញ្ជាក់ថា បើអាត្ម័នធ្វើបាបធ្ងន់ ប្រៀបដូចជាអនន្តរិយកម្មក្នុងពុទ្ធសាសនាយើង អាត្ម័ននោះចុតិចាករាងកាយហើយ រមែងទៅកើតក្នុងស្ថាននរកមិនមានពេលកំណត់ថានឹងរួចឡើយ។ ដូចគ្នានឹងមនុស្សមានទោសធ្ងន់ ត្រូវជាប់គុកអស់មួយជីវិតអីចឹងដែរ។

ពាក្យថា មិនមានពេលកំណត់នឹងរួចចាកនរក ឬមិនដឹងថាអង្កាល់ណា



www.elibraryofcambodia.org

នឹងបានទៅកើតជាមនុស្សវិញនោះ ក៏មានសេចក្តីមិនខុសគ្នានឹងគម្ពីរធម្មបទ ដែលសរសេរដោយព្រះពុទ្ធពុទ្ធឃោសាចារ្យ ក្នុងចំណុចត្រង់សត្វនរកចេះ និយាយគ្នាដែលខ្ញុំសូមសរសេរជាភាសារបស់យើងមិនចាំបាច់សរសេរជាភាសាបាលី មានសេចក្តីថា :

យប់មួយព្រះរាជាទ្រង់ព្រះនាមបសេនទិ ព្រះអង្គផ្ទំមិនលក់ ព្រោះអាស្រ័យកាមវិតក្ក, លុះដល់ពេលពាក់កណ្តាលយប់ ដែលនៅក្នុងភាពស្ងាត់ឈឹងងងឹតសូន្យនោះ ព្រះអង្គទ្រង់បានឮសម្លេងសត្វនរកនិយាយគ្នា។

សត្វនរកទី១ដែលបានផ្តើមនិយាយមុនគេនោះ វាបាននិយាយថា «រស់នៅក្នុងទីនេះយូរពន់ពេកណាស់ មិនដឹងអង្កាល់ណានឹងបានរួចចេញចាកទីនេះទេ...»។

សត្វនរកទី២ និយាយថា «បើគិតជាពេលបាន៦០ពាន់ឆ្នាំហើយ ដែលយើងមានខ្លួនកំពុងត្រូវឆេះដោយភ្លើងនរកនេះ...។

សត្វនរកទី៣ និយាយថា «ទីបំផុតនៃយើងមិនមានទេ, ទីបំផុតនៃយើងមិនប្រាកដទេ...។

សត្វនរកទី៤ និយាយថា «ខ្លួនអញបើបានរួចចេញចាកទីនេះ បានមានកំណើតជាមនុស្សវិញ អញនឹងរក្សាសីលតាមពាក្យទូន្មានរបស់អ្នកប្រាជ្ញហើយ...»។

ការនិយាយឆ្លងឆ្លើយរបស់សត្វនរកទាំងឡាយនេះ ប្រសិនបើយើងយកមកធ្វើការបកស្រាយ និងបានសេចក្តីថា ពាក្យត្អូញត្អែររបស់សត្វនរកទាំងនេះមានទាំងថ្លែងទុក្ខព្រួយមានទាំងថ្លែងរាងចាល។

ដូចនេះ, យើងត្រូវធ្វើសេចក្តីកត់សម្គាល់ថា អ្នកធ្វើបាប បាននរក, អ្នកធ្វើបុណ្យ បានឋានសួគ៌, វែងជាងនេះទៅទៀត, អ្នកធ្វើបាបតិច បាននរកតូច, អ្នកធ្វើបាបច្រើន, បាននរកធំ; អ្នកធ្វើបុណ្យតិច បានឋានសួគ៌តូច, អ្នកធ្វើបុណ្យច្រើន បានឋានសួគ៌ធំ។

គតិអាក្រក់និងគតិល្អ ដែលនឹងត្រូវកើតមានដល់មនុស្សសម្រេចមកអំពី



www.elibraryofcambodia.org

បុណ្យបាប អ្នកណាធ្វើបុណ្យមានគតិល្អ, អ្នកណាធ្វើបាបមានគតិអាក្រក់, អ្នកណាធ្វើបុណ្យតិច មានគតិល្អតិច, អ្នកណាធ្វើបុណ្យច្រើន មានគតិល្អច្រើន, អ្នកណាធ្វើបាបតិច មានគតិអាក្រក់តិច, អ្នកណាធ្វើបាបច្រើន មានគតិអាក្រក់ច្រើន ដូចមានចែងក្នុងគម្ពីរជាតកក្នុងចំណុចនៃជីវិតអន្ទោល ដែលត្រូវមានសុខទុក្ខ ព្រោះអាស្រ័យកម្លាំងបុណ្យបាបចូលមកចាត់ចែងជាមួយនឹង សុខទុក្ខដែលមានប្រចាំក្នុងសង្សារវដ្តនោះផងដែរ។

ក្នុងមេត្តសូត្រ លោកមាននិយាយដល់មេត្តាធម៌ដែលគេបានផ្សាយចំពោះសត្វដែលកំពុងរកទីកើតហៅថា "សម្ភវេសីសត្វ" ជាគូនឹងសត្វដែលកើតហើយហៅថា "ភូតសត្វ" សត្វពួកនេះធៀបបាននឹងអាត្ម័ន ដែលកំពុងស្វែងរកកន្លែងចូល ឬកន្លែងថ្កក់ ឬបានចូល បានថ្កក់ហើយ។

អាត្ម័ននេះ, លុះវាអន្ទោលយូរៗទៅ ក្នុងទីបំផុតនៃការអន្ទោលរបស់វា វារមែងរួចផុតចាកបាបទាំងពួង ហើយបានដល់នូវភាពបរិសុទ្ធ។ ក្នុងពេលនោះ, គេបានដាក់ឈ្មោះឲ្យវាថា **មហាត្ម័ន**ធៀបនឹងបាលីយើងបាននឹងពាក្យថា **"មហត្តា"** ប្រែថា "អត្តាធំ" ឬ "ខ្លួនធំ"។ ពាក្យនេះមានមកក្នុងនិគមគាថា នៃធម្មគារវសូត្រចតុក្កង្គុត្តរ ដែលខ្ញុំសូមស្រង់យកមកសរសេរទាំងអស់ក្នុងទីនេះដើម្បីបានជាគោលគំនិតនៃអ្នកអានទាំងឡាយមានដូចនេះ ៖

**"តស្មាហិ អត្តកាមេន មហត្តមភិកង្ខតា**
**សទ្ធម្មោ គរុកាតព្វោ សរំ ពុទ្ធាន សាសនំ"**

ព្រោះហេតុដូចនេះ, បុគ្គលអ្នកស្រឡាញ់ខ្លួន ប្រាថ្នាឲ្យបានជាមហត្តាបានរលឹកឃើញនូវពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ គប្បីធ្វើនូវការគោរពចំពោះព្រះសទ្ធម្ម។ តែតាមទម្លាប់យើងប្រែបទ "មហត្តា" ថា ប្រយោជន៍ធំខ្លះ ភាពជាធំខ្លះ បទដើមមានសេចក្តីមិនត្រូវតាមព្យញ្ជនៈ បទចុងក្រោយមានសេចក្តីត្រូវតាមព្យញ្ជនៈហើយ តែសេចក្តីប្រែមិនស៊ីនឹងផ្ទៃរឿងឬមិន



www.elibraryofcambodia.org

សមតាមដំណើរនៃភាសិត។

ម្យ៉ាងទៀត, សព្ទថា «មហគ្គតំ» ដែលប្រែថាដល់នូវភាពជាធំ ក៏លឿនហួសទិសដៅដែរ។ តែក្នុងពាក្យអធិប្បាយបញ្ជាក់ថា បានដល់ចិត្តដែលសម្បយុត្តដោយឈាន ឃើញថាមានដំណើរសេចក្ដីល្អមួយលំបានដែរ។

ស័ព្ទនេះ, មានមកក្នុងនិទ្ទេសនៃចិត្តានុបស្សនា ក្នុងមហាសតិដ្ឋានសូត្រ «**មហគ្គតំ វា ចិត្តំ មហគ្គតំ បជានាតិ**»

ភិក្ខុរមែងដឹងច្បាស់នូវចិត្តជាមហគ្គតៈ, ថាចិត្តនេះជាមហគ្គដូចនេះក៏មាន។

ក្នុងគម្ពីរព្រាហ្មណ៍, មាននិយាយអំពីអាត្មននេះវែងឆ្ងាយណាស់។ ក្នុងទីនេះ, ខ្ញុំស្រង់យកមតិរបស់គេខ្លះទៀត មកសរសេរថែមលើមតិមុន, ដើម្បីជាជំនួយដល់គំនិតអ្នកអានដូចមានតទៅ :

គេថា: «បុគ្គលណាឃើញសុខទុក្ខរបស់ធម្មជាតុទាំងឡាយ ស្មើដោយសុខទុក្ខរបស់ខ្លួន បុគ្គលនោះគេឲ្យឈ្មោះថា «**បរមយោគី**» ។ ពាក្យថា «**បរមយោគី**» ក្នុងទីនេះ, ស្រដៀងនឹងពាក្យថា «បរមាត្មន» ហ្នឹងដែរ។ ប្រសិនបើយើងគិតតាមលក្ខណៈពាក្យដែលមានក្នុងវេយ្យាករណ៍។ «បរមយោគី» គឺជាទិសពាក្យរបស់ «បរមាត្មន» ហ្នឹងឯង។

មានសេចក្ដីមួយអន្លើ ដែលខ្ញុំស្ដាប់បានថាជាសេចក្ដីថ្លែងឬជាពាក្យដែលគេបង្រៀនគ្នាគេថា «គប្បីស្គាល់នូវរបស់ដែលផ្សព្វផ្សាយទៅក្នុងសកលចក្រវាល ថាជារបស់មិនមានសេចក្ដីវិនាស, មិនមានអ្នកណាម្នាក់អាចធ្វើនូវរបស់ដែលមិនចេះវិនាស ឲ្យវិនាសបានដោយអំណាចមួយរបស់ខ្លួនទេ»។

របស់មិនចេះវិនាសនេះ ក៏មិនមានអ្វីដទៃក្រៅពីអាត្មន, ដែលជាធម្មជាតុស័ក្ដិសិទ្ធិទៀងទាត់របស់គេឡើយ។ មតិដដែលនេះ, មានធ្វើសេចក្ដីបញ្ជាក់យ៉ាងច្បាស់លោស់ថា «ព្រះសិវៈនោះគឺជាបុរសពិសេស ព្រះអង្គមិនមានព្រះទ័យជាប់ជំពាក់ជាមួយកិលេស, កម្ម , វិបាក និងតណ្ហាទេ»។

ព្រះសិវៈនេះទៀតក៏ជាអាត្មនហ្នឹងដែរ តែជា «បរមាត្មន» ឬ «មហាត្មន»។



www.elibraryofcambodia.org

មតិនេះ, បានសម្ដែងសេចក្ដីយល់ឃើញមួយបែបទៀតថា "នៅក្នុងអង្គនៃព្រះសិវ នោះមានពូជសព្វញ្ញូឋិតនៅអស់កាលជានិច្ច"។

មតិនេះបានធ្វើសេចក្ដីបញ្ជាក់ថែមទៀតថា ព្រះសិវៈព្រះអង្គមានតំណែងជាអាចារ្យ តំណែងនេះខ្ពស់បំផុត ព្រោះគេថា "ព្រះអង្គជាអាចារ្យរបស់អាចារ្យទាំងឡាយក្នុងសកលចក្រវាល ដោយព្រះអង្គកើតមុនគេ ហើយទ្រង់គង់នៅរហូតមិនមានប្រែប្រួល។

សេចក្ដីយល់ឃើញរបស់ពួកព្រាហ្មណ៍ក្នុងរឿងអាត្ម័ននេះ មានច្រើនយ៉ាងទៅទៀតណាស់ តែដើម្បីកុំឲ្យអ្នកអាននឿយគំនិតពេក ខ្ញុំសូមស្រង់យកយោបល់របស់គេត្រឹមតែ៣ ដែលក្នុងគំនិតរបស់ខ្ញុំ, ខ្ញុំទុកយោបល់នេះជាជាយោបល់សំខាន់ ឬជាយោបល់មានកំពស់ជាងយោបល់ទាំងអស់ ឬជាយោបល់ដែលគេទុកជាមូលដ្ឋាននៃយោបល់ទាំងឡាយ។ យោបល់៣នោះមានដូចនេះ :

១- គេសម្ដែងសេចក្ដីយល់ឃើញថា "អាត្ម័នគឺជាពូជឬគ្រាប់នៃសាកលចក្រវាល បើមិនមានអាត្ម័នសាកលចក្រវាលក៏មិនមាន"។ សេចក្ដីក្នុងចំណុចនេះ នាំឲ្យយើងយល់ថា របស់ទាំងអស់រួមទាំងសាកលចក្រវាលផង កើតមានឡើងព្រោះអាស្រ័យអាត្ម័ន បើមិនមានអាត្ម័នរបស់ទាំងអស់នេះក៏កើតឡើងពុំបាន។

២- គេសម្ដែងសេចក្ដីយល់ឃើញថា "មិនមានរបស់ណាមួយក្នុងសាកលចក្រវាលនេះ ជារបស់តាំងនៅដាច់ឡែកតែឯង ឬតាំងនូវឆ្ងាយអំពីអាត្ម័ន"។ សេចក្ដីក្នុងចំណុចនេះ, នាំឲ្យយើងធ្វើសេចក្ដីបកស្រាយថា នៅក្នុងពិភពលោកនេះ របស់ទាំងអស់សុទ្ធតែកើតឡើងដោយអាស្រ័យអាត្ម័ន, បើមិនមានអាត្ម័នរបស់ទាំងអស់កើតឡើងក៏មិនបាន, រស់នៅក៏មិនកើត។

៣- គេមានគំហើញថា "បុគ្គលណាឃើញអាត្ម័ននៅក្នុងរបស់ទាំងអស់, ឃើញរបស់ទាំងអស់នៅក្នុងអាត្ម័ន អាត្ម័នក៏មិនដោះដៃចោលរបស់ទាំងអស់នោះ ឯរបស់ទាំងអស់នោះក៏មិនលះបង់ចោលអាត្មន័" សេចក្ដីត្រង់ចំណុច



www.elibraryofcambodia.org

នេះ, នាំឲ្យយើងធ្វើអត្ថាធិប្បាយថា អាត្ម័ននិងវត្ថុធាតុទាំងអស់ រួមទាំងសកលចក្រវាលផង ជារបស់ត្រូវអាស្រ័យគ្នានឹងគ្នា រួមសុខ រួមទុក្ខជាមួយគ្នា មិនមានពេលណាដែលរបស់ទាំងពីរនេះ ត្រូវលះបង់ចោលគ្នាឡើយ។ តែបើមានលះបង់ចោលគ្នាទៅវិញនោះ ក៏ព្រោះតែមានហេតុបច្ច័យដទៃចូលមកកាច់ផ្ដាច់។

«**មហាត្ម័ន**» ឬ «អាត្ម័ន» នេះ កាលណាវាចុតិចាករូបជាទីបំផុតហើយ វាក៏ចូលទៅនៅជាមួយនឹង «បរមាត្ម័ន» ដែលជាប្រភពដើមរបស់វា, វានៅក្នុងទីនោះរហូតទៅ មិនមានចុតិទៀតទេ នេះគឺទីបំផុតនៃសង្សារវដ្ដរបស់គេ ហៅថា «និវ៌ាន» ក្នុងសាសនារបស់ព្រាហ្មណ៍ឬហិណ្ឌូ។ និព្វានដែលមានឈ្មោះហៅក្នុងលទ្ធិខាងក្រៅ,អ្នកអានអាចសង្កេតឃើញក្នុងសំនួរមួយរបស់ជោតកមាណពដែលបានធ្វើចំពោះព្រះបរមសាស្ដាចារ្យថា :

**«បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ**

**វាចាភិកង្ខាមិ មហេសិ តុយ្ហំ**

**តវ សុត្វាន និគ្ឃោសំ សិក្ខេ និព្វានមត្តនោ»។**

«បពិត្រព្រះអង្គមានជោគ, ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ, បពិត្រព្រះអង្គទ្រង់ស្វែងរកគុណធំ, សូមព្រះមេត្តាឆ្លើយនូវសំនួររបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គបានស្ដាប់ចម្លើយរបស់ព្រះអង្គ ហើយគប្បីសិក្សាអំពីនិព្វានរបស់ខ្លួន»។ ខ្ញុំសូមធ្វើសេចក្ដីបញ្ជាក់ថា :

សំនួរនេះ ជោតកមាណព បានធ្វើចំពោះព្រះសម្ពុទ្ធក្នុងគ្រាជាដំបូងដែលគួរឲ្យយើងធ្វើសេចក្ដីកត់សម្គាល់ថា មាណពនេះនៅពុំទាន់បានចេះដឹងធម្មវិន័យរបស់ពុទ្ធសាសនាទេ។ ដូចនេះ, ពាក្យថា «និព្វាន» ដែលគាត់និយាយដល់ក្នុងសំនួររបស់គាត់នោះ យើងត្រូវដៅយកនិព្វានដែលមានក្នុងលទ្ធិខាងក្រៅ ជាពិសេសគឺលទ្ធិរបស់គាត់ដែលជាលទ្ធិរបស់ព្រាហ្មណ៍នោះតែម្ដង។

ក្នុងលទ្ធិគ្រិស្ដ គេមានមតិនិងសេចក្ដីបញ្ញត្តទីបំផុតនៃសង្សារវដ្ដ ប្រហាក់ប្រហែលគ្នានឹងលទ្ធិហិណ្ឌូដែរ តែមានលក្ខណៈខុសគ្នាត្រង់លទ្ធិនេះ ច្រើន



www.elibraryofcambodia.org

និយាយអំពីទីបំផុតនៃជីវិតអន្ទោលឬសង្សារវដ្ដ ទៅជាបុគ្គលាធិដ្ឋាន: មិនសូវមាននិយាយជាធម្មាធិដ្ឋាន: ប្រែថា និយាយច្រើនតែអំពីរូបធម៌ និយាយតិចអំពីនាមធម៌។ នៅក្នុងលទ្ធិដដែលនេះ អ្នកបុណ្យគឺអ្នកបួសខាងមុខបន្ទាប់អំពីមរណៈ (ស្លាប់ហើយ) វិញ្ញាណរបស់គេរមែងឡើងទៅកើតក្នុងឋានសួគ៌ វិញ្ញាណនេះនឹងនៅជាមួយនិងព្រះអាទិទេពរបស់គេអស់កាលជានិរន្តរ៍, មិនមានផ្លាស់ប្ដូរ គឺជាមិនមានចុតិជាថ្មីទៀត។

ក្នុងលទ្ធិឥស្លាម, មតិនិងសេចក្ដីបញ្ញត្តទីបំផុតរបស់សង្សារវដ្ដ ប្រហាក់ប្រហែលគ្នានឹងលទ្ធិគ្រិស្តដែរ ព្រោះលទ្ធិនេះមានប្រវត្តិនៃកំណើត និងទ្រឹស្តីរបស់លទ្ធិមានដំណើរសេចក្ដីស្រដៀងៗគ្នា ខុសគ្នាតែលទ្ធិនេះ ត្រូវប្រជាជាតិក្នុងពិភពលោករិះគន់ខ្លះ ចំពោះត្រង់លទ្ធិនេះបានប្រើអំណាចអាវុធ ដើម្បីជាកម្លាំងដល់ការផ្សាយសាសនារបស់ខ្លួន ក្នុងនាមរបស់ព្រះអាទិទេព។

តែយ៉ាងណាក៏ដោយ អ្នកប្រាជ្ញប្រវត្តិសាស្ត្រផ្នែកសាសនា ពុំបានមានយោបល់ថា ការប្រើអាវុធរបស់គេនេះជាការត្រឹមត្រូវឬជាធម្មបញ្ហាទេ គឺជាសាសនិកបញ្ហាទៅវិញទេ។

យោបល់របស់អ្នកប្រាជ្ញប្រវត្តិសាស្ត្រសាសនានេះ ខ្ញុំយល់ថាជាយោបល់ត្រូវមែន ព្រោះព្រះអាទិទេពក្ដី ធម្មៈរបស់ព្រះអង្គក្ដី ប្រាកដជាមិនអនុញ្ញាត ឲ្យបរិស័ទផ្សាយសាសនាដោយប្រើកម្លាំងអាវុធទេ។

យោបល់ផ្ទាល់របស់ខ្ញុំ យល់ឃើញថា ប្រហែលជាមានលទ្ធិណាមួយឬជាតិណាមួយបានប្រើកម្លាំងអំណាចជិះជាន់មុន ទើបបរិស័ទនេះប្រើកម្លាំងអាវុធពារការលុះការពារខ្លួនបានហើយ អត់ទ្រាំពុំបានក៏សងដៃទៅសត្រូវរបស់ខ្លួនវិញដោយប្រើអាវុធដែរ។

ចំពោះរឿងនេះ អ្នកអានមានសេចក្ដីយល់ឃើញយ៉ាងណាស្រេចហើយនឹងគំនិតរបស់ខ្លួនចុះ។ ចំណែកនិព្វានរបស់សាសនាទាំងពីរនេះ បើធៀបនឹងនិព្វាននៃពុទ្ធសាសនារបស់យើង; និព្វានក្នុងពុទ្ធសាសនានៅត្រង់រលត់អស់នូវ



www.elibraryofcambodia.org

អ្វីៗដែលត្រូវរលត់ សូម្បីតែចិត្តក៏ត្រូវរលត់ផងដែរ។

ឯនិព្វានក្នុងសាសនាគ្រិស្តនិងឥស្លាមនៅត្រង់វិញ្ញាណដែលបានទៅចូលរួមឋាន រួមកំណើតជាមួយនឹងព្រះអាទិទេព ព្រោះព្រះអាទិទេពព្រះអង្គទ្រង់មានព្រះវិញ្ញាណបរិសុទ្ធឋិតថេរជាស្ថាពរ។

មតិខាងពុទ្ធសាសនា, បានញែកមូលហេតុគឺសង្ខារនិងនិព្វានដាច់ចេញពីគ្នា ហើយទុកដាក់សង្ខារជាខ្សែដើមនៃកំណើតបន្ទាប់អំពីអវិជ្ជាមក និព្វានជាចុងខ្សែនៃកំណើត ហើយបដិសេធនូវអត្តាចោល, តែទទួលស្គាល់នូវចុតិនិងបដិសន្ធិដែលពាក្យធម្មតាថា ស្លាប់ហើយកើតទៀតដោយសន្តតិលក្ខណៈ គឺគ្រឿងកំណត់សម្គាល់ក្នុងការតភ្ជាប់នៃជីវិតចាស់និងជីវិតថ្មី ប្រែថាជីវិតចាស់ជាមួយនឹងគ្រឿងប្រដាប់ទាំងអស់ត្រូវរលត់ទៅមែន តែត្រូវមានជីវិតថ្មីកើតជំនួសដោយអាស្រ័យថាមភាពនៃជីវិតចាស់។

សន្តតិគ្រឿងតភ្ជាប់អំពីជីវិតមួយទៅជីវិតមួយនេះមានសេចក្តីពន្យល់ពិស្តារក្នុងបដិច្ចសមុប្បាទធម៌ អ្នកអានសូមតាមមើលផ្ទាល់ខ្លួនផងចុះ ព្រោះធម៌នេះនៅក្រៅនាទីនៃការពន្យល់របស់ខ្ញុំផង មានសេចក្តីវែងឆ្ងាយពេកផងដែលខ្ញុំសុំបិត្តមិត្តអ្នកអានទាំងឡាយ មិនសរសេរក្នុងសៀវភៅនេះទេ។

មុននឹងធ្វើសេចក្តីពំភ្លឺអំពីរឿងដទៃទៀតខ្ញុំសូមធ្វើសេចក្តីបញ្ជាក់លើរឿងដដែលនេះថា សត្វស្លាប់ហើយកើតទៀត ប្រសិនបើជាបុគ្គលាធិដ្ឋាន អ្នកអានគប្បីឃើញដូចជាភិក្ខុឈ្មោះទេវទត្ត និងព្រះអង្គម្ចាស់អជាតសត្តុដែលបានធ្វើនូវសង្ឃភេទកម្មនិងបិតុឃាតកម្ម មានទោសជាអនន្តរិយកម្ម: បុគ្គលនេះត្រូវធ្លាក់ទៅកើតក្នុងនរកធំ តែមិនមែនជាមិនមានទីបំផុតទេ គឺមានទីបំផុតត្រូវបានរួចចាកឋាននរកមកកើតក្នុងលោកនៃមនុស្សយើង ក្នុងទីបំផុតនៃជីវិតអន្ទោលបានសម្រេចជាព្រះបច្ចេកពុទ្ធផង។

សេចក្តីក្នុងចំណុចនេះបញ្ជាក់ឲ្យដឹងថា ពុទ្ធសាសនារបស់យើង បានទទួលស្គាល់កំណើតចាស់ថ្មី កម្មអាក្រក់ល្អ។ កំណើតចាស់មានបាប កំណើតថ្មី



www.elibraryofcambodia.org

ក៏ត្រូវមានវិបាក ខុសគ្នាអំពីលទ្ធិខាងក្រៅ ដែលគេមើលឃើញនរកថា មិនមានទីបំផុត បុណ្យបាបមិនសំខាន់ទេ តែព្រះអាទិទេពជារបស់សំខាន់នៃមនុស្សទាំងឡាយ។

ពុទ្ធសាសនាបានធ្វើសេចក្ដីបញ្ជាក់ជាមួយនឹងសេចក្ដីពន្យល់ថា សេចក្ដីបរិសុទ្ធនៃចិត្តរបស់អ្នកត្រាប់វង្គត់ក្នុងសង្សារវដ្តត្រូវតែមាន, ភាពជាព្រះអរហន្តគឺមនុស្សយើងត្រូវតែបាន តែសង្សារសុទ្ធិក្តី ភាពនៃព្រះអរហន្តក្តី មិនមែនត្រូវបាន ត្រូវសម្រេចដោយនៅស្ងៀមទេ គឺត្រូវបាន ត្រូវសម្រេច ដោយអាស្រ័យវិរិយបារមីនិងបញ្ញាបារមី។ ភាពបរិសុទ្ធទាំងឡាយនេះ ពុំអាចនឹងសម្រេចភ្លាមៗទេ គឺត្រូវកសាងអស់រយៈកាលយ៉ាងយូរ ដូចជាការបំពេញបារមី នៃពុទ្ធភូមិដែរ ខុសគ្នាតែពុទ្ធភូមិជាសព្វញ្ញុពុទ្ធមានរយៈកាលច្រើនជាងគេបំផុតប៉ុណ្ណោះ។

ពុទ្ធសាសនា, បើនិយាយដល់ការរលត់ចិត្តបរិសុទ្ធក្នុងបច្ឆិមជាតិ ហើយមិនមានកំណើតថ្មីទៀត ជាការរលត់ ទីបំផុត មិនមានរលត់ម្តងទៀតនោះ អ្នកអានគប្បីឃើញបាលីដែលមានមកក្នុងធម្មចក្កប្បវត្តសូត្រថា : «**អយន្តិមាជាតិ នត្ថិទានិ បុនព្ភវោ**» «នេះជាជាតិមានក្នុងទីបំផុត ឥឡូវនេះ ភពថ្មីមិនមានទៀតទេ» ក្នុងបាលិអនត្តលក្ខណសូត្រថា «**ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ**» ព្រះអរហន្តរមែងដឹងថា ជាតិអស់ហើយ ព្រហ្មចរិយៈបាននៅចប់ហើយ កិច្ចដែលត្រូវធ្វើបានធ្វើស្រេចហើយ កិច្ចដែលត្រូវធ្វើដើម្បីសេចក្តីយ៉ាងនេះមិនមានទៀតទេ» នេះឯងគឺជានិព្វាន។

ពាក្យសរសើរនិព្វានថា មិនស្លាប់, មិនចុតិ បានក្នុងបាលីថា «**អប្បមាទោ អមតំ បទំ**» «សេចក្តីមិនប្រមាទជាផ្លូវមិនចេះស្លាប់» មួយកន្លែងទៀតថា «**តេ យន្តិ អច្ចុតំ ឋានំ, តស្ស គន្ត្វាន ន សោចរេ**» «មុនីទាំងឡាយនោះរមែងទៅកាន់ស្ថានមិនចុតិ ទៅដល់ទីនេះហើយរមែងមិនសោយសោក» តាមន័យនេះឃើញថា និព្វានជាទីបំផុតនៃលោក ជាវិសង្ខារ មិនមែនជាសង្ខារ, ជាអសង្ខតៈ



www.elibraryofcambodia.org

មិនមានបច្ច័យតាក់តែង, មិនមែនជាសង្ខត: មានបច្ច័យតាក់តែងឲ្យកើត, ឲ្យស្លាប់ទៀត។

និព្វានដោយសេចក្តីបរិយាយ, លោកចែកជាពីរ គឺសឧបាទិសេសនិព្វានធាតុ១, អនុបាទិសេសនិព្វានធាតុ១។ និព្វានពីរនេះ មានសេចក្តីបញ្ជាក់ក្នុងបាលីនៃទុក្កនិបាត ឥតិវុត្តកថា : **“ទ្វេ មេ ភិក្ខវេ និព្វានធាតុយោ កតមា ទ្វេ សឧបាទិសេសា ច និព្វានធាតុ អនុបាទិសេសា ច និព្វានធាតុ...”**។

សេចក្តីថា “ម្នាលភិក្ខុទាំងឡាយ! និព្វានធាតុទាំងឡាយមានពីរ និព្វានធាតុទាំងឡាយពីរនោះ មានដូចម្តេច? និព្វានធាតុជាសឧបាទិសេស មានឧបាទិសល់នៅ១, និព្វានធាតុជាអនុបាទិសេស មិនមានឧបាទិសល់នៅ១”។

ភិក្ខុទាំងឡាយ! សឧបាទិសេសនិព្វានធាតុនោះតើដូចម្តេច? ភិក្ខុទាំងឡាយ! ភិក្ខុធម្មវិន័យនេះជាព្រះអរហន្ត, មានអាសវៈអស់ហើយ មានព្រហ្មចរិយធម៌បានបំពេញចប់ហើយ មានកិច្ចដែលត្រូវធ្វើ, ធ្វើចប់ហើយ មានភារៈទម្លាក់ចោលហើយ, មានប្រយោជន៍ល្អ (គឺអរហត្ត) បានសម្រេចហើយ មានគ្រឿងប្រកបទុកជាមួយនឹងភពនេះអស់ហើយ មានឥន្ទ្រីយ៍ស្ងប់ហើយ...ភិក្ខុនោះសោយអារម្មណ៍ជាទីពេញចិត្តខ្លះមិនជាទីពេញចិត្តខ្លះមានមនោសញ្ចេតនាជាសុខខ្លះ ជាទុក្ខខ្លះ, មានរាគៈ ទោសៈ មោហៈ អស់ហើយ។

ភិក្ខុទាំងឡាយ! នេះឯងជាសឧបាទិសេសនិព្វានធាតុ។ ភិក្ខុទាំងឡាយ! ក៏អនុបាទិសេសនិព្វានធាតុនោះ តើដូចម្តេច? ភិក្ខុទាំឡាយ! ភិក្ខុជាព្រះអរហន្តខីណាស្រព... បានដឹងច្បាស់ថាខ្លួនចាកចំណង់ទាំងអស់ហើយ ភិក្ខុនោះមិនមានសេចក្តីភ្លើតភ្លើនក្នុងអារម្មណ៍ដែលខ្លួនសោយ, មានចិត្តត្រជាក់, រស់នៅក្នុងលោកប្រកបដោយសេចក្តីស្ងប់ស្ងៀម, ភិក្ខុទាំងឡាយ! នេះឯងគឺជាអនុបាទិសេសនិព្វានធាតុ។

ក្នុងចំណុចនេះ, មានសេចក្តីដែលយើងត្រូវធ្វើសេចក្តីសង្កេតចំពោះត្រង់ពាក្យថានិព្វាន ដោយសេចក្តីបរិយាយ ដែលក្នុងបាលីហៅថា “និព្វានធាតុ”។



www.elibraryofcambodia.org

«និព្វានធាតុ» មានពាក្យថា «ឧបាទិ» នៅក្នុងនោះផង «ឧបាទិ» សេចក្ដីប្រែ និងសេចក្ដីចេះចាំរបស់យើងថាជា «ខន្ធបញ្ចកៈ» ពាក្យនេះយើងស្ដាប់បានហើយ យល់ផង តែប្រសិនបើពាក្យនេះមានរូបស័ព្ទជាកត្តុសាធនៈ តាមចំណាំរបស់ខ្ញុំ ដោយមិនមានប្រទ្បំទេនោះ សេចក្ដីប្រែត្រូវបានដល់ធម្មជាតិមួយដែលជាធាតុ គ្រប់គ្រងនូវខន្ធបញ្ចកៈគឺមិនមែនជាតួខន្ធបញ្ចកៈទេ គឺជាតួអ្វីមួយដែលជា បច្ច័យនៃគំនិត នៃពំនោល នៃទំនើ។ «ឧបាទិ» ស័ព្ទនេះ បើប្រែថា «អ្នកគ្រប់ គ្រង» ដោយសេចក្ដីថា «ចូលទៅជិតកាន់យក» ក៏បានដោយសុត្តន្តន័យ។ «ឧបាទិ» ស័ព្ទប្រែថា មានចិត្តប្រកាន់យកនូវខន្ធបញ្ចកៈក៏បាន ដោយអភិ ធម្មន័យ។

សេចក្ដីនេះប្រើបានដូចគ្នាទេ គឺក្នុងព្រះសូត្រលោកដៅយកខន្ធបញ្ចកៈ ស្រេចតែម្ដង, ក្នុងអភិធម្មលោកដៅយកចិត្ត។ តែចិត្តក្ដី ខន្ធបញ្ចកៈក្ដី ដែលត្រូវ បានសម្រេចជាអ្នកឬជារូបដើរតួក្នុងរឿងនេះ របស់ទាំងពីរនេះត្រូវមានក្នុងតួ នោះដូចគ្នា ឆ្លែកគ្នាតែមានតួក្នុង, តួក្រៅ។ គឺបើយើងថា «ឧបាទិ» សំដៅយក ខន្ធបញ្ចកៈដែលមានសេចក្ដីថា ចូលទៅជិតកាន់យកក៏ត្រូវមានសំនួរថា អ្នក ណាចូលទៅជិតកាន់យក ? ចម្លើយនឹងថាទៅលើចិត្តហ្នឹងឯង។

បើយើងថា «ឧបាទិ» សំដៅយកចិត្តជាតួប្រកាន់យក ក៏ត្រូវមានសំនួរ ថា ប្រកាន់យកនូវអ្វី ? ចម្លើយក៏នឹងថាទៅលើខន្ធបញ្ចកៈហ្នឹងឯងដែរ។ ក្នុង អភិធម្ម លោកសំដៅយកចិត្ត ព្រោះធម្មជាតិនេះ ជាតួគំនិត, ជាបច្ច័យនៃកាយ វិញ្ញត្តិ គឺការកម្រើករូបកាយ និងវចីវិញ្ញត្តិ គឺការកម្រើកនៃពាក្យសម្ដីឬបញ្ចេញ សម្លេង។

ក្នុងព្រះសូត្រដដែលមានសេចក្ដីថា អាសវៈទាំងឡាយមានការអស់ទៅ, សូនបាត់ទៅ តែចរិមកចិត្តនៅមាន គឺភាពសម្រេចជាព្រះអរហត្តអរហន្តជាសឧ បាទិសេសនិព្វានធាតុ។ កាលណាចរិមកចិត្តដល់នូវភាពរលត់ហើយ អនុបា- ទិសេសនិព្វានធាតុ ក៏កើតមានក្នុងលំដាប់នោះដែរ។



www.elibraryofcambodia.org

“**និព្វាន**” ស័ព្ទជា “**សឧបាទិសេស**” គួរបកប្រែថា “មិនមានគ្រឿងចាក់ដោត” ដែលធ្លាប់ប្រែពីមុនមកថា “មិនមានគ្រឿងចងក្រង” ឬ “មិនមានគ្រឿងចាក់ស្រេះ”។

ស័ព្ទនេះបើយើងគិតតាមផ្លូវវេយ្យាករណ៍ និងឃើញថាមានរូបដើមជា “វា” ជាតុមានអត្ថថា “ចាក់” ឬ “ដោត” យុបច្ច័យដែលលោកផ្លាស់ជា “អន” ចុះក្នុងកត្តុសាធនៈ សម្រេចរូបជា “វានំ” ដោយមានអំ វិភត្តិផ្សំផងប្រែថា “មានវត្ថុជាគ្រឿងចាក់ដោត” បានសេចក្ដីពិសេសថាជា “គ្រាប់សរ” ឬ “ព្រួញ” មាន “និ” ឧបសគ្គនៅមុខប្រាប់សេចក្ដីបដិសេធ ផ្លាស់តួ “វ” ជា “ព” ហើយតម្រួតតួ សម្រេចរូបជា “និព្វានំ” ដោយមានអំវិភត្តិផ្សំផង សេចក្ដីប្រែដូចមានមកហើយ។

និព្វានសព្ទនេះ មានបទដទៃជាបទប្រៀបធៀបថា “អព្វុឡ្ហសល្លោ” មានកូនសរឬមានគ្រាប់សរដកចេញហើយ, លោកចាត់ជាគុណធម៌របស់ព្រះអរហន្ត។ ពាក្យថា “សល្លោ” ប្រែថា “កូនសរ” ឬ “គ្រាប់សរ” នេះ ពុទ្ធសាសនាបានយកមកធ្វើជាពាក្យគុណរបស់កិលេសធំៗ មានជាអាទិ៍ រាគសល្លៈ, ទោសសល្លៈ, មោហសល្លៈ... (សេចក្ដីប្រែដូចធ្លាប់ចេះចាំស្រាប់)។

“**និព្វាន**” ស័ព្ទជា “អនុបាទិសេស” គួរប្រែថា “រលត់” ក្នុងព្រះសូត្រខ្លះលោកប្រើពាក្យថា “ត្រជាក់” ជំនួសពាក្យថា “រលត់” ពាក្យទាំងពីរនេះមានន័យត្រូវគ្នា គឺត្រជាក់កើតមកអំពីរលត់កំដៅ ឬកំដៅរលត់កើតមកអំពីត្រជាក់ហ្នឹងឯង។

ដើម្បីឲ្យអ្នកអានមានពន្លឺក្នុងផ្លូវប្រតិបត្តិធម៌ជាន់ខ្ពស់ ខ្ញុំសូមសរសេរអំពីបរមត្ថបដិបទានៃនិព្វានទាំងពីរដែលមានមកក្នុងបាលីដូចមានតទៅនេះ។



www.elibraryofcambodia.org

# បាលីសម្តែងអំពីបដិបទា

«អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា
អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេ»

-អប្បមាទវគ្គ ធម្មបទ-

«ភិក្ខុមានសេចក្តីត្រេកអរក្នុងសេចក្តីមិនប្រមាទ ឬមានសេចក្តីឃើញនូវភ័យក្នុងសេចក្តីប្រមាទ អស់កាលជានិច្ច រមែងបានជាបុគ្គលមិនអភ័ព្វ គឺមិនមានសេចក្តីសាបសូន្យ សេចក្តីប្រតិបត្តិធម៌នៃភិក្ខុនោះឈ្មោះថាមានជំហានយ៉ាងវែង ជិតដល់និព្វានហើយ»។

«សត្ថុគរុ ធម្មគរុ សង្ឃេ ច តិព្វគារវោ
សមាធិគរុ អាតាបី សិក្ខាយ តិព្វគារវោ
អប្បមាទគរុ ភិក្ខុ បដិសណ្ឋារគារវោ
អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេ»។

-គារវសូត្រ សត្តកង្គុត្តរ-

«ភិក្ខុមានចិត្តធ្ងន់ក្នុងព្រះបរមសាស្តា, មានចិត្តធ្ងន់ក្នុងព្រះធម៌ មានសេចក្តីគោរពយ៉ាងក្លៀវក្លាក្នុងព្រះសង្ឃ មានព្យាយាមដ៏មានកម្លាំងធ្ងន់ធ្ងរក្នុងសមាធិ មានសេចក្តីគោរពដ៏ក្លាហានក្នុងសិក្ខាទាំងឡាយ មានសីលសិក្ខាជាដើម, មានចិត្តធ្ងន់ធ្ងរក្នុងសេចក្តីមិនប្រមាទ, មានសេចក្តីគោរពយ៉ាងស្មោះក្នុងបដិសណ្ឋារកិច្ចទាំងឡាយ ជាពិសេសធម្មបដិសណ្ឋារកិច្ច។ ភិក្ខុមានសេចក្តីប្រព្រឹត្តដូចនេះឈ្មោះថា បានឈានមួយជំហានយ៉ាងវែង ជិតនឹងបានសម្រេចនិព្វានហើយ»។



www.elibraryofcambodia.org

«យម្ហិឈានញ្ច បញ្ញា ច សវេ និព្វានសន្តិកេ»។

- ភិក្ខុវគ្គ ធម្មបទ-

«ឈាននិងបញ្ញាមាននៅក្នុងសន្តានចិត្តនៃបុគ្គលណា បុគ្គលនោះឈ្មោះថាមានសេចក្តីប្រតិបត្តិ ជិតនឹងបានសម្រេចនិព្វានហើយ»។

**«តេ ឈាយិនោ សាតតិកា និច្ចំ ទឡ្ហបរក្កមា**
**ផុស្សន្តិ ធីរា និព្វានំ យោគក្ខេមំ អនុត្តរំ»**

-អប្បមាទវគ្គ ធម្មបទ-

«អ្នកប្រាជ្ញទាំងឡាយនោះ លោកមានឈានបានសម្រេចហើយ មានសេចក្តីព្យាយាមយ៉ាងមាំអស់កាលជានិច្ច ដើម្បីតភ្ជាប់នូវឈានអំពីអង្គមួយទៅអង្គមួយទៀត, លោករមែងបានពាល់ត្រូវនូវនិព្វានជាទីក្សេមចាកយោគៈយ៉ាងខ្ពស់បំផុត»។

**«សិញ្ច ភិក្ខុ ឥមំ នាវំ សិត្តា តេ លហុមេស្សតិ**
**ឆេត្វា រាគញ្ច ទោសញ្ច តតោ និព្វានមេហិតិ»។**

-មូលសន្ធិ កច្ចាយនៈ-

«ភិក្ខុអ្នកចូរប្រញាប់បាចស្តារនូវទូក ពោលគឺសន្តានចិត្តដែលស្ថិតនៅក្នុងរូបកាយរបស់អ្នក ដែលត្រូវទឹកជំនន់ពោលគឺកិលេសធ្វើឲ្យលង់លិច ជាមួយគ្នានេះ អ្នកត្រូវកាត់ឲ្យអស់នូវរាគទោសៈ (មោហៈ ) ផង អ្នកនឹងបានដល់នូវកំពង់គឺនិព្វាន»។

«សតិ កាយគតា ឧបដ្ឋិតា
ឆសុ ផស្សាយតនេសុ សំវុតោ
សតតំ ភិក្ខុ សមាហិតោ
ជញ្ញា និព្វានមត្តនោ»។



www.elibraryofcambodia.org

-នន្ទវគ្គ ឧទាន-

«ភិក្ខុមានស្មារតីតម្កល់នៅក្នុងរូបកាយ, មានសេចក្ដីសង្រួមក្នុងអាយតនៈជាអណ្ដូង, ជាទីកើតនៃផស្សៈទាំងឡាយ៦ហើយ, មានចិត្តតម្កល់មាំក្នុងសមាធិជាប់លាប់មែនទែនហើយ (ក្នុងពេលនេះអ្នកគប្បីដឹងថា) និព្វានជារបស់នៃខ្លួនហើយ»។

## សឧបាទិសេសនិព្វាន

«តណ្ហាយ វិប្បហានេន និព្វានំ ឥតិ វុច្ចតិ»។

-បរាយនវគ្គ សុត្តន្តនិបាត-

«ព្រោះលះបង់តណ្ហាចោលអស់ លោកឲ្យឈ្មោះថានិព្វាន»។

«សព្វសោ តណ្ហានំ ខយា
អសេសវិរាគនិរោធោ និព្វានំ»។

-នន្ទវគ្គ ឧទាន-

«សេចក្ដីរលត់ដោយមិនមានសេសសល់ ព្រោះអស់នៃតណ្ហាទាំងឡាយដោយប្រការទាំងពួង, គឺជានិព្វាន»។

«ឯកា ហិ ធាតុ ឥធ ទិដ្ឋធម្មិកា
សឧបាទិសេសា ភវនេត្តិសង្ខយា»។



www.elibraryofcambodia.org

-ទុក្កនិបាត ឥតិវុត្តកៈ-

«**ធាតុ**មួយហ្នឹងឯង ប្រព្រឹត្តទៅក្នុងធម៌ គឺបុគ្គលគប្បីឃើញក្នុងលោកនេះ ជានិព្វានធាតុ មានឧបាទិសល់នៅ ព្រោះអស់ធម្មជាតិ ដែលជាធាតុនាំសត្វទៅកាន់ភព (ឬព្រោះអស់តណ្ហា)»។

អ្នកអានគប្បីដឹងថា សទិសពាក្យទាំងឡាយរបស់វិភាគៈ មាន «មទនិម្មទនោ» ជាដើម ដូចខ្ញុំបានសរសេរមកហើយក្នុងខាងដើមទាំងប៉ុន្មាននោះ ក៏លោកឲ្យឈ្មោះថា «សឧបាទិសេសនិព្វាន» ដែរ។

## អនុបាទិសេសនិព្វាន

**«អកិញ្ចនំ អនាទានំ ឯតំ ទីបំ អនាបរំ**
**និព្វានំ ឥតិ នំ ព្រូមិ ជរាមច្ចុបរិក្ខយំ»។**

-បរាយនវគ្គ សុត្តនិបាត-

«**ដែល**យើងពោលថាកោះនោះ មិនមែនជាអ្វីដទៃទេ គឺជាកន្លែងដែលមិនមានហ្មងហែង, កន្លែងដែលមិនមានកំណាន់, ជាកន្លែងអស់, កន្លែងសូន្យនៃជរានិងមច្ចុ; នេះគឺជានិព្វាន»។

**«អនុបាទិសេសា បន សម្បរាយិកា**
**យម្ហិ និរុជ្ឈន្តិ ភវានិ សព្វសោ»។**

-ទុក្កនិបាត ឥតិវុត្តកៈ-

«**ចំណែក**ធាតុដែលប្រព្រឹត្តទៅក្នុងធម៌ គឺគេគប្បីដល់ក្នុងខាងមុខ, ដែលភពទាំងឡាយរលត់អស់ដោយប្រការទាំងពួង នេះគឺនិព្វានធាតុដែលមិន



www.elibraryofcambodia.org

មានឧបាទិនៅសល់ (ប្រែថាមិនមានឧបាទិហ្នឹងឯង)»។

«**តេសំ វូបសមោ សុខោ**»

-និទានវគ្គ សំយុត្តនិកាយ-

«**ភាព**ស្ងប់ស្ងាត់នៃសង្ខារទាំងឡាយនោះ ជាសុខ»។

«**អត្ថិ ភិក្ខវេ តទាយតនំ...**»

«ភិក្ខុទាំងឡាយ! **អាយតនៈ**នោះមាន។ល។ ហ្នឹងឯងគឺជាទីបំផុតនៃទុក្ខ»

ក្នុងសូត្រនេះ លោកហៅ «និព្វាន» ថា «អាយតនៈ» បំណងលោកយ៉ាងដូចម្តេច ខ្ញុំមិនសូវយល់ដែរ ប្រសិនបើយើងដៅស្មានថា លោកហៅតាមបែបយ៉ាងអរូបជ្ឈានឬអរូបធម៌ ដូចដែលមានចេញឈ្មោះក្នុងសូត្រនេះក៏មិនត្រូវ ព្រោះមានពាក្យបដិសេធរបស់លោកក្នុងនោះស្រេចទៅហើយ ឬយើងនឹងទុកនិព្វានថាជាធម្មាយតនៈតាមដែលលោកឲ្យឈ្មោះថា និព្វានជាអសង្ខតធម៌។ ពាក្យថា ធម៌ក្នុងទីនេះ បានដល់ធម៌ដែលមិនមានបច្ច័យតាក់តែង និព្វានជាធម្មាយតនៈគឺដៅសេចក្តីថាអាយតនធម៌ដែលមិនមានបច្ច័យតាក់តែង បើទៅប្រកនេះ ខ្ញុំយល់ថាអាចទៅបាន។

ក្នុងចំណុចថាដី, ទឹក, ភ្លើង, ខ្យល់ មិនមានក្នុងនិព្វាននោះ ឆ្លុះសេចក្តីឲ្យយើងឃើញថា និព្វានមិនមានរូបក្ខន្ធ។ ដែលមិនមែនជាអាកាសានញ្ចាយតនៈជាដើមនោះ ឆ្លុះសេចក្តីឲ្យយើងយល់ថា មិនមែនជានាមខន្ធដែលមិនមែនជាលោកនេះ មិនមែនលោកដទៃ មិនមែនដួងច័ន្ទ ដួងអាទិត្យនោះ សេចក្តីហុចមកឲ្យយើងស្តាប់បានថានិព្វានមិនមែនជាលោកណាមួយដូចមានក្នុងហោរាសាស្ត្រទេ។ ដែលថា មិនមានការទៅ, មិនមានការមកជាដើម។ សេចក្តីនេះបញ្ជាក់ឲ្យយើងដឹងថា និព្វានមិនមានការសម្ពន្ធន៍ជាមួយនឹងពិភពដទៃឡើយ ទាំងការទៅដល់, ទាំងការនៅអាស្រ័យជាប្រក្រតី ទាំងការស្លាប់កើតដែលធ្លាប់ចាំថា ជីវិតអន្ទោល។ ដែលថាមិនមានទីតាំង ទីអាស្រ័យជាដើមនោះ។ សេចក្តី



www.elibraryofcambodia.org

នេះ ឆ្លុះឲ្យយើងឃើញថា និព្វានមិនមែនជាលោកដែលយើងកំពុងរស់នៅផង មិនមែនជាលោកណាដទៃទៀតដែលកំពុងរស់នៅដូចយើងផង។

តែបាលីថា «អច្ចុត ឋានំ» ដែលប្រែថា កន្លែងមិនមានចុតិ «ទីបំ» ដែលប្រែថាកោះឬទីពឹងនោះ សេចក្ដីត្រង់នេះដូចជាមានការប្រជែងគ្នា ឬមិនស្របគ្នានឹងពាក្យថា «អប្បតិដ្ឋំ» ដែលប្រែថា មិនមានទីតាំងទីអាស្រ័យ។

យ៉ាងណាក៏ដោយ, ពាក្យពីរម៉ាត់ខាងដើមបំណងរបស់លោកដៅយក «អន្តោ» ប្រែថា «ទីបំផុត» ដែលមាននៅក្នុងសូត្រដដែលនេះថា «អន្តោ ទុក្ខស្ស» ប្រែថា «ទីបំផុតនៃទុក្ខ» ពាក្យថា «ទីបំផុតនៃទុក្ខ» នេះ ខ្ញុំយល់ថាជាពាក្យវោហាររបស់លោក ជិតៗនឹងពាក្យសន្មត ម្ដងថាយ៉ាងនេះ ម្ដងថាយ៉ាងនោះ ឬដូចជានេះ ដូចជានោះ។

ដើម្បីកុំឲ្យអ្នកអានពឹងគំនិតក្នុងរឿងនេះពេក ខ្ញុំមិនឃើញមានគំនិតឯណាក្រៅអំពីគំនិតថា ដែលលោកនិយាយមកទាំងប៉ុន្មានក៏ដើម្បីឲ្យយើងកើតគំនិតក្នុងគំនោលថា ទីបំផុតនៃទុក្ខ នោះគឺជាចុងខ្សែនៃទុក្ខខន្ធប្រែថា ទុក្ខខន្ធត្រូវអស់ត្រឹមនេះឯង។

សេចក្ដីពន្យល់អំពីនិព្វាន ទោះជាបាលីក្ដី អដ្ឋកថាក្ដី អាចារ្យទាំងឡាយក្រោយៗមកក្ដី ពុំអាចឲ្យយើងស្ដាប់អស់ឆ្ងល់បានទេដូចនេះព្រោះអ្វី? ព្រោះថាសេចក្ដីពំក្លីនោះវាសម្បូរណ៍តែពាក្យបដិសេធដូចជាដីក៏មិនមែន, ទឹកក៏មិនមែន, ភ្លើងក៏មិនមែន, ខ្យល់ក៏មិនមែន... អ្វីៗសុទ្ធតែមិនមែនជានិព្វានទាំងអស់។ បំណែកពាក្យទទួលថាជានិព្វាននោះ ស្ដាប់ៗទៅតែមួយម៉ាត់ក៏មិនទាំងមានផង។ ចំណុចនេះ, ខ្ញុំបានធ្វើសេចក្ដីពំក្លី ខាងដើមហើយ ថានិព្វានជារបស់មួយលំបាកនឹងនិយាយតែមួយម៉ាត់ឲ្យត្រូវ ឬឲ្យចំតាមភាសានៃមនុស្សយើង ដោយនិព្វានមិនមានក្នុងវចនានុក្រមនៃភាសាមនុស្ស ហ្នឹងឯងហើយ ទើបអ្នកនិយាយដល់រឿងនេះ, ត្រូវប្រើពាក្យសម្ដីច្រើន, ប្រើសេចក្ដីប្រៀបធៀបច្រើន ប្រែថា និព្វាន



www.elibraryofcambodia.org

បើអ្នកណាចង់និយាយដល់ ត្រូវប្រើពាក្យជាឈ្មោះនៃនិព្វាននោះ និងពាក្យប្រៀបប្រដូចទៅនឹងអ្វីៗនៃនិព្វាននោះឲ្យបានច្រើនៗទើបមានផ្លូវខ្លះ បើមិនដូច្នេះទេ, មិនមានផ្លូវនឹងនិយាយកើតឡើយ។

ឥឡូវនេះ, យើងត្រូវព្យាយាមសិក្សា, ព្យាយាមនិយាយអំពីនិព្វាននេះជាមួយគ្នានៅក្នុងក្របខ័ណ្ឌនៃព្រះសូត្រដដែលថា "អត្ថិ ភិក្ខវេ តទាយតនំ..."។

សេចក្ដីបកប្រែមានមកក្នុងខាងដើមហើយ។ ប្រសិនបើយើងលើកយកពាក្យទាំងអស់ក្នុងព្រះសូត្រនេះ មកធ្វើវិភាគជាមួយនឹងវិចារណញ្ញាណរបស់យើងជាថ្មីទៀត ខ្ញុំដូចជាយល់ថា អ្វីៗដែលលោកថា "មិនមាន" ថា "មិនមែន" ថា "ទទេ" នោះ យើងមិនអាចបដិសេធពាក្យរបស់លោក, ហើយរកពាក្យរបស់អ្នកណាមកដាក់ជំនួសបានទេ ព្រោះអ្វី? ព្រោះខ្ញុំនឹកឃើញដល់បរមត្ថធម៌ដែលមានសម្ដែងអំពីចិត្ត, ចេតសិក, រូប, និព្វាន។

ចំពោះចិត្តនិងចេតសិត មិនមានចោទជាបញ្ហាទេ ព្រោះរបស់នេះជាអរូបធម៌ឬជានាមធម៌មានអត្ថជ្រាលជ្រៅ ដូចគ្នានឹងនិព្វានដែលយើងកំពុងគិតដល់នេះដែរ។ តែចំពោះរូបវិញ បើតាមគំនិតយើងថា របស់នេះមិនមែនមានអត្ថជ្រាលជ្រៅ ឬមិនមែនជារបស់នៅក្នុងភាពមានអាថ៌កំបាំងអ្វីទេ ព្រោះរបស់នេះមានរូបមើលឃើញ, ចាប់បាន។

យោបល់របស់យើងក្នុងរឿងនេះខុសទទេ ព្រោះរូបក្នុងបរមត្ថធម៌ លោកពុំបានសំដៅយករូបដែលចាប់បាន មើលឃើញឡើយ គឺលោកសំដៅយករូបដែលចាប់មិនបាន, មើលមិនឃើញឯណោះទៅវិញទេ។

ដើម្បីឲ្យអ្នកអានបានស្គាល់បរមត្ថធម៌ផ្នែករូបនេះ ខ្ញុំសូមលើកមហាភូតរូបទីមួយ, គឺដីមកធ្វើជាឧទាហរណ៍ ដីលោកចែកចេញជា ៤ គឺ **លក្ខណបឋវី១ សសម្ភារបឋវី១ អារម្មណបឋវី១ សម្មតិបឋវី១។ លក្ខណបឋវី**, បានដល់ដីដែលមានភាពល្អិតជាទីបំផុតចាប់ដោយដៃមិនបាន មើលដោយភ្នែកមិនឃើញ។

**សសម្ភារបឋវី**, បានដល់ដីអាការៈ២០ មានសក់, រោម, ក្រចក, ធ្មេញ,



www.elibraryofcambodia.org

ស្បែកជាដើម។ អារម្មណបឬបរី. បានដល់ដី ដែលគេដាក់ក្នុងភាជនៈអ្វីមួយ សម្រាប់ធ្វើជាវង់កសិណរបស់អ្នកចំរើនកម្មដ្ឋាន។

**សម្មតិបឋវី**, បានដល់ដីដែលគេសន្មតដូចដីស្រែ, ចម្ការ, សួន, វាលវង់, ទួល, ដម្បូកជាដើម។ ដីទាំង៤ប្រភេទនេះ មានតែលក្ខណបឋវីមួយទេ ដែលលោកចាត់ចូលក្នុងបរមត្ថធម៌។

បើតាមន័យនេះ, «និព្វាន» ដែលលោកថា នេះមិនមែន...តែរបស់ណាដែលជារបស់សម្រាប់លោកឬសម្រាប់សកលចក្រវាល។

ចំណែកខាងនិព្វានធាតុ និងរបស់ទាំងឡាយដែលត្រូវមានសម្រាប់និព្វាននោះ ក៏មិនមែនជាមិនមានទេ គឺវាមានទាំងអស់ តែរបស់នោះមិនមានបច្ច័យតាក់តែង ជាអសង្ខតធាតុឬជាវិសង្ខារ ប្រែថា «និព្វាន» ឯង ជាគុណធម៌មានប្រសិទ្ធភាពផ្លាស់សង្ខតធាតុចេញទាំងអស់ហើយដាក់អសង្ខតធាតុចូលជំនួសវិញ។

សេចក្តីសន្និដ្ឋានរបស់យើងនេះ, ខ្ញុំយល់ថាត្រូវច្រើនជាងខុស ព្រោះខ្ញុំយោលសេចក្តីទៅលើបរមត្ថធម៌ ដែលមានអត្ថថា ចិត្ត, ចេតសិក, រូប, និព្វាននោះផង, ទៅលើសច្ចៈ៦យ៉ាងដែលលោករាប់ថា **វចីសច្ចៈ សម្មតិសច្ចៈ សភាវសច្ចៈ បរមត្ថសច្ចៈ អរិយសច្ចៈ និព្វានសច្ចៈ**នោះផង។ ជាមួយនឹងយោបល់របស់ខ្ញុំខាងលើនេះ ខ្ញុំសូមឲ្យយោបល់និងសេចក្តីបញ្ជាក់មួយចំណែកទៀត ដល់អ្នកអានមានដូចតទៅនេះ។

ពាក្យដែលលោកថា «**អាយតនៈនៅមាន**» នោះ ពាក្យនេះមិនខុសគ្នានឹងភ្លើងរលត់, តែភ្លើងនៅមាន ប្រែថាភ្លើងមាននៅជានិច្ចកាល ទោះរលត់ក្តី ទោះឆេះក្តី, ប៉ុន្តែភ្លើងមានក្នុងពេលឆេះ មានជាអណ្តាត ជាផ្សែង, ជាភ្លើងមានភាពប្រាកដដល់យើងតាមផ្លូវភ្នែកឬផ្លូវកាយ ភ្លើងមានក្នុងពេលរលត់ មិនមានអណ្តាត, មិនមានផ្សែង មិនមានកំញមជាភ្លើង មានភាពមិនប្រាកដដល់អារម្មណ៍របស់យើងឡើយ។



www.elibraryofcambodia.org

ច្បាស់ជាងនេះទៅទៀត គឺភ្លើងអគ្គិសនី ភ្លើងនេះបើមិនមានគ្រឿងចាប់ ក៏នៅក្នុងភាពថាមិនមានភ្លើង លុះមានគ្រឿងចាប់ភាពភ្លើងក៏ប្រាកដឡើង។ ភ្លើងទាំងឡាយត្រូវកើត, ត្រូវឆេះ, ត្រូវប្រាកដដោយអាស្រ័យឧស, ប្រេង, ជ័រ, ខ្លាញ់, ស្មៅស្ងួតគ្រឿងចក្រ។ល។

យ៉ាងណាមិញ និព្វានដែលលោកថា នៅមានអាយតនៈក៏យ៉ាងនោះដែរ ដូចនេះព្រោះអ្វី? ព្រោះអាយតនៈធម្មតាដែលយើងមាន, យើងស្គាល់នោះ, មិនមានក្នុងនិព្វានទេ មានតែអាយតនៈជាដំណូរ ឬ **ធម្មាយតនៈ** របស់ព្រះអរហន្ត ដោយន័យថា និព្វានដែលមានឈ្មោះថា អាយតនៈនោះមានពិត, តែមនុស្សបុថុជ្ជនពុំអាចស្គាល់បានទេ ស្គាល់បានតែព្រះសម្មាសម្ពុទ្ធនិងព្រះអរហន្តទាំងឡាយប៉ុណ្ណោះ។

អាយតនៈគឺនិព្វានឬនិព្វាននៅមានអាយតនៈ អ្នកអានគប្បីដឹងថា អាយតនៈនេះមិនមានបច្ច័យតាក់តែងទេ ត្រូវនិងពុទ្ធភាសិតដែលខ្ញុំបានសរសេរខាងដើមមកហើយថា :

«**អត្ថិ ភិក្ខវេ អជាតំ អភូតំ អកតំ អសង្ខតំ...**»

«ភិក្ខុទាំងឡាយ! អាយតនៈនោះ មិនកើត, មិនមានភាព, មិនមានបច្ច័យតាក់តែង, មិនមានសង្ខារតួសវាស»។

## និព្វានបរិយាយទាំងពីរប្រភេទ

«**ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ**
**សព្វូបធិបដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ**
**និរោធោ និព្វានំ**» (សេចក្តីប្រែដូចមុន)។

**ឧបធិ**ក្នុងទីនេះជាឈ្មោះនៃកិលេស ដែលលោកបានធ្វើសេចក្តីបញ្ជាក់ក្នុងបទថា «**ឧបធិវិវេកោ**» ស្ងាត់នៃឧបធិ គឺស្ងាត់កិលេសហ្នឹងឯង ឧបធិដដែលនេះទៅជាឈ្មោះរបស់បញ្ចក្ខន្ធ, ដែលមានសេចក្តីបញ្ជាក់របស់លោកក្នុងភាសិត



www.elibraryofcambodia.org

ថា :

**«រូបេ ច សទ្ទេ ច អថោ រសេ ច**
**កាមិត្ថិយោ ចាភិវទន្តិ យញ្ញា**
**ឯតំ មលន្តិ ឧបធីសុ ញត្វា**
**តស្មា ន យិដ្ឋេ នហុតេ អរញ្ជិ»**

**យញ្ញ**បុគ្គលទាំងឡាយ តែងពោលលើកសរសើរ រូប, សម្លេង, ក្លិន, រស, កាមនិងស្ត្រីទាំងឡាយ ខ្ញុំស្គាល់ថា របស់ហ្នឹងជាគ្រឿងមន្ទិលសៅហ្មងក្នុងឧបធិទាំងឡាយ ព្រោះហេតុនោះ ទើបខ្ញុំមិនត្រេកអរក្នុងការសែនព្រេន ការបន់ស្រន់បួងសួង»។ ពាក្យថាទីស្ងប់នៃសង្ខារទាំងពួង និងពាក្យថាជាគ្រឿងលះបង់នៃឧបធិទាំងពួង សំដៅយកអនុបាទិសេសនិព្វាន។ ពាក្យបីម៉ាត់មានពាក្យថាតណ្ហក្ខយោជាដើម សំដៅយកសឧបាទិសេសនិព្វាន។ ចំណែកខាងលំដាប់នៃពាក្យ. យោបល់ខ្ញុំថាត្រូវរៀងសឧបាទិសេសនិព្វានមុន តែដែលលោករៀងដូច្នេះវិញ ប្រហែលជាលោកមានគំនិតថា គួរស្ដីដល់និព្វានជានិប្បរិយាយមុនហើយមើលទៅ។

និព្វានដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងដោយមិនមានគុណបទ មានមកក្នុងបាលីថា «និព្វានំ សុគតេន ទេសិតំ» «និព្វានគឺព្រះសុគតទ្រង់សម្ដែងហើយ» ពាក្យនេះអ្នកអានគប្បីចូលចិត្តថា ទ្រង់ប្រមូលរួបរួមរហូតដល់អនុបាទិសេសនិព្វានតែម្ដង។

កាលបើពោលដោយបុគ្គលាធិដ្ឋាន បទកិរិយារបស់អ្នកសម្រេចនិព្វានដោយរលត់ចរិមកចិត្ត ក្នុងមហាបរិនិព្វានសូត្រលោកប្រើសព្ទថា «បរិនិព្វាន» ឧទាហរណ៍ ក្នុងបទនៃកិរិយាអាខ្យាតមានដូចនេះ :

**«ចតុត្ថា ឈានា វុដ្ឋហិត្វា**
**សមនន្តរា ភគវា បរិនិព្វាយិ»**

ព្រះមានព្រះភាគទ្រង់ចេញចាកឈានទី៤ ហើយបរិនិព្វាន (រលត់អស់



www.elibraryofcambodia.org

នូវអ្វីៗដែលមិនមែនជានិព្វានឬមិនមែនជាអសង្ខតធម៌)។ បទកិរិយានាមមាន ដូចនេះ :

«បរិនិព្វុតេ ភគវតិ សហបរិនិព្វានា សក្កោ
ទេវានមិន្ទោ ឥមំ គាថំ អភាសិ :
**អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ**
**ឧប្បជ្ជិត្វានិរុជ្ឈន្តិ តេសំ វូបសមោ សុខោ**»។

«**កាល**ព្រះមានព្រះភាគទ្រង់រលត់អស់នូវធម៌ជាសត្រូវជុំវិញ ជាមួយដោយបរិនិព្វានរបស់ព្រះអង្គហើយ សក្កទេវរាជទ្រង់ពោលគាថានេះថាសង្ខារទាំងឡាយមិនទៀងហ្ន៎! មានសេចក្តីកើតឡើងហើយ សូន្យអស់ទៅវិញជាធម្មតា កើតហើយរលត់ រលត់ហើយកើត ពេលណាសត្វលោកធ្វើឲ្យសង្ខារទាំងឡាយនេះស្ងប់ សេចក្តីសុខទើបកើតមានបាន»។

ក្នុងគម្ពីរធម្មបទលោកប្រើស័ព្ទថា «**បរិនិព្វន្តិ, អនាសវា**» «បុគ្គលមិនមានអាសវៈ តែងបានសម្រេចនូវបរិនិព្វាន «តែបទជាកិរិយាកិតកៈ(កិរិយាក្រឹត) លោកពុំបានប្រើស័ព្ទថា «បរិនិព្វាន» ទេ លោកប្រើស័ព្ទថា «**បរិនិព្វុតៈ**» ដែលប្រែថារលត់ជំនួសវិញ ដូចបទថា «បរិនិព្វុតេ ភគវតិ» ក្នុងខាងដើម។

ស័ព្ទថា «បរិនិព្វុតៈ» មានរូបធាតុផ្សេងអំពីស័ព្ទថា «បរិនិព្វាន» គឺមានរូបជា «វុ» ធាតុមាន «និ» ជាបទមុខ ដៅសេចក្តីថា«រលត់» តបច្ច័យសម្រេចរូបបានជាត្រៃលិង្គ «និព្វុតោ, និព្វុតា, និព្វុតំ» បើដៅសេចក្តីទៅលើធម្មាធិដ្ឋានៈ លោកតម្រូវឲ្យចុះតិបច្ច័យ សម្រេចរូបជា «និព្វុតិ» ជាសទិសរបស់និព្វានឬនិរោធ។

ការប្រើស័ព្ទថា «បរិនិព្វុតិ, បរិនិព្វុតៈ» ជំនួសស័ព្ទថា «និព្វាន» ខ្ញុំចូលចិត្តថា ព្រោះធាតុនៃស័ព្ទថានិព្វានមិនធ្លាប់មានប្រើជាមួយនឹងតបច្ច័យ។

«**និព្វុតៈ**» ស័ព្ទនេះ បើប្រែយកសេចក្តីខុសអំពីនេះទៅក៏បាន ដូចបទថា :

«**សាលិកុរំ សុនិព្វុតំ**» បាយនៃអង្ករសាលី គឺបុគ្គលត្រកអរហើយ។ ប្រែ



www.elibraryofcambodia.org

ថា «រលត់» ដដែលដូចពាក្យថា :

**«និព្វុតា នូន សា មាតា»** ស្ត្រីជាមាតានោះមានទុក្ខរលត់ហើយ។ ប្រើក្នុងអត្ថដ៏មានជម្រៅក៏មាន ដូចបាលីអរិយសច្ចៈសម្តែងជាធម្មាធិដ្ឋានថា :

**«អត្ថិ និព្វុតិ ន និព្វុតោ បុមា»** សេចក្តីរលត់មាន (តែ) បុគ្គលរំលត់មិនមាន។ ប្រហែលជាលោកត្រូវការធ្វើសេចក្តីធម្មតា ឲ្យទៅជាសេចក្តីមានជម្រៅនោះទេដឹង! បានជាលោកថែមស័ព្ទ «បរិ» ចូលមកទៀត សម្រេចរូបជា **«បរិនិព្វុតៈ»** ប្រើបានគ្រប់លិង្គគ្រប់វចនៈ។

សេចក្តីនេះនាំឲ្យយើងចូលចិត្តថា ក្នុងទីបំផុតនៃសេចក្តីប្រតិបត្តិធម៌ដែលត្រូវបានសម្រេចនិព្វាននោះ គឺរលត់នៃចរិមកចិត្តផង រលត់នូវកំដៅដែលកើតអំពីកិលេសទាំងឡាយផង ត្រូវនឹងពាក្យខ្លះដែលបាននិយាយមកហើយថារលត់ដោយជុំវិញ ឬរលត់អស់ដោយមិនមានសេសសល់ ដែលពាក្យធម្មតាថារលត់អស់រលីង។

ពាក្យថា «រលត់» ក្តី «រលត់នូវចរិមកចិត្ត» ក្តី «រលត់ជុំវិញ» ក្តី «រលត់ដោយមិនមានសេសសល់» ក្តី «រលត់អស់រលីង» ក្តី។ ពាក្យនេះយើងត្រូវបកស្រាយនៅក្នុងក្របខ័ណ្ឌនៃការរលត់ តែរបស់ដែលត្រូវរលត់ប៉ុណ្ណោះ។

ចំណែករបស់ដែលលោកពុំបាននិយាយថារលត់នោះ យើងត្រូវធ្វើវិភាគប្រកបដោយវិចារណញ្ញាណ, ដូចខ្ញុំបានធ្វើសេចក្តីពំភ្លឺមកខ្លះហើយក្នុងចំណុចដែលស្តីដល់រឿងនេះ។

**«អាសវានំ ខយា ភិក្ខុ និច្ឆាតោ បរិនិព្វុតោ»**

-តិកនិបាត ឥតិវុត្តកៈ-

«ព្រោះអស់អាសវៈទាំងឡាយ ភិក្ខុមិនមានសម្រេក, មានកំដៅរលត់សូន្យអស់»

**«និក្ខិបិត្វា គរុំកភារំ អញ្ញំ ភារំ អនាទិយ សមូលំ**



www.elibraryofcambodia.org

**តណ្ហំ អព្ពុឡ្ហ និច្ឆាតោ បរិនិព្វុតោ»**

-ភារសូត្រ ខន្ធវារសំយុត្ត-

«ដាក់ចុះនូវភារៈចូន់ចោលហើយ មិនកាន់យកនូវភារៈដទៃទៀត, ដកចេញនូវតណ្ហាព្រមទាំងឫសមិនមានតម្រេក, មានកំដៅរលត់សូន្យអស់ (នេះឯងគឺជានិព្វាន)»

ភារៈក្នុងទីនេះ សំដៅយកបញ្ចក្ខន្ធ, កាន់យកនូវភារៈ សំដៅយកការប្រកាន់ខ្ជាប់នូវឧបាទាន, ការដាក់នូវភារៈ សំដៅយកការដកចិត្តចេញចាកឧបាទាន ឬលះបង់ខន្ធបញ្ចកៈ។

**«យេសំ សម្ពោធិយង្គេសុ សម្មាចិត្តំ សុភាវិតំ**

**អាទានបដិនិស្សគ្គេ អនុបាទាយ យេ រតា**

**ខីណាសវា ជុតិមន្តោ តេ លោកេ បរិនិព្វុតា»។**

«ចិត្តរបស់បុគ្គលណា មានការអប់រំត្រឹមត្រូវល្អហើយ ក្នុងអង្គនៃសម្ពោធិគឺបញ្ញាជាគ្រឿងញ៉ាំងខ្លួនឲ្យត្រាស់ដឹង បុគ្គលទាំងឡាយណាមិនមានចិត្តប្រកាន់មាំដោយឧបាទាន ជាអ្នកត្រេកអរក្នុងការលះបង់នូវកំណាន់ បុគ្គលទាំងឡាយនោះ ឈ្មោះថាជាអ្នកមានអាសវៈអស់ហើយ មានសេចក្តីរុងរឿងដោយញាណមានភាពរលត់នូវអ្វីៗទាំងអស់ក្នុងលោកនេះ»។

ពាក្យថា «**បរិនិព្វុតិ**» យើងពុំសូវដែលបានឃើញទេ។ «និព្វុតិ» មានដោយតិចៗ។ «និព្វុតោ» មានមួយៗ។ ស័ព្ទទាំងអស់នេះ លោកប្រើផ្លាស់ប្តូរជាមួយនឹង «និព្វាន» ជាស័ព្ទដែលយើងធ្លាប់ជួបប្រទះរឿយៗក្នុងគម្ពីរពុទ្ធសាសនា។

ភាសិតខាងលើនេះ, មានសេចក្តីផ្លែកគួរឲ្យយើងចាប់អារម្មណ៍ខ្លះដែរ គឺ «និព្វាន» លោកដៅយកការអស់, ការសូន, ការលះកិលេស, ការលះអាសវៈទាំងឡាយដទៃ ដែលមិនមែនជាបញ្ចកាមគុណ; ខុសគ្នានឹងពាក្យថា «វិរាគៈ» ដែលមានតម្រេកមិនមាន ឬប្រាសចាកតម្រេកដែលដៅយកត្រឹមតែបញ្ចកាម



www.elibraryofcambodia.org

គុណ។

អ្នកមានបញ្ញារមែងពិចារណាឃើញសេចក្តីសុខក្នុងលោកប្រកបដោយភាពផ្លាស់ប្តូរប្រែប្រួល, ជាសេចក្តីសុខបោកបន្លំ ប្រៀបបាននឹងនុយដែលព្រាននេសាទបិទភ្ជាប់លើផ្លែសន្ទូចដើម្បីបញ្ឆោតត្រី។ សេចក្តីយល់ឃើញនេះនាំឲ្យកើតគំនិតធុញទ្រាន់. ពេលវេលាកន្លងទៅកាន់តែច្រើន គំនិតធុញទ្រាន់នេះក៏មានកាន់តែច្រើនដែរ។ ដោយអាស្រ័យគំនិតធុញទ្រាន់នេះ ទើបលោកផ្លាស់ចិត្តស្វែងរកសេចក្តីសុខថ្មីទៀត ដែលពុទ្ធសាសនាឲ្យឈ្មោះថា «សុខុមសុខ» ឬ «ឯកន្តបរមសុខ» ឬ «សន្តិសុខ» ដែលយើងធ្លាប់ស្គាល់ថា «សុខកើតអំពីសេចក្តីស្ងប់» សមតាមភាសិតថា :

**«ធម្មបីតិ សុខំ សេតិ វិប្បសន្នេន**
**ចេតសា អរិយប្បវេទិតេ ធម្មេ សទារ**
**មតិ បណ្ឌិតា»** (ប្រែដូចសេចក្តីមុន)។
**«យតោ យតោ សម្មសតិ ខន្ធានំ**
**ឧទយព្វយំ លភតិ បីតិបាមោជ្ជំ**
**អមតន្តំ វិជានតំ»**។

«**ក្នុង**កាលណាៗ បុគ្គលពិចារណាឃើញសេចក្តីកើត, សេចក្តីរលត់នៃខន្ធទាំងឡាយ គេរមែងបាននូវបីតិប្រាមោទ្យ ហ្នឹងឯងជាទឹកអម្រឹតរបស់អ្នកចេះដឹងទាំងឡាយ»។ បីតិប្រាមោទ្យនេះ បានធ្វើឲ្យបុគ្គលអ្នកប្រតិបត្តិធម៌ បានដល់នូវសេចក្តីសុខយ៉ាងខ្ពស់ ដែលពុទ្ធសាសនារបស់យើងឲ្យឈ្មោះថា : «និរាមិសសុខ» ដែលមាននិព្វានជាទីបំផុត ដោយអាស្រ័យកម្លាំងនៃការប្រតិបត្តិធម៌ដែលយោគាវចរ:, បានបង្កើតឡើងបន្តិចម្តង ៗ តាមលំដាប់នោះឯង។

ក្នុងទីនេះ, ខ្ញុំសូមធ្វើសេចក្តីអធិប្បាយរឿងដទៃក្រៅពីនិព្វានបន្តិច ដើម្បីជាពន្លឺឬជាប្រយោជន៍ដល់អ្នកអាន បើមិនច្រើនក៏តិចដែរ។ មានហេតុដូចម្តេចខ្លះ ដែលជាហេតុនាំឲ្យខ្ញុំសរសេរក្រៅរឿង ? ខ្ញុំសូមឆ្លើយនឹងសំនួរនេះថា មាន



www.elibraryofcambodia.org

ហេតុក្នុងចំណុចថា កាលណាយើងនិយាយចេញព្រះនាមព្រះពុទ្ធរបស់យើងជាភាសាបាលីនោះ យើងពុំដែលពោលថា "**ពុទ្ធោ**" ទេ យើងច្រើនពោលថា "ពុទ្ធា" ឧទាហរណ៍មានជាអាទិ៍ថា "**និព្វានំ បរមំ វទន្តិ ពុទ្ធា**" ពំនោលរបស់យើងបានមានដល់ព្រះសម្មាសម្ពុទ្ធច្រើនអង្គនោះ, ដោយសេចក្ដីសង្កេតរបស់ខ្ញុំឃើញថាក្នុងគម្ពីរបាលីខ្លះគ្រាន់តែបានប្រើពាក្យជាពហុវចនៈថា ព្រះពុទ្ធទាំងឡាយ ដូចមានក្នុងឧទាហរណ៍ខាងលើក្នុងព្រះសូត្រទាំងឡាយខ្លះ មានមហាបធានសូត្រជាដើម លោកបានពោលចេញព្រះនាមព្រះសម្មាសម្ពុទ្ធ ទាំងឡាយ ដែលទ្រង់បានត្រាស់កន្លងទៅហើយទាំង៥ព្រះអង្គ គឺព្រះវិបស្សី, ព្រះសិខី, ព្រះវេស្សភូ, ព្រះកោនាគមនៈ, និងព្រះកស្សបៈ។

ការដែលពុទ្ធសាសនិកតាំងអំពីបុរាណកាលមក ចូលចិត្តចង់ឲ្យមានព្រះពុទ្ធច្រើនអង្គនោះ ប្រសិនបើយើងពិចារណាមើលទៅគ្មានបំណងអ្វីក្រៅពីចង់ឲ្យយុត្តិធម៌, សន្តិធម៌ ជាពិសេសគឺនិព្វាន មាននៅអស់កាលជានិច្ច ដើម្បីជាជម្រកជាទីសង្ឃឹមកក់ក្ដៅរបស់ខ្លួនទេ ព្រោះធម៌ទាំងឡាយនេះ ជាធម៌ដែលគេមានសេចក្ដីស្រឡាញ់ស្មើដោយជីវិតរបស់គេ។

ជាមួយនឹងសេចក្ដីស្រឡាញ់នេះ គេមានគំនិតថា មានតែព្រះទាំងឡាយទេ ដែលអាចនឹងថែរក្សាធម៌ទាំងឡាយនេះបាន។ បន្ទាប់អំពីព្រះទាំងឡាយ គេថាមានអ្នកតំណាងព្រះ គឺបុគ្គលដែលមានវត្ថុបំណងនិងឧត្តមគតិដូចព្រះទាំងឡាយមួយពួកទៀត ដែលអាចរក្សាទុកនូវធម៌ទាំងអស់នេះបានដែរ តែពុំបានពេញលេញ ដូចតួអង្គរបស់ព្រះទេ។

គោលគំនិតដែលចង់មានព្រះនិងចង់មានព្រះឲ្យបានច្រើនអង្គនោះ បញ្ជាក់សេចក្ដីឲ្យយើងឃើញថា មនុស្សធម៌ក្ដី យុត្តិធម៌ក្ដី សន្តិធម៌ក្ដី សន្តិសុខនៃជីវិតក្ដី និព្វានក្ដី។ល។ របស់ទាំងអស់នេះ ជាធម្មជាតុដែលមនុស្សយើងស្រឡាញ់រកវត្ថុអ្វីប្រៀបពុំបាន។

ដោយអាស្រ័យគោលគំនិតនេះ ទើបមនុស្សយើងនាំគ្នាបង្កើតឲ្យមាន



www.elibraryofcambodia.org

ព្រះឡើងនៅក្នុងលោកនេះ។ អ្វីជាព្រះ? សំនួរនេះខ្ញុំឆ្លើយគ្មានចាំបាច់គិតថាៈ អ្វីក៏ដោយឲ្យតែមានយុត្តិធម៌, សន្តិធម៌។ល។ នៅក្នុងនោះសុទ្ធតែជាព្រះទាំងអស់។ ប្រសិនបើមានចម្ងល់ថាដូចម្ដេចក៏ថាមនុស្សបង្កើតព្រះ បើក្នុងគម្ពីរប៊ីប្លិ៍, គម្ពីរគូរ៉ង់, គម្ពីរវេទ... មាននិយាយថា ព្រះបង្កើតមនុស្សនិងអ្វី ៗទាំងអស់ស្រេចទៅហើយ? មុននឹងសងចម្លើយក្នុងរឿងនេះ ខ្ញុំសូមធ្វើសេចក្ដីបញ្ជាក់ថា គម្ពីរទាំងអស់នោះពុំមែនសរសេរឬតែងឡើងដោយព្រះទាំងឡាយទេ គឺធ្វើឡើងដោយមនុស្សយើងដែលមានគោលគំនិតដូចខាងលើ។ ដូចនេះចម្លើយ របស់ខ្ញុំត្រូវសងដូចមានតទៅនេះ ៖

១- មនុស្សត្រូវការចង់ឲ្យជីវិតរបស់ខ្លួនមានសេរីភាពគ្រប់យ៉ាង។

២- ត្រូវការចង់ឲ្យជីវិតរបស់ខ្លួនដើរទៅដល់ទីបំផុតដែលមាននៅក្នុងគំនិត។

៣- ត្រូវការយុត្តិធម៌សម្រាប់ជីវិត។

៤- ត្រូវការសន្តិសុខសម្រាប់ជីវិត។

៥- ត្រូវការសេចក្ដីសុខដែលមានសេចក្ដីស្ងប់នៅខាងក្នុង សម្រាប់ជីវិត។

៦- ត្រូវការឲ្យមនុស្សធម៌មាននៅក្នុងលោកអស់កាលជានិច្ច។

៧- ត្រូវការឲ្យជីវិតបានសម្រេចនិព្វាន ឬត្រូវការឲ្យបានទៅនៅជាមួយនឹងព្រះអាទិទេព។ល។

ក្រៅអំពីចម្លើយដែលខ្ញុំបានសងមកហើយ ខ្ញុំសូមធ្វើសេចក្ដីពំភ្លឺថា ព្រះតាមសេចក្ដីគិតគូររបស់ខ្ញុំរួមទាំងមនុស្សដទៃផងមានពីរពួក, ពួកទី១បានដល់ព្រះដែលមានតែព្រះនាមសម្រាប់ហៅ ពុំមានរូបសម្រាប់ឃើញនោះគឺ :

**ក- ព្រះយុត្តិធម៌**

**ខ- ព្រះធម៌ឬព្រះសន្តិធម៌**

**គ- ព្រះចិត្តឬព្រះវិញ្ញាណ។**

ព្រះទាំងឡាយនេះ មាននៅក្នុងសាលកលោកអស់កាលជានិច្ចជានិរន្តរ៍ ពុំមានស្លាប់ពុំមាននិព្វានទេ តែពុំមានចលនាពុំមានសកម្មភាពអ្វីមួយ ដែល



www.elibraryofcambodia.org

អាចឲ្យមនុស្សយើងធ្វើនូវសេចក្តីកត់សម្គាល់បានទេ។

ក្នុងពេលណាមួយ ដែលមនុស្សយើងណាម្នាក់ឬច្រើននាក់ បានគោរពប្រតិបត្តិតាមព្រះទាំងឡាយមានព្រះយុត្តិធម៌ជាដើម ក្នុងពេលនោះមនុស្សទាំងឡាយដទៃទៀត ក៏នាំគ្នាតែងតាំងមនុស្សនោះឲ្យធ្វើជាព្រះរបស់ខ្លួន ហើយក្នុងពេលជាមួយនេះ គេក៏បានតែងតាំងមនុស្សជាច្រើនទៀត ដែលបានបំពេញបំណងនិងឧត្តមគតិរបស់ព្រះ ឲ្យធ្វើជាព្រះតូច ៗ ដែលយើងធ្លាប់ហៅថា «បរិវារព្រះ» ឬ «តំណាងព្រះ» ឬ «សាវ័កព្រះ»។

ដូច្នេះ, ទើបមានព្រះសាវ័ក, ព្រះភិក្ខុ, ព្រះអរិយបុគ្គល, ព្រះទេព, ព្រះឥន្ទ, ព្រះព្រហ្ម, ព្រះយ៉េស៊ូ, ព្រះមហាម៉ត, ព្រះអាចារ្យ, ព្រះគ្រូ។ល។ ចំណែកព្រះជាប្រធានឬជាធំជាងគេ ក្នុងពុទ្ធសាសនាយើងគឺព្រះសព្វញ្ញុពុទ្ធ។ ក្នុងសាសនាព្រាហ្មណ៍គឺព្រះព្រហ្មឬព្រះសិវៈឬព្រះវិស្ណុ។ ក្នុងសាសនាគ្រិស្ត គឺព្រះយ៉ៈហូវ៉ា។ ក្នុងសាសនាឥស្លាមគឺព្រះអាឡាស់។ អ្នកអានគួរធ្វើសេចក្តីកត់សម្គាល់ថា ព្រះធំៗក្នុងសាសនាខាងក្រៅ (ព្រាហ្មណ៍, គ្រិស្ត, ឥស្លាម) សាសនិកក្នុងសាសនានោះៗគេហៅថា «ព្រះជាម្ចាស់សួគ៌» ឬ «ព្រះអាទិទេព» អត្ថន័យរបស់ពាក្យនេះ អ្នកអានធ្លាប់ដឹងស្រាប់ហើយ។

សេចក្តីត្រូវការឲ្យមានព្រះច្រើនគឺជាបំណងល្អមួយរបស់មនុស្សលោក ព្រោះថា បើកាន់តែមានព្រះច្រើន សន្តិភាពរបស់ជីវិតដែលយើងចង់បាន ក៏កាន់តែមានសេចក្តីស្ថិតស្ថេរជាស្ថាពរឡើងដែរ។

ដូច្នេះហើយ, បានជាក្នុងអតីតកាលអង្វែងមកហើយនោះ មនុស្សលោកមានការប្រកួតប្រឡងគ្នាអំពីរឿងព្រះនេះ ខាងបរិមាណ, លទ្ធផលក្នុងរឿងនេះជ័យជំនះបានមកលើព្រះពុទ្ធសាសនារបស់យើង ព្រោះពុទ្ធសាសនិករបស់យើងក្នុងសម័យនោះ បានរាប់ព្រះលុះត្រាតែរាប់មិនអស់ ហើយបានធ្វើសេចក្តីប្រៀបថា ព្រះសម្មាសម្ពុទ្ធរបស់យើងមានច្រើនជាអតិបរមា ឬមានច្រើនជាអនេករាប់មិនអស់ដូចគ្រាប់ខ្សាច់ដែលមាននៅលើផ្ទៃពិភពលោក។



www.elibraryofcambodia.org

ពាក្យថា «**ឯហិបស្សិកោ**» ជាធម៌គួរហៅអ្នកដទៃឲ្យចូលមកមើលបាន ដោយន័យថា ជាធម៌គួរពេញចិត្តគួរប្រាថ្នា, ធម៌នេះក៏មិនមែនជាធម៌ណាដទៃក្រៅអំពីធម៌ដែលធ្វើឲ្យជីវិតរស់នៅក្នុងសេចក្ដីស្ងប់ ឬយុត្តិធម៌និងសន្តិធម៌នេះឡើយ។

ចំណង់នៃមនុស្សក្នុងចំណុចនេះ, មិនត្រឹមតែនាំគ្នាបង្កើតគម្ពីរធម៌អាថ៌ប៉ុណ្ណោះទេ, ថែមទាំងនាំគ្នាទន្ទឹងមើលផ្លូវព្រះទៀតផង។ ក្នុងសាសនាព្រាហ្មណ៍, ទន្ទឹងព្រះនារាយណ៍អវតារ។ ក្នុងសាសនាគ្រិស្ត, ទន្ទឹងដំណើរត្រឡប់វិលមកវិញនៃព្រះយេស៊ូ។ ក្នុងសាសនាឥស្លាម, ទន្ទឹងអ្នកតំណាងព្រះអាឡ្លាស់ថ្មីទៀត។

ក្នុងពុទ្ធសាសនាយើង, ទន្ទឹងដំណើរយាងមកនៃព្រះអរិយមេត្តេយ្យឬព្រះមេត្តេយ្យគឺជាព្រះពោធិសត្វដែលត្រូវបានមកត្រាស់ជាព្រះពុទ្ធ ក្នុងអនាគតកាល។

ព្រះពោធិសត្វអង្គនេះ បើហៅតាមសំនៀងសំស្ក្រឹតក្លាយជាព្រះស្រីអារ្យមៃត្រេយ។ បើយកសម្លេងនេះមកធ្វើជាមូលដ្ឋាននៃគំនិត ប្រហែលជារឿងនេះមិនមែនជារឿងរបស់ពួកយើងទក្ខិណនិកាយទេ គឺជារឿងរបស់ពួកឧត្តរនិកាយ, ដូចនេះព្រោះអ្វី? ព្រោះក្នុងបាលីទូទៅមិនឃើញមានរឿងនេះ មានតែក្នុងចក្រវត្តិសូត្រនៃគម្ពីរទីឃនិកាយមួយប៉ុណ្ណោះ។

ពាក្យថា «**បច្ចត្តំ វេទិតព្វោ វិញ្ញូហិ**» ដែលយើងធ្លាប់ប្រែថាជាធម៌គឺវិញ្ញូជនគប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ដោយន័យថាដឹងចំពោះខ្លួន, តាមវិស័យ, តាមសេចក្ដីព្យាយាមខាងផ្លូវបណ្ដុះបណ្ដាលសតិបញ្ញា។

ពាក្យនេះបើយើងធ្វើការបកស្រាយទៅ ក៏មិនមានអ្វីដទៃក្រៅអំពីមនោសញ្ចេតនាខាងផ្លូវគំនិតដែលមនុស្សទាំងឡាយបានធ្វើទៅលើធម្មជាតុទាំងអស់ដើម្បីរកឲ្យឃើញនូវអ្វីដែលអាចធ្វើឲ្យខ្លួនមានជីវិតរស់នៅក្នុងសេចក្ដីសុខស្ងប់។

ការស្រាវជ្រាវរកសន្តិភាពសម្រាប់ជីវិត ដែលគេបានធ្វើបន្ទាប់អំពីមនោសញ្ចេតនាខាងនឹកគិតនេះ វាអាចឲ្យគេបានជួបបណ្ដើរៗនូវសីលធម៌, មនុស្ស



www.elibraryofcambodia.org

ធម៌, យុត្តិធម៌ដែលជាមាគ៌ានៃជីវិតសន្តិភាពឬនិព្វាន ដែលជាគោលដៅចុងក្រោយបង្អស់នៃជីវិតទាំងឡាយ។

ដោយអាស្រ័យហេតុដូចពោលមកនេះ ទើបខ្ញុំមានយោបល់ថា និព្វាន មិនមែនតែក្នុងពុទ្ធសាសនាយើងទេ ជំនឿក្រៅ, សាសនាក្រៅ, និងលទ្ធិទាំងឡាយខាងក្រៅក៏មាននិព្វានហ្នឹងដែរ ខុសតែភាសានិយាយយើងថា «និព្វាន» គេថា «ព្រះវិញ្ញាណបរិសុទ្ធ» ថា «ព្រះជាម្ចាស់សួគ៌» ថា «ព្រះអាទិទេព» ប្រែថា យើងពុទ្ធសាសនិកត្រូវការធ្វើឲ្យជីវិតរបស់យើងដល់ទៅទីបំផុតមួយហៅថា «និព្វាន»។ ចំណែកព្រាហ្មណ៍សាសនិក, គ្រីស្តសាសនិក, ឥស្លាមសាសនិក ... គេត្រូវការធ្វើឲ្យអាត្មាំនអស់កិលេស, វិញ្ញាណបរិសុទ្ធ របស់គេបានទៅនៅរួមជាមួយនឹងអាត្មាំនធំជាមួយនឹងវិញ្ញាណបរិសុទ្ធ របស់ព្រះអាទិទេពនៃខ្លួន ដោយគេមានយោបល់ថា កាលណាគេបានទៅដល់ទីនោះហើយ គេអស់មានជីវិតអន្ទោលទៀតហើយ។

អ្នកអានគប្បីត្រឡប់គំនិតរបស់ខ្លួនទៅខាងក្រោយវិញ ដើម្បីពិចារណាមើលពាក្យសរសេររបស់ខ្ញុំដែលមាននិយាយអំពីរឿងព្រះអាទិទេពទាំងឡាយរៀងរាល់សាសនា។ កាលណាបានអានរឿងនេះជាថ្មីទៀតហើយ គប្បីធ្វើសំនួរខ្លួនឯងថា តើខ្ញុំសរសេរក្នុងមានបំណងដើម្បីអ្វី ? មានទីដៅយ៉ាងណា ? ចំពោះសំនួរនេះ អ្នកអានចង់ឆ្លើយយ៉ាងណាក៏ឆ្លើយទៅ។ តែបើចង់ស្តាប់ចម្លើយរបស់ខ្ញុំ ខ្ញុំសូមឆ្លើយថា ខ្ញុំមិនមានបំណងអ្វីក្រៅពីចង់បង្ហាញប្រយោជន៍សាសនា ចង់ឲ្យមនុស្សយើងដឹងថា នៅក្នុងពិភពលោកនៃមនុស្សនេះ ទោះជាអ្នកណាធ្វើអ្វី? បង្កើតអ្វី? ជាលទ្ធិសាសនាក៏ដោយ ជាលទ្ធិនយោបាយក៏ដោយ ជាលទ្ធិសេដ្ឋកិច្ចក៏ដោយ ។ល។ គោលដៅនៃគំនិតរបស់មនុស្សមិនមែនអ្វីដទៃក្រៅអំពីធ្វើឲ្យមនុស្សរស់នៅក្នុងសេរីភាព, សីលធម៌, មនុស្សធម៌, សន្តិធម៌ចុងក្រោយបង្អស់គឺនិព្វានធម៌ហ្នឹងឯង។

ប្រសិនបើមានសំនួរថា ហេតុដូចម្តេចបានជាមនុស្សគ្រប់សាសនាទាំង



www.elibraryofcambodia.org

អស់ចង់បាននិព្វានម្ល៉េះ តើនិព្វានហ្នឹងជាអ្វី? ចម្លើយ និព្វានហ្នឹងគឺជារបស់ឬធម្មជាតុមួយល្អបរិសុទ្ធ មិនមានបាប, មិនមានគ្រឿងសៅហ្មង, មិនមានទុក្ខ, មិនមានកំណើត, មិនមានចំណាស់, មិនមានជម្ងឺ, មិនមានសេចក្តីស្លាប់។ល។ ជាថ្មីទៀត។ ច្រើនជាងនេះទៅទៀត. និព្វានមិនមានអ្វីៗទាំងអស់ដែលពិភពលោកមាន ជាអាទិ៍មិនមានមនុស្សជិះជាន់គ្នា, មិនមានជម្លោះ, មិនមានចម្បាំង, មិនមានការរំលោភសេរីភាព. មិនមានការរំលោភលើសិទ្ធិ, មិនមានការរំលោភលើវណ្ណៈ។ល។ ម្យ៉ាងទៀត យើងអាចនឹងធ្វើសេចក្តីបកស្រាយថា និព្វានមិនមានធំ, មិនមានតូច, មិនមានស្តេច, មិនមានរាស្ត្រ, មិនមានត្រកូល, មិនមានពូជ, មិនមានអម្បូរ, មិនមានគោត្រ, មិនមានវណ្ណៈ, មិនមានពណ៌សម្បុរ, មិនមានសាសន៍។ល។ ដោយសេចក្តីខ្លីបំផុតគឺនិព្វានមានតែរបស់ដែលត្រូវមាន, មិនមានរបស់ដែលមិនត្រូវមាន, របស់ដែលត្រូវមានបានដល់បរមសុខ, ឬសុខស្ងប់ ឬឯកន្តបរមសុខ ដែលយើងធ្លាប់ធ្វើសេចក្តីកត់សំគាល់មកហើយថា «សេចក្តីសុខខ្ពស់បំផុត» «សេចក្តីសុខដែលមានសេចក្តីស្ងប់នៅក្នុងនោះ» «សេចក្តីសុខខ្ពស់បំផុតដាច់ដោយឡែកមិនមានគូប្រៀប» គឺសេចក្តីសុខអស់មានការប្រែប្រួល។ ដែលមិនត្រូវមានគឺទុក្ខទាំងឡាយមានទុក្ខ១២កងជាដើម។

អ្នកអានគប្បីដឹងម្យ៉ាងទៀតថា ធម៌ទាំងឡាយមានយុត្តិធម៌និងនិព្វានធម៌ជាដើម ដែលនឹងឋិតនៅឬនឹងមានជីវិតរស់នៅក្នុងលោកនេះ ត្រូវអាស្រ័យពឹងផ្អែកលើអ្នកប្រាជ្ញសីលធម៌និងទស្សនវិទូមានមនុស្សធម៌។ ដូច្នេះហើយបានជាក្នុងបុរាណកាល គេឃើញមានអ្នកប្រាជ្ញនិងទស្សនវិទូទាំងឡាយ ជាជាតិក្រិកមានប្លាតូជាដើម ជាជាតិឥណ្ឌា មានតាបសឬឥសីជាច្រើន ជាជាតិចិនមានខុងជឺជាដើម, ជនជាតិជ្វីសមានយ៉េស៊ូជាដើម។ល។ អ្នកប្រាជ្ញនិងទស្សនវិទូទាំងឡាយនេះ សុទ្ធតែបានថែរក្សានិងគាំទ្រនូវយុត្តិធម៌និងសន្តិធម៌រួមទាំងមនុស្សធម៌ផង ជាពិសេសព្រះពុទ្ធបរមគ្រូរបស់យើង ព្រះអង្គទ្រង់ធ្វើវិភាគទាន



www.elibraryofcambodia.org

យ៉ាងជំដល់ធម៌ ពួកនេះ ដូចយើងបានដឹងគ្រប់គ្នាហើយ។ ដើម្បីឲ្យអ្នកអាន មានពន្លឺក្នុងរឿងនេះ កាន់តែច្រើនឡើងជាងមុន ខ្ញុំសូមធ្វើសេចក្តីបញ្ជាក់ជាថ្មី ទៀតថា ពាក្យដែលយើងនិយាយដល់ព្រះពុទ្ធច្រើនព្រះអង្គ ដោយប្រើសព្ទជា ពហុវចនៈនោះ ពុំមែនសំដៅយកតែព្រះអង្គមួយព្រះអង្គ ដែលយើងស្គាល់ថា ជាសព្វញ្ញុពុទ្ធហ្នឹងទេ។ ឧទាហរណ៍ដែលមានមកខាងដើមថា **«និព្វានំ បរមំ វទន្តិ ពុទ្ធា»** ឧទាហរណ៍មួយទៀតថា «ឯតំ ពុទ្ធាន សាសនំ» នោះ ពាក្យនេះ មិនមែនសំដៅយកតែព្រះសម្មាសម្ពុទ្ធរបស់យើងមួយអង្គប៉ុណ្ណោះទេ គឺជា ពំនោលរបស់អ្នកចេះដឹងទាំងឡាយដទៃផង។

ដូច្នេះពាក្យថា «**ពុទ្ធា**» ដែលជាសព្ទពហុវចនៈ តែលោកប្រើជាឯកវចនៈ គឺសំដៅយកព្រះសម្មាសម្ពុទ្ធមួយអង្គទៅវិញនោះ។ គម្ពីរខ្លះលោកថាដែលប្រើ បែបនេះដើម្បីគោរពចំពោះបុគ្គល ដែលគេទុកដាក់ថាមានគុណធម៌ ខ្ពស់បំផុត ឬបុគ្គលដែលត្រូវគេលើកតម្កើងដោយគុណសម្បត្តិណាមួយ ទើបត្រូវប្រើសព្ទ ជាពហុវចនៈ ជំនួសសព្ទជាឯកវចនៈ។ ម្យ៉ាងទៀត, សព្ទថា «ពុទ្ធា»ប្រសិនបើ យើងប្រែថា «ព្រះពុទ្ធទាំងឡាយ» តាមដំណើរសព្ទជា «ពហុវចនៈ» នោះយើង ត្រូវធ្វើសេចក្តីកត់សំគាល់ដល់ព្រះពុទ្ធទាំង ៤ ពួកគឺ :

**១- ព្រះសព្វញ្ញុពុទ្ធ;**

**២- ព្រះបច្ចេកពុទ្ធ;**

**៣- ព្រះអនុពុទ្ធ ឬព្រះសាវកពុទ្ធ;**

**៤- ព្រះសុតពុទ្ធ ឬព្រះពហុស្សុតពុទ្ធ។**

ផ្លូវទៅនិព្វាន, ក្រៅអំពីធម្មទេសនាដោយបរិយាយក្នុងធម្មចក្កប្បវត្តន សូត្រ ដែលបានចង្អុលបង្ហាញមជ្ឈិមាបដិបទាផ្លូវកណ្តាល។ កាមសុខល្លិកានុ យោគផ្លូវស្តាំផុត។ អត្តកិលមថានុយោគផ្លូវឆ្វេងផុត ដែលយើងធ្លាប់ចេះចាំមក ហើយនោះ ពុំមានផ្លូវឯណាដទៃទៀតទេ។ ផ្លូវទាំង៣នេះព្រះសម្មាសម្ពុទ្ធទ្រង់ ទាត់ចោលនូវផ្លូវស្តាំផុត គឺគំនិតដែលយល់ថា ការបរិភោគកាមច្រើនបំផុតនឹង



www.elibraryofcambodia.org

បានសម្រេចនិព្វាន ជាមួយគ្នានេះព្រះអង្គទ្រង់ទាត់ចោលផ្លូវឆ្វេងផុត គឺគំនិតដែលយល់ថា ការដាក់ទណ្ឌកម្មឬធ្វើបាបរូបកាយនឹងមានសម្រេចនិព្វាន។ ក្រោយពីបានទាត់ចោលផ្លូវទាំងពីរនេះហើយ ព្រះអង្គទ្រង់បបួលបេក្ខជន និព្វាន ឲ្យដើរតាមផ្លូវ៨ប្រការឬផ្លូវកណ្ដាលជំនួសផ្លូវទាំងពីរ ដែលទ្រង់បានទាត់ចោលនោះ។ អ្នកអានសូមត្រឡប់ទៅមើលផ្លូវកណ្ដាលដែលខ្ញុំបានសរសេរមកម្ដងហើយក្នុងខាងដើម។

អ្នកសម្រេចនិព្វាន បានជួបប្រទះនឹងអ្វីខ្លះ? ចំពោះសំនួរនេះបើខ្ញុំមិនឆ្លើយក៏អ្នកអានអាចឆ្លើយបានដែរ តែដើម្បីឲ្យបញ្ហានេះមានសេចក្ដីទូលំទូលាយ ហើយឲ្យមានជម្រៅបន្តិចផង ខ្ញុំសូមជូនចម្លើយដូចមានតទៅនេះ :

**១- អ្នកសម្រេចនិព្វាន** ត្រូវបានជួបប្រទះនូវបរមសុខ

**២- សេចក្ដីសុខ** ដែលអ្នកសម្រេចនិព្វានត្រូវបាននោះ គឺជាសេចក្ដីសុខសុទ្ធ ពុំមានលាយឡំដោយទុក្ខទេ។

**៣- សេចក្ដីសុខ** ដែលអ្នកសម្រេចនិព្វានត្រូវបាននោះ មិនមែនមានតែក្នុងនិព្វានបរិយាយ (សឧបាទិសេសនិព្វាន) ដែលដៅយកសុខក្នុងជីវិតបច្ចុប្បន្ន ព្រោះចិត្តលែងប្រកាន់ឧបាទិប៉ុណ្ណោះទេ។

**៤- សេចក្ដីសុខ** ព្រោះរម្ងាប់នូវសង្ខារមួយអន្លើដោយឧបាទិដែលមានចែងក្នុងបាលីថា «តេសំ វូបសមោ សុខោ» ក៏ត្រូវកើតមានដល់អ្នកសម្រេចនិព្វានក្នុងពេលជាបន្តបន្ទាប់គ្នាដែរ។

សេចក្ដីចូលចិត្តរបស់យើងក្នុងរឿងនិព្វានសុខឬសេចក្ដីសុខដទៃនោះមានច្រើនបែបច្រើនប្រការណាស់ តែគោលគំនិតធំៗមានត្រឹមតែ៣គឺ :

**១- មតិខ្លះ** ថានិព្វានសុខនោះ គឺទីបំផុតនៃទុក្ខហ្នឹងឯង, មតិនេះមានសំអាងលើបាលីថា «ឯសេវន្តោ ទុក្ខស្ស»។

**២- មតិខ្លះ** ដៅយកសេចក្ដីសុខនេះថាមានក្នុងពេលដែលរលត់ចរិមកចិត្តដ៏សម្បយុត្តដោយសុខទុក្ខ សព្វថ្ងៃដូចជាគេពោលសរសើរបុគ្គល ដែលដល់



www.elibraryofcambodia.org

នូវមរណកាលថា ស្លាប់ទៅបានសុខឬដូចពំនោលដែលមានក្នុងគម្ពីរអត្ថកថាថា "សុត្តប្បពុទ្ធោ វិយ" សេចក្តីស្លាប់ដូចមនុស្សយើងដេកលក់ហើយភ្ញាក់ឡើង។

**៣- មតិខ្លះ** ថាសេចក្តីសុខនេះ ស្រេចហើយនឹងគេប្រកាន់យក ឬស្រេចហើយនឹងសេចក្តីប្រាកដជាក់លាក់ ដែលមានឡើងដល់ខ្លួនគេ ដូចជាគេប្រកាន់យកឬគេមានគំហើញថា អាយតនៈជាអណ្តូងជាទីកើតអារម្មណ៍នោះ ជាប្រភពនៃសុខឬដូចជាមានគំនិតថា ខ្លួនរបស់គេឬខ្លួនបុគ្គលដទៃ ដែលបានធ្វើប្រយោជន៍ដល់លោក ស្លាប់ទៅមានគេគោរពរាប់អាន ធ្វើគ្រឿងសក្ការបូជា។ សេចក្តីគោរពរាប់អានជាមួយនឹងតង្វាយផ្សេងៗនេះ បានជាទីពេញចិត្ត ហើយ សេចក្តីពេញចិត្តនេះ ក៏ជាធម្មជាតមួយនាំឲ្យគេមានសេចក្តីសុខ។ មតិនេះគេមានសំអាងទៅលើបាលី ថា "បេច្ច នន្ទតិ" អ្នកមានបុណ្យបានធ្វើហើយលះបង់លោកនេះទៅរមែងមានសេចក្តីសប្បាយរីករាយ។ សម្រាប់អ្នកប្រតិបត្តិធម៌ដែលមានចិត្តធុញទ្រាន់ចំពោះលោកឬមានចិត្តខ្ពស់ ការហាត់ចិត្តរបស់គេទៅក្នុងផ្លូវនៃនិព្វានអស់កាលជាប្រក្រតីនោះ ឈ្មោះថាគេបានបោះជំហានយ៉ាងវែងជិតៗទៅដល់និព្វានហើយ ដូចមានសេចក្តីបញ្ជាក់ជាពាក្យបាលីថា "និព្វានស្សេវសន្តិកេ" ( ពាក្យប្រែដូចមុន )។

## សេចក្តីសរុប

ចិត្តរបស់មនុស្សដែលធ្លាប់មានសេចក្តីត្រេកអររីករាយក្នុងអារម្មណ៍ឬអារម្មណ៍ជាគ្រឿងញុំាងចិត្តនៃមនុស្សឲ្យមានតម្រេក សេចក្តីស្រវឹងក្នុងអារម្មណ៍ឬអារម្មណ៍ដឹកនាំចិត្តឲ្យកើតសេក្តីស្រវឹង។ ចិត្តប្រភេទនេះ ខាងក្រោយមកកើតមានសេចក្តីនឿយណាយធុញទ្រាន់ ដោយអាស្រ័យសេចក្តីត្រិះរិះពិចារណាដែលគេបានធ្វើដោយឧបាយនៃបញ្ញា។ សេចក្តីត្រេកអរក្នុងអារម្មណ៍នៃចិត្តរបស់គេក៏អស់ ចិត្តរបស់គេក៏រួចចាកគ្រឿងសៅហ្មង, ចិត្តបានដល់នូវភាពបរិសុទ្ធ ជាមួយនឹងភាពស្ងប់, បរិមកចិត្តនៃព្រះយោគាវចរក៏រលត់ក្នុងពេលជា



www.elibraryofcambodia.org

អវសាន។ និព្វិទា, វិរាគៈ, វិមុត្តិ, វិសុទ្ធិ, សន្តិ និងនិព្វាន កើតឡើងតាមលំដាប់គ្នា, បិតនៅក្នុងលំដាប់គ្នា, ធម្មជាតុទាំងឡាយនេះមានការទាក់ទងដល់គ្នានឹងគ្នាដោយប្រការដូច្នេះឯង។

បុគ្គលដែលសម្បូរណ៍ដោយសាមិសសុខ គប្បីដឹងថាសុខនេះមានទុក្ខនៅលាយឡំផង កាលបើដឹងដូច្នេះហើយ មានផ្លូវនឹងធ្វើឲ្យនឿយណាធុញទ្រាន់ជាងបុគ្គលដែលមិនសម្បូរណ៍ដោយសាមិសសុខឬខ្វះខាតសាមិសសុខ ដូចនេះព្រោះអ្វី? ព្រោះអ្នកដែលគ្រាន់តែបានឃើញគេបានសេចក្តីសប្បាយ ឬគ្រាន់តែបានធុំក្លិនសេចក្តីសប្បាយតែពុំទាន់បានសប្បាយនោះ វានៅជាប់ចិត្តចង់មានចង់សប្បាយខ្លាំងណាស់ វាពុំអាចធ្វើឲ្យនឿយណាយឬឲ្យស្អប់ខ្ពើមសេចក្តីសប្បាយហ្នឹងបានទេ ឧទាហរណ៍ដូចអ្នកធុំក្លិនរសជាតិអាហារឆ្ងាញ់ តែពុំទាន់បានស៊ីអាហារនោះ វាពុំអាចលះបង់លែងគិតគូរដល់អាហារដែលវាចង់ស៊ីនោះបានទេ។

សេចក្តីនឿយណាយធុញទ្រាន់ឯណា ដែលកើតឡើងព្រោះទាល់គំនិតព្រោះគ្មានសមត្ថភាពនឹងចាប់យកនូវរបស់ដែលខ្លួនត្រូវការឲ្យបានដូចបំណងសេចក្តីនឿយណាយបែបនេះ លោកពុំបានចាត់ចូលក្នុងនិព្វិទាទេ។

វិរាគធម៌ គឺអរិយមគ្គទាំង៤ ដែលបុគ្គលណាចំរើនបានហើយ ចិត្តរបស់បុគ្គលនោះ រមែងរួចផុតចាកអាសវៈទាំងឡាយ ដែលពុទ្ធសាសនារបស់យើងឲ្យឈ្មោះថា "**ព្រះខីណាស្រព**" ជាសន្តិបុគ្គល, ជាវិសុទ្ធិបុគ្គល, ប្រែថាបុគ្គលមានចិត្តស្ងប់, មានចិត្តបរិសុទ្ធ ប្រៀបបាននឹងសម្ពត់ដែលគេបោកគក់អស់គ្រឿងសៅហ្មង ឬអស់កំអែល របស់នោះរមែងមានសាច់សស្អាត បរិសុទ្ធដូច្នោះដែរ។

ព្រះខីណាស្រពទាំងឡាយ ដល់ពេលអស់ព្រះជន្ម លោកក៏ត្រូវបានរលត់នូវអ្វីៗទាំងអស់រួមទាំងរលត់ដោយមិនមានសេសសល់នូវចរិមកចិត្តដូចជាភ្លើង ដែលត្រូវរលត់បាត់សូន ក្នុងពេលដែលអស់គ្រឿងសម្រាប់ឆេះ។



www.elibraryofcambodia.org

ដោយន័យនេះអ្នកអានគប្បីដឹងថា **បរមត្ថបដិបទា** ជាបដិបទាជាន់ខ្ពស់ ហើយជាបដិបទា មានគុណភាពគួរដល់អ្នកឃើញទុក្ខឃើញភ័យរបស់សង្សារវដ្ត ជាពិសេសគួរដល់អ្នកសម្បូណ៌សាមិសសុខ ហើយមានគំនិតចង់ដូរសាមិសសុខរបស់ខ្លួននឹងនិរាមិសសុខ គឺថាចង់ប្រើនិរាមិសសុខវិញ។ សេចក្តីប្រតិបត្តិធម៌បែបនេះ ពុទ្ធសាសនារបស់យើងលោកឲ្យឈ្មោះថា «អនុបុព្វបដិបទា» ប្រែថា ប្រតិបត្តិតាមលំដាប់ គឺដំបូងត្រូវប្រតិបត្តិធម៌ សម្រាប់ធ្វើឲ្យជីវិតបច្ចុប្បន្នរស់នៅបានស្រួល, បានសោយនូវរសនៃសាមិសសុខ បានដល់បដិបទាបច្ចុប្បន្ន៤យ៉ាងគឺ :

**១- ឧដ្ឋានសម្បទា;**

**២- អារក្ខសម្បទា;**

**៣- កល្យាណមិត្តតា;**

**៤- សមជីវិតា។**

ជាបន្ទាប់ត្រូវប្រតិបត្តិធម៌ សម្រាប់ធ្វើឲ្យជីវិតបរលោករស់នៅបានស្រួល សោយរសនៃសាមិសសុខខ្ពស់បន្តិចឡើង បានដល់សម្បទាបរលោក៤យ៉ាងគឺ:

**១- សទ្ធាសម្បទា,**

**២- សីលសម្បទា,**

**៣- ចាគសម្បទា,**

**៤- បញ្ញាសម្បទា។**

ជាទីបំផុតត្រូវប្រតិបត្តិធម៌ សម្រាប់ធ្វើឲ្យអស់នូវជីវិតអន្ទោល, សោយរសនៃនិរាមិសសុខ បានដល់បរមត្ថសម្បទា៤គឺ :

**១- ទុក្ខសច្ចៈ,**

**២- ទុក្ខសមុទយសច្ចៈ,**

**៣- ទុក្ខនិរោធសច្ចៈ,**

**៤- ទុក្ខនិរោធគាមិនីបដិបទាសច្ចៈ។**



www.elibraryofcambodia.org

( សម្បទាទាំង៣យ៉ាងនេះខ្ញុំមិនបានធ្វើសេចក្តីបកប្រែនិងសេចក្តីអធិប្បាយទេ អ្នកអានចង់ដឹងសូមមើលក្នុងសៀវភៅឈ្មោះ «**ជីវិតសន្តិភាព**» របស់ខ្ញុំ )។

ក្នុងទីបំផុតនេះ, ខ្ញុំសូមទាញអារម្មណ៍ជាមួយនឹងការក្រើនរំលឹកស្មារតីអ្នកអានជាអ្នកត្រាច់រង្គាត់ក្នុងវាលវដ្តសង្សារ មិនត្រូវបានប្រតិបត្តិធម៌ខុសលំដាប់ឬរំលងថ្នាក់ទេ គឺជាមិនត្រូវមើលងាយធម៌ជាបុព្វភាគនិងមជ្ឈិមភាគ ហើយលើកតម្កើងធម៌ជាបច្ឆិមភាគតែម្យ៉ាងឡើយ ព្រោះធម៌ទាំងអស់នេះព្រះសម្មាសម្ពុទ្ធរបស់យើង ព្រះអង្គទុកដាក់ដូចជាកាំជណ្តើរដែលអ្នកប្រាថ្នាសេចក្តីសុខសម្រាប់ជីវិត ត្រូវឡើងជាន់កាំទី១ ជាដម្បូង, បន្ទាប់មកត្រូវជាន់កាំទី២, ក្រោយបង្អស់ត្រូវជាន់កាំទី៣។ ប្រតិបត្តិដូច្នេះទើបអាចរើខ្លួនចេញចាកសង្សារវដ្តបាន។ ឯព្រះពុទ្ធសាសនាក៏ចេះតែមានសេចក្តីចំរើនរុងរឿងដោយអាស្រ័យការចេះប្រតិបត្តិធម៌ត្រូវតាមលំដាប់ ឬត្រូវតាមសេចក្តីណែនាំរបស់ព្រះសម្មាសម្ពុទ្ធនៃយើង ដោយន័យថាយើងទាំងឡាយក៏បានសម្រេចនូវសេចក្តីសុខ ទាំងផ្នែកសាមិសៈទាំងផ្នែកនិរាមិស ព្រះពុទ្ធសាសនាក៏មានជីវិតរស់នៅក្នុងលោកនេះអស់រយៈកាលមិនមានទីបំផុតឡើយ។

**ចប់**

សន្តិធម៌ ចូរចំរើនអស់កាលជានិរន្តរ៍!
មនុស្សធម៌ ចូរឋិតនៅក្នុងប្រជាសត្វលោក!
សកលប្រជាជាតិ ចូរមានវឌ្ឍនភាពសម្រាប់ជីវិត!



www.elibraryofcambodia.org

តម្កល់ទុកតាមលេខ៤២ ចុះថ្ងៃទី ១១-១-១៩៧១
បោះពុម្ពលើកទី២ ចំនួន ២០០០ក្បាល

## ដំណឹងពិសេស

សូមអញ្ជើញសួររកនៅ បណ្ណាគារ ពន្លឺជាតិ លេខ ៣៦៥ (ខ) ស្ថិតនៅខាងត្បូងពេទ្យចិនចម្ងាយប្រមាណប្រហែល១៥០ម ផ្លូវមុនីវង្ស (ជៀងខាងលិចហាងសាំងកាល់តិច) នូវសៀវភៅដែលនិពន្ធដោយ ភិក្ខុធម្មបាល ខៀវ-ជុំ ដែលមានដូចខាងក្រោមនេះ ។

១- ជីវិតសន្តិភាព
២- ជីវិតតស៊ូ
៣- ពុទ្ធវិទ្យា រឿងបុណ្យ បាប
៤- យុវជីវិត
៥- ជីវិតគ្រប់លក្ខណ៍
៦- ជីវិតឈ្នះលោក
៧- ទានទស្សនៈ
៨- វិញ្ញាណទស្សនៈ
៩- វេយ្យាករណ៍យើង

**សូមអរគុណទុកជាមុន**



www.elibraryofcambodia.org

យើងខ្ញុំជាកូន ខ្ញៅ យុនសំរ៉ង ខ្ញៅ យ៉ាតណៃ ខ្ញៅសុខផល ខ្ញៅ វិសាល ខ្ញៅ រ៉ាមុន
ខ្ញៅ ភារាដា ខ្ញៅ ចំរើន ខ្ញៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook
ដើម្បីឧទ្ទិសកុសល់ដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ញៅ ពាញ និង ឧបាសិកា ឈរ យឿន

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **ទាវ បញ្ញា**

សីហា ឆ្នាំ ២០១៥


បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការព្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។


សូមអរគុណ

ខ្ញៅ យុនសំរ៉ង

ប្រធាន

**មូលនិធិខ្មែរសម្រាប់ការសិក្សា**

www.elibraryofcambodia.org

បោះពុម្ពផ្សាយឡើងវិញ

ដោយ **ស៊ិន - សុវណ្ណនិ**

សាស្ត្រាចារ្យពុទ្ធិក

សាកលវិទ្យាល័យ ព្រះសីហនុរាជ.ភ.ព



ONLINE
IN TOUCH WITH YOUR WORLD
អ្នកផ្តល់សេវាអ៊ីនធើណែតឈានមុខគេនៅកម្ពុជា
The leading Internet Service & VoIP Provider in Cambodia
WWW.ONLINE.COM.KH

Find us at
facebook.com/ideabookpublishing

ISBN 978999-6332-56-2

9 789996 332562

១២ ០០០ រៀល

SI_256

www.elibraryofcambodia.org